## ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Journal

លេខ៨ ខែមិថុនា ឆ្នាំ២០២២ | Vol.8-June-2022



រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**
ឯកឧត្តមបណ្ឌិត **ផុន កសិកា**
ឯកឧត្តមបណ្ឌិត **អ៊ឹម បុណ្ណា**
ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**
ឯកឧត្តមបណ្ឌិត **គិន នា**
ឯកឧត្តមបណ្ឌិត **មាយ ប៊ូរ៉ា**
ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**
ឯកឧត្តម **សូត្រ សំណាង**
ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
លោក **ហេង វីរិទ្ធិ**
លោក **សាន សុរាជនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**
លោក **ធឿន សុត្ថា**
លោក **ហេង ហុកមេង**
លោកស្រី **សំរិទ្ធ ចរិយា**
លោក **កៅ សុម៉ាឡេត**
លោក **ទ្រឿង មករា**
លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិដែលក្នុងនោះរាជបណ្ឌិត្យសភាកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវលើជំនាញផ្សេងៗនិងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីប្រាំបីនេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងភាសាវិទ្យា សេដ្ឋកិច្ច គ្រប់គ្រង អប់រំ និងនយោបាយជាដើម សុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់ បណ្ឌិត្យសភាចារ្យ អ្នកស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបេក្ខជនបណ្ឌិត។ ការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវថ្មីៗបែបវិទ្យាសាស្ត្រគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ ក៏ដូចជាជួយជម្រុញដល់អ្នកស្រាវជ្រាវទាំងឡាយកាន់តែមានឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាននិងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អនូវចំណុចខ្វះខាតនិងកំហុសឆ្គងដែលអាចកើតមានដោយអចេតនា ទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេស ឱ្យកាន់តែមានសុក្រិតភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

**គណៈកម្មការទស្សនាវដ្ដីវិទ្យាសាស្ត្ររាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១. សំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នាក្នុងភាសាខ្មែរទំនើប **បេក្ខជនបណ្ឌិត ហ៊ីញ សាង** ------ ១

២. សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យនៅកម្ពុជា "សក្តានុពល និងកត្តាប្រឈមនៃអចលនទ្រព្យនៅកម្ពុជា" **បេក្ខជនបណ្ឌិត ប៉ាត បញ្ញា** ------------------------------------------------------------------------------------ ៩

៣. កត្តាប្រឈម កាលានុវត្តភាព និងចក្ខុវិស័យនៃឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌកម្ពុជា **បេក្ខជនបណ្ឌិត វង្ស ពេជ្របុរី** ------------------------------------------------------------------------ ១៩

៤. វឌ្ឍនភាពសេដ្ឋកិច្ចខេត្តក្រចេះតាមរយៈវិស័យកសិកម្ម **បេក្ខជនបណ្ឌិត ហេង លីដា**-------------២៩

៥. ការសិក្សាពីសំណេរពាក្យកម្លាយនៃភាសាខ្មែរទំនើបក្នុងក្របខណ្ឌ *សំរាយតំរូត* ៖ ការវិភាគពីគោលការណ៍អាស្រ័យឫស **បេក្ខជនបណ្ឌិត ផល សុភឿន** ----------------------------------------------- ៥១

៦. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម ២០១៤-២០១៩ **បេក្ខជនបណ្ឌិត អួន សំអុល** --- ៥៨

៧. ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រសម្រាប់អភិបាលកិច្ចសាលារៀននៅកម្ពុជា **បេក្ខជនបណ្ឌិត ស៊ុន សុនិមិត្ត** --------------------------------------------------------------------------------------- ៦៥

៨. ទំនាក់ទំនងចិន ជប៉ុន ស្តីពីបញ្ហាសមុទ្រចិនខាងត្បូងនិងតួនាទីរបស់កម្ពុជា **បេក្ខជនបណ្ឌិត ហេង សារិទ្ធ** --------------------------------------------------------------------------------------------------៧១

៩. ការគ្រប់គ្រងវិស័យសាសនានៅខេត្តកំពង់ចាម៖ ទស្សនៈនៃការគ្រប់គ្រងវិស័យសាសនានៅខេត្តកំពង់ចាម **បេក្ខជនបណ្ឌិត ស្រី សុភ័ក្រ្ត** ------------------------------------------------------------- ៧៧

១០. ប្រព័ន្ធគ្រប់គ្រងប្រព័ន្ធថាមពលអគ្គិសនី **បេក្ខជនបណ្ឌិត ម៉ា សំអាល់** ----------------------- ៨៣

១១. ទិដ្ឋភាពទូទៅនៃទំនាក់ទំនងការទូតកម្ពុជា-ជប៉ុនឆ្នាំ២០០៨-២០១៨ **និស្សិត ហុង សុវណ្ណសុនិតា** -------------------------------------------------------------------------------------------៩៥

១២. ការអនុវត្តការលក់ទិញអចលនវត្ថុនៅខណ្ឌសែនសុខ **និស្សិត យ៉ុន មករា** ----------------- ១០៣

# សំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នាក្នុងភាសាខ្មែរទំនើប

*បេក្ខជនបណ្ឌិត៖* ***ហ៊ិញ សាង***
*ជំនាញ៖* ***ភាសាវិទ្យា***
*គ្រូណែនាំ៖* ***បណ្ឌិត ជុំ ស៊ុនណាង***

## មូលន័យសង្ខេប

អត្ថបទសិក្សានេះធ្វើឡើងក្នុងគោលបំណងសិក្សាសំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នា មានអត្ថិភាព និងភាពសមស្របក្នុងក្របខណ្ឌសម្ព័ន្ធនៃសំណង់ឈ្នះក្នុងភាសាខ្មែរទំនើប។ យើងខ្ញុំពិចារណាលើចំណុចបីគឺ (ក) កិរិយាសព្ទស៊េរី (ខ)លំដាប់សមាសភាគនៃព្រឹត្តិការណ៍ចលនា (គ)ករណីពាក់ព័ន្ធព្រឹត្តិការណ៍ចលនា។ ការសិក្សានេះ អនុវត្តវិធីពិពណ៌នានិងវិធីប្រៀបធៀប គឺពិពណ៌នាវិសេសភាពនៃកិរិយាសព្ទចូលរួមស្ថាបនាន័យក្នុងសំណង់ឈ្នះផ្អែកលើលក្ខណៈសម្ព័ន្ធ និងប្រៀបធៀបទម្រង់សម្ព័ន្ធឈ្នះនៃការសិក្សាមួយចំនួនដើម្បីស្វែងរកគំហើញថ្មី។ លទ្ធផលនៃការសិក្សាបានរកឃើញថា សំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នាក្នុងភាសាខ្មែរទំនើប មានលំដាប់សមាសភាគសម្ព័ន្ធជាបដិមាភាព(iconicity) កន្សោមកិរិយាទី១ ពិពណ៌នាបែបនៃចលនា ខណៈកន្សោមកិរិយាទី២ ពិពណ៌នានូវទិដ្ឋភាពបរិវេណផ្សេងៗ ក្នុងព្រឹត្តិការណ៍ចលនារួមមួយ។

*ពាក្យគន្លឹះ៖ សំណង់កិរិយាសព្ទស៊េរី កិរិយាចលនា ចលនាដំណាលគ្នា ភាសាខ្មែរ។*

## ១- សេចក្តីផ្តើម

ភាសាខ្មែរជាភាសាឯកព្យាង្គនិងមានវត្តមានដ៏យូរលង់មួយនៅភូមិភាគអាស៊ីអាគ្នេយ៍។ ឆ្លងតាមការសង្កេតនៃការប្រើប្រាស់ភាសានៅក្នុងប្រជុំរឿងព្រេងខ្មែរ យើងខ្ញុំឃើញថាបាតុភូតកិរិយាសព្ទស្ថិតនៅបន្តបន្ទាប់គ្នាដោយមិនមានឈ្នាប់ក្នុងប្រណាប់ប្រធានតែមួយមានសម្បូរបែប។ ក្នុងសំណង់នីមួយៗ អាចមានកិរិយាសព្ទពីរឬបី ឬច្រើនទៅទៀត ប៉ុន្តែមានប្រធានវេយ្យាករណ៍តែមួយ ពិពណ៌នាហេតុភេទ[១]ផ្សេងៗ ដែលបានកើតឡើងទៅតាមចិរវេលា។ កិរិយាសព្ទទាំងឡាយអាចមានតម្លៃសកម្ម *(នាំ ពុន រែក បរ)* ឬអកម្ម*(ហូរ ហើរ លយ)* និងមានលទ្ធភាពតភ្ជាប់*(ចាកចេញ ឡើង តាម វិលមក ត្រឡប់មក ក្រាបថ្វាយបង្គំលា ហើរឡើង ចូលទៅ)*។ បាតុភូតពិសេសនេះ មិនសូវកើតមានក្នុងអម្បូរភាសាឥណ្ឌូ-អឺរ៉ុបនោះទេ។ អ្នកភាសាវិទ្យាឱ្យឈ្មោះហៅថា «serial verb construction» ក្នុងការសិក្សានេះ យើងខ្ញុំសន្មតហៅជាភាសាខ្មែរថា «សំណង់កិរិយាសព្ទស៊េរី»។

ភាសាក្នុងអម្បូរឥណ្ឌូ-អឺរ៉ុបដូចភាសាអង់គ្លេសជាដើម ការពិពណ៌នាព្រឹត្តិការណ៍មួយ គេអាចប្រើវចនតា *take* និង *bring* ខណៈដែលភាសាឯកព្យាង្គវិញពិពណ៌នាអំពើបែបនេះ តម្រូវឱ្យមានឯកតាភាសា[២]ពីរដូចជា *carry go* និង *carry come* ដើម្បីពិពណ៌នាន័យ *នាំទៅ* និង *នាំមក។* ទន្ទឹមនឹងនោះ គេអាចប្រើមុខងារវេយ្យាករណ៍ដូចជា *ធ្នាក់* ឬ *គុណកិរិយា* ដើម្បីបង្ហាញអំពីគន្លងនៃចលនា ប្រភពនៃចលនា ឬគោលដៅនៃចលនា។ ចំពោះភាសាឯកព្យាង្គវិញ គេនឹងបន្ថែមកិរិយាសព្ទខាងចុងមួយផ្សេងទៀត។

---

[១] ស្តែងប្រាប់នូវ **ព័ត៌មាន រឿងរ៉ាវ ព្រឹត្តិការណ៍** អ្វីមួយក្នុងបរិបទជាក់ស្តែង។

[២] ប្រើក្នុងអត្ថបទនេះ សំដៅយកធាតុនៃភាសាក្នុងកម្រិតជា **វចនតា កន្សោមពាក្យ ឃ្លា និងឈ្នះ** តែប៉ុណ្ណោះ។

ថ្វីដ្បិតតែបាតុភូតខាងលើមាននៅក្នុងភាសាខ្មែរ ប៉ុន្តែបញ្ហានេះមិនសូវបានចាប់អារម្មណ៍ច្រើននៅឡើយ។ អ្នកសិក្សាបរទេសមួយចំនួនក៏បានសិក្សាមួយភាគ មានដូចជា Mikami (1981) សិក្សាសំណង់កិរិយាសព្ទស៊េរីក្នុងភាសាវៀតណាមនិងភាសាខ្មែរ។ លោកផ្អែកលើរចនាសម្ព័ន្ធផ្ទៃក្រោម(deep structure) ដែលមានទម្រង់សម្ព័ន្ធ $NP_0V_1(NP_1)V_2(NP_2)$ ដើម្បីពិពណ៌នាលក្ខណៈវិនិច្ឆ័យនៃសំណង់កិរិយាសព្ទស៊េរីទាំងឡាយ។ Chhany (1995) ផ្អែកលើលក្ខណៈកិរិយាសកម្មនិងកិរិយាអកម្ម សិក្សាទំនាក់ទំនងក្នុងករណី៤យ៉ាង គឺទំនាក់ទំនងរវាងកិរិយាសកម្មនិងសកម្ម កិរិយាសកម្មនិងអកម្ម កិរិយាអកម្មនិងសកម្ម កិរិយាអកម្មនិងអកម្ម ក្នុងប្រណាប់ប្រធាននៃសំណង់ល្បះដែលហៅថាកិរិយាសព្ទស៊េរី(serial verb) និងកិរិយាបំពេញ(completive verb)ក្នុងភាសាខ្មែរ។ លោកស្រីសន្និដ្ឋានជាបឋមថា *«ពុំមានភាពខុសគ្នារវាងសំណង់កិរិយាសព្ទស៊េរី ជាមួយសំណង់ឃ្លារណបមិនកំណត់ (non-finite subordination construction) ចំណុចនេះមានន័យថាកិរិយាសព្ទទីពីរជាកិរិយារណបមិនកំណត់ហើយជាកម្មរងរបស់ឃ្លាច្បង។»*[៣] ចំពោះ Haiman (2011) បានកត់សំគាល់នូវលក្ខណៈវិនិច្ឆ័យនៃកិរិយាសព្ទស៊េរីក្នុងភាសាខ្មែរថាមានលក្ខណៈន័យខុសគ្នាពីសំណង់ដែលមានកន្សោមកិរិយាសព្ទផ្សំ(complex predicates)។ លោកស្នើឡើងទម្រង់វេយ្យាករណ៍ក្នុងករណី៤ បែបគឺ សំណង់លទ្ធផល សំណង់បង្ហាញទិសដៅ សំណង់ស្នូល និងសំណង់បញ្ជាក់ទិដ្ឋភាពបំពេញ។

ស្នាដៃទាំងឡាយរៀបរាប់មកនេះ បានវិភាគទានយ៉ាងសំខាន់សម្រាប់យើងខ្ញុំយកមកពិចារណា និងសិក្សាមួយផ្នែកទៀតចំពោះបាតុភូតពិសេសនេះក្នុងភាសាខ្មែរ។ ក្នុងអត្ថបទសិក្សានេះ យើងខ្ញុំលើកយកករណីមួយផ្សេង គឺសំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នាក្នុងភាសាខ្មែរទំនើប មកឆ្លុះបញ្ចាំងនិងស្វែងយល់ទាំងអស់គ្នាដូចតទៅ។

## ២- សមាសភាគក្នុងសំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នា

កិរិយាសព្ទមានច្រើនប្រភេទទៅតាមមុខងារសម្ព័ន្ធនីមួយៗ ក្នុងនោះកិរិយាចលនា ជាប្រភេទកិរិយាសព្ទចូលរួមស្ថាបនាន័យក្នុងសំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នា។ ប្រភេទកិរិយាទាំងនោះ មានលំដាប់សម្ព័ន្ធច្បាស់លាស់ និងស្តែងនូវទិដ្ឋភាពផ្សេងៗនៃព្រឹត្តិការណ៍ចលនា។

### ២.១- ព្រឹត្តិការណ៍ចលនា

ទស្សនៈ Talmy(1975) ពិពណ៌នាថា *«ក្នុងបរិបទចលនាមួយ មានអង្គតា(figure) ដែលជាអង្គតាបម្លាស់ទី ត្រូវបានយល់ថា អង្គតានោះមានទំនាក់ទំនងចលនាជាមួយអង្គតាមួយផ្សេងទៀត។ អង្គតាទីពីរនេះ ប្រសិទ្ធិនាមហៅថាបរិវេណ(ground)។»*[៤] បរិវេណនៅចំណុចចាប់ផ្តើមនៃចលនាហៅថា *ប្រភព* (source) បរិវេណពាក់ព័ន្ធវិសាលភាពនៃចលនាហៅថា *គន្លង* (path) បរិវេណប្រាប់ទីបំផុតនៃចលនាហៅថា *គោលដៅ* (goal)។

---

[៣] Chhany Sak-Humphry, *'Serial' and 'Completive' verbs in Khmer?* Papers from the Third Annual Meeting of the Southeast Asian Linguistics Society, ed. M. Alves, p. 117-204, 1995. *«[...] There is no difference between the serial verb construction and the non-finite subordination construction. This implies that the serial verbs $V_2$ is the non-finite subordinate verb and is the complement of the higher clause.»*

[៤] Talmy, L., ***Semantics and Syntax of motion***, In J.P. Kimball (Ed.), ***Syntax and Semantics*** (Vol.4), New York: Academic Press, 1975 p.181, *"In a motion situation, the FIGURE - the moving object - is perceived to be in motion in relation to another object. This second object is termed the GROUND."*




*រូបភាព១៖ គំរូទម្រង់ព្រឹត្តិការណ៍ចលនាជំណាលគ្នា*

ឧទាហរណ៍៖ ឪពុកខ្ញុំ**ដឹក**គោឈ្មោល១នឹម**ទៅ**ស្រែ។[៥]

បរិបទនៃសំណង់នេះ មានអង្គតាចូលរួម៣ *«ឪពុកខ្ញុំ» «គោឈ្មោល១នឹម»* និង *«ស្រែ»* មានកិរិយាសព្ទ២ គឺ *«ដឹក»* និង *«ទៅ»*។ កិរិយាសកម្ម *«ដឹក»* បង្ហាញបែបនៃចលនា ពិពណ៌នានូវរបៀបដែលអង្គតាបម្លាស់ទី *«ឪពុកខ្ញុំ»* ទទួលយកអង្គតា *«គោឈ្មោល១នឹម»* ឆ្ពោះទៅអង្គតាបរិវេណមួយផ្សេងទៀត *«ស្រែ»។ វចនតា «ទៅ»* ជាកិរិយាសព្ទបង្ហាញទិស និងកំណត់គោលដៅនៅទីបំផុតនៃចលនា។

Talmy គូសបញ្ជាក់បន្ថែមថា *«ព្រឹត្តិការណ៍ចលនាជម្មតាមួយ ក្រៅពីសមាសភាគ អង្គតា (figure) និង បរិវេណ(ground) នៅមានសមាសភាគ គន្លង(path) និងចលនា(motion)។»*[៦] សមាសភាគទាំង ៤ នេះហើយដែលបង្កើតបានជាព្រឹត្តិការណ៍ចលនា។

### ២.២- បន្លែកលក្ខណៈកិរិយាសព្ទ

បន្លែកលក្ខណៈនៃកិរិយាសព្ទជាបញ្ហាមួយធំ និងមានភាពស្មុគស្មាញជាទីបំផុត។ កិរិយាសព្ទខាងចុង ជាបញ្ហាចម្បង។ ក្នុងករណីខ្លះ យើងពិបាកបន្លែកលក្សណ៍[៧] រវាង *ធ្នាក់* និង *កិរិយាសព្ទ*។ ប៉ុន្តែទោះជាយ៉ាងណា យើងខ្ញុំនឹងបង្ហាញនូវកំហិត និងលក្ខណៈនៃកិរិយាសព្ទមួយចំនួនដែលដំណើរការក្នុងព្រឹត្តិការណ៍ចលនាដូចខាងក្រោម៖

#### ២.២.១- កិរិយាសព្ទពិពណ៌នាបែបនៃចលនា

**ក- កិរិយាដឹកជញ្ជូន**(Transport Verbs) កិរិយាសព្ទប្រភេទនេះ ជាកិរិយាសកម្ម ពិពណ៌នានូវរបៀបដែលអង្គតាបម្លាស់ទីទទួលយកអង្គតាមួយទៀត(មនុស្ស សត្វ វត្ថុ)ចលនាក្នុងលម្ហអាកាស មានដូចជា *ដឹក ពាំ នាំ រែក យួរ ពុន លី សែង។ល។*

**ខ- កិរិយាបម្លាស់ទី**(Locomotion Verbs) កិរិយាសព្ទប្រភេទនេះ ជាកិរិយាអកម្ម ពិពណ៌នានូវរបៀបដែលអង្គតាបម្លាស់ទីចលនាក្នុងលម្ហអាកាស មានដូចជា *រត់ ហក់ លោត ដើរ ហើរ វារ លូន រមៀល ហូរ ពោរ ប៉ោង ។ល។*

#### ២.២.២- កិរិយាសព្ទពិពណ៌នាទិដ្ឋភាពបរិវេណ

**ក- កិរិយាបង្ហាញគន្លងនៃចលនា** កិរិយាសព្ទប្រភេទនេះជាកិរិយាសកម្មទាមទារកម្មបទផ្ទាល់ ដែលជាកន្សោមនាមបង្ហាញគន្លងនៃចលនា។ កិរិយាប្រភេទនេះ រួមមានដូចជា *ឆ្លង ឆ្លងកាត់ កាត់ទទឹង ឡោមព័ទ្ធ ចូល តាម ទៅតាម ។ល។* និងអាចបង្ហាញគន្លងនៃចលនាលើក្រោមដូចជា *ឡើង ចុះ។*

---

[៥] ក្រសួងអប់រំ *ភាសាខ្មែរថ្នាក់ទី៨* ឆ្នាំ២០១០ ទំព័រ៦២។

[៦] Talmy, L., ***Toward a Cognitive Semantics***, vol.2, Cambridge, MA: MIT Press, 2000, p.25, *"It is analyzed as having four components: besides Figure and Ground, there are Path and Motion."*

[៧] ជុំ ស៊ុនណាង ***កម្រងអត្ថបទស្រាវជ្រាវភាសា វប្បធម៌ និងអក្សរសាស្ត្រខ្មែរ*** វិទ្យាស្ថានភាសាជាតិរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៩ ទំព័រ៩។

**ខ- កិរិយាបង្ហាញប្រភពនៃចលនា៖** កិរិយាសព្ទប្រភេទនេះ មានជាអាទិ៍ *លា ចាកចេញ ចេញ គេច គេចចេញ ដកថយ ក្រោក។ល។* ។ ភាគិន[៨] នៃកិរិយាសព្ទប្រភេទនេះ ប្រាប់ឱ្យដឹងប្រភពនៃចលនា។ វាជាកន្សោមនាមបង្ហាញទីកន្លែង ឬទីតាំងណាមួយ។

**គ- កិរិយាបង្ហាញគោលដៅនៃចលនា៖** កិរិយាសព្ទប្រភេទនេះមានលក្ខណៈបិទ[៩] មានដូចជា *ទៅ* និង *មក*។ ភាគិននៃកិរិយាសព្ទប្រភេទនេះ បង្ហាញទីតាំង ឬឈ្មោះទីកន្លែងណាមួយ ដែលជាគោលដៅនៃអង្គតាបម្ចាស់ទី ឬជាកន្សោមកិរិយាមួយប្រាប់ពីគោលបំណងរបស់ព្រឹត្តិការណ៍ចលនាទាំងមូល។

កិរិយាសព្ទ *ទៅ* និង *មក* មានលទ្ធភាពតភ្ជាប់ជាមួយកិរិយាផ្សេងៗទៀត។ វាមិនត្រឹមតែជាកិរិយាសព្ទកំណត់គោលដៅនៅទីបំផុតនៃចលនា ថែមទាំងប្រាប់នូវទិសនៃចលនា ដោយអាស្រ័យប្រត្យក្សារម្មណ៍(perception) របស់អ្នកពោលក្នុងបរិបទជាក់ស្តែង។ ប្រសិនបើទីកន្លែងប្រាប់គោលដៅនៅឆ្ងាយពីអង្គតាបម្ចាស់ទី និងឆ្ងាយពីអ្នកពោល កិរិយាសព្ទ *ទៅ* នឹងបានពោលឡើងដើម្បីបង្ហាញទិសនៃចលនាសំដៅទៅគោលដៅ។ ផ្ទុយមកវិញ បើអ្នកពោលនៅជិតគោលដៅ កិរិយាសព្ទ *មក* នឹងបានពោលឡើងដើម្បីបង្ហាញទិសនៃចលនាសំដៅមកគោលដៅ។

សរុបសេចក្តី ការពិពណ៌នាលំដាប់សមាសភាគក្នុងរូបភាព១ ស្តែងឱ្យយើងដឹងថា ព្រឹត្តិការណ៍ចលនាកើតឡើងរួមមានអង្គតាបម្ចាស់ទីនិងអង្គតាបរិវេណ ក្នុងទំនាក់ទំនងមួយមានលំដាប់ជាបដិមាភាព។ ក្របខណ្ឌសម្ព័ន្ធនេះបកស្រាយបានព្រឹត្តិការណ៍ចលនាក្នុងភាសាខ្មែរ។ ព្រឹត្តិការណ៍ចលនា អាចមានតម្លៃកិរិយាសកម្ម ឬអកម្ម ដែលស្តែងឱ្យដឹងបែបនៃចលនា(ម.២.២.១) ស្ថិតនៅទីតាំងខាងដើម និងបន្ទាប់មកជាទិដ្ឋភាពបរិវេណ(ម. ២.២.២) ស្ថិតនៅទីតាំងខាងក្រោយ។ លំដាប់សមាសភាគនេះ ជាសញ្ញាណនៃសំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នា។ សំណង់ប្រភេទនេះ អាចមានកិរិយាសព្ទពីរ ឬច្រើនជាងពីរដំណើរការក្នុងប្រណាប់ប្រធានតែមួយ ពិពណ៌នាទិដ្ឋភាពផ្សេងៗនៃព្រឹត្តិការណ៍ចលនាទាំងមូល។ បើក្នុងករណីផ្លាស់ប្តូរលំដាប់សមាសភាគក្នុងសំណង់ល្បះ កិរិយាសព្ទខាងចុងមានលក្ខណៈបិទ ស្ថិតនៅទីតាំងខាងដើម សំណង់ប្រភេទនោះ មិនបានចាត់ទុកថាជាសំណង់កិរិយាសព្ទស៊េរីចលនាដំណាលគ្នានោះទេ ប៉ុន្តែត្រូវបានយល់ថា ជាសំណង់គោលបំណង ដែលមានកន្សោមកិរិយាសព្ទទី២ ជាកម្មបទរងនៃកន្សោមកិរិយាសព្ទខាងដើមទៅវិញ។

ឧទាហរណ៍៖ គាត់**មក**ផ្ទះ**លេង**នឹងកូន។[១០]

ក្នុងសំណង់ល្បះនេះ Chhany (1995) ពិពណ៌នាថា កិរិយាសព្ទ *«មក»* និង *«លេង»* មានប្រធានវេយ្យាករណ៍តែមួយគឺ *«គាត់»* និងអវត្តមាននៃឈ្នាប់។ កន្សោមកិរិយាទី២ *«លេងនឹងកូន»* មិនមានកន្សោមនាមប្រធាន ដូច្នោះ*«លេងនឹងកូន»* ជាឃ្លាវណបមិនកំណត់នៃកិរិយាសព្ទ*«មក»* ដែលស្ថិតក្នុងកន្សោមកិរិយាទី១។ ផ្ទុយទៅវិញ បើកន្សោមកិរិយាទី២ មានកន្សោមនាមប្រធាន យើងនឹងមានសំណង់ល្បះពីរដាច់ដោយឡែក។ នៅមាន

[៨] វចនានុក្រមឌីជីថល់ Orkida សមមូលនឹងភាសាអង់គ្លេសថា participant ដែលស្តែងអំពីអ្នកចូលរួម ឬ កន្សោមនាមដែលកិរិយាសព្ទទាមទាក្នុងមុខងារស្លាបនាន័យនៃព្រឹត្តិការណ៍។

[៩] ជាប្រភេទកិរិយាសព្ទខាងចុង កំណត់និងធ្លោះទៅរកគោលដៅនៅទីបំផុត ឬគោលបំណងអ្វីមួយ។

[១០] Chhany Sak-Humphrey, *'Serial' and 'Completive' verbs in Khmer*, The third Annual Meeting of the Southeast Asian Linguistics Society, ed. M. Alves, pp. 177-204, 1995.

សំណង់មួយចំនួនទៀត Chhany លើកឡើងក្នុងន័យដដែលដូចជា *«គាត់ទៅ Waikiki រាំជាមួយយើង។»* ឬ *«ក្មេងមកផ្សារទិញសៀវភៅ។»* សំណង់ទាំងនេះ កិរិយាសព្ទបង្គោលមានលក្ខណៈបិទ *«ទៅ»* និង *«មក»* កន្សោមកិរិយាទី២ ជាកម្មបទរងបំពេញន័យឱ្យកិរិយាបង្គោលខាងដើម ស្តែងគោលបំណងនៃអំពើរបស់ប្រធាន។

ក្នុងអត្ថបទនេះ យើងខ្ញុំមិនបានសិក្សាប្រភេទសំណង់ល្បះដូច្នោះទេ ប៉ុន្តែសិក្សាសំណង់ល្បះពិពណ៌នាព្រឹត្តិការណ៍ចលនាជំណាលគ្នាដែលមានលំដាប់សមាសភាគដូចទម្រង់រូបភាពទី១។

## ៣- វិធីសាស្ត្រស្រាវជ្រាវ

យើងខ្ញុំស្រង់សំណង់ល្បះចេញពីប្រជុំរឿងព្រេងខ្មែរទាំង៩ភាគ។ ទិន្នន័យប្រមូលបាន១៤៦ល្បះ ដែលមានកិរិយាសព្ទស្ថិតនៅបន្តបន្ទាប់គ្នាដោយមិនមានឈ្នាប់ក្នុងប្រណាប់ប្រធានតែមួយ។ ក្នុងចំណោមល្បះទាំងនោះ យើងខ្ញុំបន្លែកកិរិយាសព្ទដាក់តាមប្រភេទនីមួយៗ។ ផ្អែកលើលក្ខណៈសម្ព័ន្ធ លំដាប់សមាសភាគនៃគម្រូទម្រង់ព្រឹត្តិការណ៍ចលនាជំណាលគ្នានៅកថាភាគ២ លើកយកសំណង់ល្បះចំនួន ១០ មកពិពណ៌នា និងប្រៀបធៀបទម្រង់សម្ព័ន្ធល្បះតែប៉ុណ្ណោះ ដើម្បីសឱ្យឃើញករណីផ្សេងៗនៃព្រឹត្តិការណចលនាជំណាលគ្នាក្នុងភាសាខ្មែរទំនើប។

## ៤- សំណង់កិរិយាសព្ទស៊េរីចលនាជំណាលគ្នាក្នុងភាសាខ្មែរទំនើប

ក្នុងបរិបទនេះ យើងខ្ញុំនឹងអនុវត្តគោលការណ៍សម្ព័ន្ធដែលបានលើកឡើងនៅកថាភាគ២ ដើម្បីពិពណ៌នាន័យនៃសំណង់កិរិយាសព្ទស៊េរីចលនាជំណាលគ្នាក្នុងករណីនីមួយដូចខាងក្រោម៖

### ៤.១- ករណីព្រឹត្តិការណ៍ចលនាពាក់ព័ន្ធបរិវេណមួយ

ព្រឹត្តិការណ៍ចលនាមួយតម្រូវឱ្យមានបរិវេណមួយក្នុងចំណោមបរិវេណទាំងឡាយ ដើម្បីពិពណ៌នាទិដ្ឋភាពបរិវេណផ្សេងៗ ដែលជាវិសាលភាពនៃចលនា។ សូមសង្កេតសំណង់ល្បះមួយចំនួនដូចតទៅ៖

(១) បុរសទាំងបីនាក់**នាំគ្នាចុះទូក**។[១១]

សំណង់(១) មានកន្សោមកិរិយាពីរក្នុងប្រណាប់ប្រធានតែមួយ។ កន្សោមកិរិយាទី១ *«នាំគ្នា»* មានកិរិយាសកម្មស្តែងបែបនៃចលនា និងកន្សោមកិរិយាទី២ *«ចុះទូក»* បង្ហាញវិសាលភាពនៃចលនា ដែលជាទិដ្ឋភាពមួយបញ្ជាក់គន្លងនៃចលនាឆ្ពោះទៅបរិវេណ«ទូក»។ កន្សោមកិរិយាទាំងពីរមានប្រធានវេយ្យាករណ៍រួមគ្នា ក្នុងទំនាក់ទំនងស្ថាបនាន័យនៃព្រឹត្តិការណ៍ចលនាជំណាលគ្នា។

(២) នៅចន្លោះៗថ្មនោះ មានទឹកថ្លា**ហូរហែងៗចេញ**ពីរន្ធថ្ម។[១២]

សំណង់(២) ក្នុងកន្សោមកិរិយាទី១ *«ហូរហែងៗ»* មានកិរិយាអកម្ម ពិពណ៌នារបៀបដែលអង្គតាបម្លាស់ទីចលនាក្នុងលម្ហអាកាសឆ្ពោះទៅបរិវេណ។ បរិវេណនៅទីនេះ ស្តែងដោយកន្សោមកិរិយាទី២ *«ចេញពីរន្ធថ្ម»* បញ្ជាក់ទិដ្ឋភាពប្រភពនៃចលនា។

### ៤.២- ករណីព្រឹត្តិការណ៍ចលនាពាក់ព័ន្ធដល់បរិវេណច្រើនជាងមួយ

---

[១១] ប្រជុំរឿងព្រេងខ្មែរ ភាគ១ ទំព័រ៣៤។

[១២] ដ.ឯ.ម. ភាគ៦ ទំព័រ៦៥។

សំណង់ពិពណ៌នាព្រឹត្តិការណ៍ចលនាពាក់ព័ន្ធដល់បរិវេណច្រើនជាងមួយ គឺមានសម្បូរបែបក្នុងទិន្នន័យភាសាខ្មែរ។ វិសាលភាពនៃចលនាពាក់ព័ន្ធដល់បរិវេណនោះ អាចមានកិរិយាសព្ទពីរ បី ឬច្រើនទៅទៀត ដែលពិពណ៌នាទិដ្ឋភាពផ្សេងៗនៃចលនា។ យើងនឹងសង្កេតមើលសំណង់ខាងក្រោមដូចតទៅៈ

(៣) តាចាស់**ពុន**បាយសំណុំទឹកបំពង់**ចាកចេញ**ពីផ្ទះ**ទៅ**។[១៣]

សំណង់(៣) កន្សោមកិរិយាទី១ *«ពុនបាយសំណុំទឹកបំពង់»* មានកិរិយាសកម្ម*«ពុន»* ពិពណ៌នារបៀបដែលអង្គតាបម្លាស់ទីទទួលយកអង្គតា *«បាយសំណុំទឹកបំពង់»* ចលនាក្នុងលម្ហអាកាសឆ្ពោះទៅបរិវេណ។ ចំពោះទិដ្ឋភាពបរិវេណមានពីរ គឺកន្សោមកិរិយា*«ចាកចេញពីផ្ទះ»* បង្ហាញប្រភពនៃចលនា និងកន្សោមកិរិយា*«ទៅ ø»* បង្ហាញគោលដៅនៃចលនា។ ប៉ុន្តែក្នុងបរិបទនេះ អវត្តមានកន្សោមនាមដែលបង្ហាញទីកន្លែង បញ្ជាក់នូវគោលដៅនៃព្រឹត្តិការណ៍ចលនាទាំងមូល។

(៤) កូនឯង**រែកអង្ករនេះឡើងតាម**គាត់ឱ្យឆាប់។[១៤]

សំណង់(៤) កន្សោមកិរិយាទី១*«រែកអង្ករនេះ»* មានកិរិយាសកម្ម*«រែក»* ពិពណ៌នារបៀបដែលអង្គតាបម្លាស់ទីទទួលយកអង្គតា *«អង្ករនេះ»* ចលនាក្នុងលម្ហអាកាសឆ្ពោះទៅបរិវេណ។ ទិដ្ឋាភាពបរិវេណបង្ហាញគន្លងនៃចលនារួមមាន*«ឡើង»* និង*«តាម»*។ ក្នុងបរិបទនេះ កិរិយាសព្ទ*«ឡើង»* អវត្តមានកន្សោមនាមកម្មបទ ដូច្នោះ*«ឡើង»* និង*«តាម»* មានលទ្ធភាពតភ្ជាប់។ ចំពោះ វចនតា*«តាម»*[១៥] មានកម្មបទ*«គាត់»* ជាកន្សោមនាមជីវចលដែលបញ្ជាក់ភាវៈមានជីវិត ដូច្នោះ*«តាម»* មានមុខងារជាកិរិយាសព្ទប្រាប់គន្លងនៃចលនា។

(៥) ដង្កៀនោះ**នាំ**ប្រពន្ធ**ចុះចាកចេញមក**លំនៅដើម។[១៦]

សំណង់(៥) ជាទិដ្ឋភាពមួយផ្សេងទៀត កន្សោមកិរិយាទី១និងទី២ មានទំនាក់ទំនងដូចករណីខាងលើដែរ។ ក្នុងកន្សោមកិរិយាទី១ *«នាំប្រពន្ធ»* មានកិរិយាសកម្ម*«នាំ»* ពិពណ៌នានូវរបៀបដែលអង្គតាបម្លាស់ទី*«ដង្កៀនោះ»* ទទួលយកអង្គតា*«ប្រពន្ធ»* ចលនាក្នុងលម្ហអាកាសឆ្ពោះទៅបរិវេណ។ ចំពោះទិដ្ឋភាពបរិវេណមានបី រួមមានគន្លងនៃចលនា*«ចុះ ø»* និងប្រភពនៃចលនា*«ចាកចេញ ø»* ឆ្ពោះទៅគោលដៅនៃចលនា*«មកលំនៅដើម»*។ ក្នុងបរិបទនេះ អវត្តមាននៃកន្សោមនាមកម្មបទគន្លងនៃចលនា និងកន្សោមនាមកម្មបទប្រភពនៃចលនា ដូច្នោះកិរិយាសព្ទទាំងពីរមានលទ្ធភាពតភ្ជាប់ ទៅជា*«**ចុះចាកចេញមកលំនៅដើម**»* តាមលំដាប់។

### ៤.៣- ករណីព្រឹត្តិការណ៍ចលនាពាក់ព័ន្ធនឹងបរិវេណចលនាវិលត្រឡប់

ចំពោះករណីនេះ គឺពិពណ៌នាព្រឹត្តិការណ៍ចលនាមួយពាក់ព័ន្ធដល់បរិវេណចលនាវិលត្រឡប់។ ចលនាវិលត្រឡប់ តែងសំដៅទៅរកគោលដៅមួយនៅទីបំផុត ហើយជាទូទៅមានលំដាប់សមាសភាគដូចតារាងខាងក្រោមៈ

---

[១៣] -ដ- ភាគ១ ទំព័រ៥៨។

[១៤] ដ.ឯ.ម. ភាគ១ ទំព័រ៥៦។

[១៥] ពាក្យ*«តាម»* ក្នុងបរិបទនេះ ជាប្រភេទកិរិយាសព្ទដែលបង្ហាញគន្លងនៃចលនា មានកម្មបទជាកន្សោមនាមជីវចល [+ animate] ឬ អង្គតាបម្លាស់ទី។ ក្នុងករណីដែលកម្មបទរបស់*«តាម»* ជាកន្សោមនាមអជីវចល បញ្ជាក់ទីតាំងឬទីកន្លែង*«តាម»* មានមុខងារជាធ្នាក់ និងឆ្លើយសំនួរឱ្យកិរិយាបង្គោលក្នុងន័យប្រព្រឹត្តទៅបែបណាទៅវិញ។ ឧបមាសំណង់*«ទូកលយសន្សឹមៗតាមដងស្ទឹង។»* ក្នុងនោះ*«តាមដងស្ទឹង»* ជាកន្សោមមានធ្នាក់ រួមមានធ្នាក់*«តាម»* និងកន្សោមនាមអជីវចល*«ដងស្ទឹង»* ដែលប្រាប់បែបប្រព្រឹត្តទៅនៃចលនាខាងដើម។

[១៦] ដ.ឯ.ម. ភាគ១ ទំព័រ១៤។

| បែបនៃចលនា | ចលនាវិលត្រឡប់ | កិរិយាកំណត់ | កម្មបទ | គុណកិរិយា |
|---|---|---|---|---|
| [±កិរិយាសកម្ម] | វិល ត្រឡប់ វិលត្រឡប់ | ទៅ មក ចូល | កន | វិញ |

*តារាង១ លំដាប់សមាសភាគនៃព្រឹត្តិការណ៍ចលនាពាក់ព័ន្ធនឹងបរិវេណចលនាវិលត្រឡប់*

បរិវេណចលនាវិលត្រឡប់ អាចមានទិដ្ឋភាពពិពណ៌នាផ្សេងៗទៅតាមប្រត្យក្សារម្មណ៍នៃម្ចាស់ភាសាចំពោះព័ត៌មាន ឬរឿងរ៉ាវអ្វីមួយ។ សំណង់ប្រភេទនេះ នឹងមានលំដាប់សមាសភាគដូចក្នុងតារាង១ ក៏ប៉ុន្តែក្នុងករណីខ្លះ អាចអវត្តមាននៃសមាសភាគណាមួយ។ សូមសង្កេតមើលសំណង់ល្បះដូចតទៅ៖

(៦) ព្រានព្រៃម្នាក់ឈ្មោះកៃវៈ[...]**នាំយក**ប្រើសនោះ**វិលត្រឡប់មក**ផ្ទះ*វិញ* [...]។[១៧]

សំណង់(៦) ក្នុងកន្សោមកិរិយាទី១ *«នាំយកប្រើសនោះ»* មានកិរិយាសកម្ម*«នាំយក»* ប្រាប់បែបនៃចលនាដែលអង្គតាបម្លាស់ទី*«ព្រានព្រៃម្នាក់ឈ្មោះកៃវៈ»* ទទួលយកអង្គតា*«ប្រើសនោះ»* ចលនាឆ្ពោះទៅបរិវេណ។ បរិវេណស្តែងដោយកន្សោមកិរិយាទី២ រួមមានកិរិយា*«វិលត្រឡប់»* ប្រាប់នូវចលនាវិលត្រឡប់ឆ្ពោះទៅគោលដៅ *«មកផ្ទះ»*។ សំណង់ប្រភេទនេះតែងមានគុណកិរិយា*«វិញ»* នៅខាងចុង បញ្ជាក់ចលនាវិលត្រឡប់ឱ្យកាន់តែច្បាស់ថែមទៀត។

(៧) សេដ្ឋី**ក្រាបថ្វាយបង្គំលា****នាំ**កូន**ត្រឡប់មក**ផ្ទះ។[១៨]

ព្រឹត្តិការណ៍ចលនាមួយប្រព្រឹត្តទៅ អាចមានសកម្មភាព ឬហេតុភេទណាមួយកើតឡើងជាខាងដើម។ ប៉ុន្តែព្រឹត្តិការណ៍ ឬសកម្មភាពនោះជាធាតុមួយផ្សេងទៀត ដែលមានទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍ចលនាទាំងមូល។ សំណង់(៧) ជាទិដ្ឋភាពបញ្ជាក់នូវទំនាក់ទំនងនោះ។ យើងឃើញថា ក្នុងប្រណាប់ប្រធាន ព្រឹត្តិការណ៍ចលនា *«នាំកូនត្រឡប់មកផ្ទះ»* មានទំនាក់ទំនងទាំងស្រុងទៅនឹងសកម្មភាពខាងដើមរបស់ប្រធាន*«ក្រាបថ្វាយបង្គំលា»*។ កន្សោម*«ក្រាបថ្វាយង្គំលា»* ជាកន្សោមកិរិយាបញ្ជាក់នូវសកម្មភាពរបស់ប្រធានមុនពេលបម្លាស់ទី*«នាំកូនវិលត្រឡប់មកផ្ទះ»*។ ចំពោះ ព្រឹត្តិការណ៍ចលនា *«នាំកូនវិលត្រឡប់មកផ្ទះ»* នៅរក្សាលំដាប់សមាសភាគ កន្សោមទី១*«នាំកូន»* ស្តែងបែបនៃចលនា និងកន្សោមទី២ *«វិលត្រឡប់មកផ្ទះ»* បង្ហាញទិដ្ឋភាពបរិវេណនៃចលនាដដែល។

## ៤- សេចក្តីសន្និដ្ឋាន

សំណង់ទាំងឡាយដែលបកស្រាយខាងលើបញ្ជាក់ថា ភាសាខ្មែរមានបាតុភូតកិរិយាសព្ទស៊េរីចលនាដំណាលគ្នា ដែលកិរិយាសព្ទទាំងនោះស្ថិតនៅបន្តបន្ទាប់គ្នាដោយមិនមានឈ្នាប់ក្នុងប្រណាប់ប្រធានតែមួយ។ ការសិក្សានេះ បានរកឃើញថា ទំនាក់ទំនងនៃកន្សោមកិរិយាទាំងពីរមានលំដាប់សមាសភាគជាបដិមាភាព(iconicity) គឺ កន្សោមកិរិយាទី១ ពិពណ៌នាបែបនៃចលនា(ម. ២.២.១) ខណៈកន្សោមកិរិយាទី២ ពិពណ៌នាទិដ្ឋភាពបរិវេណ (ម. ២.២.២)។ កន្សោមកិរិយាទាំងពីរមានប្រធានវេយ្យាករណ៍មួយរួមគ្នា និងទំនាក់ទំនងក្នុងគោលស្ថាបនាន័យនៃព្រឹត្តិការណ៍ចលនាដំណាលគ្នាដែលមានទិដ្ឋភាពបរិវេណផ្សេងៗ។

---

[១៧] ជ.ឯ.ម. ភាគ១ ទំព័រ៧៤។

[១៨] -ដ- ភាគ១ ទំព័រ៧។

លទ្ធផលនៃការសិក្សានេះ ខុសពីការសិក្សាមុនលើលក្ខណៈសម្ព័ន្ធ Chhany (1995) សិក្សាសំណង់ល្បះដែលមានកិរិយាសព្ទកំណត់ស្ថិតនៅទីតាំងខាងដើម ក្នុងន័យពិពណ៌នាកន្សោមកិរិយាទី២ ជាកម្មបទរងបំពេញន័យឱ្យកិរិយាបង្គោល។ ចំពោះ Mikami (1981) សិក្សាទំនាក់ទំនងកន្សោមកិរិយាទាំងពីរ ពិពណ៌នាអំពើកើតឡើងបន្តបន្ទាប់ និងស្របគ្នាក្នុងពេលតែមួយ។ អំពីកិរិយាទិសដៅ ដែល Haiman (2011) ពិពណ៌នា គឺពាក់ព័ន្ធដល់អំពើតែប៉ុណ្ណោះ ពុំបានសិក្សាលើករណីចលនា ដូចបានពិពណ៌នានៅកថាភាគ៤ នៃការសិក្សានេះ។

ការសិក្សានេះក៏បានរកឃើញដែរថា កិរិយាសព្ទខាងចុងបញ្ជាក់ទិដ្ឋភាពបរិវេណនោះមានលក្ខណៈន័យ និងមុខងារសម្បូរបែបគួរពិចារណា។ ឧបមាពាក្យ *«តាម»* បើក្នុងសំណង់ដែលកម្មបទ *«តាម»* ជាកន្សោមនាមអជីវចលប្រាប់ទីកន្លែងឬទីតាំងអ្វីមួយ ពាក្យ *«តាម»* មានមុខងារជាធ្នាក់។ ផ្ទុយទៅវិញ បើកម្មបទរបស់ *«តាម»* ជាកន្សោមនាមជីវចល ឬអង្គតាបម្ចាស់ទី *«តាម»* មានមុខងារជាកិរិយាសព្ទ។

អត្ថបទសិក្សានេះ ជាជំហានមួយដែលយើងខ្ញុំលើកយកករណីព្រឹត្តិការណ៍ចលនាមកសិក្សាមួយភាគប៉ុណ្ណោះ។ លទ្ធផលនៃការសិក្សាគ្រាន់តែជាជ្រុងមួយឆ្លុះបញ្ចាំងបាតុភូតពិសេសក្នុងភាសាខ្មែរ និងអាចចូលរួមវិភាគទានដល់អ្នកសិក្សាឯទៀត យកទៅពិចារណាសិក្សាឱ្យកាន់តែស៊ីជម្រៅថែមទៀត។

## គន្ថនិទ្ទេស

១- ជុំ ស៊ុនណាង *កម្រងអត្ថបទស្រាវជ្រាវភាសា វប្បធម៌ និងអក្សរសាស្ត្រខ្មែរ* វិទ្យាស្ថានភាសាជាតិរាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ២០១៩។

២- វង្ស មេង **សម្ព័ន្ធវិទ្យា** គ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ ភ្នំពេញ ២០២១។

៣- នៅ ស៊ុន *វេយ្យាករណ៍ខ្មែរសម្រាប់មធ្យមសិក្សា* គ្រឹះស្ថានបោះពុម្ពនិងចែកចាយ ភ្នំពេញ ២០១៣។

៤- អៀវ កើស *ភាសាខ្មែរការល្បងពិនិត្យដោយរកហេតុផង* បណ្ណាគារ មិត្តសេរី ភ្នំពេញ ១៩៦៧។

៥- Dixon R.M.W., *A Semantic Approach to English Grammar*, Oxford: OUP, 2005.

៦- Haiman, J., *Cambodian Khmer: Complex verbal predicates and verbal clumps*, John Benjamins, London Oriental and African Language Library, vol. 16, 2011.

៧- Jarkey, N., *Serial Verbs in White Hmong*, Brill, Leiden, 2015.

៨- Mikami, Naomitsu, *Serial verb construction in Vietnamese and Cambodian*, Gengo Kenkyu, 79, 1981.

៩- Poley, J.A., & Van Valin, R.D., Jr., *Functional syntax and universal grammar*, Cambridge: Cambridge University Press, 1984.

១០- Chhany Sak-Humphrey, *'Serial' and 'Completive' verbs in Khmer*, The third Annual Meeting of the Southeast Asian Linguistics Society, ed. M. Alves, 1995, pp. 177-204.

១១- Talmy, L., *Semantics and Syntax of motion*, In J.P. Kimball (Ed.), *Syntax and Semantics* (Vol.4), New York: Academic Press, 1975.

១២- Talmy, L.,*'Toward a Cognitive Semantics'*, vol.2, Cambridge, MA: MIT Press, 2000.

# សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យនៅកម្ពុជា
# "សក្តានុពល និងកត្តាប្រឈមនៃអចលនទ្រព្យនៅកម្ពុជា"

*បេក្ខជនបណ្ឌិត៖* ***ប៉ាត បញ្ញា***
*ជំនាញ៖* ***នីតិសាស្ត្រ***
*គ្រូណែនាំ៖* ***បណ្ឌិត ផុន ម៉ុនថាល់***

## ១-សក្តានុពលនៃអចលនទ្រព្យ

អចលនទ្រព្យ ជាធាតុចាំបាច់ជួយទ្រទ្រង់ដល់ជីវភាពសង្គម សេដ្ឋកិច្ច នយោបាយ រៀបចំរចនាសម្ព័ន្ធក្នុងប្រទេស និងលើកមុខមាត់ជាតិទៅកាន់ឆាកអន្តរជាតិ។ សិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យគឺជាបូរណសិទ្ធិដែលប្រមូលផ្តុំទៅដោយសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើអចលនទ្រព្យ។ ផ្អែកលើកំណត់ត្រាទូទៅនៃវិស័យអចលនទ្រព្យនៅកម្ពុជា បានបង្ហាញពីតថភាពជាក់ស្តែងឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈសមិទ្ធផលនៃវិស័យកសិកម្ម សំណង់ ទេសចរណ៍ ឧស្សាហកម្ម និងទំហំវិនិយោគក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ សមិទ្ធផលនៃអចលនទ្រព្យកើតឡើងតាមរយៈ៖

**ទី១-ការគ្រប់គ្រងដីធ្លី៖** ក្រោយឆ្នាំ១៩៧៩ របបកម្មសិទ្ធិដីធ្លីនៅកម្ពុជាត្រូវបានអនុវត្តសិទ្ធិដោយពីរទម្រង់គឺសិទ្ធិភោគៈនិងសិទ្ធិកម្មសិទ្ធិ។ ប្រការនេះ សិទ្ធិភោគៈអាចស្នើសុំបណ្ណដីបញ្ជាក់ពីសិទ្ធិតាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងសិទ្ធិកម្មសិទ្ធិ អាចទទួលបានបណ្ណកម្មសិទ្ធិតាមរយៈ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែលត្រូវអនុវត្តមួយភូមិម្តងតាមគម្រោងរដ្ឋបាលដីធ្លីរបស់រាជរដ្ឋាភិបាល។ សមត្ថកិច្ចគ្រប់គ្រងអចលនទ្រព្យរួមមាន ក្រសួងស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដែលមានតួនាទីភារកិច្ចអនុវត្តការងារតាមមុខសញ្ញា តាមផ្នែក និងតួនាទីភារកិច្ចរៀងៗខ្លួនដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល។ ក្នុងនោះ រដ្ឋបាលសុរិយោដី ជាសមត្ថកិច្ចជំនាញក្នុងការចេញបណ្ណកម្មសិទ្ធិលើដីធ្លី និងលិខិតអនុញ្ញាតសាងសង់។ តាមរយៈការអនុវត្តយន្តការគ្រប់គ្រងដីធ្លី របបកម្មសិទ្ធិដីធ្លីនៅកម្ពុជាមានសុវត្ថិភាពជាងមុន ហើយរដ្ឋអាចប្រមូលចំណូលថវិការជាតិពីវិស័យនេះទាំងថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ ប្រការនេះ ក្រសួងអនុវត្តការងារពីចាប់ផ្តើមដល់ឆ្នាំ២០២០ សម្រេចចេញបណ្ណកម្មសិទ្ធិ៦ ០៧៦ ៨៩៣បណ្ណ ស្មើនឹង៨៦,៨% នៃក្បាលដីប៉ាន់ស្មាន ៧លានក្បាលដី ចេញលិខិតអនុញ្ញាតសាងសង់៥៣ ២៨៧ គម្រោងលើផ្ទៃ ១៥៣ ៦២៥ ៨១៩ម$^២$ ទុនវិនិយោគ ៦០ ៨៧២ ៤១១ ដុល្លារ និងចំណូលជាតិក្នុងឆ្នាំ២០២០ ៤៧៩ ៨២៤ ១៦៩ ៣៦២រៀល ថយចុះ២,៤១%ធៀបឆ្នាំ២០១៩ ដោយវិបត្តិCOVID-19។

**ទី២-នីតិវិធីដោះស្រាយវិវាទដីធ្លី៖** ស្ថាប័នដោះស្រាយវិវាទដីធ្លីដែលកម្ពុជាធ្លាប់បានយកអនុវត្តកន្លងមក និងកំពុងតែអនុវត្តមានស្ថាប័ននីតិប្រតិបត្តិ និងតុលាការ។ យន្តការដោះស្រាវវិវាទដីធ្លីរបស់រដ្ឋា

ភិបាលអនុវត្តតាមរយៈ រដ្ឋបាលឃុំសង្កាត់ គណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដី អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងក្រុមការងារដោះស្រាយវិវាទទៅតាមករណីវិវាទនីមួយៗ។ ប្រការនេះ ជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំពោះដីធ្លីពុំទាន់ចុះបញ្ជីបណ្ណកម្មសិទ្ធិឬកំពុងចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ សំដៅឱ្យភាគីវិវាទមានវប្បធម៌យោគយល់គ្នា និងកាត់បន្ថយវិវាទបញ្ជូនទៅតុលាការ។ ការអនុវត្តកន្លងមក ពីឆ្នាំ២០០៣-២០២០ ទួលពាក្យបណ្ដឹង ១៣ ៥៦៦ករណី ដោះស្រាយបញ្ចប់ ១០ ៥៥៣ករណី និងកំពុងដោះស្រាយ ៣០១៣ករណី។ ចំណែកឯ ស្ថាប័នតុលាការ ដោះស្រាយវិវាទនៃសិទ្ធិលើដីធ្លី(ដីធ្លីមានបណ្ណកម្មសិទ្ធិ) វិវាទលើរឿងក្ដីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងការផ្ទេរ-ការប្រគល់សិទ្ធិលើដីនិងវិវាទទាំងឡាយដែលមិនទាន់ត្រូវបានដោះស្រាយបញ្ចប់ដោយស្ថាប័នរដ្ឋាភិបាល។

**ទី៣-ការវិនិយោគ៖** កាលពីមុនកម្ពុជាត្រូវបានគេល្បីថាជាវាលពិឃាត តំបន់អសន្តិសុខ ចំការមីន ទីក្រុងខ្មោចដែលមនុស្សគ្រប់គ្នាភ័យខ្លាច ប៉ុន្តែពេលនេះបានប្រែក្លាយទៅជាប្រទេសមួយ ដែលមានសន្តិសុខពេញលេញ ជាមជ្ឈមណ្ឌលផលិតចែកចាយទំនិញគ្រប់ប្រភេទ បណ្ដុំការរស់នៅប្រកបដោយប្រណិតភាព និងតំបន់ទេសចរណ៍ដ៏រស់រវើក។ ការរីកចម្រើននេះបានបង្ហាញឱ្យឃើញតាមរយៈវត្តមាននៃទីក្រុងរណប អគារពាណិជ្ជកម្ម បុរី ខុនដូ សំណង់លំនៅឋាន អគាររដ្ឋបាល អគារសាធារណៈ អគារសិក្សា ផ្ទះសំណាក់ សណ្ឋាគារ រមណីយដ្ឋាន រោងចក្រ ឃ្លាំង ផ្សារទំនើបសាងសង់ឡើងជាបន្តបន្ទាប់ និងទេសចរណ៍ទាំងធនធានធម្មជាតិ និងសម្បត្តិបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជួយជំរុញកាលានុវត្តន៍ភាពបន្ថែមទៀតដោយធ្វើឱ្យកម្ពុជារឹតតែស្រស់បំព្រងពុំចាញ់ប្រទេសជិតខាង តំបន់អាស៊ីអាគ្នេយ៍ និងក្នុងសកលលោកនោះឡើយ។ ការអនុវត្តរយៈពេលជាងពីរទសវត្សរ៍ ផ្ដើមចេញពីកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងរដ្ឋ និងឯកជននាំឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់លេខ៦ក្នុងចំណោមប្រទេសសេដ្ឋកិច្ចរីកចម្រើនលឿនជាងគេនៅលើពិភពលោក សម្រេចបានកំណើនសេដ្ឋកិច្ច៧%/ឆ្នាំ ការកើនឡើងផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់ៗ ពីចន្លោះ៧៣៨ដុល្លារឆ្នាំ២០០៨ដល់១៧០៦ដុល្លារឆ្នាំ២០១៩ និងកំពុងឈានឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់កម្ពុជា ជាប្រទេសចំណូលខ្ពស់នាពេលអនាគត។ ក្នុងនោះ កម្ពុជាឈរទីតាំងយុទ្ធសាស្ត្រក្នុងតំបន់អាស៊ាន កំពុងប្រែខ្លួនជា«**រោងចក្រអាស៊ី**»នៅកណ្ដាលតំបន់មេគង្គ សក្ដានុពលសេដ្ឋកិច្ច និងការតភ្ជាប់ខ្ពស់ជាងគេ ហើយទីផ្សារអចលនវត្ថុមានតម្លៃសមរម្យ មានន័យថាក្រោមទីផ្សារតម្លៃអចលនវត្ថុនៃប្រទេសជាច្រើនក្នុងតំបន់អាស៊ាន និងសកលលោកផ្ដល់ឱកាសក្នុងការរកប្រាក់ចំណេញសម្រាប់វិនិយោគិនទាំងក្នុងស្រុក និងបរទេស។

## ២-កត្តាប្រឈមនៃអចលនទ្រព្យ

វិស័យអចលនទ្រព្យមានការផ្លាស់ប្ដូរជាបន្តបន្ទាប់ និងត្រូវបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅទូលំទូលាយទាំងផ្នែកច្បាប់ និងផ្នែកស្ថាប័នសមត្ថកិច្ច។ ផ្ទុយទៅវិញ ការអនុវត្តសិទ្ធិកម្មសិទ្ធិប្រព្រឹត្តទៅ

ក្នុងក្របខណ្ឌច្បាប់ជាធរមាន មានលក្ខណៈប្លែកៗពីគ្នា ក្រោមរបបគតិយុត្តខុសគ្នាតាមប្រភេទនីមួយៗ និងប្រើប្រាស់ក្រោមទម្រង់ខុសគ្នាអាចជាការចន្លោះប្រហោងដល់មាត្រាច្បាប់ និងការអនុវត្តនៃស្ថាប័នសមត្ថកិច្ចចំពោះអចលនទ្រព្យ។ កត្តាប្រឈមនៃអចលនទ្រព្យ ជាអាទិ៍៖

**ទី១-ដីធ្លីមិនទាន់ចុះបញ្ជីចេញបណ្ណកម្មសិទ្ធិ៖** បច្ចុប្បន្ននេះកម្ពុជាពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីបញ្ចប់ការងារចុះបញ្ជីដីធ្លី និងចេញបណ្ណកម្មសិទ្ធិឱ្យរួចរាល់ចំពោះក្បាលដីទាំងអស់នៅទូទាំងប្រទេសនៅឡើយទេ។ មិនតែប៉ុណ្ណោះ ដីរដ្ឋ ដីឯកជន និងដីសមូហភាពមួយចំនួនក៏មិនទាន់ត្រូវបានកំណត់អត្តសញ្ញាណក្បាលដី អត្តសញ្ញាណម្ចាស់ដី ព្រំប្រទល់នៃដីឱ្យបានច្បាស់លាស់នៅឡើយទេ។ ប្រការនេះ ដីធ្លីនៅតែជាប្រភពនៃវិវាទ ការកាន់កាប់ដោយខុសច្បាប់ ពុំទទួលបានការរៀបចំផែនការប្រើប្រាស់ដីធ្លីឱ្យទៅតាមលទ្ធភាពនិងមិនទទួលបានការគាំពារពេញលេញដោយក្របខណ្ឌច្បាប់ជាធរមាន។ ឧ-វិវាទនៃសិទ្ធិភោគៈ សិទ្ធិសមូហភាព និងការចូលកាន់កាប់ទន្ទ្រានយកដីរដ្ឋដើម្បីយកជាកម្មសិទ្ធិ ប្រើក្នុងរូបភាពជាភោគៈ។

**ទី២-សម្បទានដីសេដ្ឋកិច្ចមានទំហំធំធេង ប៉ុន្តែមិនគ្រប់ជ្រុងជ្រោយ៖** ការផ្តល់សម្បទានដីត្រូវបានធ្វើឡើងដោយមិនគោរពសិទ្ធិលើទ្រព្យសម្បត្តិឯកជន សិទ្ធិភោគៈ និងសិទ្ធិសមូហភាព ឬពុំប្រកាន់ខ្ជាប់តាមការកំណត់នៃច្បាប់ស្តីពីការផ្តល់ទំហំដីសម្បទាន ឬពុំបានធ្វើការវាយតម្លៃជាបឋមពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ឬពុំធ្វើចំណាត់ថ្នាក់ឱ្យបានត្រឹមត្រូវជាមុននូវដីដែលត្រូវទទួលបានដោយស្របច្បាប់សម្រាប់ការធ្វើអនុប្បយោគ និងមិនគោរពដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការពិគ្រោះយោបល់ ឬទទួលសំណងដោយសមរម្យ និងយុត្តិធម៌។ រីឯ ការអនុវត្តសម្បទានដីក៏រំលោភទាំងស្រុងនឹងមាត្រា៥៨នៃច្បាប់ភូមិបាល ចែងថាសម្បទានដីសេដ្ឋកិច្ចមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សម្រាប់ថែទាំ ផ្លូវទឹក បឹង ត្រពាំង និងដែនទឹកបម្រុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋនោះឡើយ។ ប៉ុន្តែផ្ទុយទៅវិញដីសម្បទានតែងតែបិទសិទ្ធិប្រជាពលរដ្ឋជានិច្ច ឬជាការបណ្តេញចេញដោយការបង្ខំ។ ករណីខ្លះសម្បទានដីសេដ្ឋកិច្ចគ្រាន់តែបំផ្លាញទៅដល់បរិស្ថាន និងធនធានធម្មជាតិតែប៉ុណ្ណោះដែលនាំឱ្យរដ្ឋាភិបាលពុំទទួលផលចំណេញអ្វីសោះពីសម្បទាននេះ។ ដោយឡែក សម្បទានដីសេដ្ឋកិច្ចចំនួន៤ ក្នុងភូមិសាស្ត្រស្រុកភ្នំស្រួច និងឱរ៉ាល់ ខេត្តកំពង់ស្ពឺត្រូវបានដកហូតដោយពិនិត្យឃើញថាមានផលប៉ះពាល់ជាងការអភិវឌ្ឍ។

**ទី៣-ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងដីរដ្ឋមិនទាន់មានប្រសិទ្ធភាព៖** ក្នុងក្របខណ្ឌអនុវត្ត រដ្ឋាភិបាលបានសម្រចលក់ ដូរ ជួល និងសម្បទានទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយមិនចាំបាច់ឆ្លងរដ្ឋសភា ព្រឹទ្ធសភា ឬមិនលម្អិតពីលទ្ធភាពនៃទ្រព្យសម្បត្តិ ឬរៀបចំដែនដី ឬការធ្វេសប្រហែសនៃស្ថាប័នថ្នាក់មូលដ្ឋានជាហេតុនាំឱ្យមានទំនាស់ដីធ្លីនៅមូលដ្ឋាន ប៉ះពាល់ដល់បរិស្ថាន បាត់បង់ព្រៃឈើ សត្វ

ព្រៃ ការតាំងទីលំនៅថ្មីគ្មានផែនការច្បាស់លាស់ ការធ្វើអាជីវកម្មរ៉ែគ្មាននីរន្តភាព គំរាមកំហែងការរស់នៅប្រជាពលរដ្ឋ ប៉ះពាល់ដល់សហគមន៍ជនជាតិដើម តំបន់ការពារធម្មជាតិបាត់បង់បន្តិចម្តងៗ តំបន់ទេសចរណ៍ តំបន់បេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ តំបន់ឆ្នេរ តំបន់កោះ និងជួរភ្នំមួយចំនួនទៀត។ ចំណុចទាំងនេះ ប្រសិនបើពុំបានរៀបចំប្លង់គោល ធ្វើចំណាត់ថ្នាក់ដី ការចុះបញ្ជីដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ រួមទាំងរៀបចំតំបន់ប្រើប្រាស់ដីតាមលទ្ធភាពសម្រាប់បច្ចុប្បន្ន និងអនាគតឱ្យរួចរាល់ទេនោះ ប្រាកដណាស់ផលប៉ះពាល់ខ្លាំងជាសាធារណៈនៅពេលរដ្ឋាភិបាលសម្រេចលក់ ដូរ ជួលនិងសម្បទានដីក្នុងន័យសេដ្ឋកិច្ចណាមួយ។

**ទី៤-សំណង់គ្មានច្បាប់និងអាណាធិបតេយ្យនៅបន្តឱ្យមានការសាងសង់និងគ្មានការរុះរើ៖** សំណង់គ្មានច្បាប់ សំណង់ អាណាធិបតេយ្យដែលទាមទារសិទ្ធិលើទីតាំងសំណង់ជាបណ្តោះអាសន្នតាមទីក្រុងទីប្រជុំជន និងជនបទកាន់តែស្រួចស្រាល់នៅពេលតម្លៃទីផ្សារដីធ្លីបានកើនឡើងខ្ពស់ ប៉ុន្តែការដោះស្រាយស្ថានភាពសំណង់អាណាធិបតេយ្យមិនទាន់គ្រប់ជ្រុងជ្រោយ និងជៀតជ្រែកពីជនឱកាសនិយមបង្កផលប៉ះពាល់បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគម្រោងអភិវឌ្ឍក្នុងប្រទេសជាដើម។ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សង្កេតឃើញថាសំណង់រីកចម្រើនយ៉ាងឆាប់រហ័សទាំងលំនៅឋាន បុរី អគារសហកម្មសិទ្ធិ អគារពាណិជ្ជកម្ម រោងចក្រ កាស៊ីណូ សណ្ឋាគារ ផ្ទះសំណាក់ អគារស្នាក់នៅ ឃ្លាំង និងស្ថានីយ៍ប្រេងឥន្ធនៈទូទាំងប្រទេស។ ប្រការនេះ បើមិនបានរៀបចំឱ្យបានត្រឹមត្រូវតាមប្លង់រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទេនោះ បញ្ហាប្រឈមអាចនឹងកើតមានដូចជាសំណង់អាណាធិបតេយ្យ គ្មានរបៀបរៀបរយ សំណង់លើដីរដ្ឋ អគារគ្មានគុណភាព ខ្វះសួនសាធារណៈ ឬប្រព័ន្ធផ្លូវសាធារណៈ និងអគារសម្រាប់សេវាសាធារណៈផ្សេងៗ។

**ទី៥-ខ្វះដីបម្រុងទុក និងអគាររដ្ឋនៅមូលដ្ឋាន៖** បរិបទកម្ពុជា រដ្ឋមិនទាន់មានផែនការរក្សាដីធ្លីទុកក្នុងមូលដ្ឋាននៃឃុំសង្កាត់ទូទាំងប្រទេសសម្រាប់ដោះបន្ទុកសង្គម ការអភិវឌ្ឍ ឬផែនការសម្រាប់អនាគតនៅឡើយទេ។ ទន្ទឹមនឹងនេះ សំណង់របស់រដ្ឋក៏មិនទាន់បានរៀបចំដើម្បីបំពេញតម្រូវការឱ្យបានគ្រប់គ្រាន់សម្រាប់ទាំងវិស័យរដ្ឋបាលសាធារណៈ សេវាសាធារណៈ វិស័យទេសចរណ៍ និងសម្រាប់សាធារណៈជនទូទៅ ទាំងខ្មែរ និងបរទេស ព្រមទាំងអាចយកឱកាសនេះ សម្រាលបន្ទុកនៃសង្គមដល់ជនក្រីក្រ ជនពិការ កុមារកំព្រា និងក្រុមបុគ្គលដែលមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញដី ឬអគារស្នាក់នៅ សម្រាប់បច្ចុប្បន្ន និងអនាគត។ ប្រការនេះ រដ្ឋក៏អាចយកទ្រព្យដែលបម្រុងទុកនោះដើម្បីជួល ឬវិនិយោគ ឬសម្បទាន និងផ្តល់ជាសេវាផ្សេងៗ ដែលធ្វើឱ្យមានផលចំណេញទាំងរដ្ឋ ទាំងប្រជាពលរដ្ឋនិងវិនិយោគិន។

**ទី៦-ធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភារៈបច្ចេកទេសពុំទាន់គ្រប់គ្រាន់ឆ្លើយតបទំហំការងារ៖** ជាការពិតណាស់ រាល់ការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់មិនថាវិស័យណាមួយនោះឡើយទាមទារជាចាំបាច់នូវធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភារៈបច្ចេកទេសដើម្បីអនុវត្តការងារ ប៉ុន្តែបើគ្មានការចូលរួមនៃចំណុចទាំងនេះទេនាំឱ្យការអភិវឌ្ឍមានការយឺតយ៉ាវ និងត្រូវប្រឈមស្ទើរតែគ្រប់បញ្ហាទាំងអស់។ ក្របខណ្ឌអនុវត្តទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិតែងតែប្រឈមនឹងបញ្ហាទាំងនេះសម្រាប់ការអនុវត្តការងារជាប្រចាំថ្ងៃលើយន្តការគ្រប់គ្រង ការប្រើប្រាស់ ការចុះបញ្ជីដីធ្លី សំណង់ និងដោះស្រាយវិវាទ។

**ទី៧-យន្តការ និងនីតិវិធីនៃការចុះបញ្ជី ឬស្នើសុំសេវាពាក់ព័ន្ធដីធ្លី និងសំណង់ពីស្ថាប័នមានសមត្ថកិច្ចថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិមានលក្ខណៈស្មុគស្មាញ យឺតយូរ និងចំណាយថវិកាច្រើន៖** ការអនុវត្តជាក់ស្តែង រាល់ការស្នើសុំសេវាទាំងអស់ដែលកំណត់ក្នុងប្រកាសរួមរវាងក្រសួងដនស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសំណើសុំចុះបញ្ជីដីធ្លី សុំលិខិតអនុញ្ញាតសាងសង់ ផ្ទេរកម្មសិទ្ធិ បង្កើតសិទ្ធិប្រាតិភោគប្រត្យ ប្តូរប្រភេទដី បង្រួមក្បាលដី បំបែកក្បាលដី បង្កើតសិទ្ធិដួល សម្បទានដី ស្នើសុំធ្វើអាជីវកម្មនិងអភិវឌ្ឍអចលនទ្រព្យផ្សេងៗជាដើមត្រូវចំណាយពេលយូរជាងការកំណត់នៃប្រកាស ស្មុគស្មាញ និងអាចមានអំពើពុករលួយកើតឡើងក្នុងដំណាក់កាលជួយសម្រួលឯកសារ។ រីឯកម្មសិទ្ធិករ ឬតំណាងត្រូវជួបបញ្ហាប្រឈមលើការចំណាយពេលវេលា ថវិកា និងជួបមន្ត្រីផ្ទាល់ ដើម្បីផ្តិតមេដៃទម្រង់បែបបទ ឯកសារលិខិតលក់ផ្តាច់ អំណោយផ្តាច់ សន្តតិកម្ម ពាក្យស្នើសុំ និងឯកសារណាបផ្សេងៗទៀតយកទៅចរន្តការតាមនីតិវិធី និងបែបបទរដ្ឋបាល ទើបចាំទទួលឯកសារទៅបង់ពន្ធប្រថាប់ត្រានៅសាខាពន្ធដាររាជធានីខេត្ត ខណ្ឌ និងអគ្គនាយកដ្ឋានពន្ធដារ។ ការបង់ពន្ធប្រថាប់ត្រា កម្មសិទ្ធិករ ឬតំណាងត្រូវជួបមន្ត្រីពន្ធដារ ឬនាំមន្ត្រីពន្ធដារពិនិត្យវាស់វែងធ្វើបច្ចុប្បន្នភាពទីតាំងដីជាក់ស្តែង និងរង់ចាំវិក័យបត្រពន្ធដារឱ្យរដ្ឋបាលសុរិយោដីបន្តចរន្តការផ្ទេរកម្មសិទ្ធិស្ថាពរ។ នីតិវិធីកាន់តែស្មុគស្មាញជាហេតុធ្វើឱ្យជនឱកាសនិយមមួយចំនួនអាចកេងចំណេញ និងករណីអំពើពុករលួយកើតឡើងនៅក្នុងដំណើរនៃការចរន្តឯកសារ ឬកម្មសិទ្ធិករជួបការលំបាក ក្នុងការបំពេញលើឯកសារយកទៅចរន្តការតាមនីតិវិធីដែលបង្ខំចិត្តប្រគល់ឯកសារឱ្យឈ្មួញ ឬមន្ត្រីដើម្បីបំពេញនីតិវិធីនៃការចរន្តឯកសារឱ្យពួកគាត់ដែលលេចចេញការទាមទារកម្រៃជើងសារថ្លៃ ឬតម្លៃបង់ពន្ធប្រថាប់ត្រា ថ្លៃហួសពីតម្លៃតម្រូវឱ្យបង់ប្រាក់ផងដែរ។

## ៣-ទស្សនវិស័យនៃការដោះស្រាយ

ក្នុងនីតិកាលកន្លងទៅ កម្ពុជាសម្រេចសមិទ្ធផលធំៗជាច្រើនគួរឱ្យកត់សម្គាល់ទាំងការអនុម័តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដីធ្លី ការចុះបញ្ជី បែងចែកដី សម្បទាន ការប្រមូលចំណូលថវិកាជាតិ និងយន្តការដោះស្រាយវិវាទដីធ្លី ព្រមទាំងបន្តអនុវត្តយ៉ាងសកម្មនៃកំណែទម្រង់ដីធ្លីដោយពង្រឹងលើការគ្រប់គ្រង រៀបចំ ប្រើប្រាស់ និងបែងចែកដីកាត់បន្ថយភាពក្រីក្រ ធានាសន្តិសុខ

សៀង បរិស្ថាន ធនធានធម្មជាតិ និងអភិវឌ្ឍសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែបន្តកើតមានឡើងដែលរដ្ឋាភិបាលបានដោះស្រាយកន្លងមក និងកំពុងបន្តដោះស្រាយនាពេលបច្ចុប្បន្ន ព្រមទាំងបន្តទៅអនាគតផងដែរ។ ជាទសន្សនវិស័យ កម្ពុជាត្រូវបន្តខិតខំពិនិត្យចំណុចខ្វះចន្លោះនៃប្រព័ន្ធច្បាប់ដោយវិសោធនកម្ម ឬកសាងច្បាប់បន្ថែម ប្រព័ន្ធយុត្តធម៌ កំណែទម្រង់ប្រព័ន្ធស្ថាប័ន និងមិនត្រូវអត់ឱនឱ្យនោះឡើយចំពោះអំពើល្មើសទាំងឡាយដែលប្រព្រឹត្តដោយសាធារណៈជន មន្ត្រីរាជការសា-ធារណៈ និងជនបរទេស។ ជាទស្សនវិស័យនៃការដំណោះស្រាយ ជាអាទិ៍៖

**ទី១-ការងារនីតិកម្ម ត្រូវពង្រឹងនីតិរដ្ឋឱ្យកាន់តែមានភាពរឹងមាំថែមទៀត៖** កម្ពុជាគួរធ្វើសេចក្តីព្រាងច្បាប់ ដូចជាសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម មានន័យថាដីធ្លីទាំងអស់នៅទូទាំងប្រទេសកម្ពុជាត្រូវតែរៀបចំ គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងប្រកបដោយប្រសិទ្ធភាពតាមរយៈការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លីតាមផ្នែក តំបន់ និងលទ្ធភាពនៃដី។ ឱ-កំណត់ និងកម្រិតសិទ្ធប្រើប្រាស់តាមតំបន់សំណង់លំនៅឋាន តំបន់ផលិតកម្មកសិកម្ម តំបន់ការពារ និងអភិរក្ស តំបន់ទេសចរណ៍បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិ តំបន់ឧស្សាហកម្ម រោងចក្រ និងពាណិជ្ជកម្មជាដើមធានាសណ្តាប់ធ្នាប់ បរិស្ថាន និងសុវត្ថិភាពដីធ្លី។ ជាពិសេស កំណត់ និងកម្រិតសិទ្ធិនៃការប្រើប្រាស់លើដីចំណីដូចជាដីចំណីអូរ ព្រែក បឹង ប្រឡាយ ស្ទឹង ទន្លេ សមុទ្រ និងភ្នំដោយជាក់លាក់ ធានាប្រើប្រាស់ជាសាធារ-ណៈ មិនមែនប្រើប្រាស់បានតែចំពោះបុគ្គលដែនមានដីជាប់ដីចំណីនោះទេដែលជាបញ្ហាប្រឈមមួយនៅតែគ្មានការដោះស្រាយ។ សេចក្តីព្រាងច្បាប់ស្តីពីការអភិវឌ្ឍដី សំដៅរៀបចំដីទាំងដីរដ្ឋ និងដីឯកជនឱ្យបានត្រឹមត្រូវនឹងឱ្យចំទិសដៅដោយគ្រប់គ្រងការបំបែកក្បាលដី ឬបង្រួមក្បាលដីជាដីឡូត៍សម្រាប់លក់ និងឡូត៍សម្រាប់សាងសង់លំនៅឋាន អគារឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ និងលើកកម្ពស់ការអភិវឌ្ឍតំបន់បៃតង ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រព័ន្ធលំហសាធារណៈ និងបរិក្ខារសាធារណៈសម្រាប់ទូទៅក្នុងដែនដីកម្ពុជា។ ការអភិវឌ្ឍដីកំណត់ប្លង់គោល ប្លង់ប្រើប្រាស់ដី សិក្សាពីផលប៉ះពាល់ និងតម្រូវឱ្យមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចករណីប្តូរប្រភេទដីសម្រាប់សាងសង់ កែសម្រួលក្បាលដីសម្រាប់អភិវឌ្ឍ គម្រោងបែងចែកជាដីឡូត៍ កែប្រែហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍលំនៅឋាន បុរី អគារសហកម្មសិទ្ធិ អគារស្នាក់នៅ តំបន់ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម រោងចក្រ សួនច្បារ សួនឧស្សាហកម្ម តំបន់ទេសចរណ៍ គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង តំបន់ចម្រុះ និងគម្រោងអភិវឌ្ឍនានា។

**ទី២-ការបណ្តុះបណ្តាលធនធានមនុស្ស៖** សំដៅធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងចែកជូនសៀវភៅច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យដីធ្លី សំណង់ ជាពិសេសក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តី

ពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋទៅដល់ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ គណៈមេធាវី សាកលវិទ្យាល័យ វិទ្យាល័យ ស្ថាប័នរដ្ឋ នគរបាលយុត្តិធម៌ និងមន្ត្រីរាជការ សាធារណៈជននៅរាជធានីខេត្ត ក្រុងស្រុកខណ្ឌ ឃុំសង្កាត់ ភូមិទូទាំងប្រទេសដើម្បីឱ្យឯកសារច្បាប់គោលទាំងនេះទុកសម្រាប់ជាមូលដ្ឋានអនុវត្តការងារ ឬជាឯកសារស្រាវជ្រាវផ្សេងៗទៀតនាពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងអនុវត្តឱ្យបានត្រឹមត្រូវតាមស្មារតីនៃច្បាប់។

**ទី៣-យន្តការដោះស្រាយវិវាទ រដ្ឋបាលតុលាការ និងសេវាយុត្តិធម៌៖** សំដៅបង្កិតសិទ្ធិទទួលបានយុត្តិធម៌ឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន តំបន់ឆ្ងាយៗដោយផ្តល់ភាពងាយស្រួលដល់សាធារណៈជនទូទៅ។ ប្រការនេះ យន្តការដោះស្រាយវិវាទដីធ្លីរបស់រដ្ឋាភិបាល រដ្ឋបាលតុលាការ ទាមទារការអនុវត្តការងារដោយយកចិត្តទុកដាក់ខ្ពស់លើចំណាត់ការ និងដោះស្រាយរឿងក្តីឱ្យបានត្រឹមត្រូវតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាបានសុវត្ថិភាពគតិយុត្តិ បង្កើនការជឿទុកចិត្តជាសាធារណៈ លឿន រហ័ស ចំណាយប្រាក់តិច និងលើកកម្ពស់កិត្យានុភាពប្រព័ន្ធយុត្តិធម៌។ រដ្ឋត្រូវមានសេវាយុត្តិធម៌ដោយសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រៀបចំមេធាវីការពារក្តីជូនដល់ប្រជាពលរដ្ឋក្រីក្រ និងសេវាយុត្តិធម៌។

**ទី៣-កំណែទម្រង់យន្តការអនុវត្ត ដោយធានាការរៀបចំដីធ្លីឱ្យបានត្រឹមត្រូវ និងចំទិសដៅ៖** ស្ថាប័នមានសមត្ថកិច្ចត្រូវខិតខំប្រឹងប្រែងបំពេញការងារអនុលោមតាមក្របខណ្ឌច្បាប់ ផ្តល់សេវាយុត្តិធម៌ និងសេវាសាធារណៈជូនប្រជាពលរដ្ឋតាមភារកិច្ច តួនាទី និងមុខសញ្ញារៀងៗខ្លួន ព្រមទាំងផ្តល់ជាតុចូលថ្មីៗបន្ថែមទៀត ធានាអភិវឌ្ឍស្ថាប័នឱ្យល្អប្រសើរ ជាអាទិ៍៖

- ការគ្រប់គ្រងដីធ្លីត្រូវកំណត់វិធានធានាសិទ្ធិកម្មសិទ្ធិដី លទ្ធភាព ការគ្រប់គ្រង ប្រើប្រាស់ បែងចែកដី លើកកម្ពស់សុវត្ថិភាព និងជម្រុញការអភិវឌ្ឍទីក្រុង ទីប្រជុំជនដល់ជនបទ។ ប្រការនេះពង្រឹងការគ្រប់គ្រងដី ធ្វើចំណាត់ថ្នាក់ដី ឬចំណាត់ថ្នាក់ដីសារឡើងវិញរវាងដីប្រភេទផ្សេងគ្នា កសាងផែនការប្រើប្រាស់ដីដោយរៀបចំបែងចែកជាតំបន់ ជាផ្នែក និងត្រួតពិនិត្យការគ្រប់គ្រងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព ឬជួបបញ្ហាប្រឈមចាំបាច់ត្រូវមានយន្តការដោះស្រាយបន្តឱ្យឆ្លើយតបតាមសភាពការទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតុលាការ។
- សម្បទានសេដ្ឋកិច្ចត្រូវធ្វើប្រព័ន្ធផ្តល់ ពិនិត្យ និងតាមដានការអនុវត្តសម្បទានដីសេដ្ឋកិច្ច ជលផល ធនធានរ៉ែ ព្រៃឈើជាយុទ្ធសាស្ត្រត្រូវសម្របសម្រួលពីអ្នកពាក់ព័ន្ធ នីតិវិធីវាយតម្លៃ និងឯកភាពជាស្តង់ដារ ព្រមទាំងដោះស្រាយផលប៉ះពាល់ឱ្យអស់ កិច្ចសហប្រតិបត្តិការ ការងារគ្រប់គ្រង អភិវឌ្ឍសេដ្ឋកិច្ចប្រជាជន និងសហគមន៍មូលដ្ឋាន។

- បង្កើនសុវត្ថិភាពសិទ្ធិកម្មសិទ្ធិដីធ្លី និងអភិវឌ្ឍទីផ្សារដីធ្លីដោយបញ្ជាក់ច្បាស់ពីកម្មសិទ្ធិ ការកត់ត្រាកម្មសិទ្ធិ និងសិទ្ធិដ៏ទៃទៀតនៃកម្មសិទ្ធិទាំងអស់ទាំងកម្មសិទ្ធិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របតាមក្របខណ្ឌច្បាប់ជាធរមាន។ ប្រការនេះ ចាំបាច់កំណត់អត្តសញ្ញាណក្បាលដី និងអត្តសញ្ញាណម្ចាស់ដីទូទាំងប្រទេសច្បាស់លាស់ ដោយជម្រុញការងារវាស់វែង ការចុះបញ្ជី និងផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ បុគ្គលឯកជន សហគមន៍ជនជាតិដើមភាគតិច អគារសហកម្មសិទ្ធិ សម្បទានដីសង្គមកិច្ច សម្បទានដីសេដ្ឋកិច្ច និងដីរដ្ឋមានដីការដកហូតបញ្ចប់ទូទាំងប្រទេស។
- ការរៀបចំដែនដីនឹងនគរូបនីយកម្មជាចាំបាច់ត្រូវការរៀបចំផែនការប្រើប្រាស់ដី និងការបែងចែកដីធ្លីឱ្យបានត្រឹមត្រូវតាមប្រភេទ និងលទ្ធភាពនៃដីធ្លី ដូចជាដីធ្លីសម្រាប់កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ លំនៅឋាន ទីក្រុង ទីប្រជុំជន សម្បទានដីសេដ្ឋកិច្ច សម្បទានសង្គមកិច្ច តំបន់ការពារ និងអភិរក្សសំដៅធ្វើវិចារណកម្មប្រើប្រាស់ដីធ្លី ជៀសវាងការប្រើប្រាស់ដី និងបំប្លែងប្រើដីពុំចំសក្តានុពល ប៉ះពាល់បរិស្ថាន ប្រយោជន៍សាធារណៈ និងមិនតាមលទ្ធភាពដី។
- ការដោះស្រាយបញ្ហាសំណង់បច្ចុប្បន្ន និងអនាគតដោយអភិវឌ្ឍស្ថាប័នគ្រប់គ្រងសំណង់ ពង្រឹងអាជីវកម្មសំណង់ វិនិយោគសំណង់ កំណត់ស្តង់ដាសំណង់ ពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកបិទការដ្ឋាន និងផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្ម សំណង់ជូនប្រជាជន ឬវិនិយោគិនជាចាំបាច់ និងបន្ទាន់បំផុត។ ប្រការនេះ ការគ្រប់គ្រង និងអភិវឌ្ឍសំណង់ត្រូវសម្របសម្រួល និងជំរុញវិនិយោគ ពង្រឹងភាពជាដៃគូវិស័យឯកជន និងបង្កើនការងារជូនប្រជាពលរដ្ឋ ព្រមទាំងកំណត់ពីស្តង់ដានៃសំណង់រដ្ឋ និងឯកជន។
- រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាមួយក្របខណ្ឌនៃការរៀបចំដែនដី នឹងនគរូបនីយកម្ម ហើយការអភិវឌ្ឍនេះដោយផែនការមេតភ្ជាប់គ្នាឱ្យគ្រប់ជ្រុងជ្រោយទាំងផ្នែករឹង និងផ្នែកទន់លើវិស័យគមនាគមន៍ដឹកជញ្ជូន ថាមពលអគ្គិសនី បច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ប្រព័ន្ធធារាសាស្រ្ត និងវិស័យទឹកស្អាត។ ប្រការនេះ ត្រូវស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់រូបភាពទាំងថ្នល់ ផ្លូវដែក ផ្លូវទឹក កំពង់ផែ ស្ពាន និងអាកាសយានដ្ឋានតភ្ជាប់រវាងគ្រប់តំបន់ទូទាំងប្រទេស ទីក្រុង ទីប្រជុំជន និងជនបទ តភ្ជាប់ជាមួយប្រទេសជិតខាងឱ្យទៅប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនមួយងាយស្រួល ស្ថិរភាព សុវត្ថិភាពនិងតម្លៃទាបសម្រួលដល់ពាណិជ្ជកម្ម ទេសចរណ៍ អភិវឌ្ឍន៍ជនបទ សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោក នឹងបម្រើដល់កិច្ចការពារខ្សែក្រវ៉ាត់ព្រំដែនខណ្ឌសីមាជាតិ។
- ការអភិវឌ្ឍផ្នែកឯកជន នឹងការងារជាការរៀបចំតាមរយៈវិធានការដាក់ស្តែងសម្រួលពាណិជ្ជកម្ម ធុរកិច្ច វិនិយោគ និងអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបនឹងតម្រូវការទីផ្សារ។ ប្រការនេះ

វិស័យឯកជន និងការវិនិយោគវិស័យកសិកម្ម សំណង់ លំនៅឋាន និងកសិឧស្សាហកម្មត្រូវផ្ដល់អាទិភាពលើការដោះស្រាយទឹក អភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ទូរគមនាគមន៍ ថាមពលអគ្គិសនី ឧស្សាហកម្មអតិពលកម្ម ឧស្សាហកម្មកែច្នៃនាំចេញ ឧស្សាហកម្មទេសចរណ៍ និងការអភិវឌ្ឍធនធានមនុស្ស។

**ទី៤-ដីបម្រុងទុក និងសំណង់រដ្ឋ៖** រដ្ឋត្រូវតែមានដីបម្រុងទុកក្នុងទំហំណាមួយសមរម្យនៅគ្រប់មូលដ្ឋានឃុំសង្កាត់ទូទាំងប្រទេស ឬរៀបចំផែនការដីរដ្ឋឱ្យបានច្បាស់លាស់ដើម្បីប្រើប្រាស់តាមប្រភេទ និងលទ្ធភាពនៃដី ដូចជាជួល សម្បទាន អភិវឌ្ឍ និងបម្រើសេវាសាធារណៈ ឬបន្ទុកសង្គម។ ម្យ៉ាងទៀត រដ្ឋត្រូវអភិវឌ្ឍវិស័យសំណង់ឱ្យបានច្រើន និងគ្រប់គ្រាន់ជួយបម្រើដល់រដ្ឋបាលសាធារណៈ សេវាសាធារណៈ សេវាបន្ទុកសង្គម និងទេសចរណ៍។

ទោះបីជាយ៉ាងណាក៏ដោយ ទស្សនវិស័យនៃការដោះស្រាយទាមទារឱ្យមានកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័នសមត្ថកិច្ច និងក្របខណ្ឌគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តរឹងមាំ នីតិរដ្ឋ ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈបច្ចេកទេស ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា និងសហប្រតិបត្តិការជាប្រព័ន្ធនៃស្ថាប័នពាក់ព័ន្ធមូលដ្ឋានដល់ថ្នាក់ជាតិ ចូលរួមពីសាធារណៈជន អង្គការជាតិ ឬអន្តរជាតិ និងថវិការគាំទ្រយ៉ាងមុតមាំគ្រប់គ្រាន់ជានាតុល្យភាពអនុវត្តវិស័យនេះ។

## សេចក្ដីសន្និដ្ឋាន

វិស័យអចលនទ្រព្យ ជាធាតុចាំបាច់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចសង្គម នយោបាយ រចនាសម្ព័ន្ធរដ្ឋ និងលើកមុខមាត់ប្រទេសលើឆាកអន្តរជាតិ។ ក្នុងរយៈកាលកន្លងមកនេះ កម្ពុជាមានក្របខណ្ឌច្បាប់ និងរចនាសម្ព័ន្ធស្ថាប័នដឹកនាំ គ្រប់គ្រងវិស័យនេះ។ ក៏ប៉ុន្តែបញ្ហាប្រឈមនៅបន្តកើតមានឡើងដែលរាំងស្ទះដល់ការអភិវឌ្ឍ។ ដូច្នេះវិស័យនេះ គួរតែ៖

- មានការយកចិត្តទុកដាក់ពីស្ថាប័នរដ្ឋាភិបាលជានាការអភិវឌ្ឍដីធ្លីឱ្យប្រសើរឡើង
- បញ្ចប់ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធឱ្យបានឆាប់ និងគ្រប់គ្រងដោយប្រព័ន្ធព័ត៌មានវិទ្យា ព្រមទាំងដោះស្រាយសំណង់គ្មានច្បាប់ ឬអាណាធិបតេយ្យ និងការកាន់កាប់ដីខុសច្បាប់
- ផ្ដល់សេវាសាធារណៈ សេវាបន្ទុកសង្គមលើបំណុល ឬការបង់រំលស់ សេវាយុត្តិធម៌ឱ្យខិតជិតប្រជាពលរដ្ឋ ដីរដ្ឋបម្រុងទុកភូមិឃុំសង្កាត់ និងអគាររដ្ឋសម្រាប់បម្រើសេវា ឬជនក្រីក្រ

- បង្កើតជាសួនទេសចរណ៍ សេវាទេសចរណ៍ និងសន្តិសុខស្បៀង
- បង្កើតទីផ្សារការងារ ការបណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងនីតិរដ្ឋដើម្បីប្រកួតប្រជែងក្នុងមូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ។
- កសាងមុខមាត់ជាតិតាមរយៈវិស័យដីធ្លី និងសំណង់ស្របតាមក្របខណ្ឌរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសោភណភាព និងបង្ហាញកិត្យានុភាពលើឆាកអន្តរជាតិ។

# កត្តាប្រឈម ភាពនុវត្តភាព និងចក្ខុវិស័យនៃឧស្សាហកម្មកាត់ដេរ សំលៀកបំពាក់ និងវាយនភណ្ឌកម្ពុជា

*បេក្ខជនបណ្ឌិត៖* ***ខេង ពេជ្រមុនី***
*គ្រូណែនាំ៖* ***បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី***

## ១. សេចក្តីផ្តើម

ក្រោយទទួលបានឯករាជ្យភាព, បូរណភាពទឹកដី, សាមគ្គីភាពជាតិ, ស្ថិរភាពនយោបាយ, និងសុខសន្តិភាពពេញលេញ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវសមិទ្ធិផលសេដ្ឋកិច្ចជាច្រើនរួម មានការគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការបង្កើនទំនាក់ទំនងការបរទេសជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងអន្តរជាតិ ក្នុងន័យកៀគរវិនិយោគិនបរទេសមកក្នុងប្រទេសដើម្បីឱ្យមានលំហូរទាំងហិរញ្ញវត្ថុ បច្ចេក-វិទ្យា និងឱកាសការងារ។ ក្នុងចំណោមសមិទ្ធិផលរបស់កម្ពុជាកន្លងមក, វិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌ បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការសម្រេចបាននូវវឌ្ឍនភាពជាបន្តបន្ទាប់តាមរយៈការនាំចេញសរុបរបស់កម្ពុជាប្រមាណ៧០ភាគរយ បង្កើតការងារប្រមាណ៨០ម៉ឺនកន្លែងដល់កម្មករនិយោជិតដោយផ្ទាល់ និង១លានជាងនាក់ដោយប្រយោល លើសពីនេះទៅទៀតបានចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងកម្ពុជាមកត្រឹមក្រោម១០ភាគរយផងដែរ។ ទន្ទឹមនឹងសមិទ្ធ-ផលនេះ កម្ពុជាហាក់នៅមានភាពផុយស្រួយក្នុងវិស័យនេះផងដែរ បានកំពុងនឹងជួបប្រទះនោះ គឺមានដូចជា(១) ឥទ្ធិពលពីការប្រែប្រួលនៃឧស្សាហកម្មកាត់ដេរសកល (២) កំណើនផលិតភាពនៅមានកម្រិត និងកង្វះខាតកម្មករជំនាញក្នុងស្រុក (៣) កង្វះភាពជាម្ចាស់ និងឧស្សាហកម្មគាំទ្រ (៤)កង្វះពិពិធកម្មទីផ្សារនាំចេញ និងការពឹងផ្អែកលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និង(៥)បញ្ហាលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ-និយោជិត។ ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមក ទោះបីជាមានបញ្ហាប្រឈមចម្បងជាចម្រើនដែលវិស័យនេះកំពុងជួបប្រទះ កម្ពុជានៅតែអាចទាញយកនូវផលចំណេញសេដ្ឋកិច្ចពីក្នុងវិស័យនេះ ព្រមទាំងចាត់ទុកវិស័យនេះជាវិស័យចន្ទល់ សេដ្ឋកិច្ច តាមរយៈការវិធានការ និងចក្ខុវិស័យសម្រាប់ការលើកស្ទួយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់និងវាយនភណ្ឌត្រូវមានដូចជា (ក) បង្កើនផលិតភាពការងារ និងកម្មករជំនាញក្នុងស្រុក (ខ) បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្មគាំទ្រ (គ) ជំរុញពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរសំលៀកបំពាក់ និង (ឃ) លើកកម្ពស់វិនិយោគក្នុងស្រុក និងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់។ លើសពីនេះទៅទៀត ស្របតាមកម្មវិធីកំណែទម្រង់ជាតិដែលមានវត្តមានបច្ចុប្បន្ន និងការគិតគូរបន្តនូវយុទ្ធសាស្ត្រយ៉ាងមុតស្រួច ព្រមទាំងកិច្ចខិតខំប្រឹងប្រែង ពីថ្នាក់ដឹកនាំ និងក្រសួងស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ច វិស័យនេះនៅតែជាចន្ទល់សេដ្ឋកិច្ចកម្ពុជាដ៏សំខាន់ និងអភិវឌ្ឍខ្លួនដើម្បីសម្រេចបានគោលបំណងរួមនៃសេដ្ឋកិច្ចជាតិឆ្ពោះទៅកាន់ឋានៈប្រទេសមានចំណូលកម្រិតខ្ពស់ក្នុងឆ្នាំ២០៥០យ៉ាងពិតប្រាកដ។

## ២. កត្តាប្រឈម

កត្តាបញ្ហាប្រឈមនាពេលបច្ចុប្បន្នដែលឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌនៅកម្ពុជាបានកំពុងនឹងជួបប្រទះនោះ គឺមានដូចជា៖ (១) ឥទ្ធិពលពីការប្រែប្រួលនៃឧស្សាហកម្មកាត់ដេរសកល (២) កំណើនផលិតភាពនៅមានកម្រិត និងកង្វះខាតកម្មករជំនាញក្នុងស្រុក (៣) កង្វះភាពជាម្ចាស់ និងឧស្សាហកម្មគាំទ្រ (៤)កង្វះពិពិធកម្មទីផ្សារនាំចេញ និងការពឹងផ្អែកលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និង(៥) បញ្ហាលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ-និយោជិត។

### ក. ឥទ្ធិពលពីការប្រែប្រួលនៃឧស្សាហកម្មកាត់ដេរសកល

ជាការពិតណាស់ កម្ពុជាងាយរងផលប៉ះពាល់ពីការប្រែប្រួល និងនិន្នាការនៃការវិវត្តឧស្សាហកម្មកាត់ដេរសំលៀកបំពាក់សកល។ ជាក់ស្តែង កម្ពុជាពឹងផ្អែកលើការនាំចេញទៅប្រទេស គោលដៅទីផ្សារធំៗដែលបានផ្តល់នូវប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ពោលគឺ សហរដ្ឋអាម៉េរិក និង សហភាពអឺរ៉ុប ដែលបច្ចុប្បន្នកម្ពុជាមានការយឺតយ៉ាវក្នុងការកសាងនិងបង្កើតទីផ្សារក្នុងប្រទេសដ៏រឹងមាំមួយ និងបង្កើននូវផលិតភាពនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ព្រមទាំងពង្រឹងនូវគុណភាព និងសិក្សាបន្ថែមអំពីការបង្កើតនូវរោងចក្រឧស្សាហកម្មគាំទ្រផងដែរ។ ក្នុងន័យនេះ កម្ពុជាគួរសិក្សាអំពីតថភាពវិបត្តិសេដ្ឋកិច្ចកន្លងមក ការយឺតយ៉ាវនៃការដឹកជញ្ជូនវត្ថុធាតុដើមស្ថិរភាពនៃការផ្គត់ផ្គង់ និងថ្លៃចំណាយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពោលគឺ ទឹក ភ្លើង និងថ្លៃដឹកជញ្ជូន ព្រមទាំងភាពចាស់ទុំនៃវិជ្ជាជីវៈរបស់កម្មករនិយោជិតនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដើម្បីជំរុញនូវផលិតភាពការងារ និងបង្កើននូវតម្លៃបន្ថែមនៅក្នុងវិស័យកាត់ដេរ។

បច្ចុប្បន្ន កម្ពុជាបានកំពុងនឹងផលិតនូវផលិតផលកាត់ដេរសំលៀកបំពាក់ដែលថ្លៃងាយ ប្រែប្រួលតម្លៃបន្ថែមទាប និងប្រាក់ចំណេញពីការផលិតនោះនៅមានកម្រិត ពីព្រោះឧស្សាហកម្មកាត់ដេរនៅកម្ពុជាផ្ទាល់គឺពឹងផ្អែកទាំងស្រុងទៅលើមជ្ឈដ្ឋានខាងក្រៅ ពោលគឺ ទីផ្សារគោលដៅ តម្រូវការរបស់អ្នកបញ្ជាទិញវត្ថុធាតុដើមសម្រាប់ប្រតិបត្តិការ និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។ ដូច្នេះ នៅពេលអ្នកបញ្ជាទិញមានការប្រែប្រួលទៅលើថ្លៃទំនិញដែលនាំចេញ ឬការប្រែប្រួលនៅលើថ្លៃនៃការនាំចូលនូវវត្ថុធាតុដើមមកកម្ពុជា ឥទ្ធិពលនោះនឹងបង្កឱ្យមានការគំរាមកំហែងដល់ឧស្សាហកម្មកាត់ដេរកម្ពុជាដែលមានទម្រង់ជារោងចក្រកាត់ដេរ និងវេចខ្ចប់យ៉ាងខ្លាំង។

### ខ. កំណើនផលិតភាពនៅមានកម្រិត និងកង្វះខាតកម្មករជំនាញក្នុងស្រុក

ទោះបីជាមានវត្តមានឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌនៅកម្ពុជាជាង២ទសវត្សក៏ដោយ ប៉ុន្តែផលិតភាពការងារ និងកម្មករជំនាញនៅតែជាបញ្ហាប្រឈមដ៏សំខាន់ក្នុងការរារាំងការវិវត្តនៃឧស្សាហកម្មកាត់ដេរនេះឱ្យក្លាយទៅជាឧស្សាហកម្មមួយដែលមានលក្ខណៈពេញលេញ។ យោងតាមភាគរយនៃអ្នកវិនិយោគបរទេសក្នុងវិស័យឧស្សាហកម្មកាត់ដេរ ៩៥ភាគរយជាអ្នកវិនិយោគចិន។ វិនិយោគិនចិនដែលមកវិនិយោគនៅកម្ពុជាគឺអនុវត្តនៅក្នុងទម្រង់វិនិយោគបរទេសតាមរយៈខ្សែបណ្តោយ

ដែលជាការវិនិយោគផ្ទាល់ពីបរទេសសំដៅលើការបែងចែកភូមិសាស្ត្រ សង្វាក់ផលិតកម្មរបស់ក្រុមហ៊ុនទៅតាមតំបន់ដែលផ្តល់នូវសញ្ញាណវិជ្ជមានពីថ្លៃវត្ថុធាតុដើម និងកម្លាំងពលកម្ម។

ដូច្នេះការវិនិយោគបរទេសរបស់វិនិយោគិនចិននៅក្នុងវិស័យនេះ នៅតែជាទម្រង់ម៉ៅការតាមរយៈកិច្ចសន្យានៅឡើយ ឬជាប្រភេទរោងចក្រកាត់ដេរ វេចខ្ចប់ (CMT)។ ដូច្នេះ វិនិយោគិនដែលបានវិនិ-យោគនៅកម្ពុជាមិនបានយកចិត្តទុកដាក់ក្នុងការប្រើប្រាស់កម្មករឱ្យអស់ពីលទ្ធភាព និងបណ្តុះបណ្តាលកម្មករ ក្នុងន័យកសាងសមត្ថភាព និងបង្កើននូវផលិតភាពរបស់ពួកគេនោះឡើយ។ បញ្ហាទាំងអស់នេះគឺជាបញ្ហាចម្បងដែលទាញឱ្យផលិតភាពនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានកម្រិតទាបដែលក្នុងនោះគួបផ្សំជាមួយៈ (១) កម្រិតអប់រំទូទៅរបស់កម្មករនៅមានកម្រិតទាប (២) កង្វះខាតវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងជំនាញខ្ពស់មុនពេលចូលបម្រើការងារ ពោលគឺមានដូចជា ជំនាញវិស្វកម្មឧស្សាហកម្ម ការរចនាម៉ូដ ការគ្រប់គ្រងការបញ្ជាទិញវត្ថុធាតុដើម ការត្រួតពិនិត្យគុណភាពជាដើម។ ជារួមឧស្សាហកម្មកាត់ដេរនៅកម្ពុជាគឺមានការប្រើប្រាស់នូវកម្លាំងពលកម្មទាំងស្រុងដែលក្នុងនោះមិនបានគិតគូរដល់ការបណ្តុះបណ្តាលជំនាញឱ្យបានត្រឹមត្រូវនោះឡើយ ទើបធ្វើឱ្យមានការវិវត្តមកកាន់ឧស្សាហកម្មដែលមានលក្ខណៈពេញលេញមានការយឺតយ៉ាវ។

ជារួម កង្វះនូវកម្លាំងពលកម្មជំនាញជាបញ្ហាចម្បងដែលធ្វើឱ្យវិស័យកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌនៅកម្ពុជាមានការស្រូបយកនូវកម្លាំងពលកម្មត្រឹមតែកម្រិត៨០ម៉ឺនកន្លែង ដែលនេះជាតួលេខមួយថេរក្នុងរយៈពេលចុងក្រោយនេះ។ ភាពខ្វះខាតនូវកម្លាំងពលកម្មជំនាញ និងបច្ចេកទេស គួបផ្សំជាមួយការពិចារណាលើការវិនិយោគបន្ថែមរបស់វិនិយោគិនបរទេស គឺជាកត្តាចម្បងដែលរាជរដ្ឋាភិ-បាលកម្ពុជាគួរយកចិត្តទុកដាក់ក្នុងការជំរុញគាំទ្រ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាល និងផែនការគន្លងអាជីពសម្រាប់កម្មករនិយោជិតត្រឹមត្រូវ។ ទន្ទឹមនឹងនេះការប្រកាសឱ្យប្រើនូវច្បាប់វិនិយោគថ្មី សបញ្ជាក់ឱ្យឃើញថារាជរដ្ឋាភិបាលកម្ពុជាបានកំពុងយកចិត្តទុកដាក់លើកស្ទួយការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាព ព្រមទាំងសុខុមាលភាពរបស់កម្មករនិយោជិតដែលកំពុងបម្រើការនៅតាមវិស័យ អនុវិស័យជាពិសេសក្នុងរោងចក្រកាត់ដេរផ្ទាល់តែម្តង។

### គ. កង្វះភាពជាម្ចាស់ និងឧស្សាហកម្មគាំទ្រ

យើងសង្កេតបានថា ភាពជាម្ចាស់នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់និងវាយនភណ្ឌនៅកម្ពុជាមានចំនួនត្រឹមតែ៥ភាគរយតែប៉ុណ្ណោះ ខណៈដែល៩៥ភាគរយទៀត គឺមានការកាន់កាប់ដោយវិនិយោគិនបរទេស។ ក្នុងន័យនេះ កម្ពុជាគឺមានការប្រឈម យ៉ាងខ្លាំងចំពោះការដកចេញយ៉ាងឆាប់រហ័សរបស់វិនិយោគិនបរទេសទៅកាន់ប្រទេសផ្សេងទៀត នៅតំបន់អាស៊ីអាគ្នេយ៍ ដែលផ្តល់នូវអត្ថ-ប្រយោជន៍ការលើកទឹកចិត្តនិងការផ្តល់នូវលក្ខខណ្ឌវិនិយោគប្រសើរជាងកម្ពុជា ពោលគឺ ប្រទេសភូមាប្រទេសបង់ក្លាដេសនិងស្រីលង្កា។

ទន្ទឹមនឹងការនាំចេញនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌបានរួមចំណែកនៅក្នុងសេដ្ឋកិច្ចកម្ពុជាខ្លាំងក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែពឹងពីការនាំចេញតាមទម្រង់រោងចក្រកាត់ដេរ និងវេចខ្ចប់ ដោយតម្លៃបន្ថែមពីការសម្រេចបាននូវផលិតផលកាត់ដេរចុងក្រោយនេះមិនបានផ្តល់តម្លៃបន្ថែមខ្ពស់សម្រាប់កម្ពុជានោះទេ។ លើសពីនេះទៅទៀត យោងតាមទិន្នន័យ ក្នុងការនាំចូលរបស់កម្ពុជាយើងសង្កេតឃើញថាកម្ពុជាស្ទើរតែនាំចូលនូវផលិតផលវត្ថុធាតុដើមក្នុងការផលិតផលិតផលកាត់ដេរទាំងស្រុងពីប្រទេសចិន។ ក្នុងន័យនេះ រោងចក្រត្រូវពឹងផ្អែកលើការនាំចូល ដើម្បីបម្រើខ្សែប្រវាក់ផលិតកម្មរបស់ខ្លួន ដែលនេះជាហានិភ័យមួយដែលអាចប៉ះពាល់ដល់ដំណើរការផលិតកម្មរបស់ខ្លួន ប្រសិនបើខ្លួនធ្វើការព្យាករនូវកាលបរិច្ឆេទនៃការទទួលបាននូវវត្ថុធាតុដើមយឺតយ៉ាវផងដែរ។

ជារួម វត្ថុធាតុដើមក្នុងការផលិតផលិតផលកាត់ដេរសំលៀកបំពាក់នៅកម្ពុជា គឺមានការបញ្ជាទិញពីប្រទេសចិន និងប្រទេសកូរ៉េខាងត្បូង ប៉ុន្តែបើគិតពីរយៈពេលនៃការដឹកជញ្ជូនកម្ពុជាហាក់ដូចជាមានការយឺតយ៉ាវ បើធៀបទៅនឹងភូមិសាស្ត្រប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ ដូចជា ប្រទេសវៀត-ណាម និងប្រទេសបង់ក្លាដេសជាដើម។ ដូច្នេះ ការដឹកជញ្ជូននូវផលិតផលសម្រេចទៅកាន់ទីផ្សារគោលដៅ គឺត្រូវចំណាយពេលយូរជាងគូរប្រកួតប្រជែង និងពុំមានលក្ខណៈប្រកួតប្រជែង។

យោងតាមរបាយការណ៍របស់សមាគមកាត់ដេរកម្ពុជា រយៈពេលបញ្ជូនទំនិញមកកម្ពុជាជាទូទៅគឺប្រហែល២១ ទៅ២៨ថ្ងៃ ដើម្បីទទួលវត្ថុធាតុដើមពីប្រទេសចិន។ ជាមធ្យម កម្ពុជាត្រូវប្រឈមរយៈពេលបញ្ជូនទំនិញទៅទីផ្សារ ចំនួន៨៧ថ្ងៃ ឬស្មើនឹង៣ខែ ដែលក្នុងនោះមានការបែងចែកជាសកម្មភាព០៣ធំៗ៖ **(១) ២៨ថ្ងៃសម្រាប់ទទួលការផ្គត់ផ្គង់វត្ថុធាតុដើម (២) ៣១ថ្ងៃសម្រាប់ដំណើរការផលិតកម្ម និង (៣) ២៧ថ្ងៃសម្រាប់ការដឹកជញ្ជូនទៅកាន់ទីផ្សារ។**

ទន្ទឹមនឹងនោះ បញ្ហាកង្វះខាតនូវរោងចក្រឧស្សាហកម្មគាំទ្រ ដូចជារោងចក្រផលិតក្រណាត់ និងផលិតផលផ្សេងទៀត គឺដោយសារតែចរិតលក្ខណៈនៃឧស្សាហកម្មទាំងនេះមានការប្រើប្រាស់នូវគ្រឿងចក្រ និងម៉ាស៊ីនជាច្រើន ដែលត្រូវការបរិមាណអគ្គិសនីយ៉ាងសន្ធឹកសន្ធាប់ គួបផ្សំនឹងថ្លៃអគ្គីសនីនៅកម្ពុជាមិនទាន់មានភាពប្រកួតប្រជែងនិងវិសាលភាពនៃការផ្គត់ផ្គង់មិនទាន់ពេញលេញ ដូច្នេះវិនិយោគិនបរទេសមិនទាន់ហ៊ានសម្រេចចិត្តមកបង្កើតរោងចក្រផ្នែកគាំទ្រដល់ឧស្សាហកម្មកាត់ដេរនៅឡើយទេ។

### ឃ. កង្វះពិពិធកម្មទីផ្សារនាំចេញ និងការពឹងផ្អែកលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

បច្ចុប្បន្នទីផ្សារនាំចេញកម្ពុជា ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវយើងវាយតម្លៃបានថាទីផ្សារនៃការនាំចេញផលិតផលកាត់ដេរសំលៀកបំពាក់របស់កម្ពុជា គឺពឹងផ្អែកខ្លាំងទៅលើគោលដៅប្រទេសដែលបានផ្តល់នូវប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជា ពោលគឺ សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប។ ផ្អែកលើទិន្នន័យនេះការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារគោលដៅទាំង២ គឺមានរហូត ទៅដល់៧០ភាគរយ នៃចំណែកទីផ្សារសរុប។ ជាកត្តាសត្យានុម័តការនាំចេញទៅកាន់ទីផ្សារធំទាំង២នេះបានជួយ

ដល់ការជំរុញកំណើននៃវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ប៉ុន្តែការពឹងផ្អែកទៅលើគោលដៅទីផ្សារទាំង២នេះ បានផ្តល់នូវហានិភ័យនិងបញ្ហាប្រឈមជាច្រើន ដល់កម្ពុជា។

ទន្ទឹមនឹងនោះ វិបត្តិកូវីដ១៩បានផ្តល់នូវហានិភ័យដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចកម្ពុជា រោងចក្រជាច្រើនបានប្រកាសផ្អាកដំណើរការផលិតកម្ម និងខ្លះទៀតបានបិទជាស្ថាពរតែម្តង។ នៅក្នុងឆ្នាំ២០១៩ រោងចក្រកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌនៅកម្ពុជាមានចំនួន៧៦១រោងចក្រ ដែលផ្តល់ឱកាសការងារដល់កម្មករចំនួន៧០ម៉ឺនកន្លែង ប៉ុន្តែនៅក្នុងកំឡុងពេលវិបត្តិកូវីដ១៩ រោងចក្រមួយចំនួនបានសុំផ្អាកនិងបិទដែលទិន្នន័យរោងចក្រដែលដំណើរការនៅក្នុងឆ្នាំ២០២០ មានចំនួនមកត្រឹមតែ៦២៤ តែប៉ុណ្ណោះដែលបានផ្តល់នូវឱកាសការងារដល់កម្មករចំនួន៦០ម៉ឺនកន្លែងសម្រាប់ដំណើរការវិស័យនេះទាំងមូល។ លើសពីនេះទៅទៀត យើងសង្កេតឃើញថាមានការរាំងស្ទះនូវខ្សែប្រវាក់ផលិតកម្ម ខ្សែប្រវាក់ផ្គត់ផ្គង់ និងការផ្លាស់ប្តូរដំណើរការពាណិជកម្មតាមរយៈការកាត់បន្ថយចំនួននៃការបញ្ជាទិញពីបរិមាណច្រើនមកតិច ដើម្បីស្របទៅនឹងបរិមាណនៃតម្រូវការរបស់អ្នកប្រើប្រាស់។

**ខ. បញ្ហាលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ-និយោជិត**

ជាមធ្យម កម្មករ-និយោជិតចំណាយក្នុងកម្រិតតិចតួចលើចំណីអាហារមួយពេល ហើយរោងចក្រភាគច្រើនពុំបានរៀបចំជាកន្លែងអាហារដ្ឋានបានសមរម្យ ដើម្បីឱ្យកម្មករ-និយោជិតអង្គុយបរិភោគបានត្រឹមត្រូវនោះទេ។ ជាមួយនឹងការទទួលបានអាហារូបត្ថម្ភក្នុងកម្រិតទាបបែបនេះ កម្មករ-និយោជិតនឹងពុំអាចមានផលិតភាពខ្ពស់ដូចការរំពឹងទុកនោះទេ។ ជាងនេះទៅទៀត កម្មករ-និយោជិតមួយចំនួនត្រូវធ្វើដំណើរដោយឈរលើថយន្តកែច្នៃ (អាចមានឬគ្មានដំបូល) ក្នុងចម្ងាយឆ្ងាយពីផ្ទះមកកន្លែងធ្វើការ និងងាយប្រឈមនឹងគ្រោះថ្នាក់ចរាចរណ៍ផងដែរ។ ទន្ទឹមនេះ ប្រមាណជា៧០ភាគរយនៃរោងចក្រសរុបមានកម្តៅលើសលប់នៅច្រើនផ្នែកនៃកន្លែងធ្វើការឬក៏កន្លែងធ្វើការទាំងស្រុងតែម្តងនៅរោងចក្រ។ យោងតាមរបាយការណ៍របស់កម្មវិធី(BFC) ជាទូទៅបានរាយការណ៍ពីបណ្តារោងចក្រដែលមានសីតុណ្ហភាពខ្ពស់ជាង៣២ ដឺក្រេ។ កង្វះការអនុវត្តឱ្យបានតឹងរ៉ឹងលើការត្រួតពិនិត្យលើលក្ខខណ្ឌការងាររួមទាំងសុខភាព និងសុវត្ថិភាពការងារ ជាពិសេស នៅតាមរោងចក្រ-សហគ្រាសដែលម៉ៅការបន្តដែលត្រូវបានប៉ាន់ប្រមាណថាមានប្រហែល៣០០ទៅ៤០០ គឺជាបញ្ហាប្រឈមចំពោះភាពប៉ាន់ប្រមាណនិងស្ថិរភាពនៃវិស័យនេះផងដែរ។ ហើយព័ត៌មានអំពីលក្ខខណ្ឌការងារ និងអនុលោមភាពជាមួយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅតាមរោងចក្រសហគ្រាសម៉ៅការនេះនៅមានកម្រិតតិចតួចនៅឡើយ។ ដូច្នេះ បញ្ហាដែលកើតឡើងនៅតាមបណ្តារោងចក្រ សហគ្រាសម៉ៅការបន្តទាំងនោះបានជះឥទ្ធិពលអវិជ្ជមានដល់វិស័យនេះទាំងមូល ត្បិតថារោងចក្រ-សហគ្រាសទាំងនោះមិនស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងពាណិជ្ជកម្ម សមាគមកាត់ដេរកម្ពុជា និងកម្មវិធី BFC នោះទេ ដែលមានវិសាលភាពត្រួតពិនិត្យតែលើរោងចក្រនាំចេញប៉ុណ្ណោះ។ ប៉ុន្តែ រោងចក្រ-សហគ្រាសទាំងនោះត្រូវបានតម្រូវឱ្យចុះបញ្ជីជាមួយបេឡាជាតិរបបសន្តិសុខសង្គមដែលស្ថិតក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលគ្រប់គ្រងទិន្នន័យទាំងនោះ។

## ៣. កាលានុវត្តភាព និងចក្ខុវិស័យ

យោងតាមបរិការណ៍បច្ចុប្បន្ននេះ ប្រទេសចិនបានបោះជំហានទៅកាន់ដំណាក់កាលទី៦ដែលជាដំណាក់កាលនៃការធ្លាក់ចុះនៃឧស្សាហកម្មកាត់ដេរ ដោយមានកំណើននូវថ្លៃផលិតកម្មដែលជាសញ្ញាណមួយក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរទីតាំងរោងចក្រ ទាំងរោងចក្រប្រភេទកាត់ដេរ និងរោងចក្របម្រើឱ្យឧស្សាហកម្មគាំទ្រទៅកាន់ប្រទេសនានាក្នុងតំបន់។ យោងតាមលក្ខណៈភូមិសាស្ត្រ ប្រវត្តិ-សាស្ត្រ វប្បធម៌និងទំនាក់ទំនងមិត្តភាពរបស់កម្ពុជា និងចិន ដែលថ្មីៗនេះបានឈានទៅកាន់កម្រិតថ្មីមួយដែលមានឈ្មោះថា “ មិត្តភាពដែកថែប ” ពិតណាស់កម្ពុជាប្រាកដជាទទួលបាននូវការវិនិយោគពីមិត្តចិនក្នុងគោលបំណងជំរុញវិស័យឧស្សាហកម្មកាត់ដេរដែលមានទម្រង់ពេញលេញមួយដែលគិតគូរពីការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់កម្មករនិងការវិនិយោគទៅលើគ្រឿងចក្រ បច្ចេកវិទ្យា ព្រមទាំងការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រ ពោលគឺរោងចក្រផលិតផលក្រណាត់និងវត្ថុធាតុដើមផ្សេងៗទៀតក្នុងការគាំទ្រដល់ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌទាំងមូលដូចទៅនឹងទំហំវិនិយោគរបស់ចិននៅក្នុងវិស័យសំណង់និងអចលនទ្រព្យផងដែរ។

ដើម្បីសម្រេចបាននូវការវិវត្តខ្លួនមកក្នុងដំណាក់កាលទី៣ និងឈោងចាប់កាលានុវត្តភាពថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបាន រៀបចំនូវច្បាប់វិនិយោគថ្មីដែលបានរំលេចនូវចំណុចសំខាន់ៗ ពោលគឺ (១) លក្ខន្តិកៈ និងលក្ខណៈសម្បត្តិនៃនីតិវិធីវិនិយោគនៅកម្ពុជា និង (២) ការធានានិងការលើកទឹកចិត្តដល់វិនិយោគិនបរទេស។ ក្នុងនោះមានការលើកទឹកចិត្តជាច្រើន ដែលអាចឱ្យកម្ពុជាចាប់ទាញនូវវិនិយោគិនបរទេសជាច្រើនមកកម្ពុជា តាមរយៈការបន្ធូរបន្ថយនូវការបង់ពន្ធជាលក្ខណៈជំហាន និងជម្រើសដែលបង្កឱ្យមានភាពងាយស្រួលដល់សមាជិកគ្រួសារវិនិយោគិននិងបុគ្គលិកបរទេស។ តាមរយៈបទពិសោធន៍នៃវិបត្តិសេដ្ឋកិច្ច និងការសិក្សាពីគំរូនៃការវិវត្តក្នុងឧស្សាហកម្មកាត់ដេរមក កម្ពុជានៅតែមានកាលានុវត្តភាពក្នុងការចាត់ទុកឧស្សាហកម្មកាត់ដេរនេះជាវិស័យសំខាន់មួយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា។

ឆ្លងកាត់បទពិសោធន៍នៃវិបត្តិសេដ្ឋកិច្ចបច្ចុប្បន្ន កម្ពុជាគួរផ្តោតការយកចិត្តទុកដាក់ និងចាត់ទុកវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ជាវិស័យមួយដែលធន់ និងតែងតែចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ។ ជាគោលការណ៍ រដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័ន និងវិស័យឯកជនគួរមានវិធានការមួយចំនួនក្នុងការលើកស្ទួយវិស័យនេះដែលជា វិស័យមួយមិនអាចមើលរំលងបាន និងមិនគួរបោះបង់ចោលទាំងស្រុងនោះឡើយ។ ដូច្នេះ វិធានការ និងចក្ខុ-វិស័យសម្រាប់ការលើកស្ទួយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌត្រូវមានដូចជា (ក) បង្កើនផលិតភាពការងារ និងកម្មករជំនាញក្នុងស្រុក (ខ) បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្មគាំទ្រ និង (គ) ជំរុញពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរសំលៀកបំពាក់ និង (ឃ) លើកកម្ពស់វិនិយោគក្នុងស្រុក និងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់។

### ក. បង្កើនផលិតភាពការងារ និងកម្មករជំនាញក្នុងស្រុក

កម្ពុជាគួរពង្រឹងនិងបង្កើននូវសមត្ថភាព និងផលិតភាពការងាររបស់កម្មករក្នុងស្រុកក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ពោលគឺជំរុញ និងលើកទឹកចិត្តដល់វិនិយោគិនបរទេស ក្នុងការបណ្តុះបណ្តាលសមត្ថភាពកម្មករ និយោជិតនៅតាមរោងចក្រកាត់ដេរមួយចំនួន។ ការបណ្តុះបណ្តាលទាំងនោះអាចចាប់ផ្តើមក្នុងកម្រិតណាមួយដូចជា៖ (១) ការរចនាម៉ូដសំលៀកបំពាក់ (២) ជំនាញក្នុងការបញ្ជាម៉ាស៊ីនគ្រឿងចក្រ (៣)ការបញ្ជាទិញវត្ថុធាតុដើម និង(៤) សមត្ថភាពជំនាញគ្រប់គ្រងនៅក្នុងរោងចក្រទៅតាមផ្នែកនីមួយៗចៀសវៀងក្នុងការពឹងផ្អែកលើកម្លាំងពលកម្មបរទេសច្រើនលើសលប់។

ទន្ទឹមនឹងនោះ រដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធគួរមានវិធានការក្នុងការលើកគម្រោងបណ្តុះបណ្តាលប្រចាំត្រីមាស ឆមាសឬឆ្នាំដែលមានកូតាកម្មករ និយោជិត ជូនទៅរោងចក្រកាត់ដេរសំ-លៀកបំពាក់គោលដៅដែលសហការណ៍ក្នុងការកសាង និងបណ្តុះបណ្តាលសមត្ថភាពកម្មករជំនាញ។ លើសពីនេះទៅទៀត រដ្ឋាភិបាលកម្ពុជាអាចឆ្លៀតឱកាសនេះចូលរួមក្នុងការវាស់វែងផលិតភាពការងាររបស់កម្មករ និយោជិតមុននិងក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលផងដែរ។

ការបណ្តុះបណ្តាលនេះ គឺជាយន្តការក្នុងការបង្កើនផលិតភាពការងារ និងកម្មករជំនាញក្នុងស្រុកគួបផ្សំជាមួយនឹងបរិយកាសធុរកិច្ច និងច្បាប់វិនិយោគដែលផ្តល់ការអនុគ្រោះបំផុតដល់វិនិយោគិននោះ កម្ពុជាសង្ឃឹមយ៉ាងមុតមាំថាខ្លួនពិតជាអាចពង្រឹងនូវឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងតំបន់ និងជំរុញការវិនិយោគបរទេសមកកាន់កម្ពុជា ក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់និងវាយនភណ្ឌទៀតផង។

ទន្ទឹមនឹងនោះ កម្ពុជាគួរបន្តពង្រឹងធនធានមនុស្ស និងបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរតាមរយៈ៖

- ការលើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សា ទាំងសាធារណៈ និងឯកជន ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាដែលជាតម្រូវការសម្រាប់វិស័យនេះ ដូចជា៖ ជំនាញផ្នែកវាយនភណ្ឌ ជំនាញរចនា ជំនាញវិស្វកម្មឧស្សាហកម្ម ជំនាញការបញ្ជាទិញ និងជំនាញភាពជាអ្នកដឹកនាំ និងគ្រប់គ្រងជាដើម ឬសហការ ជាមួយសាកលវិទ្យាល័យ ឬវិទ្យាស្ថានដែលផ្តល់កម្មវិធី ឬវគ្គសិក្សានេះស្រាប់ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។
- ការលើកទឹកចិត្ត និងពិនិត្យលទ្ធភាពក្នុងការគាំទ្រផ្នែកធនធានហិរញ្ញវត្ថុក្នុងការបញ្ជូននិស្សិត និងនិយោជិតកម្ពុជាដែលមានសក្តានុពលទៅបន្តការសិក្សាជំនាញចាំបាច់ក្នុងវិស័យនេះ នៅសាកលវិទ្យាល័យនិងវិទ្យាស្ថាននៅក្រៅប្រទេស។
- អនុវត្តនូវគោលនយោបាយស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ តាមរយៈការជំរុញការស្រាវ-ជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាស្តីពីស្តង់ដាគុណភាពផលិតផលវាយនភណ្ឌ, ការសិក្សាអំពីការច្នៃវត្ថុធាតុដើម ដើម្បីផលិតសំលៀកបំពាក់ ការតេស្តទៅលើគុណភាពផលិតផលវាយនភណ្ឌ និងការអភិវឌ្ឍបច្ចេកទេសព័ត៌មានវិទ្យានៅក្នុងវិស័យកាត់ដេរ។

- ជំរុញកិច្ចសហប្រតិបត្តិការជាមួយប្រទេសដៃគូរដែលមានបទពិសោធន៍ក្នុងវិស័យកាត់ដេរ ក្នុងការចែករំលែកបទពិសោធន៍ក្នុងការគ្រប់គ្រងវិស័យកាត់ដេរនិងការទាក់ទាញនូវការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាទំនើបផងដែរ។
- រដ្ឋាភិបាលនិងក្រសួងអប់រំជំរុញកម្មវិធីអាហារូបករណ៍ ដោយផ្តោតសំខាន់លើផ្នែកវាយនភណ្ឌ និងច្នៃម៉ូដដល់សិស្ស-និស្សិតទៅកាន់ប្រទេសដែលមានបទពិសោធន៍ផ្នែកកាត់ដេរ ក្នុងន័យកាត់បន្ថយថ្លៃបណ្តុះបណ្តាលសិស្ស និងសិស្សផ្ទាល់បានសិក្សាបទពិសោធន៍អនុវត្តនៅបណ្តាប្រទេសទាំងនោះ។
- រដ្ឋាភិបាល និងសមាគមកាត់ដេរកម្ពុជាផ្តល់នូវមូលនិធិស្រាវជ្រាវផ្នែកវាយនភណ្ឌក្នុងកម្រិតបច្ចេកទេសដែលអាចផ្តល់នូវធាតុចូលសំខាន់ក្នុងការបន្តគាំទ្រនិងចីរភាពរបស់វិស័យកាត់ដេរ។

## ខ. ផ្តោតសំខាន់លើលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ

ការផ្តោតសំខាន់លើលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករនិយោជិតជាកត្តាសំខាន់ក្នុងការពង្រឹងភាពប៉ាន់ប្រមាណនិងស្ថិរភាពនៃវិស័យឧស្សាហកម្មកាត់ដេរនេះ។ ភាពប្រសើរនៃលក្ខខណ្ឌការងារនិងសុខុមាលភាព ជាផ្នែកមួយដ៏សំខាន់សម្រាប់ម្ចាស់ម៉ាកផលិតផលសម្រេចចិត្តដាក់ការបញ្ជាទិញរបស់ខ្លួនលើកកម្ពស់កេរ្តិ៍ឈ្មោះនៃឧស្សាហកម្មកាត់ដេរ ហើយធានាការពារទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងអ្នកផលិតនៅកម្ពុជានឹងឈានទៅជំរុញឱ្យមានការវិនិយោគរយៈពេលវែងផងដែរ។

វិធានការក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងសុខុមាលភាពកម្មករមានដូចតទៅ៖

- ពង្រឹងការអនុវត្តនៅតាមបណ្តារោងចក្រ-សហគ្រាសស្របតាមកម្មវិធី BFC
- ជំរុញការកសាងសមត្ថភាព និងការផ្លាស់ប្តូរចំណេះដឹងរវាងកម្មវិធី BFC និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទៅនឹងបរិការណ៍កម្ពុជា។
- ពង្រឹងសុវត្ថិភាព និងផាសុកភាពនៃមធ្យោបាយដឹកជញ្ជូនកម្មករ តាមរយៈការបង្កើតយន្តការគាំទ្រ, ការពិនិត្យលទ្ធភាពផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម និងផ្តល់ឥណទានដែលមានការប្រាក់ទាបជូនអ្នកផ្តល់សេវាបើកបរឱ្យមានលទ្ធភាពប្រើប្រាស់រថយន្តដឹកជញ្ជូន ប្រកបដោយសុវត្ថិភាព និងតម្រូវឱ្យមានធានារ៉ាប់រង។
- ពង្រឹងតួនាទី និងផ្តល់ការគាំទ្រចាំបាច់ ដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យបន្តស្ថិតជាគ្រឹះស្ថានអព្យាក្រឹត្យឯករាជ្យ និងមិនលំអៀងក្នុងការដោះស្រាយវិវាទការងារ។
- ការពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃការផ្តល់របបសន្តិសុខសង្គម ដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម (បសស) បច្ចុប្បន្ន ជូនកម្មករ-និយោជិត តាមការវិវត្តជាក់ស្តែងនៃវិស័យនេះ រួមមាន ការគិតគូរពីលទ្ធភាពនៃការផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងការងារ។
- ការពិនិត្យលទ្ធភាពកំណត់ប្រាក់ឈ្នួលអប្បបរមាតាមតំបន់ដល់កម្មករ-និយោជិត។

### គ. បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្មគាំទ្រ

យោងតាមការសិក្សាស្រាវជ្រាវកន្លងមកលក្ខណៈវិនិច្ឆ័យរបស់អ្នកបញ្ជាទិញ គឺមានដូចជាការគោរពច្បាប់បទបញ្ញត្តិការងារ ការគោរពតាមគោលការណ៍នៃការពារបរិស្ថាន ការអភិវឌ្ឍផលិតផលនិងចំណេះដឹងផ្នែករចនាបថ វត្ថុធាតុដើម និងថេរវេលាក្នុងការដឹកជញ្ជូន។ ទន្ទឹមនឹងការទាក់ទាញនូវការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រ និងបែងចែកនូវប្រភេទនៃឧស្សាហកម្មគាំទ្រកម្ពុជាគួរពិនិត្យលទ្ធភាពសិក្សាអំពីផែនការបែងចែកតំបន់ភូមិសាស្ត្រឧស្សាហកម្មគាំទ្រជាតំបន់ និងមានលក្ខណៈតភ្ជាប់ជាមុនដោយផ្តល់ភាពងាយស្រួលដល់វិនិយោគិនបរទេសនិងកាត់បន្ថយអត្រាចំណាកស្រុករបស់កម្មករ។ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធគួរបែងចែកនូវខ្សែច្រវាក់ផលិតកម្មក្នុងវិស័យឧស្សាហកម្មកាត់ដេរជាប្រភេទ ដូចជា៖

(១) ឧស្សាហកម្មគាំទ្របន្ទាប់បន្សំមូលដ្ឋាន៖ អំបោះ និង ទ្បេរ ជាដើម។

(២) ឧស្សាហកម្មគាំទ្របន្ទាប់បន្សំជាសម្ភារៈតុបតែង៖ គ្រឿងតុបតែង ខ្សែដេរភ្ជាប់។

(៣) ឧស្សាហកម្មគាំទ្រសម្រាប់ការបញ្ចប់ការផលិត៖ កាតុង បន្ទះការក្រដាស ឬ ផ្ទាំងប្លាស្ទិក។

ការបែងចែកនេះ គឺមានភាពងាយស្រួលក្នុងការស្វែងរកវិនិយោគិនគោលដៅ និងការផ្តល់ជូននូវការលើកទឹកចិត្តស្របទៅតាមប្រភេទវិនិយោគរបស់ពួកគេផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាអាចជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ណាមួយដែលមានទីតាំងអំណោយផលដល់រោងចក្រកាត់ដេរវេចខ្ចប់មួយចំនួននៅក្នុងប្រទេស ក្នុងន័យបម្រើនូវវត្ថុធាតុដើមក្នុងការផលិតដល់ពួកគេ ដែល អាចកាត់បន្ថយនូវថ្លៃដើមរយៈពេលនៃដំណើរការផលិតកម្ម និងរយៈពេលនៃការដឹកជញ្ជូនផងដែរ។ ទន្ទឹមនឹងនោះ គួរយកចិត្តទុកដាក់នូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលគាំទ្រដល់ឧស្សាហកម្មទាំងនោះពោលគឺផ្លូវ ថ្នល់ ព្រមទាំងធានាបាននូវស្ថិរភាពនៃការផ្គត់ផ្គង់ និងថ្លៃចំណាយទៅលើទឹក ភ្លើងផងដែរ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល និងបណ្តាស្ថាប័នពាក់ព័ន្ធអាចលើកទឹកចិត្តដល់ អ្នកវិនិយោគក្នុងស្រុក និងបរទេសក្នុងការវិនិយោគបន្ថែមនិងជំរុញឱ្យសហគ្រិនចូលរួមក្នុងការទិញមូលបត្រភាគហ៊ុន (Stock) និងមូលបត្របំណុល (Bond) ដែលអាចជំរុញនូវឱ្យមានលំហូរទុនវិនិយោគក្នុងស្រុក។

ជារួម នៅពេលដែលមានការបែងចែកនូវឧស្សាហកម្មគាំទ្រទៅតាមផ្នែកនីមួយៗដូចខាងលើកម្ពុជាបានកាត់បន្ថយនូវហានិភ័យពីផលប៉ះពាល់ពីមជ្ឈដ្ឋានខាងក្រៅ ពោលគឺតាមរយៈការរង់ចាំការដឹកជញ្ជូនវត្ថុធាតុដើម ភាពមិនច្បាស់លាស់អំពីថ្លៃទំនិញពីអ្នកបញ្ជាទិញ និងថ្លៃវត្ថុធាតុដើម ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការទទួលបាននូវប្រាក់ចំណេញទាប និងភាពយឺតយ៉ាវនៃការដឹកជញ្ជូន។

### ឃ. ជំរុញពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរសំលៀកបំពាក់

បច្ចុប្បន្នកម្ពុជាពឹងផ្អែកសំខាន់ទៅលើគោលដៅទីផ្សារធំៗទាំង២របស់ខ្លួនដែលបានទទួលនូវប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។ ប៉ុន្តែ យោងតាមទិន្នន័យនៃការនាំចេញរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា យើងអាចវាយតម្លៃបានថាទីផ្សារផ្សេងៗក្រៅពីសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប កម្ពុជា មាន

សក្តានុពលក្នុងការនាំចេញទៅកាន់ប្រទេសមួយចំនួនទៀតដូចជា ប្រទេសជប៉ុន កូរ៉េខាងត្បូង និង កាណាដាជាដើម។ ដូច្នេះ កម្ពុជាគួរជំរុញពិពិធកម្មទីផ្សាររបស់ខ្លួនទៅកាន់ប្រទេសផ្សេងទៀត ដោយកុំពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទាំងស្រុង។ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នគួរសិក្សាអំពីតម្រូវការ និងទីផ្សារផលិតផលកាត់ដេរបន្ថែមទៀត ព្រមទាំងពង្រឹងនូវគុណភាព ផលិតផលកាត់ដេររបស់ខ្លួន ដើម្បីឈោងចាប់យកនូវឱកាសនាពេលអនាគត។ ទន្ទឹមនឹងនោះ កម្ពុជា គួរជំរុញការចុះកិច្ចព្រមព្រៀងទ្វេភាគីទៅកាន់ប្រទេសគោលដៅឱ្យបានកាន់តែច្រើន ជាជាងប្រព័ន្ធអនុគ្រោះពន្ធ។ យោងតាមតថភាពជាក់ស្តែង នៅពេលដែលប្រព័ន្ធអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុបត្រូវបានព្យួរ មានន័យថា រាល់ទំនិញរបស់កម្ពុជានាំចូលទៅកាន់ប្រទេសដែលនៅក្នុងសហភាពអឺរ៉ុបនោះនឹងមានការគិតពន្ធទៅតាមអត្រាមុខទំនិញនីមួយៗ។

ជារួម ក្រៅពីបញ្ហាប្រឈមកម្ពុជានៅតែមានឱកាស និងកាលានុវត្តភាពដែលជាចក្ខុវិស័យក្នុងការលើកស្ទួយវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់បានតាមរយៈ (១)ការបង្កើនផលិតភាពការងារនិងកម្មករជំនាញក្នុងស្រុក (២) បង្កើនការវិនិយោគក្នុងវិស័យឧស្សាហកម្មគាំទ្រ និង (៣)ជំរុញពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរសំលៀកបំពាក់។

### ខ. លើកកម្ពស់វិនិយោគក្នុងស្រុក និងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់

ដើម្បីឆ្លើយតបទៅកាន់បរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤វិស័យកាត់ដេរសំលៀកបំពាក់និងវាយនភណ្ឌគួរឈោងចាប់នូវកាលានុវត្តភាពបច្ចេកវិទ្យាថ្មី ក្នុងន័យបង្កើននូវតម្លៃបន្ថែមខ្ពស់។ រាជរដ្ឋាភិបាលគួរលើកទឹកចិត្តនិងជំរុញការវិនិយោគទាំងក្នុងស្រុក និងបរទេសក្នុងឧស្សាហកម្មដែលផ្តល់នូវតម្លៃបន្ថែមគួរដូចខាងក្រោម៖

- សិក្សាអំពីតម្រូវការទីផ្សារ និងតម្រូវការវិនិយោគ (ទាំងការវិនិយោគថ្មី និងការវិនិយោគឡើងវិញ)លើការផលិតនូវផលិតផលកាត់ដេរ ឬ/និងផលិតផល គាំទ្រដែលមានតម្លៃបន្ថែមខ្ពស់ និងលើផលិតផលថ្លៃខ្ពស់ ព្រមទាំងមានលក្ខណៈពិសេស។
- ជំរុញការតភ្ជាប់កាន់តែប្រសើររវាងរោងចក្រនាំចេញ និងរោងចក្រសហគ្រាសម៉ៅការបន្តក្នុងវិស័យនេះ តាមរយៈយន្តការលើកទឹកចិត្តដែលមានស្រាប់និងថ្មី ដោយមានការចូលរួមយ៉ាងជិតស្និទ្ធជាមួយសមាគមកាត់ដេរកម្ពុជា និងភាគីពាក់ព័ន្ធ។
- ជំរុញនិងលើកទឹកចិត្តដល់ការវិនិយោគដែលមានការផ្លាស់ប្តូរខ្សែច្រវាក់ផលិតកម្មពីរោងចក្រវេចខ្ចប់ (CMT)មកលក្ខណៈទម្រង់ពេញលេញ (Full package)
- លើកទឹកចិត្តដល់អ្នកវិនិយោគក្នុងស្រុកក្នុងការបង្កើនលទ្ធភាព គុណភាព និងទំនើបកម្មផលិតកម្មរបស់ខ្លួនដែលអាចឈានទៅជារោងចក្រសហគ្រាសនាំចេញ។

# វឌ្ឍនភាពសេដ្ឋកិច្ចខេត្តក្រចេះតាមរយៈវិស័យកសិកម្ម

*បេក្ខជនបណ្ឌិត៖ **ហេង លីដា***

*ជំនាញ៖ **វិទ្យាសាស្ត្រសេដ្ឋកិច្ច***

*គ្រូណែនាំ៖ **បណ្ឌិត ឆេង វណ្ណារិទ្ធ***

## ១-សេចក្ដីផ្ដើម

តាមរបាយការណ៍របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះបានបង្ហាញថា នៅក្នុងឆ្នាំ២០១៨ សេដ្ឋកិច្ចខេត្តក្រចេះមានប្រមាណ ២.០៣៧.២៤៥លានរៀល គិតជាដុល្លារប្រហែលជាង ៥០៣លាន ដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ = ៤.០៥០រៀល) បើគិតតាមថ្លៃនៅឆ្នាំ២០១៨ស្មើនឹង២,៣% នៃសេដ្ឋកិច្ចជាតិ ហើយតាមបរិមាណចំណូលនេះ នាំឱ្យខេត្តមានកំណើនសេដ្ឋកិច្ចប្រមាណជា៦,៦% នៅឆ្នាំ២០១៨ធៀបនឹងឆ្នាំ២០១៧ និងប្រាក់ចំណូលសម្រាប់ម្នាក់មាន ១.២៨៥ដុល្លារអាម៉េរិក អត្រាកំណើនមាន៩,៧% បើធៀបនឹងឆ្នាំ២០១៧[១]។ ឆ្នាំ២០១៧ មានប្រមាណ ១.៨២៥.៧៧៧,៥លាន រៀល គិតជាដុល្លារប្រហែលជាង៤៥៣លានដុល្លារអាម៉េរិក បើគិតតាមថ្លៃនៅឆ្នាំ២០១៧ស្មើនឹង២,២% នៃសេដ្ឋកិច្ចជាតិ តាមបរិមាណចំណូលនេះ នាំឱ្យខេត្តមានកំណើនសេដ្ឋកិច្ចប្រមាណជា៥,៧% នៅឆ្នាំ ២០១៧ធៀបនឹងឆ្នាំ២០១៦[២] និងប្រាក់ចំណូលសម្រាប់ម្នាក់មាន ១.១៧១ដុល្លារអាម៉េរិក អត្រាកំណើន មាន៦,៣% បើធៀបនឹងឆ្នាំ២០១៦។ ឆ្នាំ២០១៦ មានប្រមាណ ១.៦៩៣.៥៦៨,៩លានរៀល គិតជា ដុល្លារប្រហែល ៤២០,២លានដុល្លារអាម៉េរិក បើគិតតាមថ្លៃនៅឆ្នាំ២០១៦ ស្មើនឹង២,១% នៃសេដ្ឋកិច្ច ជាតិបើធៀបនឹងឆ្នាំ២០១៥ និងប្រាក់ចំណូលសម្រាប់ម្នាក់មាន ១.១០១ដុល្លារអាម៉េរិក អត្រាកំណើន មាន៧,៣% បើធៀបនឹងឆ្នាំ[៣]។ ឆ្នាំ២០១៥ សេដ្ឋកិច្ចខេត្តមាន ១.៥៥៩.៨២៩,២លានរៀល ឬស្មើនឹង ៣៨៧,១លានដុល្លារអាម៉េរិក តាមបរិមាណចំណូលនេះ នាំឱ្យខេត្តមានកំណើនសេដ្ឋកិច្ចប្រមាណជា ៦.៦% នៅឆ្នាំ២០១៤ ប្រាក់ចំណូលសម្រាប់ម្នាក់មាន ១.០២៦ដុល្លារអាម៉េរិក អត្រាកំណើនមាន ៥,៨% បើធៀបនឹងឆ្នាំ២០១៤[៤]។ ចំណូលសេដ្ឋកិច្ចធំរបស់ខេត្ត ពឹងផ្អែកលើវិស័យបីគឺ វិស័យកសិកម្ម វិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម។

---

[១] មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ, «***សេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨*** » របាយការណ៍របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះ, បោះពុម្ពផ្សាយឆ្នាំ២០១៨, ទំព័រ៣

[២] មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ, «***សេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៧*** » របាយការណ៍របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះ, បោះពុម្ពផ្សាយឆ្នាំ២០១៧, ទំព័រ៣

[៣] មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ, «***សេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៦*** -របាយការណ៍របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះ, បោះពុម្ពផ្សាយឆ្នាំ២០១៦, ទំព័រ៣

[៤] មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ, «***សេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៥*** -របាយការណ៍របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះ, បោះពុម្ពផ្សាយឆ្នាំ២០១៥, ទំព័រ៣

### ក្រាហ្វិកទី១៖ កំណើនសេដ្ឋកិច្ចខេត្តក្រចេះពីឆ្នាំ២០១២-២០១៨




*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

### ក្រាហ្វិកទី២៖ ប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋខេត្តក្រចេះម្នាក់ពីឆ្នាំ២០១១-២០១៧




*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

### តារាងទី១៖ ផលិតផលក្នុងស្រុកសរុបរបស់ខេត្តក្រចេះពីឆ្នាំ២០១៦-២០១៨

| ផលិតផលក្នុងស្រុកសរុប | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| ផ.ស.ស ថ្លៃបច្ចុប្បន្ន (ជាលានរៀល) | 1,740,047.3 | 1,876,782.2 | 2,037,245.4 |
| ផ.ស.ស ថ្លៃស្ថេរ ២០១១ (ជាលានរៀល) | 1,491,521.8 | 1,577,879.6 | 1,682,107.1 |
| ផ.ស.ស (ជាលានដុល្លារអាម៉េរិក) | 432.0 | 465.7 | 503.0 |
| ផ.ស.ស សម្រាប់ក្នាក់ (ជាដុល្លារអាម៉េរិក) | 1,130.3 | 1,203.5 | 1,284.5 |
| កំណើន ផ.ស.ស (GDP) | 6.7% | 5.8% | 6.6% |

*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

### តារាងទី២៖ ផលិតផលក្នុងស្រុកសរុបរបស់ខេត្តក្រចេះពីឆ្នាំ២០១៦-២០១៨ តាមវិស័យ

| ផ.ស.ស. តាមវិស័យ (ថ្លៃថេរ២០១១) | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| កសិកម្ម (ជាលានរៀល) | 756,835.8 | 794,932.1 | 836,624.8 |
| ឧស្សាហកម្ម (ជាលានរៀល) | 155,630.6 | 171,193.0 | 191,085,0 |
| សេវាកម្ម (ជាលានរៀល) | 579,055.5 | 611,754.5 | 654,397.4 |
| ផ.ស.ស (GDP) | 1,491,521.8 | 1,577,879.6 | 1,682,107.1 |

*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

### តារាងទី៣៖ ផលិតផលក្នុងស្រុកសរុបរបស់ខេត្តក្រចេះពីឆ្នាំ២០១៦-២០១៨ កំណើនតាមវិស័យ

| ផ.ស.ស. តាមវិស័យ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| កសិកម្ម | 6.01% | 5.03% | 5.24% |
| ឧស្សាហកម្ម | 9.8% | 10.0% | 11.6% |
| សេវាកម្ម | 6.7% | 5.6% | 7.0% |
| ផ.ស.ស (GDP) | 6.7% | 5.8% | 6.6% |

*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

### តារាងទី៤៖ កំណើនតាមវិស័យធៀបនឹងផលិតផលក្នុងស្រុកសរុបរបស់ខេត្តក្រចេះពីឆ្នាំ២០១៦-២០១៨

| ផ.ស.ស. សមាមាត្រតាមវិស័យ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| កសិកម្ម | 52.1% | 51.4% | 51.7% |
| ឧស្សាហកម្ម | 10.7% | 11.3% | 12.2% |
| សេវាកម្ម | 36.7% | 36.5% | 36.1% |
| ផ.ស.ស (GDP) | 100.0% | 100.0% | 100.0% |

*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

### តារាងទី៥៖ កំណើនតាមវិស័យ ធៀបនឹងផលិតផលក្នុងស្រុកសរុបរបស់ជាតិពីឆ្នាំ២០១៦-២០១៨

| កំណើនផលិតផលសរុបក្នុងស្រុក (ផ.ស.ស %) | កម្ពុជា ២០១៨ | ក្រចេះ ២០១៨ |
|---|---|---|
| កសិកម្ម | 1.6% | 5.2% |
| ឧស្សាហកម្ម | 12.3% | 11.6% |
| សេវាកម្ម | 6.1% | 7.0% |
| ផ.ស.ស (GDP) | 7.5% | 6.6% |

*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

## ២-ចក្ខុវិស័យសេដ្ឋកិច្ចពីវិស័យកសិកម្ម

វិស័យកសិកម្ម គឺជាវិស័យសក្តានុពលទី១ ក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ខេត្តក្រចេះ។ តាមរបាយការណ៍របស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះបានបង្ហាញថា វិស័យកសិកម្មមានសមាមាត្រចូលរួមក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.-GDP) របស់ខេត្តក្រចេះ នៅឆ្នាំ២០១៨ ប្រមាណជា ៥១,៧%[៥]។ ជាក់ស្តែង នៅឆ្នាំ២០១៤ វិស័យកសិកម្មបាននាំមកនូវចំណូលសេដ្ឋកិច្ចសម្រាប់ខេត្តចំនួន ៦៨៦.៩៩៦,២លានរៀល គិតជាដុល្លាប្រហែលជាង១៧០លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់ ១ដុល្លារ=៤.០២៨រៀល)ស្មើនឹង៥៥,២% នៃសេដ្ឋកិច្ចខេត្ត, នៅឆ្នាំ២០១៥ បាននាំមកនូវចំណូលសេដ្ឋកិច្ចចំនួន ៧១៣.៩៥៨,២លានរៀល គិតជាដុល្លាប្រហែលជាង ១៧៧លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=៤.០២៨រៀល)ស្មើនឹង៥៤,៥% នៃសេដ្ឋកិច្ចខេត្ត មានកំណើន៤% បើធៀបនឹងឆ្នាំ ២០១៤, ក្នុងឆ្នាំ២០១៦ បានចំនួន ៧៥៦.៨៣៥,៨លានរៀលគិតជាដុល្លាប្រហែលជាង ១៨៧លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=៤.០២៨រៀល) ស្មើនឹង៥២,១% នៃសេដ្ឋកិច្ចខេត្ត មានកំណើន ៦,១% បើធៀបនឹងឆ្នាំ២០១៥, ក្នុងឆ្នាំ២០១៧ បានចំនួន ៧៩៤.៩៣២,១លានរៀល គិតជាដុល្លារប្រហែលជាង ១៩៧លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=៤.០២៨រៀល) ស្មើនឹង៥១,៤%នៃសេដ្ឋកិច្ចខេត្ត មានកំណើន៥,០៣% បើធៀបនឹងឆ្នាំ២០១៦ និង ក្នុងឆ្នាំ២០១៨ បានចំនួន ៨៣៦.៦២៤,៨លានរៀល គិតជាដុល្លារប្រហែលជាង ២០៧លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=៤.០២៨រៀល) ស្មើនឹង៥១,៧% នៃសេដ្ឋកិច្ចខេត្ត មានកំណើន៥,២៤% បើធៀបនឹងឆ្នាំ២០១៧។ បើធ្វើផលធៀបកំណើនជាមធ្យមសម្រាប់រយៈពេល៥ឆ្នាំនេះ (២០១៤-២០១៨) វិស័យកសិកម្មខេត្តក្រចេះមានកំណើន ៥,២%[៦], ក្នុងនោះ ការងារដាំដុះដំណាំបាននាំចំណូលចំនួន ៣១០.៥៥៥,៦លានរៀល គិតជាដុល្លារប្រហែលជាង៧៦លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=4,0៥0រៀល) ស្មើនឹង ៣៩,០៧% នៃចំណូលសរុបពីវិស័យកសិកម្ម មានកំណើន៥,៤% បើធៀបនឹងឆ្នាំ២០១៦[៧], ការងារចិញ្ចឹមសត្វបាននាំចំណូលចំនួន ៦៨.៥១៩,៣លានរៀល គិតជាដុល្លារប្រហែលជាង១៦លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=4,0៥0រៀល) ស្មើនឹង៨,៦២%នៃចំណូលសរុបពីវិស័យកសិកម្មមានកំណើន៤,៤%[៨], ការងារជលផល និងនេសាទបាននាំចំណូលចំនួន ២៣៤.៣៥១,៦លានរៀល គិតជាដុល្លារប្រហែលជាង៥៧លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ=4,0៥0រៀល) ស្មើនឹង២៩,៤៧% នៃចំណូលសរុបពីវិស័យកសិកម្ម មានកំណើន៤,៦%[៩] និងការងាររុក្ខា ប្រម៉ាញ់បាននាំចំណូលចំនួន ១៨១.៥០៥,៦លានរៀល គិតជាដុល្លារប្រហែលជាង៤៤លានដុល្លារអាម៉េរិក (អត្រាប្តូរប្រាក់១ដុល្លារ =៤.០៥០រៀល) ស្មើនឹង២២,៨៣%នៃចំណូលសរុបពីវិស័យកសិកម្ម មានកំណើន៦,១%[១០] ហើយប្រជាពលរដ្ឋក្នុងខេត្តមានអាយុពី១៨-៦០ឆ្នាំ ប្រកបរបរកសិកម្មជាចម្បងមានចំនួនប្រមាណជា៨១,៥%។

---

[៥] មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ, «*សេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨*» -ដ.ឯ.ម- ទំព័រ១២

[៦] មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ, «*សេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨*» -ដ.ឯ.ម- ទំព័រ១២

[៧] -ដ-

[៨] -ដ-

[៩] -ដ-

[១០] -ដ-

## ក្រាហ្វិកទី៣៖ កំណើនវិស័យកសិកម្មរបស់ខេត្តក្រចេះពីឆ្នាំ២០១២-២០១៧




*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៧ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៧*

## តារាងទី៦៖ ចំណូលផ្សេងៗក្នុងវិស័យកសិម្មរបស់ខេត្តក្រចេះពីឆ្នាំ២០១៦-២០១៨

| កសិកម្មតម្លៃបន្ថែម (ជាលានរៀល) | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| ដំណាំ | 297,058.0 | 310,555.6 | 327,442.3 |
| ចិញ្ចឹមសត្វ | 66,091.5 | 68,519.3 | 71,511.8 |
| ជលផល និង នេសាទ | 221,826.2 | 234,351.6 | 245,048.9 |
| រុក្ខាកម្ម | 171,860.2 | 181,505.6 | 192,621.7 |
| កសិកម្ម (ជាលានរៀល) | 756,835.8 | 794,932.1 | 836,624.8 |

*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៨ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៨*

ស្ថានភាពរួមនៃការងារបង្កបង្កើនផលស្រូវ ដំណាំរួមផ្សំ និង ដំណាំកសិ-ឧស្សាហកម្ម តាមឆ្នាំបន្តបន្ទាប់មកនេះ ក្រោមការគាំទ្រឧបត្ថម្ភគ្រប់មធ្យោបាយជាអាទិ៍ ពីរាជរដ្ឋាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និង ដៃគូអភិវឌ្ឍន៍ គួបផ្សំនឹងការខិតខំប្រឹងប្រែងឧស្សាហ៍ព្យាយាមរបស់កសិករផងនោះ បានជម្រុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និង ជំនួសបាននូវការលំបាកផ្សេងៗ ហើយអាចវាយតម្លៃបានថាបរិមាណផលស្រូវ និង ដំណាំរួមផ្សំមួយចំនួនមានការកើនឡើង ធៀបនឹងឆ្នាំកន្លងទៅ។ ការងារបង្កបង្កើនផលពីមួយឆ្នាំទៅមួយឆ្នាំមានការវិវឌ្ឍល្អ និង មានការចាប់អារម្មណ៍ខ្ពស់ពីកសិករ ជាពិសេស ការកែប្រែពីការធ្វើកសិកម្មតាមបែបបុរាណ យថាផល មកជាកសិកម្មតាមក្បួនខ្នាតត្រឹមត្រូវ និង ស៊ីជម្រៅ។ ក្រៅពីនេះ ផ្នែកឯកជនបានចូលរួមយ៉ាងសំខាន់ក្នុងដំណើរការវិនិយោគដំណាំកសិ-ឧស្សាហកម្ម ដូចជា កៅស៊ូ និង ដំឡូងមី ដែលជាគន្លឹះជួយឱ្យវិស័យនេះមានការរីកចម្រើនថែមមួយកម្រិតទៀត និង បានធ្វើឱ្យជីវភាព

កសិករកាន់តែមានភាពល្អប្រសើរឡើងតាមរយៈការផ្តល់ការងារបន្ថែមដល់កសិករ ដែលរស់នៅជុំវិញតំបន់វិនិយោគ និង ផ្តល់ចំណេះដឹងបច្ចេកទេសថ្មីៗអំពីការដាំដុះ តាមក្បួនខ្នាតត្រឹមត្រូវជូនកសិករ។ ជាក់ស្តែងបើតាមរបាយការណ៍ដែលចេញផ្សាយនៅក្នុង ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥ និង ឆ្នាំ២០១៩» សម្រាប់ការគ្រប់គ្រង និង អភិវឌ្ឍន៍មូលដ្ឋាន ភូមិ ឃុំ-សង្កាត់ ដែលរៀបចំដោយមន្ទីរផែនការខេត្តក្រចេះ ដែលចេញផ្សាយឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩ បានបង្ហាញថា ស្ថានភាពមុខរបរចម្បងក្នុងវិស័យកសិកម្ម ក្នុងឆ្នាំ២០១១ មនុស្សប្រកបមុខរបរផ្នែកកសិកម្មមានចំនួនសរុប១២៧.២៧០នាក់ ស្មើនឹង៦៦,៨%[១១], ឆ្នាំ២០១២មានចំនួនសរុប១១៩.៩៨២នាក់ ស្មើនឹង៨៣%[១២], ក្នុងឆ្នាំ២០១៣មានចំនួនសរុប១៣៦.៤៨៣នាក់ ស្មើនឹង៨២%[១៣], ក្នុងឆ្នាំ២០១៤មានចំនួនសរុប១៣៦.១០០នាក់ ស្មើនឹង៨២,២%[១៤], ក្នុងឆ្នាំ២០១៥មានចំនួនសរុប១៣៨.៥៥៦នាក់ ស្មើនឹង៨១,៤%[១៥], ក្នុងឆ្នាំ២០១៦មានចំនួនសរុប១៤៣.៩៧៥នាក់ ស្មើនឹង៨១,៣%[១៦], ក្នុងឆ្នាំ២០១៧មានចំនួនសរុប១៥១.០៦១នាក់ ស្មើនឹង៨១,៥%[១៧] និង ក្នុងឆ្នាំ២០១៨មានចំនួនសរុប១៤៧.៤៩៨នាក់ ស្មើនឹង៨១,២%[១៨]។

**តារាងទី៧៖ ស្ថានភាពកសិករពីឆ្នាំ២០១៥-២០១៨**

| បរិយាយ | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|
| គ្រួសារមានដីស្រែតិចជាង១ហិកតា | 18,305 | 18,099 | 17,683 | 18,038 |
| គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន | 11,879 | 11,892 | 12,146 | 12,666 |
| ចំនួនគ្រួសារមានដីដាំដំណាំចម្ការតិចជាង១ហិកតា | 12,321 | 12,738 | 13,009 | 11,601 |
| ចំនួនគ្រួសារគ្មានដីដាំដំណាំចម្ការផ្ទាល់ខ្លួន | 14,361 | 14,777 | 16,116 | 14,944 |

*ប្រភព៖ ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៦ និង ឆ្នាំ២០១៩*

**តារាងទី៨៖ ស្ថានភាពមុខរបរចម្បងពីឆ្នាំ២០១៦-២០១៨**

| បរិយាយ | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|
| សរុបអ្នកមានអាយុ១៨-៦០ឆ្នាំ | 187,995 | 197,630 | 205,382 | 207,270 |
| ចំនួនស្រីមានអាយុ១៨-៦០ឆ្នាំ | 95,857 | 100,603 | 103,200 | 103,977 |

[១១] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២*» របស់មន្ទីរផែនការខេត្តក្រចេះ ចេញផ្សាយឆ្នាំ២០១២ ទំព័រ១២

[១២] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*» របស់មន្ទីរផែនការខេត្តក្រចេះ ចេញផ្សាយឆ្នាំ២០១៥ ទំព័រ៧

[១៣] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦*» របស់មន្ទីរផែនការខេត្តក្រចេះ ចេញផ្សាយឆ្នាំ២០១៦ ទំព័រ៧

[១៤] -ដដ-

[១៥] -ដដ-

[១៦] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩*» របស់មន្ទីរផែនការខេត្តក្រចេះ ចេញផ្សាយឆ្នាំ២០១៩ ទំព័រ៧

[១៧] -ដដ-

[១៨] -ដដ-

| | | | | | |
|---|---|---|---|---|---|
| ចំនួនប្រុសមានអាយុ១៨-៦០ឆ្នាំ | | 92,138 | 97,027 | 102,182 | 103,293 |
| សរុបអ្នកមានមុខរបរចម្បង | | 170,139 | 176,987 | 185,414 | 181,751 |
| %សរុបអ្នកមានមុខរបរចម្បង | | 90.5 | 89.6 | 90.3 | 87.7 |
| %ស្រីមានមុខរបរចម្បង (គិតក្នុងស្រី១៨-៦០ឆ្នាំ) | | 74.3 | 72.2 | 73.5 | 69.2 |
| %ប្រុសមានមុខរបរចម្បង (គិតក្នុងប្រុស១៨-៦០ឆ្នាំ) | | 84.9 | 85.1 | 83.6 | 82.8 |
| **មុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | | | | |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | 138,556 | 143,975 | 151,061 | 147,498 |
| %អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម (គិតក្នុងមុខរបរចម្បង) | | 81.4 | 81.3 | 81.5 | 81.2 |
| %ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម (គិតក្នុងមុខរបរចម្បង) | | 39.8 | 38.9 | 39.2 | 38.0 |
| ក្នុងនោះ | %អ្នកមានមុខរបរធ្វើស្រែ | 52.9 | 50.1 | 48.0 | 46.4 |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | 8.0 | 10.0 | 11.2 | 13.3 |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | 14.2 | 15.3 | 15.9 | 15.6 |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | 2.3 | 2.3 | 2.1 | 1.9 |
| | %អ្នកមានមុខរបរនេសាទ | 1.6 | 1.6 | 1.6 | 1.4 |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | 1.9 | 1.5 | 2.1 | 2.2 |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | 0.5 | 0.4 | 0.5 | 0.4 |

*ប្រភព៖ ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩» របស់មន្ទីរផែនការខេត្តក្រចេះ ចេញផ្សាយឆ្នាំ២០១៩*

ស្ថានភាពជារួមនៃការងារដាំដុះ គឺមានការដាំដុះស្រូវ ការដាំដុះដំណាំរយៈពេលខ្លី និង ការដាំដុះដំណាំឧស្សាហកម្ម ដែលតាមតួលេខស្តីពីការដាំដុះកន្លងមកបានបង្ហាញថា៖

## ២.១-ស្រូវប្រាំង

ក្នុងឆ្នាំ២០០៩ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៤.៧៩៥ហិកតា ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវប្រាំងជាក់ស្តែង មាន៩១,៤២% (ស្មើនឹង១៣.៥២៥,៥៨ហិកតា) ទិន្នផលស្រូវប្រាំងដែលទទួលបានជាមធ្យមគឺ២,៣៨តោនក្នុង១ហិកតា ដោយបរិមាណផលស្រូវប្រាំងសរុបដែលទទួលបានគឺ ៣២.១៥៤,៦១តោន។ ក្នុងឆ្នាំ២០១០ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៥.៤០១ហិកតា (មានការកើនឡើង៦០៦ហិកតា គិតជាភាគរយកំណើនស្មើនឹង៤,០៩% បើធៀបនឹងឆ្នាំ២០០៩) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន ៨៨,៤៧% (ស្មើនឹង១៣.៦២៥,២៦ហិកតា) មានការថយចុះចំនួន២,៩៥% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០០៩ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ មានការកើនឡើង៩៩,៦៨ហិកតា ច្រើនជាងឆ្នាំ២០០៩) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,៧១តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០០៩ចំនួន០,៣៣តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៣៦.៩១១,៩៣តោន (កើនឡើង៤.៧៥៧,៣២តោន ខ្ពស់ជាងឆ្នាំ២០០៩ ឬ

ប្រមាណជា១៤,៧៩%បើធៀបនឹងឆ្នាំ២០០៩)។ ក្នុងឆ្នាំ២០១១ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៥.២៦៣ហិកតា (ថយចុះ១៣៨ហិកតា គិតជាភាគរយថយចុះ០,៩០% បើធៀបនឹងឆ្នាំ២០១០) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវប្រាំងជាក់ស្តែងគឺមាន៩៤,៤៥% (ស្មើនឹង១៤.៤១៥,៩០ហិកតា មានការកើនឡើងចំនួន៥,៩៨% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១០ ហើយបើគិតជាចំនួនហិកតាវិញ គឺកើនឡើង៧៩០,៦៤ហិកតាច្រើនជាងឆ្នាំ២០១០) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,៦៧តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១០ ចំនួន០,០៤តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៣៨.៤៩៣,៩២តោន (កើនឡើង១.៥៨១,៩៩តោនខ្ពស់ជាងឆ្នាំ២០១០ ឬប្រមាណជា៤,២៨% បើធៀបនឹងឆ្នាំ២០១០)[១៩]។ ក្នុងឆ្នាំ២០១២ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុប មាន១៤.១៨១ហិកតា (ថយចុះ១.០៨២ហិកតា គិតជាភាគរយថយចុះ៧,៦២%បើធៀបនឹងឆ្នាំ២០១១) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន ៨៩,៥៥% (ស្មើនឹង១២.៦៩៩,០៨ហិកតា មានការថយចុះចំនួន១៣,៥១% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុប ក្នុងឆ្នាំ២០១១ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះ១.៧១៦,៨២ហិកតាតិចជាងឆ្នាំ២០១១) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ២,៦៣តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១១ចំនួន០,០៤តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៣៣.៣៨៤,៤៦តោន (ថយចុះ៥.១០៩,៤៦តោនទាបជាងឆ្នាំ២០១១ ឬប្រមាណជា១៥,៣០%បើធៀបនឹងឆ្នាំ២០១១)។ ក្នុងឆ្នាំ២០១៣ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន ១៦.១៧៣ហិកតា (កើនឡើង១.៩៩២ហិកតា គិតជាភាគរយកើនឡើង១៤,០៤% បើធៀបនឹងឆ្នាំ២០១២) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន៨៣,៩៥% (ស្មើនឹង១៣.៥៧៧,២៣ហិកតា មានការថយចុះចំនួន៥,៦% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១២ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង៨៧៨,១៥ហិកតាច្រើនជាងឆ្នាំ២០១២) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,៣៩តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១២ ចំនួន០,២៤តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៣២.៣៨៥,៩៣តោន (ថយចុះ៩៩៨,៥៣តោនទាបជាងឆ្នាំ២០១២ ឬប្រមាណជា៣,០៨% បើធៀបនឹងឆ្នាំ២០១២)។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៦.១៧៣ហិកតា (ដូចគ្នានឹងឆ្នាំ២០១៣) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន ៧៩,៨២% (ស្មើនឹង១២.៩០៩,២៨ហិកតា មានការថយចុះចំនួន៥,១៧% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៣ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះ៦៦៧,៩៤ហិកតាតិចជាងឆ្នាំ២០១៣) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,៣៩តោនក្នុង១ហិកតា (ដូចគ្នានឹងឆ្នាំ២០១៣) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៣០.៩០៧,៤៨តោន (ថយចុះ១.៤៧៨,៤៥តោនទាបជាងឆ្នាំ២០១៣ ឬប្រមាណជា៤,៧៨%បើធៀបនឹងឆ្នាំ២០១៣)[២០]។ ក្នុងឆ្នាំ២០១៥ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៨.០៣៩ហិកតា (កើនឡើង១.៨៦៦ហិកតា គិតជាភាគរយកើនឡើង១១

[១៩] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២*» -ដ.ឯ.ម- ទំព័រ១៤

[២០] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*» -ដ.ឯ.ម- ទំព័រ១១

,៩៣% បើធៀបនឹងឆ្នាំ២០១៤) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ ស្តែងមាន៧៥,៨០% (ស្មើនឹង១៣.៦៧៣,៥៦ហិកតា មានការថយចុះចំនួន៥,១៧% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៤ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង៧៦៤,២៨ ហិកតាច្រើនជាងឆ្នាំ២០១៤) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ២,៣០តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៤ ចំនួន០,០៩តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៣១.៤៥៣,៩៨តោន (កើនឡើង៥៤៦,៥តោនច្រើនជាងឆ្នាំ២០១៤ ឬប្រមាណជា១,៧៦% បើធៀបនឹងឆ្នាំ២០១៤)[២១]។ ក្នុងឆ្នាំ២០១៦ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៩.០១០ហិកតា (កើនឡើង៩៧១ហិកតា គិតជាភាគរយកើនឡើង៥,៣៨% បើធៀបនឹងឆ្នាំ២០១៥) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន៧៣,៩២% (ស្មើនឹង១៤.០៥២,១៩ហិកតា មានការថយចុះចំនួន១,៨៨% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៥ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង៣៧៨,៦៣ ហិកតាច្រើនជាងឆ្នាំ២០១៥) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ២,៤៣តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៥ ចំនួន០,១៣តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៣៤.១៦៣,៩៣តោន (កើនឡើង២.៧០៩,៩៥តោនច្រើនជាងឆ្នាំ២០១៥ ឬប្រមាណជា៨,៦១% បើធៀបនឹងឆ្នាំ២០១៥)។ ក្នុងឆ្នាំ២០១៧ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៩.០១០ហិកតា (ដូចគ្នានឹងឆ្នាំ២០១៦) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះ ស្រូវជាក់ស្តែងមាន៧៤,៣៧% (ស្មើនឹង១៤.១៣៧,៧៣ហិកតា មានការកើនឡើងចំនួន០,៤៥% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៦ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង៨៥,៥៤ហិកតា ច្រើនជាងឆ្នាំ២០១៦) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ២,៩៦តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៦ចំនួន ០,៥៣តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៤១.៨០៥,០៨តោន (កើនឡើង៧.៦១៤,១៥តោនច្រើនជាងឆ្នាំ២០១៦ ឬប្រមាណជា២២,៣៦% បើធៀបនឹងឆ្នាំ២០១៦)។ ក្នុងឆ្នាំ២០១៨ ផ្ទៃដីសម្រាប់ដាំដុះស្រូវប្រាំងសរុបមាន១៥.៧៩៧ហិកតា (ថយចុះ៣.២១៣ហិកតា គិតជាភាគរយថយចុះ២០,៣៣% បើធៀបនឹងឆ្នាំ២០១៧) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន៩០,៩០% (ស្មើនឹង១៤.៣៥៩,៤៧ហិកតា មានការកើនឡើងចំនួន១៦,៥៣% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៧ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង២២១,៧៤ហិកតា ច្រើនជាងឆ្នាំ២០១៧) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ៣,០៥តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៧ ចំនួន០,០៩តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៤៣.៧៨៣,៥៥តោន (កើនឡើង១.៩៧៨,៤៧តោនច្រើនជាងឆ្នាំ២០១៧ ឬប្រមាណជា៤,៧៣% បើធៀបនឹងឆ្នាំ២០១៧)[២២]។ ជារួម ស្រូវប្រាំងនេះជាមធ្យមទទួលផលបាន ៣៥.៥៤៣តោន ក្នុងមួយឆ្នាំ បាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន

[២១] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦*» -ដ.ឯ.ម- ទំព័រ១១

[២២] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩*» -ដ.ឯ.ម- ទំព័រ១១

៣២.៤៩៣.៧៨៦.៥២២រៀល ឬស្មើនឹង ៨.០៤៨.៩៩៣,៤៤ដុល្លារអាម៉េរិក[២៣] ក្នុងមួយឆ្នាំសម្រាប់ខេត្តក្រចេះ[២៤]។

### ២.២-ស្រូវវស្សា

ក្នុងឆ្នាំ២០០៩ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៣២.២១៤ហិកតា ក្នុងនោះបើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវវស្សាជាក់ស្តែងមាន៩៤,៩៥% (ស្មើនឹង៣០.៥៨៧,១៩ហិកតា) ទិន្នផលស្រូវវស្សាដែលទទួលបានជាមធ្យមគឺ២,០៣តោនក្នុង១ហិកតា ដោយបរិមាណផលស្រូវវស្សាសរុបដែលទទួលបានគឺ៦១.៩៩៤,៥១តោន។ ក្នុងឆ្នាំ២០១០ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៣៣.៤៥៣ហិកតា (មានការកើនឡើង១.២៣៩ហិកតា គិតជាភាគរយកំណើនស្មើនឹង៣,៨៤% បើធៀបនឹងឆ្នាំ២០០៩) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែង មាន៩២,៦៤% (ស្មើនឹង៣០.៩៩០,៨៥ហិកតា) មានការថយចុះចំនួន២,៣១% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០០៩ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ មានការកើនឡើង៤០៣,៦៦ហិកតា ច្រើនជាងឆ្នាំ២០០៩) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,០៥តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០០៩ចំនួន០,០២តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៦៣.៤២៩,៤២តោន (កើនឡើង១.៤៣៤,៩១តោន ខ្ពស់ជាងឆ្នាំ២០០៩ ឬប្រមាណជា២,៣១%ធៀបនឹងឆ្នាំ២០០៩)។ ក្នុងឆ្នាំ២០១១ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៣៦.៩៩៦ហិកតា (មានការកើនឡើង៣.៥៤៣ហិកតា គិតជាភាគរយកើនឡើង១០,៥៩% ធៀបនឹងឆ្នាំ២០១០) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវវស្សាជាក់ស្តែងគឺមាន ៩៥,៤៧% (ស្មើនឹង៣៥.៣២០,០៨ហិកតា មានការកើនឡើងចំនួន១៣,៩៦% ធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុប ក្នុងឆ្នាំ២០១០ ហើយបើគិតជាចំនួនហិកតាវិញ គឺកើនឡើង៤.៣២៩,២៣ហិកតាច្រើនជាងឆ្នាំ២០១០) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,១៨តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១០ ចំនួន០,១៣តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៧៦៩០៣,០០តោន (កើនឡើង១៣.៤៧៣តោនខ្ពស់ជាងឆ្នាំ២០១០ ឬប្រមាណជា២១,២៤% បើធៀបនឹងឆ្នាំ២០១០)[២៥]។ ក្នុងឆ្នាំ២០១២ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៣៥.១៧៩ហិកតា (ថយចុះ១.៨១៧ហិកតា គិតជាភាគរយថយចុះ៥,១៦% ធៀបនឹងឆ្នាំ២០១១) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន ៩៧,១២% (ស្មើនឹង៣៤.១៦៥,៨៤ហិកតា មានការកើនឡើងចំនួន១,៦៥% ធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១១ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះចំនួន១.១៥៤,២៣ហិកតា តិចជាងឆ្នាំ២០១១) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,២១តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបាន

[២៣] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» ដែលចេញផ្សាយដោយនាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន, ក្រសួងពាណិជ្ជកម្ម។

[២៤] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» ការផ្សាយរបស់មន្ទីរផែនការខេត្តក្រចេះ, ឆ្នាំ២០១២, ២០១៥, ២០១៦ និង ឆ្នាំ២០១៨, ទំព័រ១៤, ទំព័រ១១, ទំព័រ១១ និង ទំព័រ១១

[២៥] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២*» -ដ.ឯ.ម- ទំព័រ១៤

ជាមធ្យម ឆ្នាំ២០១១ ចំនួន០,០៣តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៧៥.៥៥៣,៧៣តោន (ថយចុះ១.៣៤៩,២៧តោនទាបជាងឆ្នាំ២០១១ ឬប្រមាណ១,៧៨% ធៀបនឹងឆ្នាំ២០១១)។ ក្នុងឆ្នាំ២០១៣ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៤០.៩៨៦ហិកតា (កើនឡើង៥.៨០៧ហិកតា គិតជាភាគរយកើនឡើង១៦,៥០% បើធៀបនឹងឆ្នាំ២០១២) ក្នុងនោះបើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន ៧៨,៣៦% (ស្មើនឹង៣២.១១៦,៦២ហិកតា មានការថយចុះចំនួន១៨,៧៦% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១២ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះ២.០៤៩ហិកតាតិចជាងឆ្នាំ២០១២) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,១៣តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១២ ចំនួន០,០៨តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៦៨.៤៤៩,៥៨តោន (ថយចុះ៧.១០៤,១៥តោនទាបជាងឆ្នាំ២០១២ ឬប្រមាណជា១០,៣៧% បើធៀបនឹងឆ្នាំ២០១២)។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៤១.៤៨៣ហិកតា (កើនឡើង៤៩៧ហិកតា គិតជាភាគរយកើនឡើង១,២១% បើធៀបនឹងឆ្នាំ២០១៣) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន ៧១,២០% (ស្មើនឹង២៩.៥៣៥,៨៩ហិកតា មានការថយចុះចំនួន ៧,១៦% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៣ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះ២.៥៨០,៧២ហិកតាតិចជាងឆ្នាំ២០១៣) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,០៨តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៣ ចំនួន០,០៥តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៦១.៤០៤,៩៦តោន (ថយចុះ ៧.០៤៤,៦២តោនទាបជាងឆ្នាំ២០១៣ ឬប្រមាណជា១១,៤៧% បើធៀបនឹងឆ្នាំ២០១៣)[២៦]។ ក្នុងឆ្នាំ២០១៥ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៤១.៣៤៨ហិកតា (ថយចុះ១៣៥ហិកតា គិតជាភាគរយថយចុះ០,៣២% បើធៀបនឹងឆ្នាំ២០១៤) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន៨០,៧២% (ស្មើនឹង៣៣.៣៧៦,១០ហិកតា កើនឡើងចំនួន៩,៥២% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៤ ប៉ុន្តែបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង៣.៨៤០ហិកតាច្រើនជាងឆ្នាំ២០១៤) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ១,៩៦តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៤ចំនួន ០,១២តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៦៥.៣៩៥,៧១តោន (កើនឡើង៣.៩៩០,៧៥តោនច្រើនជាងឆ្នាំ២០១៤ ឬប្រមាណជា៦,៤៩% បើធៀបនឹងឆ្នាំ២០១៤)[២៧]។ ក្នុងឆ្នាំ២០១៦ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៣៩.០១៧ហិកតា (ថយចុះ២.៣៣១ហិកតា គិតជាភាគរយកើនឡើង៥,៩៧% បើធៀបនឹងឆ្នាំ២០១៥) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវជាក់ស្តែងមាន៨២,៥៣% (ស្មើនឹង៣២.២០០,៧៣ហិកតា មានការថយចុះចំនួន១,៨១% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៥ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះចំនួន១.១៧៥,៣៧ហិកតាតិចជាងឆ្នាំ២០១៥) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,១៦តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៥ចំនួន០,២តោនក្នុង១ហិកតា)

---

[២៦] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*» -ដ.ឯ.ម- ទំព័រ១១

[២៧] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦* » -ដ.ឯ.ម- ទំព័រ១១

ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៦៩.៤៨៧,២៩តោន (កើនឡើង៤.០៩១,៥៨តោន ច្រើនជាងឆ្នាំ២០១៥ ឬប្រមាណជា៦,២៥% បើធៀបនឹងឆ្នាំ២០១៥)។ ក្នុងឆ្នាំ២០១៧ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៣៩.១៣៤ហិកតា (កើនឡើង១១៧ហិកតា គិតជាភាគរយកើនឡើង ០,២៩% បើធៀបនឹងឆ្នាំ២០១៦) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះ ស្រូវដាក់ស្តែងមាន៧៩,៥១% (ស្មើនឹង៣១.១១៥,៤៤ហិកតា មានការថយចុះចំនួន៣,០២% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៦ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការថយចុះ១.០៨៥,២៩ហិកតា តិចជាងឆ្នាំ២០១៦) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,៧៩តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៦ចំនួន ០,៦៣តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៨៦.៧៥៨,០៤តោន (កើនឡើង១៧.២៧០,៧៥តោនច្រើនជាងឆ្នាំ២០១៦ ឬប្រមាណជា២៤,៨៥% បើធៀបនឹងឆ្នាំ២០១៦)។ ក្នុងឆ្នាំ២០១៨ ផ្ទៃដីសម្រាប់ដាំដុះស្រូវវស្សាសរុបមាន៤៤.៣៣១ហិកតា (កើនឡើង៥.១៩៧ហិកតា គិតជាភាគរយកើន១៣,២៨% បើធៀបនឹងឆ្នាំ២០១៧) ក្នុងនោះ បើគិតជាភាគរយនៃផ្ទៃដីដែលបានដាំដុះស្រូវដាក់ស្តែងមាន៨១,៧២% (ស្មើនឹង៣៦.២២៧,២៩ហិកតា មានការកើនឡើងចំនួន២,២១% បើធៀបនឹងភាគរយនៃផ្ទៃដីដែលបានដាំសរុបក្នុងឆ្នាំ២០១៧ ហើយបើគិតជាចំនួនហិកតាវិញ គឺមានការកើនឡើង៥.១១១,៨៥ហិកតា ច្រើនជាងឆ្នាំ២០១៧) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ២,១៩តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៧ ចំនួន០,៦តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៧៩.៣៣២,០៦តោន (ថយចុះ៧.៤២៥,៩៨តោនទាបជាងឆ្នាំ២០១៧ ឬប្រមាណជា៩,៣៦% បើធៀបនឹងឆ្នាំ២០១៧)[២៨]។ ជារួម ស្រូវវស្សានេះជាមធ្យមទទួលផលបាន៧០.៨៧០,៤តោនក្នុងមួយឆ្នាំ បាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ៦៤.៧៨៩.០១០,៩៧៦ រៀល ឬស្មើនឹង១៦.០៤៨.៨០១,៣៣ដុល្លារអាម៉េរិក[២៩] ក្នុងមួយឆ្នាំសម្រាប់ខេត្តក្រចេះ[៣០]។

## ២.៣-ស្រូវបង្កើនរដូវ

ក្នុងឆ្នាំ២០០៩ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន១៦៣ហិកតា ទិន្នផលស្រូវបង្កើនរដូវដែលទទួលបានជាមធ្យមគឺ៥,២៩តោនក្នុង១ហិកតា បរិមាណផលស្រូវបង្កើនរដូវសរុបដែលទទួលបានគឺ៣៦៦,៩៦តោន។ ក្នុងឆ្នាំ២០១០ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន២៣០ហិកតា (មានការកើនឡើង៦៧ហិកតា គិតជាភាគរយកំណើនស្មើនឹង៤១,១០% បើធៀបនឹងឆ្នាំ២០០៩) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ៥,១០តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០០៩ ចំនួន០,១៩តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៦២៧,៥០តោន (កើនឡើង២៦០,៥៤តោនខ្ពស់ជាងឆ្នាំ២០០៩ ឬប្រមាណជា៧០,៩៩%បើធៀប

---

[២៨] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩*» -ដ.ឯ.ម- ទំព័រ១១

[២៩] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៣០] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៤, ទំព័រ១១, ទំព័រ១១ និង ទំព័រ១១

នឹងឆ្នាំ២០០៩)។ ក្នុងឆ្នាំ២០១១ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន១.១៨០ហិកតា (មានការកើនឡើង៩៥០ហិកតា គិតជាភាគរយកើនឡើង៤១៣,០៤% បើធៀបនឹងឆ្នាំ២០១០) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ៤,៥០តោន ក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១០ចំនួន០,៦តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុប ដែលទទួលបានគឺ ២.៦៥៥តោន (កើនឡើង២.០២៧,៥តោនខ្ពស់ជាងឆ្នាំ២០១០ ឬប្រមាណជា៣២៣,១០% បើធៀបនឹងឆ្នាំ២០១០)[៣១]។ ក្នុងឆ្នាំ២០១២ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន១.២៨១ហិកតា (កើនឡើង១០១ហិកតា គិតជាភាគរយកើនឡើង៨,៥៥% បើធៀបនឹងឆ្នាំ២០១១) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ៥,០៤តោន ក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១១ចំនួន ០,៥៤តោន ក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ២.៧៧៣,៧៣តោន (កើនឡើង ១១៨,៧៣តោន ច្រើនជាងឆ្នាំ២០១១ ឬប្រមាណ ៤,៤៧% បើធៀបនឹងឆ្នាំ២០១១)។ ក្នុងឆ្នាំ២០១៣ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន១.៤៨៧ហិកតា (កើនឡើង២០៦ហិកតា គិតជាភាគរយកើនឡើង១៦,០៨% បើធៀបនឹងឆ្នាំ២០១២) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ៥,០៤តោនក្នុង១ហិកតា (ដូចគ្នានឹងឆ្នាំ២០១២) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៣.៦១៩,៩៧តោន (កើនឡើង៨៤៦,២៤តោនច្រើនជាងឆ្នាំ២០១២ ឬប្រមាណជា៣០,៥០% បើធៀបនឹងឆ្នាំ២០១២)។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន៣០៤ហិកតា (ថយចុះ១.១៨៣ហិកតា គិតជាភាគរយថយចុះ៣៨៩,១៤% បើធៀបនឹងឆ្នាំ២០១៣) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ៩,៣៣តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៣ចំនួន៤,២៩តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៨៧០,១៧តោន (ថយចុះ២.៧៤៩,៨តោនទាបជាងឆ្នាំ២០១៣ ឬប្រមាណជា៣១៦% បើធៀបនឹងឆ្នាំ២០១៣)[៣២]។ ក្នុងឆ្នាំ២០១៥ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន២៧៦ហិកតា (ថយចុះ២៨ហិកតា គិតជាភាគរយថយចុះ១០,១៤% បើធៀបនឹងឆ្នាំ២០១៤) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ៥,០៦តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យម ឆ្នាំ២០១៤ ចំនួន ៤,២៧តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៦៨៥,៩០តោន (ថយចុះ១៨៤,២៧តោនតិចជាងឆ្នាំ២០១៤ ឬប្រមាណជា២៦,៨៦% បើធៀបនឹងឆ្នាំ២០១៤)[៣៣]។ ក្នុងឆ្នាំ២០១៦ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន៣៥៨ហិកតា (កើនឡើង៨២ហិកតា គិតជាភាគរយកើនឡើង២៩,៧១% បើធៀបនឹងឆ្នាំ២០១៥) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ៤,២៥តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៥ ចំនួន០,៨១តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៨៥៧តោន (កើនឡើង១៧១,១តោនច្រើនជាងឆ្នាំ២០១៥ ឬប្រមាណជា២៤,៩៤% បើធៀបនឹងឆ្នាំ២០១៥)។ ក្នុងឆ្នាំ២០១៧ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន៧៧៥ហិកតា (កើនឡើង៤១៧ហិកតា គិតជាភាគរយកើនឡើង១១៦,៤៨% បើធៀបនឹងឆ្នាំ២០១៦) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ៤,៩៤តោន ក្នុង១

[៣១] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២*» -ដ.ឯ.ម- ទំព័រ១៤

[៣២] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*» -ដ.ឯ.ម- ទំព័រ១១

[៣៣] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦*» -ដ.ឯ.ម- ទំព័រ១១

ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៦ចំនួន ០,៦៣៩តោនក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ១.៨៤៣,០៧តោន (កើនឡើង៩៨៦,០៧តោនច្រើនជាងឆ្នាំ២០១៦ ឬប្រមាណជា១១៥,០៦% បើធៀបនឹងឆ្នាំ២០១៦)។ ក្នុងឆ្នាំ២០១៨ ផ្ទៃដីសម្រាប់ដាំដុះស្រូវបង្កើនរដូវសរុបមាន៣.០១៥ហិកតា (កើនឡើង២.២៤០ហិកតា គិតជាភាគរយកើនឡើង ២៨៩,០៣% បើធៀបនឹងឆ្នាំ២០១៧) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ៤,១០តោន ក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៧ចំនួន ០,៨៤តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៦.៣២២,៨៨តោន (កើនឡើង ៤.៤៧៩,៨១តោនខ្ពស់ជាងឆ្នាំ២០១៧ ឬប្រមាណជា២៤៣,០៦% បើធៀបនឹងឆ្នាំ២០១៧)[៣៤]។ ជារួម ស្រូវបង្កើនរដូវនេះជាមធ្យមទទួលផលបាន២.០៦១,៧តោនក្នុងមួយឆ្នាំ បាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន១.៨៨៤.៧៨៥.៥២៣រៀល ឬស្មើនឹង៤៦៧.៨៧៧,៧៦ដុល្លារអាម៉េរិក[៣៥] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៣៦]។

## ២.៤-ស្រូវចម្ការ

ក្នុងឆ្នាំ២០០៩ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន៣១៦ហិកតា ទិន្នផលស្រូវចម្ការដែលទទួលបានជាមធ្យមគឺ ១,៤៨តោន ក្នុង១ហិកតា បរិមាណផលស្រូវចម្ការសរុបដែលទទួលបានគឺ ៤៦៩,១៥តោន។ ក្នុងឆ្នាំ២០១០ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន៦៧៦ហិកតា (កើនឡើង ៣៦០ហិកតា គិតជាភាគរយកំណើនស្មើនឹង១១៣,៩២% បើធៀបនឹងឆ្នាំ២០០៩) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ១,៤១តោន ក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០០៩ចំនួន០,០៧តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៩៥០,៩១តោន (កើនឡើង ៤៨១,៧៦តោន ខ្ពស់ជាងឆ្នាំ២០០៩ ឬប្រមាណជា ១០២,៦៨% បើធៀបនឹងឆ្នាំ២០០៩)។ ក្នុងឆ្នាំ២០១១ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន៤៥៣ហិកតា (ថយចុះ២២៣ហិកតា គិតជាភាគរយថយចុះ ៤៩,២២% បើធៀបនឹងឆ្នាំ២០១០) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ១,៥៩តោន ក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១០ ចំនួន០,១៨តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៧២១,០៣តោន (ថយចុះ២២៩,៨៨តោនតិចជាងឆ្នាំ២០១០ ឬប្រមាណជា៣១,៨៨% បើធៀបនឹងឆ្នាំ២០១០)[៣៧]។ ក្នុងឆ្នាំ២០១២ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន១.៥៤៦ហិកតា (កើនឡើង១.០៩៣ហិកតា គិតជាភាគរយកើនឡើង២៤១,២៨% បើធៀបនឹងឆ្នាំ២០១១) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ១,៦២តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១១ ចំនួន០,០៣តោនក្នុង១ហិកតា) ដោយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ២.៥០៤,៥២តោន (កើនឡើង១.៧៨៣,៤៩តោន

---

[៣៤] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩*» -ដ.ឯ.ម- ទំព័រ១១

[៣៥] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៣៦] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ ២០១៩*» -ដ.ឯ.ម-, ទំព័រ១៤, ទំព័រ១១, ទំព័រ១១ និង ទំព័រ១១

[៣៧] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២*» -ដ.ឯ.ម- ទំព័រ១៤

ច្រើនជាងឆ្នាំ២០១១ ឬប្រមាណ២៤៧,៣៥%បើធៀបនឹងឆ្នាំ២០១១)។ ក្នុងឆ្នាំ២០១៣ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន១.៣២២ហិកតា (ថយចុះ២២៤ហិកតា គិតជាភាគរយកើនឡើង ១៦,៩៤% បើធៀបនឹងឆ្នាំ២០១២) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ៣,២៤តោនក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១២ ចំនួន១,៦២តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ៤.២៨៥,៤៨តោន (កើនឡើង ១.៧៨០,៩៦តោន ច្រើនជាងឆ្នាំ២០១២ ឬប្រមាណជា៧១,១០% បើធៀបនឹងឆ្នាំ២០១២)។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន៤១៣ហិកតា (ថយចុះ៩០៩ហិកតា គិតជាភាគរយថយចុះ ២២០,០៩% បើធៀបនឹងឆ្នាំ២០១៣) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ១,៧៣តោនក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៣ចំនួន ១,៥១តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ៧១៥តោន (ថយចុះ ៣.៥៧០,៤៨តោន ទាបជាងឆ្នាំ២០១៣ ឬប្រមាណជា៤៩៩,៣៦% បើធៀបនឹងឆ្នាំ២០១៣)[៣៨]។ ក្នុងឆ្នាំ២០១៥ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន៥៦៤ហិកតា (កើនឡើង ១៥១ហិកតា គិតជាភាគរយកើនឡើង ៣៦,៥៦% បើធៀបនឹងឆ្នាំ២០១៤) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ១,៨៣តោន ក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៤ចំនួន ០,១តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ ១.០៣៣,០៨តោន (កើនឡើង ៣១៨,០៨តោន ច្រើនជាងឆ្នាំ២០១៤ ឬប្រមាណជា៤៤,៤៨% បើធៀបនឹងឆ្នាំ២០១៤)[៣៩]។ ក្នុងឆ្នាំ២០១៦ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន ១.០៨២ហិកតា (កើនឡើង ៥១៨ហិកតា គិតជាភាគរយកើនឡើង ៩១,៨៤% បើធៀបនឹងឆ្នាំ២០១៥) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ១,៧៨តោន ក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៥ចំនួន ០,០៥តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ១.៩២៥,០៧តោន (កើនឡើង ៨៩១,៩៩តោន ច្រើនជាងឆ្នាំ២០១៥ ឬប្រមាណជា ៨៦,៣៤% បើធៀបនឹងឆ្នាំ២០១៥)។ ក្នុងឆ្នាំ២០១៧ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន ១.១៨២ហិកតា (កើនឡើង១០០ហិកតា គិតជាភាគរយកើនឡើង ៩,២៤% បើធៀបនឹងឆ្នាំ២០១៦) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ១,៧៧តោន ក្នុង១ហិកតា (ទាបជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៦ ចំនួន ០,០១តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបានគឺ២.០៩៤,៩០តោន (កើនឡើង ១៦៩,៨៣តោន ច្រើនជាងឆ្នាំ២០១៦ ឬប្រមាណជា ៨,៨២% បើធៀបនឹងឆ្នាំ ២០១៦)។ ក្នុងឆ្នាំ២០១៨ ផ្ទៃដីសម្រាប់ដាំដុះស្រូវចម្ការសរុបមាន ៤.២៦៥ហិកតា (កើនឡើង ៣.០៨៣ហិកតា គិតជាភាគរយកើនឡើង ២៦០,៨២% បើធៀបនឹងឆ្នាំ២០១៧) ទិន្នផលស្រូវដែលទទួលបានជាមធ្យមគឺ ២,៣៤តោន ក្នុង១ហិកតា (ខ្ពស់ជាងទិន្នផលដែលទទួលបានជាមធ្យមឆ្នាំ២០១៧ចំនួន ០,៥៧តោន ក្នុង១ហិកតា) ហើយបរិមាណផលស្រូវសរុបដែលទទួលបាន គឺ ៩.៩៥៨,៧៨តោន (កើនឡើង ៧.៨៦៣,៨៨តោន ខ្ពស់ជាងឆ្នាំ២០១៧ ឬប្រមាណជា ៣៧៥,៣៨% បើធៀបនឹងឆ្នាំ២០១៧)[៤០]។ ជារួម ស្រូវចម្ការនេះជាមធ្យមទទួលផលបាន២.៤៦៥,៧តោនក្នុងមួយឆ្នាំ

---

[៣៨] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*» -ដ.ឯ.ម- ទំព័រ១១

[៣៩] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦* » -ដ.ឯ.ម- ទំព័រ១១

[៤០] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩* » -ដ.ឯ.ម- ទំព័រ១១

បាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ២.២៥៣.៨៤៤.០២៦រៀល ឬស្មើនឹង ៥៥៨.២៩៦,៧៦ ដុល្លារអាមេរិក[៤១] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៤២]។

### ២.៥-ដំណាំរយៈពេលខ្លី

ដំណាំរយៈពេលខ្លីរួមមានដំណាំពោត, សណ្ដែកសៀង, សណ្ដែកបាយ, សណ្ដែកដី, ដំឡូងមី, ដំឡូងជ្វា និង ល្ងជាដើម។ ពីឆ្នាំ២០០៩ ដល់ ២០១៨ ផ្ទៃដីសម្រាប់ដាំពោតសរុបជាមធ្យមមាន ២.០១០ហិកតា ទិន្នផលពោតដែលទទួលបានជាមធ្យមគឺ ៣,៦០តោន ក្នុង១ហិកតា បរិមាណផលពោតជាមធ្យមដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ៧៤៧,៧៩២តោន ឬស្មើនឹង៧.៤៧៧,៩២ តោនក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ១៥.៤០៤.៥១៥.២០០រៀល[៤៣] ឬស្មើនឹង ៣.៨១៥.៨៣២,៣៥ដុល្លារអាមេរិក[៤៤] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៤៥]។ ផ្ទៃដីសម្រាប់ដាំសណ្ដែកសៀងសរុបជាមធ្យមមាន ២.២៣៩ហិកតា ទិន្នផលសណ្ដែកសៀងដែលទទួលបានជាមធ្យមគឺ ១,៩៨តោនក្នុង១ហិកតា បរិមាណផលសណ្ដែកសៀងជាមធ្យម ដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ៤០.៣២៥,៣៧តោន ឬស្មើនឹង ៤.០៣២,៥៣តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ១.៧៣៣.៩៨៧.៩០០រៀល[៤៦] ឬស្មើនឹង ៤២៩.៥២៣,៨៧ដុល្លារអាមេរិក[៤៧] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៤៨]។ ផ្ទៃដីសម្រាប់ដាំសណ្ដែកបាយសរុបជាមធ្យមមាន៣១៧,៥០ហិកតា ទិន្នផលសណ្ដែកបាយដែលទទួលបានជាមធ្យមគឺ ១,៩០តោន ក្នុង១ហិកតា បរិមាណផលសណ្ដែកបាយជាមធ្យមដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ១៧.៤០៩,៤៦តោន ឬស្មើនឹង ១.៧៤០,៩៤ តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន១១.៤២០.៥៦៦.៤០០រៀល[៤៩]

---

[៤១] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាមេរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៤២] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្ដីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៤, ទំព័រ១១, ទំព័រ១១ និង ទំព័រ១១

[៤៣] គណនាក្នុងសន្ទស្សន៍តម្លៃ២០៦០៛/១គីឡូក្រាម តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៤៤] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាមេរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៤៥] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្ដីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

[៤៦] គណនាក្នុងសន្ទស្សន៍តម្លៃ៤៣០០៛/១គីឡូក្រាម តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៤៧] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាមេរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៤៨] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្ដីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

[៤៩] គណនាក្នុងសន្ទស្សន៍តម្លៃ៦៥៦០៛/១គីឡូក្រាម តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

ឬស្មើនឹង ២.៨២៨.៩៧៣,៥៩ដុល្លារអាម៉េរិក[៥០] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៥១]។ ផ្ទៃដីសម្រាប់ដាំសណ្តែកដីសរុបជាមធ្យមមាន ៨០៨,១៦ហិកតា ទិន្នផលសណ្តែកដីដែលទទួលបានជាមធ្យមគឺ ១,៥៧តោនក្នុង១ហិកតា បរិមាណផលសណ្តែកដីជាមធ្យម ដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ៩.៥៣៦,៣៦តោន ឬស្មើនឹង៩៥៣,៦៣តោនក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន៧.៥៧១.៨២២.២០០រៀល[៥២] ឬស្មើនឹង១.៨៧៥.៦០៦,១៩ដុល្លារអាម៉េរិក[៥៣] ក្នុងមួយឆ្នាំសម្រាប់ខេត្តក្រចេះ[៥៤]។ ផ្ទៃដីសម្រាប់ដាំដំឡូងមីសរុបជាមធ្យមមាន ៣២.២៥៩,៨៣ហិកតា ទិន្នផលដំឡូងមីដែលទទួលបានជាមធ្យមគឺ ១០,៧៤តោន ក្នុង១ហិកតា បរិមាណផលដំឡូងមីជាមធ្យមដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ៤.៦៦៥.៧៤០,១៤តោន ឬស្មើនឹង ៤៦៦.៥៧៤តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ១៣៩.៩៧២.២០០.០០០រៀល[៥៥] ឬស្មើនឹង៣៤.៦៧២.៣៣០,៩៣ដុល្លារអាម៉េរិក[៥៦] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៥៧]។ ផ្ទៃដីសម្រាប់ដាំដំឡូងជ្វាសរុបជាមធ្យមមាន ១១៣,៦៦ហិកតា ទិន្នផលដំឡូងជ្វាដែលទទួលបានជាមធ្យមគឺ ៤,៦២តោនក្នុង១ហិកតា បរិមាណផលដំឡូងជ្វាជាមធ្យម ដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ៥.២១៧,៥៣តោន ឬស្មើនឹង ៥២១,៧៥តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន៧៨២.៦២៥.០០០រៀល[៥៨] ឬស្មើនឹង ១៩៣.៨៦៣,០១ដុល្លារអាម៉េរិក[៥៩] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៦០]។ ផ្ទៃដីសម្រាប់ដាំល្ងសរុបជាមធ្យមមាន ៨៧៣,៨៣ហិកតា ទិន្នផលល្ងដែលទទួលបានជាមធ្យមគឺ ១,២៥តោនក្នុង១ហិកតា បរិមាណផលល្ងជាមធ្យមដែលទទួលបានក្នុងរយៈពេល១០ឆ្នាំនេះគឺ ១១.៨២៣,១២តោន ឬស្មើនឹង ១.១៨២,៣១តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ច

---

[៥០] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៥១] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

[៥២] គណនាក្នុងសន្ទស្សន៍តម្លៃ៧៩៤០៛/១គីឡូក្រាម តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៥៣] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៥៤] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

[៥៥] គណនាក្នុងសន្ទស្សន៍តម្លៃ៣០០៛/១គីឡូក្រាម តាមតម្លៃដែលបានចុះផ្សាយនៅក្នុងគេហទំព័រ http://nokorwatnews.com/archives/358791, នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

[៥៦] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៥៧] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

[៥៨] គណនាក្នុងសន្ទស្សន៍តម្លៃ១៥០០៛/១គីឡូក្រាម តាមតម្លៃដែលបានចុះផ្សាយនៅក្នុងគេហទំព័រ http://chk-news.com/?p=15411, នៅថ្ងៃទី៣០ ខែកុម្ភៈ ឆ្នាំ២០១៨

[៥៩] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៖ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៦០] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

ជាមធ្យមចំនួន ១២.៩៣២.៤៨៦.០០០រៀល[៦១] ឬស្មើនឹង ៣.១០៤.៤០៥,៧៤ដុល្លារអាម៉េរិក[៦២] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៦៣]។

## ២.៦-ដំណាំរយៈពេលវែង

ដំណាំរយៈពេលខ្លីរួមមានអំពៅ, កៅស៊ូ, ម្រេច, ស្វាយចន្ទី និង ស្វាយ ជាដើម។ ពីឆ្នាំ២០១២ ដល់ ២០១៨ ទិន្នផលកៅស៊ូដែលទទួលបានជាមធ្យមក្នុងរយៈពេល៧ឆ្នាំនេះគឺ ៦.៨៤៧.២៦៤តោន ឬស្មើនឹង ៩៧៨.១៨០,៥៧តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ៥.១៣៣.៥៨៩.៤៥៦.៩១៤រៀល[៦៤] ឬស្មើនឹង ១.២៧១.៦៣៤.៧៤២,៨៥ដុល្លារអាម៉េរិក[៦៥] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ។ ទិន្នផលអំពៅដែលទទួលបានជាមធ្យមក្នុងរយៈពេល៧ឆ្នាំនេះគឺ ២៧.១១៣ តោន ឬស្មើនឹង ៣.៨៧៣,២៨តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ៤៦៩.០៩២.៩៤០,៨០រៀល[៦៦] ឬស្មើនឹង ១១៦.១៩៨,៤០ដុល្លារអាម៉េរិក[៦៧] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ។ ទិន្នផលម្រេចដែលទទួលបានជាមធ្យមក្នុងរយៈពេល៧ឆ្នាំនេះគឺ ១១៨.០០៥តោន ឬស្មើនឹង ១៦.៨៥៧,៨៥តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ៦៧៧.៦៨៥.៨៥៧,១៤រៀល[៦៨] ឬស្មើនឹង ១៦៧.៨៦៨.៦៧៩ដុល្លារអាម៉េរិក[៦៩] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ។ ទិន្នផលស្វាយចន្ទីដែលទទួលបានជាមធ្យមក្នុងរយៈពេល៧ឆ្នាំនេះគឺ ២.៨៦៥.០៨១តោន ឬស្មើនឹង ៤០៩.២៩៧,២៨តោន ក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ២.៤៥៥.៧៨៣.៧១៤.២៨៥,៧០រៀល[៧០] ឬស្មើនឹង ៦០៨.៣១៨.៩៧៨ដុល្លារអាម៉េរិក[៧១] ក្នុងមួយឆ្នាំ សម្រាប់

---

[៦១] គណនាក្នុងសន្ទស្សន៍តម្លៃ១០៦០០៛/១គីឡូក្រាម តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៦២] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៦៣] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១២, ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ ២០១៩*» -ដ.ឯ.ម-, ទំព័រ១៦, ទំព័រ១៣, ទំព័រ១៣ និង ទំព័រ១៤

[៦៤] គណនាក្នុងសន្ទស្សន៍តម្លៃ១៣០០$/១តោន តាមតម្លៃដែលបានចុះផ្សាយនៅក្នុងគេហទំព័រ https://cambonomist.com/news/rubber-export-increase-while-price-down-/ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨

[៦៥] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៦៦] គណនាក្នុងសន្ទស្សន៍តម្លៃ៣០$/១តោន តាមតម្លៃដែលបានចុះផ្សាយនៅក្នុងគេហទំព័រ https://www.rasmeinews.com/archives/134197 នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨

[៦៧] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៦៨] គណនាក្នុងសន្ទស្សន៍តម្លៃ៤០២០០៛/១គីឡូក្រាម តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៦៩] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៧០] គណនាក្នុងសន្ទស្សន៍តម្លៃ៦០០០៛/១គីឡូក្រាម តាមតម្លៃដែលបានចុះផ្សាយនៅក្នុងគេហទំព័រ https://www.rasmeinews.com/archives/32012 នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨

[៧១] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

ខេត្តក្រចេះ។ ទិន្នផលស្វាយដែលទទួលបានជាមធ្យមក្នុងរយៈពេល៧ឆ្នាំនេះគឺ ២៤.០៥១តោន ឬស្មើនឹង៣.៤៣៥,៨៥តោនក្នុង១ឆ្នាំ ដែលបាននាំមកនូវចំណូលសេដ្ឋកិច្ចជាមធ្យមចំនួន ៤.៣៩៧.៨៨៨.០០០រៀល[៧២] ឬស្មើនឹង ១.០៨៩.៣៩៥ដុល្លារអាម៉េរិក[៧៣] ក្នុងមួយឆ្នាំ សម្រាប់ខេត្តក្រចេះ[៧៤]។

## ២.៧-ការចិញ្ចឹមសត្វ

សត្វចិញ្ចឹមដែលបងប្អូនប្រជាពលរដ្ឋក្នុងខេត្តក្រចេះនិយមចិញ្ចឹមរួមមាន គោ, ក្របី, ជ្រូក, មាន់, ទា, ពពែ និង ត្រីជាដើម។ តាមតួលេខពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៨បានបង្ហាញថា ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមគោនៅ ក្នុងឆ្នាំ២០១២មានចំនួន ២០.៩០៦.៤០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន ១៧.៩៦៦.៨០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ១៦.៧៥១.៨០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ១៦.៦៨៥.៨០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ១៦.៤៤០.០០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ១៦.៩១០.២០០ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន ១៧.២០៥.៤០០ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមគោនេះទទួលបាន ១៧.៥៥២.៣៤២,៨៥ដុល្លារអាម៉េរិក សម្រាប់ខេត្តក្រចេះ។ ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមក្របីនៅក្នុងឆ្នាំ២០១២មាន ៦.៥៩៤.៦០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន៦.៣៥៧.៦០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ៥.៣៣១.២០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ៤.៨៨៩.២០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ៤.៦៩៩.០០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ៤.៤៩៥.៤០០ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន ៤.២១០.២០០ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមក្របីនេះ ទទួលបាន ៥.២២៥.៣១៤,២៨ដុល្លារអាម៉េរិក សម្រាប់ខេត្តក្រចេះ។ ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមជ្រូកនៅក្នុងឆ្នាំ២០១២មាន ១.៥១៨.២៥០ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន១.៥៣៨.៥៥០ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ១.៤៩០.៥០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ១.៤៦៤.១០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ១.៥២២.៦០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ១.៣៥៥.៥៥០ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន ១.២៥០.០០០ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមជ្រូកនេះទទួលបាន ១.៤៤៨.៥០៧,១៤ដុល្លារអាម៉េរិក សម្រាប់ខេត្តក្រចេះ។ ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមមាន់នៅក្នុងឆ្នាំ២០១២មាន ១.១១៤.១៣៦ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន ១.១០៦.៥៧២ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ១.២៤៤.៧៣២ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ១.៤០៣.៧៩២ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ១.៤២៦.៨២៤ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ១.៥៤៣.៤៣២ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន ១.៨៦៤.៨៦០ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមមាន់នេះទទួលបាន ១.៣៨៦.៣៣៥,៤២ដុល្លារអាម៉េរិក

[៧២] គណនាក្នុងសន្មតស្សន៍តម្លៃ១២៨០៛/១គីឡូក្រាម (ដោយយកតម្លៃ៦០០៛+១២០០៛+១៤០០៛+១៥០០៛+១៧០០៛បូកចូលគ្នារួចចែកយកមធ្យមភាគ) តាមតម្លៃដែលបានចុះផ្សាយនៅក្នុងគេហទំព័រ https://cambonomist.com/news/cambodia-mangoes-price-hikes-2019/ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨

[៧៣] គណនាក្នុងអាត្រាប្តូរប្រាក់ ១ដុល្លារអាម៉េរិក = ៤០៣៧៛ តាម «*របាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧*» -ដ.ឯ.ម-

[៧៤] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩*» -ដ.ឯ.ម-, ទំព័រ១៤, ទំព័រ១៤ និង ទំព័រ១៥

សម្រាប់ខេត្តក្រចេះ។ ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមទានៅក្នុងឆ្នាំ២០១២មាន ៩៤.១៥២ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន ៨៦.៩៦៤ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ១១៨.២៩០ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ១០៥.២៥៥ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ១៤០.៤៩៩ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ១៦៦.៥៩៩ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន១៥៥.៥៧៧ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមទានេះទទួលបាន ១២៣.៩០៥,១៤ដុល្លារអាម៉េរិក សម្រាប់ខេត្តក្រចេះ។ ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមពពែនៅក្នុងឆ្នាំ២០១២មាន ៧.៣៥០ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន ៧០.៧០០ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ៣៩.៨៥០ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ១៧.៤៥០ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ១៨.៨៥០ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ៧៣.៤០០ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន ២០.៥៥០ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមពពែនេះទទួលបាន ៣៥.៤៥០ដុល្លារអាម៉េរិក សម្រាប់ខេត្តក្រចេះ និង ប្រាក់ចំណូលដែលទទួលបានពីការចិញ្ចឹមត្រី នៅក្នុងឆ្នាំ២០១២មាន ២៨០.២៣៣ដុល្លារអាម៉េរិក, ឆ្នាំ២០១៣ មាន ២៨០.៣៨៣ដុល្លារអាម៉េរិក, ឆ្នាំ២០១៤ មាន ៣២១.៣៦០ដុល្លារអាម៉េរិក, ឆ្នាំ២០១៥ មាន ១៣៥.៤៤៥ដុល្លារអាម៉េរិក, ឆ្នាំ២០១៦ មាន ២២៨.៥៦០ដុល្លារអាម៉េរិក, ឆ្នាំ២០១៧ មាន ២៣៦.០៧៣ដុល្លារអាម៉េរិក និង ឆ្នាំ២០១៨ មាន ២០៣.៥០០ដុល្លារអាម៉េរិក គិតជាមធ្យមក្នុង១ឆ្នាំ ចំណូលពីការចិញ្ចឹមត្រីនេះទទួលបាន ២៤០.៧៩៣,៤២ដុល្លារអាម៉េរិក សម្រាប់ខេត្តក្រចេះ[៧៥]។

ជាសរុបមក ការដាំដំណាំរយៈពេលខ្លីបានផ្តល់ចំណូលដល់ប្រជាពលរដ្ឋក្នុងខេត្តក្រចេះ ជាមធ្យមសម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០១២ ចំនួន៩២,៦ដុល្លារអាម៉េរិក, ក្នុងឆ្នាំ២០១៣ ចំនួន១២៨,៨ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង៣៩,០៩%, បើធៀបនឹងឆ្នាំ២០១២, ក្នុងឆ្នាំ២០១៤ ចំនួន១១០,៤០ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ១៤,២៨%, បើធៀបនឹងឆ្នាំ២០១៣[៧៦], ក្នុងឆ្នាំ២០១៥ ចំនួន១០៤,២ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ៥,៦១%, បើធៀបនឹងឆ្នាំ២០១៤[៧៧], ក្នុងឆ្នាំ២០១៦ ចំនួន១២៣,៤ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង១៨,៤២%, បើធៀបនឹងឆ្នាំ២០១៥, ក្នុងឆ្នាំ២០១៧ ចំនួន១៤២,២ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង១៥,២៣%, បើធៀបនឹងឆ្នាំ២០១៦, ក្នុងឆ្នាំ២០១៨ ចំនួន១០៦,៨ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ២៣,៤៨%, បើធៀបនឹងឆ្នាំ២០១៧[៧៨] បើគិតជាមធ្យមសម្រាប់រយៈពេល៧ឆ្នាំលើការដាំដំណាំរយៈពេលខ្លីនេះ គឺមានប្រមាណជា១១៥,៤៨ដុល្លារអាម៉េរិក សម្រាប់ប្រជាពលរដ្ឋខេត្តក្រចេះក្នុង១ឆ្នាំៗ។ ការដាំដំណាំរយៈពេលវែងបានផ្តល់ចំណូលដល់ប្រជាពលរដ្ឋក្នុងខេត្តក្រចេះ ជាមធ្យមសម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០១២ ចំនួន១០១,៤ដុល្លារអាម៉េរិក, ក្នុងឆ្នាំ២០១៣ ចំនួន១៧៩,៩ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង៧៧,៤១%, បើធៀបនឹងឆ្នាំ២០១២, ក្នុងឆ្នាំ២០១៤ ចំនួន១០០,៦ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ៤៤,០៨%, បើធៀបនឹងឆ្នាំ២០១៣[៧៩], ក្នុងឆ្នាំ២០១៥ ចំនួន១១៥ដុល្លារអាម៉េរិក

---

[៧៥] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥, ឆ្នាំ២០១៦ និង ឆ្នាំ២០១៩* » -ដ.ឯ.ម-, ទំព័រ១៤, ទំព័រ១៤ និង ទំព័រ១៥

[៧៦] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*»-ដ.ឯ.ម-, ទំព័រ១២

[៧៧] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦*»-ដ.ឯ.ម-, ទំព័រ១២

[៧៨] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩*»-ដ.ឯ.ម-, ទំព័រ១៣

[៧៩] មន្ទីរផែនការខេត្តក្រចេះ, «*ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥*»-ដ.ឯ.ម-, ទំព័រ១២

គិតជាភាគរយកើនឡើង១៤,៣១%, បើធៀបនឹងឆ្នាំ២០១៤[៩០], ក្នុងឆ្នាំ២០១៦ ចំនួន១២៣,៣ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង៧,២១%, បើធៀបនឹងឆ្នាំ២០១៥, ក្នុងឆ្នាំ២០១៧ ចំនួន២៨១,៣ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង១២៨,១៤%, បើធៀបនឹងឆ្នាំ២០១៦, ក្នុងឆ្នាំ២០១៨ ចំនួន២៨.៦១២,៤ដុល្លារអាម៉េរិក គិតជាភាគរយកើនឡើង១០.០៧១,៣៤%, បើធៀបនឹងឆ្នាំ២០១៧[៩១] បើគិតជាមធ្យមសម្រាប់រយៈពេល៧ឆ្នាំលើការដាំដំណាំរយៈពេលវែងនេះ គឺមានប្រមាណជា៤.២១៦,២៧ដុល្លារអាម៉េរិក សម្រាប់ប្រជាពលរដ្ឋខេត្តក្រចេះក្នុង១ឆ្នាំៗ។ ការចិញ្ចឹមសត្វ និង វារីវប្បកម្មបានផ្តល់ចំណូលដល់ប្រជាពលរដ្ឋក្នុងខេត្តក្រចេះ ជាមធ្យមសម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០១២ ចំនួន៨៥,២ដុល្លារអាម៉េរិក, ក្នុងឆ្នាំ២០១៣ ចំនួន៧៤,៤ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ១២,៦៧%, បើធៀបនឹងឆ្នាំ២០១២, ក្នុងឆ្នាំ២០១៤ ចំនួន៦៨,៦ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ៧,៧៩%, បើធៀបនឹងឆ្នាំ២០១៣[៩២], ក្នុងឆ្នាំ២០១៥ ចំនួន៦៦,៣ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ៣,៣៦%, បើធៀបនឹងឆ្នាំ២០១៤[៩៣], ក្នុងឆ្នាំ២០១៦ ចំនួន៦២,៤ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ៥,៨៨%, បើធៀបនឹងឆ្នាំ២០១៥, ក្នុងឆ្នាំ២០១៧ ចំនួន៦១,១ដុល្លារអាម៉េរិក គិតជាភាគរយថយចុះ២,០៨%, បើធៀបនឹងឆ្នាំ២០១៦, ក្នុងឆ្នាំ២០១៨ ចំនួន៦១,២ដុល្លារអាម៉េរិក ស្មើនឹងឆ្នាំ២០១៧[៩៤] បើគិតជាមធ្យមសម្រាប់រយៈពេល៧ឆ្នាំលើការចិញ្ចឹមសត្វ និង វារីវប្បកម្មនេះ គឺមានប្រមាណជា៦៨,៤៥ដុល្លារអាម៉េរិក សម្រាប់ប្រជាពលរដ្ឋខេត្តក្រចេះក្នុង១ឆ្នាំៗ។

***តារាងទី៨៖ ចំណូលពីការដំណាំរយៈពេលខ្លី វែង និង ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ឆ្នាំ២០១២-២០១៤***

| បរិយាយ | 2012 | 2013 | 2014 |
|---|---|---|---|
| សរុបចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីការដាំដំណាំខ្លី-វែង ការចិញ្ចឹមសត្វនិងវារីវប្បកម្ម (គិតជាដុល្លារអាម៉េរិក) | 279.2 | 383.1 | 279.6 |
| ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំរយៈពេលខ្លី (គិតជាដុល្លារអាម៉េរិក) | 92.6 | 128.8 | 110.4 |
| ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំរយៈពេលវែង (គិតជាដុល្លារអាម៉េរិក) | 101.4 | 179.9 | 100.6 |
| ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីការចិញ្ចឹមសត្វ វារីវប្បកម្ម (គិតជាដុល្លារអាម៉េរិក) | 85.2 | 74.4 | 68.6 |

*ប្រភព៖ ដកស្រង់ពីឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៥» របស់មន្ទីរផែនការខេត្តក្រចេះ ឆ្នាំ២០១៩ ទំព័រ១២*

[៩០] មន្ទីរផែនការខេត្តក្រចេះ, «***ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦***» -ដ.ឯ.ម-, ទំព័រ១២

[៩១] មន្ទីរផែនការខេត្តក្រចេះ, «***ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩***» -ដ.ឯ.ម-, ទំព័រ១៣

[៩២] មន្ទីរផែនការខេត្តក្រចេះ, «***ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៥***» -ដ.ឯ.ម-, ទំព័រ១២

[៩៣] មន្ទីរផែនការខេត្តក្រចេះ, «***ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៦***» -ដ.ឯ.ម-, ទំព័រ១២

[៩៤] មន្ទីរផែនការខេត្តក្រចេះ, «***ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចខេត្តក្រចេះ ឆ្នាំ២០១៩***» -ដ.ឯ.ម-, ទំព័រ១៣

*ឆ្នាំ២០១៥-២០១៨*

| បរិយាយ | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|
| សរុបចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីការដាំដំណាំខ្លី-វែង ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ( គិតជាដុល្លារអាម៉េរិក ) | 285.5 | 309.1 | 484.6 | 28,780.3 |
| ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំរយៈពេលខ្លី ( គិតជាដុល្លារអាម៉េរិក ) | 104.2 | 123.4 | 142.2 | 106.8 |
| ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំរយៈពេលវែង ( គិតជាដុល្លារអាម៉េរិក ) | 115.0 | 123.3 | 281.3 | 28,612.4 |
| ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីការចិញ្ចឹមសត្វវារីវប្បកម្ម ( គិតជាដុល្លារអាម៉េរិក ) | 66.3 | 62.4 | 61.1 | 61.2 |

*ប្រភព៖ ឯកសារព័ត៌មានស្ថានភាព ស្តីពី សេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៦ និង ឆ្នាំ២០១៩» របស់មន្ទីរផែនការខេត្តក្រចេះ ឆ្នាំ២០១៦, ២០១៩*

*ក្រាហ្វិកទី៤៖ ចំណែកនៃវិស័យកសិកម្មរបស់ខេត្តក្រចេះពីឆ្នាំ២០១១-២០១៧*




*ប្រភព៖ ឯកសារសេដ្ឋកិច្ចខេត្តក្រចេះឆ្នាំ២០១៧ ក្នុងអត្ថបទធ្វើបទបង្ហាញរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តក្រចេះ ឆ្នាំ២០១៧*

## សេចក្តីសន្និដ្ឋាន

ដូច្នេះតាមរយៈលទ្ធផលដែលបានលើកឡើងបង្ហាញខាងលើ គេអាចមើលឃើញថាវិស័យកសិកម្មគឺកម្លាំងចលករដ៏សំខាន់ជាងគេទី១ ចំពោះវឌ្ឍនភាពសេដ្ឋកិច្ចរបស់ខេត្តក្រចេះ ព្រោះវិស័យនេះ បាននាំប្រាក់ចំណូលប្រមាណជា ៩៧៨.៤១៨,៨លានរៀល (ប្រហែលជាង២៤២លានដុល្លារអាម៉េរិក) ឬស្មើនឹង ៥៤,៧% នៃសេដ្ឋកិច្ចខេត្ត មកចាក់បំពេញក្នុងអាងសេដ្ឋកិច្ចខេត្ត ព្រមទាំងបានផ្តល់ការងារដល់មនុស្សចំនួន១៥៧.៤៨៦នាក់ ឬស្មើនឹង ៨១% នៃចំនួនកម្លាំងពលកម្មសរុបទូទាំងខេត្ត ហើយរក្សាបាននូវកំណើនផ.ស.សរបស់ខេត្តលើវិស័យកសិកម្មនេះ ប្រមាណជា ៥,២% ខណៈដែលកំណើនផ.ស.ស.កម្ពុជាលើវិស័យកសិកម្មនេះ មានប្រមាណជា ១,៦% ក្នុងនោះ ការងារដាំដុះដំណាំបាននាំប្រាក់ចំណូលប្រមាណជា ៣៩,០៧%, ការងារចិញ្ចឹមសត្វបាននាំប្រាក់ចំណូលប្រមាណជា ៨,៦២%, ការងារជលផលនិងនេសាទ បាននាំប្រាក់ចំណូលប្រមាណជា ២៩,៤៧% និង ការងាររុក្ខាប្រម៉ាញ់បាននាំប្រាក់ចំណូលប្រមាណជា ២២,៨៣% នៃចំណូលសរុបពីវិស័យកសិកម្ម។

# ការសិក្សាពីសំណេរពាក្យកម្លាយនៃភាសាខ្មែរទំនើប
# ក្នុងក្របខ័ណ្ឌ *សំរាយតំរួត*
# "ការវិភាគពីគោលការណ៍អាស្រ័យឫស"

*បេក្ខជនបណ្ឌិតៈ* ***ផល សុភឿន***
*ជំនាញៈ* ***ភាសាវិទ្យា***
*គ្រូណែនាំៈ* ***បណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ***

## ១- សេចក្តីផ្តើម

តាំងពីបរមបុរាណមក ការសរសេរពាក្យក្នុងភាសាខ្មែរជារាយព្យាង្គឬជាតំរួតព្យាង្គ បានកើតមានឡើងជាហូរហែ ដោយភាគច្រើនពាក្យកម្លាយតាមរយៈផ្នត់ដែលមានសូរអេ'ម[1] រមែងតែងតែមានសំណេរជារាយព្យាង្គដូចមានជាភស្តុតាងនៅក្នុងសិលាចារឹក[2] សាស្ត្រាស្លឹករឹត សៀវភៅ និងឯកសារបោះពុម្ពផ្សាយជាលាយលក្ខណ៍អក្សរស្រាប់។

ប៉ុន្តែ ចាប់ពីឆ្នាំ២០០៣មក មាននិន្នាការទៅរកការសរសេរពាក្យកម្លាយជារាយព្យាង្គឬជាតំរួតព្យាង្គ ដោយប្រកាន់តាមសំណេរនៃឫស។ ប្រការនេះបណ្តាលមកពីគេបានឃើញការណែនាំដែលមាននៅខាងដើមនៃវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបង្កើតបានជាគោលការណ៍មួយឡើងសម្រាប់ការសរសេរពាក្យកម្លាយនានា នៅក្នុងភាសាខ្មែរ។ គោលការណ៍នោះត្រូវបានលោកគ្រូបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ ហៅថា *គោលការណ៍ជួន ណាត* ឬ *គោលការណ៍អាស្រ័យឫស*[3] ។ ស្នេរនៃនិក្ខេបបទនេះមិនមានចិត្តអគតិក្នុងលក្ខណៈជាបុគ្គលឬមិនមានបំណងបដិសេធលើគោលការណ៍នេះទេ តែជាការសិក្សានិងជាការឆ្លុះបញ្ចាំងពីអប្រក្រតីភាពនិងភាពមានចន្លោះប្រហោង នៃគោលការណ៍នេះតែប៉ុណ្ណោះ។

## ២- គោលការណ៍អាស្រ័យឫស

ជាការពិតណាស់ ដោយផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងនិទាននៃវចនានុក្រម ឫសជាប្រភពនៃការកំណត់សំណេរនៃពាក្យកម្លាយ។

គោលការណ៍អាស្រ័យឫសបានចែងថា ពាក្យដែលកើតចេញពីឫសមានសំណេររាយត្រូវសរសេររាយដែរ។ ឧទាហរណ៍ *ដំណើរ កំណើត ទំនាប ចំណូល* មានសំណេរជា

[1] ច័ន្ទ សំណព្វ ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំ.១០៥។
[2] វង់ សុធារ៉ា ***សិលាចារឹកនៃប្រទេសកម្ពុជា សម័យកណ្តាល*** គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត ភ្នំពេញ ឆ្នាំ២០១២ ទំ. ២៥២។ (ពាក្យ សំតេច ដែលមាននៅក្នុងសិលាចារឹកវត្តនគរបាជ័យ ខេត្តកំពង់ចាម (K82B)។
[3] ច័ន្ទ សំណព្វ ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំ.១០៣។

រាយព្យាង្គបែបនេះដោយសារតែវាជាពាក្យកម្លាយរៀងគ្នាចេញមកពីឫស *ដើរ កើត ទាប ចូល* ដែលមានសំណេរជាព្យាង្គរាយ។

ផ្ទុយទៅវិញ ពាក្យ *ចម្ការ ចម្រើន កម្លាំង បម្រុង* ត្រូវសរសេរជាគ្រួតបែបនេះពីព្រោះវាជាពាក្យកម្លាយចេញមកពីឫស *ថ្ការ ច្រើន ខ្លាំង ប្រុង* ដែលមានសំណេរជាព្យាង្គតំរួត[4]។

គោលការណ៍អាស្រ័យឫសនេះជាវិធានខ្លី ងាយស្រួលចងចាំ មើលហើយហាក់ដូចជាសមហេតុសមផលដែរ ដោយសារតែការផ្ដល់ឧទាហរណ៍ដ៏ចង្អៀតនេះនិងមានលក្ខណៈសម្រិតសម្រាំងដោយផ្ដោតទៅលើតែឧទាហរណ៍ណាដែលបង្ហាញចំៗទៅលើគោលការណ៍នេះ។

ជាក់ស្ដែង ការផ្ដល់ឧទាហរណ៍ថា *កំណើត ដំណើរ ចំណាយ ដំហាន* ជាពាក្យកម្លាយដែលត្រូវសរសេរជារាយព្យាង្គបែបនេះ ដោយសារតែពាក្យទាំងនេះត្រូវបានកម្លាយចេញរៀងគ្នាពីឫស *កើត ដើរ ចាយ ឈាន* ដែលមានសំណេរជាព្យាង្គរាយនោះ អាចឱ្យមនុស្សសាមញ្ញទូទៅឬអ្នកអក្សរសាស្ត្រខ្លះជឿតាមបានដោយមិនចាំបាច់ពិចារណា។

ប៉ុន្តែ សម្រាប់ អ្នកអក្សរសាស្ត្រដែលមានជំនាញពិតប្រាកដវិញនោះ គោលការណ៍នេះមិនមានសុក្រឹតភាពទេ ហើយការកំណត់សំណេរនៃពាក្យកម្លាយដោយអនុលោមតាមសំណេរនៃឫស ក៏ចោទជាបញ្ហាចម្រូងចម្រាស់ពេកណាស់។

## ៣- ការវិភាគជាប្រព័ន្ធទៅលើនិដ្ឋភាពនៃគោលការណ៍អាស្រ័យឫស

ប្រឈមទៅនឹងគោលការណ៍អាស្រ័យឫសដែលបានបង្ហាញជូនខាងលើ លោកបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ បានសង្កេតឃើញមានអតក្កភាពជាច្រើនដែលកើតឡើងដោយលោកបានសិក្សាវិភាគនៅក្នុងសៀវភៅ សំណេរនិងអក្ខរាវិរុទ្ធខ្មែរ[5]។ ជាក់ស្ដែង ពាក្យ *កើត* ដែលគេបានសន្មតថាជាពាក្យដែលសរសេរដោយគ្មានការគ្រួតអក្សរ[6] លុះពេលកម្លាយទៅបានជាពាក្យ *ខ្នើត បង្កើត* ដែលមិនសរសេរជារាយព្យាង្គដូចគោលការណ៍អាស្រ័យឫសចែងមកទេ។

គេមិនអាចសំអាងតែទៅលើពាក្យកម្លាយ *កំណើត* ដែលសរសេររាយព្យាង្គ ដើម្បីកំណត់សំណេរពាក្យទាំងអស់បានឡើយ ដោយសារតែមានពាក្យកម្លាយផ្សេងទៀតដែលកើតចេញពីឫស *កើត* ដែលនោះ មានសំណេរជាព្យាង្គតំរួត ជាអាទិ៍ *ខ្នើត* និងជាតំរួតព្យាង្គដូចជា *បង្កើត* ជាដើម។

---

[4] ជួន ណាត ***វចនានុក្រមខ្មែរ*** និទាន ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧។

[5] ច័ន្ទ សំណព្វ ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០០៨ ទំ.១០៧។

[6] ច័ន្ទ សំណព្វ ***អក្សរ ព្យាង្គ ពាក្យ*** រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០១២ ទំ.២១។

សូមបញ្ជាក់ថា ពាក្យដែលមានសំណេរផ្ទុយពីវិធានដែលគោលការណ៍អាស្រ័យឫសចែងមកបែបនេះ ពោលគឺអតក្កភាពទីមួយនៃគោលការណ៍អាស្រ័យឫសនេះ មានច្រើនណាស់ ជាអាទិ៍ *បញ្ចេញ បញ្ចូល បញ្ជាន់ បណ្ដេញ បណ្ដើរ បណ្ដូរ កញ្ចាស់ កង្វៀច ពង្រីក ពង្រឹង* ដែលសុទ្ធតែមានសំណេរជាតំរួតព្យាង្គ តែកម្លាយចេញពីពាក្យឫស *ចេញ ចូល ជាន់ ដេញ ដើរ ដូរ ចាស់ វៀច រីក រឹង* ដែលមានសំណេរជាព្យាង្គរាយ។

ប្រការនេះ ស្ដែងពីករណីដែលសំណេរនៃពាក្យកម្លាយមិនអនុលោមទៅតាមសំណេរនៃពាក្យឫស ហើយដែលផ្ទុយពីវិធាននៃគោលការណ៍អាស្រ័យឫស។ ដូច្នេះ វាជាករណីមួយដែលបង្ហាញថាគោលការណ៍នេះមិនមានសុក្រឹតភាពទេ ហើយក៏គ្មានសកលភាពដែលអាចយកទៅអនុវត្តចំពោះពាក្យកម្លាយផ្សេងៗទៀតបានទូទៅដែរ។

ទន្ទឹមនឹងនេះ អតក្កភាពទីពីរក៏កើតមានឡើងដែរចំពោះពាក្យកម្លាយចេញពីឫសដែលមានសំណេរជាព្យាង្គតំរួត។ ជាក់ស្ដែង *ចំពោះ សំណើ សំណាក់ គគ្រឹក សស្រាក់សស្រាំ* សុទ្ធតែជាពាក្យកម្លាយចេញពីឫស *ឆ្ពោះ ស្នើ ស្នាក់ គ្រឹក ស្រាក់ស្រាំ* ដែលមានសំណេរជាព្យាង្គតំរួត តែបែរជាត្រូវបានសរសេរជារាយព្យាង្គទៅវិញ។ ទាំងនៅក្នុងករណីនេះ ទាំងនៅក្នុងករណីខាងលើ គោលការណ៍អាស្រ័យឫសមិនត្រូវបានយកមកអនុវត្តក្នុងការកំណត់សំណេរនៃពាក្យកម្លាយទាំងនេះឡើយ ហើយក៏មិនអាចយកទៅអនុវត្តសម្រាប់ករណីផ្សេងៗបានទៀតដែរ ដូចមានបង្ហាញជូនក្នុងកថាខណ្ឌជាបន្តបន្ទាប់នេះ។

ប្រសិនបើ គេត្រូវប្រកាន់តាមគោលការណ៍អាស្រ័យឫសដែលមានចែងក្នុងនិទានសម្ដេចព្រះសង្ឃរាជ ជួន ណាត មែននោះ ម្ល៉េះសមពាក្យកម្លាយទាំងនោះត្រូវសរសេរជាតំរួតព្យាង្គ *ចម្ពោះ សម្នើ សម្នាក់ គ្គ្រឹក ស្ស្រាកស្ស្រាំ* បែបនេះបាត់ទៅហើយ។ ផ្ទុយទៅវិញ សំណេរពាក្យកម្លាយបែបនេះ ដែលត្រូវតាមគោលការណ៍អាស្រ័យឫសដែលចែងមកនោះ បែរជាមិនត្រូវបានសរសេរកត់ទុកនិងតម្រូវឱ្យប្រើនោះទេ។ មិនតែប៉ុណ្ណោះ ប្រសិនបើមាននរណាម្នាក់សរសេរពាក្យបែបនេះនោះ ប្រាកដជាត្រូវគេបដិសេធចោលនិងចាប់ជាកំហុសជាក់ជាមិនខាន។ ប្រការនេះស្ដែងពីភាពមិនត្រឹមត្រូវនិងការមិនអាចយកមកអនុវត្តបានរបស់គោលការណ៍អាស្រ័យឫសនៅក្នុងការសរសេរពាក្យកម្លាយនៃភាសាខ្មែរ។

លើសពីនេះទៅទៀត អតក្កភាពទីបីអាចត្រូវបានសង្កេតឃើញតាមរយៈការកម្លាយពាក្យ *ជាន់* ដោយផ្នត់នានា៖ *ជាន់* ជាឫសដែលគេអាចយកទៅកម្លាយឱ្យកើតបានទៅជា *ជំនាន់* ដែលមានសំណេរជារាយព្យាង្គក៏ពិតមែន តែគេមិនអាចយកឧទាហរណ៍មួយនេះទៅធ្វើជាសកលភាពក្នុងការបង្កើតគោលការណ៍អាស្រ័យឫសដែរ ដោយហេតុថាឫស *ជាន់* ដដែលនេះក៏អាចកម្លាយបានទៅជាពាក្យ *ឈ្នាន់ បញ្ជាន់* ដែលមានសំណេរជាព្យាង្គតំរួតនិងតំរួតព្យាង្គទៅវិញ។

គេអាចមានឧទាហរណ៍ជាច្រើនទៀតស្ដីពីករណីនេះ។ ជាក់ស្ដែង *កាន់ ចុក ដើរ គាប់ ជិត* ជាពាក្យដែល មានសំណេរជាព្យាង្គរាយ ហើយអាចកម្លាយតាមរយៈផ្នត់ដែក[-អ'ម/ណ-] [-អ'ម/ន-][7] ឱ្យកើតបានទៅជាពាក្យកម្លាយរៀងគ្នាជា *កំណាន់ ប្រកាន់ ចំណុក ដំណើរ គំនាប់ ជំនិត* ដែលមានសំណេរជា រាយព្យាង្គ ដែលហាក់ដូចជាស្របតាមវិធានដែលគោលការណ៍អាស្រ័យឫសចែងមក។ ប៉ុន្ដែ គេមិនត្រូវប្រទ្បាំយកឧទាហរណ៍ទាំងនេះមកធ្វើជាករណីទូទៅដែលស្ដែងពីសកលភាពបាននោះទេ ដោយហេតុឫស *កាន់ ចុក ដើរ គាប់ ជិត* ដដែលនេះក៏អាចត្រូវបានកម្លាយដោយផ្នត់ផ្សេងទៀតឱ្យកើតបានជាពាក្យ *ខ្នាន់ បង្កាន់ ផ្ទុក បញ្ចុក ថ្មើរ បណ្ដើរ ផ្គាប់ បង្គាប់ ភ្ជិត បញ្ជិត* ដែរ។

មិនតែប៉ុណ្ណោះ អតក្កភាពទីបួននឹងស្ដែងឡើងយ៉ាងច្បាស់ក្រលែតតាមរយៈអនិរន្តរភាពនៃគោលការណ៍អាស្រ័យឫស ក្នុងការបកស្រាយពីសំណេរនៃពាក្យ *ជម្រើស ជ្រើស* និង *រើស* ។ ប្រសិនបើគេផ្អែកលើគោលការណ៍អាស្រ័យឫស ហើយអះអាងថា *ជម្រើស* ត្រូវតែសរសេរជាតំរួតព្យាង្គបែបនេះ ពីព្រោះវាត្រូវបានកម្លាយចេញពីឫស *ជ្រើស* ដែលមានសំណេរជាព្យាង្គតំរួតនោះ ចុះហេតុអ្វីបានជាពាក្យ *ជ្រើស* ដែលកម្លាយចេញពីឫស *រើស* មានសំណេរជាព្យាង្គរាយសោះ បែរជាត្រូវសរសេរជាព្យាង្គតំរួតទៅវិញ? បើតាមគោលការណ៍អាស្រ័យឫស ទាំងពាក្យ *ជ្រើស* ទាំងពាក្យ *ជម្រើស* គួរណាស់តែត្រូវបានសរសេរជារាយព្យាង្គនិងព្យាង្គរាយវិញទើបត្រូវ។ ប៉ុន្ដែ ការណ៍ពិតមិនដូច្នោះឡើយ ដូចយើងបានបង្ហាញនិងបានបញ្ជាក់ស្រាប់ថា សំណេរនៃពាក្យកម្លាយមិនអាស្រ័យលើសំណេរនៃពាក្យឫសនោះទេ[8]។

ករណីអនិរន្តរភាពនេះ កើតមានទៅលើពាក្យកម្លាយចេញពីឫសជាច្រើនទៀត។ ជាក់ស្ដែង *ចាំ* ជាឫសដែលមានសំណេរជាព្យាង្គរាយនិងអាចកម្លាយបានទៅជា *ចំណាំ ប្រចាំ* ដែលមានសំណេរជារាយព្យាង្គមែនពិត តែគេមិនអាចសន្និដ្ឋានថាគឺសំណេរនៃពាក្យឫស *ចាំ* ដែលជាកត្តាកំណត់នោះទេ ពីព្រោះគេឃើញមានពាក្យកម្លាយចេញពីឫស *ចាំ* ដដែលនេះ ដូចជា *ឲ្យាំ ផ្ទាំ បញ្ចាំ* ជាដើម ដែលមានសំណេរជាព្យាង្គតំរួតនិងតំរួតព្យាង្គ។ ដូចគ្នាដែរចំពោះករណីនៃពាក្យកម្លាយចេញពីឫស *គាប់* ដែលមានជាអាទិ៍ *គំនាប់ ផ្គាប់ បង្គាប់*។

សក្ខីកម្មមួយទៀតអាចរំលេចចេញបានតាមរយៈសំណេរនៃ *លំអ* ឬ *លម្អ សំគាល់* ឬ *សម្គាល់* ដែលជាពាក្យកម្លាយចេញពីឫសរៀងគ្នា *ល្អ ស្គាល់* ដែលមានសំណេរជាព្យាង្គតំរួត។ ប្រការនេះស្ដែងឱ្យឃើញថា គេអាចសរសេរពាក្យកម្លាយជារាយព្យាង្គឬតំរួតព្យាង្គបាន

---

[7] វេយ្យាករណ៍ប្រពៃណីថាជាផ្នត់ដែក[-អិម/ន-]។ ប៉ុន្ដែ វេយ្យាករណ៍បរន្ដនិយមចែងថាមិនមានស្រៈអិទេ ក្នុងករណីដែលព្យញ្ជនៈខ្មែរមានមូលភេទអអិដូចអ្វីដែលមានចែងមកនេះ។ (សូមមើលវេយ្យាករណ៍ថ្នាក់ទី៥ ក្រសួងអប់រំ សាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨៣ ទំ.៣៦)។

[8] វង្ស មេង ***អន្តបទ /-ម-/ និង /-ន-/ នៅក្នុងភាសាខ្មែរ*** និក្ខេបបទបណ្ឌិតភាសាវិទ្យា រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំ.៣៥។

ដោយមិនទាក់ទងនឹងសំណេរនៃពាក្យឫសទេ។ ជាការពិតណាស់ *លំអ សំគាល់* ត្រូវជារាយព្យាង្គបែបនេះគឺដោយសារតែគេបានកត់ត្រាសូរអេ'មនៃផ្នត់ដោយស្រៈអំ ទោះបីឫសរបស់វាជាព្យាង្គតំរួតក៏ដោយចុះ។ ចំណែកពាក្យ *លម្អ សម្គាល់* អាចសរសេរជាតំរួតព្យាង្គបែបនេះបានគឺដោយសារគេបានកត់ត្រាសូរអេ'មនៃផ្នត់ដោយស្រៈកប់តួអំនឹង *ម* ទៅវិញទេ ពោលគឺមិនអនុលោមទៅតាមសំណេរនៃឫស *ល្អ ស្គាល់* នោះទេ។

អតក្កភាពទាំងប្រាំយ៉ាងដូចដែលបានបង្ហាញជូនខាងលើនេះ បានបង្ហាញយ៉ាងច្បាស់ថា ការយកសំណេរនៃពាក្យឫសមកធ្វើជាអំណះអំណាងក្នុងការកំណត់សំណេរនៃពាក្យកម្លាយ ពិតជាប្រការមួយមិនត្រឹមត្រូវតាមសត្យានុម័តនៃការប្រើប្រាស់ភាសានោះទេ ហើយមិនអាចជាបង្អែកនៅក្នុងការសន្និដ្ឋានទៅលើសំណេរនៃពាក្យកម្លាយទូទៅបានដែរ។

សេចក្ដីវិភាគនៅពេលនេះបានបញ្ជាក់យ៉ាងច្បាស់ថា គោលការណ៍អាស្រ័យឫសដែលមានចែងក្នុងនិទានរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត នោះ មិនមានសាកលភាពទេ ទាំងក្នុងសច្ចភាពនៃបាតុភូតដែលកើតមានឡើងក្នុងសំណេរនៃភាសាខ្មែរ។

ដោយឈរលើចម្បាស់ភាពនៃបរន្តនិយមដែលជាទ្រឹស្ដីបង្កើតឡើងដោយបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ *ព្យាង្គរាយ រាយព្យាង្គ តំរួតព្យាង្គ ព្យាង្គតំរួត* ជាបច្ចេកសព្ទដែលស្ដែងពីសញ្ញាណផ្សេងៗគ្នា[9]។ ការប្រើបច្ចេកសព្ទទាំងនេះ បានជួយរំលេចឱ្យឃើញកាន់តែច្បាស់ពីគម្លាតរវាងសំណេរនៃពាក្យឫសនិងសំណេរនៃពាក្យកម្លាយ។ ជាក់ស្ដែង ឫសទាំងអស់ដែលមានសំណេរជាព្យាង្គរាយ មិនអាចបង្កើតបានជាពាក្យកម្លាយដែលមានសំណេរជាព្យាង្គរាយនោះទេ ហើយឫសដែលមានសំណេរជាព្យាង្គតំរួតក៏មិនអាចបង្កើតបានជាពាក្យកម្លាយដែលមានសំណេរជាព្យាង្គតំរួតដែរ។ លោកបានបញ្ជាក់ថាសំណេរនៃពាក្យកម្លាយទាំងអស់មិនអនុលោមតាមសំណេរនៃឫសនោះទេ តែវាអាស្រ័យលើផ្នត់ ដូចមានគោលការណ៍អាស្រ័យផ្នត់[10]របស់លោកបានបញ្ជាក់ស្រាប់។

## ៤- សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើគោលការណ៍អាស្រ័យឫសរួចមក អាត្មាភាពយល់ឃើញថា គោលការណ៍នេះមិនមានសុក្រឹតភាពទេ ហើយទស្សនៈដែលប្រកាន់យកសំណេរនៃពាក្យកម្លាយដោយអនុលោមតាមសំណេរនៃឫសនោះ គឺជាការភាន់ច្រលំមួយដែលបានកើតឡើងដោយសារតែមិនបានសិក្សាវិភាគឱ្យបានល្អិតល្អន់ទៅតាមបាតុភូតនៃការប្រើប្រាស់នៅក្នុងភាសាខ្មែរ។

---

[9] ច័ន្ទ សំណព្វ ***សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៨ ទំ.៨៦-៩៦។

[10] ដ.ដ ទំ.១១៥។

ជាការពិតណាស់ សំណោរនៃពាក្យឫសមិនអាចជាកត្តាកំណត់ពីសំណោរនៃពាក្យកម្លាយបានទេ ពីព្រោះភ្នាក់ងារសកម្មក្នុងការបង្កើតកម្លាយគឺផ្នត់នៅក្នុងបរន្តកម្ម (ចលនាសកម្មទ្វេទិស) មួយដោយមានឫសជាសហបទ។

ការសិក្សាស្រាវជ្រាវនេះក៏បានបង្ហាញឱ្យឃើញផងដែរថា សំណោរពាក្យកម្លាយមិនអនុលោមតាមសំណោរនៃពាក្យឫសនោះទេ ទោះបីជានៅក្នុងការកម្លាយពាក្យខ្លះ ដូចជា *គ្រប់ ភ្លឺ* ឱ្យកើតបានទៅជាពាក្យកម្លាយ *បង្គ្រប់ ពន្លឺ* ដែលមានសំណោរគ្រួតក៏ដោយចុះ ពីព្រោះករណីនេះកើតឡើងដោយចៃដន្យតែប៉ុណ្ណោះ មិនមែនដោយសារតែសំណោរនៃពាក្យឫសជាអ្នកកំណត់នោះទេ។

ចុះបើបែបនេះមែន តើតាមពិតទៅ សំណោរនៃពាក្យកម្លាយអាស្រ័យលើអ្វីទៅវិញ? តើមានអ្វីជាអ្នកកំណត់សំណោរនៃពាក្យកម្លាយដែរឬទេ?

តាមទ្រឹស្តីបរន្តនិយម ពាក្យកម្លាយកើតចេញពីចលនាសកម្មទ្វេទិសរវាងផ្នត់និងឫស នៅក្នុង *បរបទ*[11] មួយកំណត់ច្បាស់លាស់។ នៅក្នុងករណីដែលសំណោរនៃពាក្យឫសមិនមែនជាកត្តាកំណត់ពីសំណោរនៃពាក្យកម្លាយទេនោះ ការសិក្សាស្រាវជ្រាវបានផ្តោតទៅលើផ្នត់។ តើរបកគំហើញថ្មីស្តីពីតួនាទីនៃផ្នត់ មានខ្លឹមសារយ៉ាងណាដែរ?

អាត្មាភាពនឹងសិក្សាស្រាវជ្រាវបន្តទៀតទៅលើចំណុចទាំងនេះ រួចនឹងចុះផ្សាយក្នុងទស្សនាវដ្តីនេះ នៅលេខក្រោយទៀត។

---

[11] ផ្សេងពី *បរិបទ* (Context) បច្ចេកសព្ទ *បរបទ* (Extext) ជាផ្នែកនៃអត្ថបទដែលមិនចូលរួមក្នុងបរន្តកម្មទេ តែមានតួនាទីបង្កើតលំនឹងន័យដែលកើតចេញពីបរន្តកម្មមួយ។

# គន្ថនិទ្ទេស


## ក- ឯកសារភាសាជាតិ

១- ក្រសួងអប់រំ *វេយ្យាករណ៍* ថ្នាក់ទី៥ សាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៨០។

២- ច័ន្ទ សំណព្វ *វិភាគវេយ្យាករណ៍* រាជបណ្ឌិត្យសភាកម្ពុជា ២០១៧។

៣- ច័ន្ទ សំណព្វ *អក្សរ ព្យាង្គ ពាក្យ* រាជបណ្ឌិត្យសភាកម្ពុជា ២០១៣។

៤- ច័ន្ទ សំណព្វ *សំណេរនិងអក្ខរាវិរុទ្ធខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា ២០០៨។

៥- ច័ន្ទ សំណព្វ *បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ* ភ្នំពេញ ២០១០។

៦- ជួន ណាត *"វចនានុក្រមខ្មែរ ភាគទី១និងភាគទី២"* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១១ គ.ស.១៩៦៧។

៧- វង្ស មេង *អន្តបទ /-ម-/ និង /-ន-/ នៅក្នុងភាសាខ្មែរ* និក្ខេបបទបណ្ឌិតភាសាវិទ្យា រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ។

៨- វង់ សុធារ៉ា *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្ដាល* គ្រឹស្ថានបោះពុម្ពផ្សាយនគរវត្ត ភ្នំពេញ ២០១២

## ខ- ឯកសារភាសាបរទេស

1- CHAN Somnoble *Identité et variation des unités de langue : Étude des unités lexico-grammaticales en Khmer contemporain, Université de Paris X-Nanterre, France, 2002*

2- CHAN Somnoble *Linguistique appliquée : Systématique des emplois de təw en Khmer contemporain, Université de Paris X-Nanterre, France, 1998.*

3- CHAN Somnoble *Étude du fonctionnement de ba:n en Khmer contemporain, Université de Paris X-Nanterre, France, 1997.*

4- CHAN Somnoble *Recueil de poèmes : Textos de l'été, Université Royale de Phnom Penh, 1995.*

## ឃ- ព្រឹត្តិបត្រ ទស្សនាវដ្ដី និងសារព័ត៌មាន

### ១- ស្នាដៃជាភាសាខ្មែរ

-ច័ន្ទ សំណព្វ « *ពាក្យកម្ចាយនិងពាក្យក្លាយ* » នៅក្នុង៖ ទស្សនាវដ្ដីរាជបណ្ឌិតសភាកម្ពុជា លេខ១ ធមាសទី១ ឆ្នាំ២០០៩។

-សូ មុយឃៀង *ព្យាង្គតំរួតក្នុងសម័យខេមរយានកម្ម* នៅក្នុង៖ទស្សនាវដ្ដីគ្រូបង្រៀនលេខ ២៧ ភ្នំពេញ ឆ្នាំ២០០៦ ទំព័រ៣៨។

# «សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម» ២០១៤-២០១៩

*បេក្ខជនបណ្ឌិត៖* ***អួន សំអុល***
*ជំនាញ៖* ***រដ្ឋបាលសាធារណៈ***
*គ្រូណែនាំ៖* ***បណ្ឌិត សយ រាសី***

## ១-សេចក្តីផ្តើម

*«ក្រុមប្រឹក្សា»* កើតចេញពីពាក្យក្រុមនិងប្រឹក្សា។ ក្រុមសំដៅលើការប្រមូលផ្តុំមនុស្សចាប់ពីពីរនាក់ឡើងទៅ។ ប្រឹក្សា សំដៅដល់ការពិគ្រោះយោបល់ឬការជជែកស្វែងរកចំណុចរួមមួយ។ រួមមក ក្រុមប្រឹក្សា បានន័យថា ការបង្កើតឡើងដោយមនុស្សមួយក្រុម ដើម្បីផ្តល់ប្រឹក្សាយោបល់ទៅលើបញ្ហាអ្វីមួយនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បើតាមន័យច្បាប់ ក្រុមប្រឹក្សាគឺជានីតិបុគ្គលសាធារណៈ ដែលបង្កើតឡើងតាមរយៈច្បាប់រៀបចំអង្គការ ហើយបើកផ្លូវឱ្យមានការបោះឆ្នោតសកល ឬអសកល។

ក្រុមប្រឹក្សាមាន ២ប្រភេទធំៗ គឺក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតសកល បានដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតអសកល បានដល់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។ ប្រជាពលរដ្ឋទាំងពីរភេទមានអាយុ ១៨ ឆ្នាំឡើងទៅ ហើយមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គអ្នកមានសិទ្ធិបោះឆ្នោតដោយផ្ទាល់ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ដោយឡែកក្នុងនាមប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងមុខតំណែង មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកនៃក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ[1]ដែលជាអ្នកតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[2]។

ចំណែកឯមុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជន ដែលបានទទួលសំឡេងឆ្នោតច្រើនជាងគេបង្អស់[3]។ ដោយឡែកមុខតំណែងប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌវិញ គឺជា

---

[1] ស ខេង, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា,* (បទឧទ្ទេសនាម) ឆ្នាំ២០១៨ ទំព័រ ៣៣

[2] ក្រសួងមហាផ្ទៃ, *តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលខេត្ត,* ឆ្នាំ២០១១ ទំព័រ ១០

[3] *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* មាត្រា ៣២

បេក្ខជន ដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវជ្រើសរើសបេក្ខជនដែលមានលេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានសំឡេងបានការច្រើនជាងគេ [4]។

ជារួមមក ក្រុមប្រឹក្សាគឺជាតំណាងឱ្យប្រជាពលរដ្ឋ និងជាអ្នកធ្វើសេចក្តីសម្រេចនានា ក្នុងនាមប្រជាពលរដ្ឋពាក់ព័ន្ធទៅនឹងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន សំដៅបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សា មានអាណត្តិការងារប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។ ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែងក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ[5]។

ក្នុងអាណត្តិទី២ នៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ខេត្តកំពង់ចាមមានក្រុមប្រឹក្សាចំនួន **២១** រូប ស្រី **២**រូប ត្រូវបានបង្កើតឡើងដោយការបោះឆ្នោតអសកលកាលពីថ្ងៃអាទិត្យ ទី១៨ ខែឧសភា ឆ្នាំ២០១៤ ពីសមាជិក សមាជិកានៃក្រុមប្រឹក្សាឃុំ និងសង្កាត់ទូទាំងខេត្តមានចំនួន **១០៩** ឃុំ សង្កាត់ ស្មើនឹង **១៦២** នាក់ ដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្តកំពង់ចាមរបស់ខ្លួន។ ក្នុងនោះ ចែកចេញជាសង្កាត់មានចំនួន ៤ ស្មើនឹង **៣៦** នាក់ និងឃុំចំនួន **១០៥** ស្មើនឹង**១២៦** នាក់។

ជាលទ្ធផលគណបក្សនយោបាយចំនួន **២** គឺគណបក្សប្រជាជនកម្ពុជាទទួលបានចំនួន **១១** អាសនៈ និងគណបក្សសង្គ្រោះជាតិទទួលបានចំនួន **១០** អាសនៈ។ រីឯប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម ត្រូវបានទៅលើគណបក្សប្រជាជនកម្ពុជា (១១/២១) និងត្រូវបានរៀបចំពិធីប្រកាសចូលកាន់មុខតំណែងជាផ្លូវការនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពង់ចាមតំណាងរាជរដ្ឋាភិបាលកម្ពុជា [6] តាមការណែនាំរបស់ក្រសួងមហាផ្ទៃ អនុលោមតាមច្បាប់ដែលចែងថា «កិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សាត្រូវប្រារព្ធធ្វើឡើងនៅក្នុងរយៈពេលមិនឱ្យលើសពីដប់បួន (១៤) ថ្ងៃ បន្ទាប់ពីថ្ងៃដែល

---

[4] *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, មាត្រា១៧ ឆ្នាំ២០០៨

[5] *-ដ-*, មាត្រា១៥-មាត្រា១៦

[6] សេចក្តីសម្រេចលេខ ១០១ សសរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ***ស្តីពីការចាត់តាំងសមាសភាពតំណាងរាជ រដ្ឋាភិបាលដែលជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីចូលរួមជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សា រាជធានី ខេត្ត អាណត្តិទី២***

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា [7]។

ក្នុងការអនុវត្តតួនាទី ភារកិច្ច ក្រុមប្រឹក្សាខេត្តកំពង់ចាមបានប្រើប្រាស់សិទ្ធិអំណាចចំនួន **២** គឺសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ២- សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

### ២.១-សិទ្ធិអំណាចខាងបញ្ញត្តិ

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការដាក់ចេញដីកា ការកែប្រែ និងការលុបចោលដីកាស្របតាមនីតិវិធីជាធរមាន។ ដីការបស់ក្រុមប្រឹក្សា គឺជាវិធានខាងផ្លូវច្បាប់ មានលក្ខណៈជាបទបញ្ញាទូទៅ ហើយក៏ជាលិខិតបទដ្ឋានគតិយុត្តខ្ពស់ជាងគេបំផុត សម្រាប់ការគ្រប់គ្រង និងដោះស្រាយបញ្ហាជាក់លាក់ណាមួយ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ គឺជាការណែនាំការអនុវត្ត ឬការបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស និងជាការណែនាំការអនុវត្តកិច្ចការដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា (ហៅកាត់ថា ដីកាបទបញ្ញាទូទៅ)។

ក្នុងការដាក់ចេញនូវដីកា ក្រុមប្រឹក្សាខេត្តកំពង់ចាម បានពិចារណាទៅលើក្របខណ្ឌច្បាប់ដែលស្ថិតនៅក្នុងវិសាលភាពនៃ ៖

- តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន
- មុខងារ និងឬធនធានដែលប្រគល់មកពីថ្នាក់ជាតិ
- មុខងារ និងឬធនធានដែលបានធ្វើប្រតិភូកម្មមកឱ្យពីថ្នាក់ជាតិ ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះមិនកំណត់ដោយផ្នែកខ្លះ ឬទាំងស្រុងនូវសិទ្ធិក្នុងការអនុម័តដីកា និង
- កិច្ចការណាមួយដែលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដែលតម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា។

ដីកាដែលក្រុមប្រឹក្សាបានពិនិត្យ និងអនុម័តក្នុងអាណត្តិទី២ (២០១៤-២០១៨) មានចំនួន **៣៨៩** ដីកា ក្នុងនោះឆ្នាំ២០១៤ មានចំនួន ១៦ ដីកា ឆ្នាំ២០១៥ មានចំនួន ៥២ ដីកា ឆ្នាំ២០១៦ មានចំនួន ៩៨ ដីកា ឆ្នាំ២០១៧ មានចំនួន ៧៥ ដីកា និងឆ្នាំ២០១៨ មានចំនួន ១៤៨ ដីកា [8]។

រាល់ដីការបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម សុទ្ធតែត្រូវបានឆ្លងកាត់កិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តដោយយកសំឡេងគាំទ្រ ៥០% បូកមួយ នៃចំនួនសមាជិកក្រុមប្រឹក្សាមានវត្តមានក្នុងកិច្ចប្រជុំ។

---

[7] -ជ.ឯ.ម- មាត្រា ៦២-៧៧

[8] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម អាណត្តិទី២ ឆ្នាំ២០១៩ ទំព័រ ២

មុននឹងដាក់ឱ្យអនុវត្តនូវដីកា រដ្ឋបាលខេត្តតែងតែបានបញ្ជូននូវរាល់ដីកា ដែលបានអនុម័ត ដោយក្រុមប្រឹក្សារបស់ខ្លួន ទៅក្រសួងមហាផ្ទៃយ៉ាងយូរប្រាំ(០៥) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកា ដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។ ក្រសួងមហាផ្ទៃសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ធ្វើការពិនិត្យនីត្យានុកូលភាពលើដីកានោះ។ ក្នុងករណីពិនិត្យឃើញថា ដីកាមានអនីត្យានុកូលភាព ក្រសួងមហាផ្ទៃជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រុមប្រឹក្សាដែលចេញដីកានោះ ដោយបញ្ជាក់អំពីហេតុផល ឬចំណុចដែលផ្ទុយពីបទបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដើម្បីឱ្យក្រុមប្រឹក្សាធ្វើការកែតម្រូវឡើងវិញ។ ក្រោយពេលទទួលបានសេចក្ដីជូនដំណឹងពីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាបានណែនាំឱ្យអង្គភាពទទួលភារកិច្ចធ្វើការកែតម្រូវដីកានេះឡើងវិញ ក្នុងអំឡុងពេលសាមសិប(៣០) ថ្ងៃនៃថ្ងៃធ្វើការ ហើយដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សាពិនិត្យ និងអនុម័តឡើងវិញនូវចំណុចដែលបានកែតម្រូវទាំងនោះ ដោយដាក់ចេញនូវដីកាស្ដីពីការកែសម្រួលដីកា។

**២.២- សិទ្ធិអំណាចខាងប្រតិបត្តិ**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការដាក់ចេញនូវសេចក្ដីសម្រេចនានា។ សេចក្ដីសម្រេចមួយចំនួនទាក់ទងទៅនឹងការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា គឺជាសិទ្ធិអំណាចរបស់គណៈអភិបាលវិញ តែត្រូវដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាដូចគ្នា លើកលែងតែលិខិតបទដ្ឋានគតិយុត្តណាដែលចែងកំណត់ដោយឡែក។

សេចក្ដីសម្រេច គឺជាលិខិតបទដ្ឋានគតិយុត្តដែលចេញដោយរដ្ឋបាលខេត្ត ដោយផ្អែកលើមូលដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ ដីការបស់ក្រុមប្រឹក្សា ឬ តម្រូវការរបស់មូលដ្ឋានក្នុងការសម្រេចកិច្ចការអ្វីមួយដែលមានលក្ខណៈមិនស្ថិតស្ថេរយូរអង្វែង។

ការដាក់ចេញសេចក្ដីសម្រេច គឺដើម្បី ៖

- អនុវត្តខ្លឹមសាររបស់ដីកា និងលិខិតបទដ្ឋានគតិយុត្តរបស់ថ្នាក់ជាតិ
- ណែនាំអនុវត្តកិច្ចការណាមួយ ដែលស្ថិតក្នុងសិទ្ធិអំណាច និងសមត្ថកិច្ចរបស់រដ្ឋបាល
- បង្កើតឡើងនូវគណៈកម្មាធិការ អនុគណៈកម្មាធិការ គណៈកម្មការ និងក្រុមការងារនានារបស់រដ្ឋបាលខេត្ត
- ប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិករបស់រដ្ឋបាលខេត្ត។

សេចក្ដីសម្រេចណាមួយដែលមានខ្លឹមសារផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តនានារបស់ថ្នាក់ជាតិ ឬដីការបស់ក្រុមប្រឹក្សាខ្លួន សេចក្ដីសម្រេចនោះនឹងពុំមានសុពលភាពឡើយ។

រីឯតម្រូវការនៃការដាក់ចេញសេចក្ដីសម្រេច ត្រូវបានកំណត់ដោយផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តនានារបស់ថ្នាក់ជាតិ ឬដីការបស់ក្រុមប្រឹក្សា

ខ្លួន និងឬតម្រូវការក្នុងមូលដ្ឋាន។ ករណីផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តនានារបស់ថ្នាក់ជាតិ និងដីការបស់ក្រុមប្រឹក្សា ពុំចាំបាច់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័តឡើយ តែត្រូវរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន នៅក្នុងកិច្ចប្រជុំបន្ទាប់ពីការចេញសេចក្តីសម្រេចនោះ។ រីឯតម្រូវការនៃការដាក់ចេញសេចក្តីសម្រេចផ្អែកតាមតម្រូវការក្នុងមូលដ្ឋានវិញ ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

សេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តកំពង់ចាមបានពិនិត្យ និងអនុម័តក្នុងអាណត្តិទី២ (២០១៤-២០១៨) មានចំនួន **៧៤៣** សេចក្តីសម្រេច ក្នុងនោះឆ្នាំ២០១៤ មានចំនួន ២២៧ សេចក្តីសម្រេច ឆ្នាំ២០១៥ មានចំនួន ១៤៥ សេចក្តីសម្រេច ឆ្នាំ២០១៦ មានចំនួន ១២០ សេចក្តីសម្រេច ឆ្នាំ២០១៧ មានចំនួន ១៥០ សេចក្តីសម្រេច និងឆ្នាំ២០១៨ មានចំនួន ១០១ សេចក្តីសម្រេច [៩]។

គ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្តកំពង់ចាម សុទ្ធតែត្រូវបានឆ្លងកាត់កិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តដោយយកសំឡេងគាំទ្រ ៥០% បូកមួយនៃចំនួនសមាជិកក្រុមប្រឹក្សាមានវត្តមានក្នុងកិច្ចប្រជុំ។

សរុបរួមមកសិទ្ធិអំណាចទាំងពីរ គឺសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ត្រូវធ្វើឡើងក្នុងអង្គប្រជុំក្រុមប្រឹក្សាខេត្តរបស់ខ្លួន ហើយធានាថា សេចក្តីសម្រេចទាំងនោះ ត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។ ក្រុមប្រឹក្សាខេត្ត បានតម្រូវឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។ ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យអភិបាលខេត្តធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទ នីតិវិធីដើម្បីដោះស្រាយកិច្ចការទាំងនោះ បើករណីកិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះ ចែងមិនច្បាស់លាស់ ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាខេត្តមិនអាចអនុវត្តបាន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្ត ធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាប់។ ផ្អែកតាមយន្តការនេះ គ.ជ.អ.ប. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយករណីនេះ។

---

[៩] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាខេត្តកំពង់ចាម អាណត្តិទី២ ឆ្នាំ២០១៩ ទំព័រ ២

ម្យ៉ាងវិញទៀត រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តតែងតែបានធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិណាមួយ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខេត្ត និងជាវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង ៖

- ✓ ការរៀបចំដើម្បីទទួល មុខងារ ភារកិច្ច និងធនធានថ្មី ដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ✓ ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ✓ ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត
- ✓ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យ របស់ក្រុមប្រឹក្សាប្រភេទរួមគ្នាប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ✓ ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត
- ✓ បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត
- ✓ ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ អង្គភាព ផ្នែក និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ✓ ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- ✓ ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ✓ ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ✓ សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និង
- ✓ កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ✓ ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធ

- ✓ ការសម្រេចឱ្យសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តយល់ថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំ ដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ✓ ការពិនិត្យ ស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ✓ ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ ដែលប្រព្រឹត្តដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ✓ ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ✓ ការពិនិត្យ និងដោះ ស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ✓ ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលខេត្ត និង
- ✓ បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់ [10]។

## ៣-សេចក្តីសន្និដ្ឋាន

ក្នុងអាណត្តិទី២ នៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៤-២០១៩ នេះ ក្រុមប្រឹក្សាខេត្តកំពង់ចាមបានអនុវត្តតាមតួនាទី ភារកិច្ចស្របតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ដោយប្រើប្រាស់សិទ្ធិអំណាចចំនួនពីរ គឺសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិ ក្នុងកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញនៃក្រុមប្រឹក្សាខេត្តរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ការប្រើប្រាស់សិទ្ធិអំណាចនេះ មិនមានការរំលោភបំពានអំណាចគ្នាទៅវិញទៅមករវាងក្រុមប្រឹក្សា និងគណៈអភិបាលនោះទេ គឺអនុវត្តតាមតួនាទី ភារកិច្ចរៀងៗខ្លួនដោយមាននាយករដ្ឋបាលខេត្តជាសេនាធិការ៕

---

[10] អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី*តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក* មាត្រា១៥

# ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ សម្រាប់អភិបាលកិច្ចសាលារៀននៅកម្ពុជា

*បេក្ខជនបណ្ឌិត៖* ***ស៊ុន សុនិមិត្ត***
*គ្រូណែនាំ៖* ***បណ្ឌិត ឈិត វណ្ណឫទ្ធិ***

## ១. ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ

យោងតាមគេហទំព័ររបស់ Esri [1] ដែលជាក្រុមហ៊ុននាំមុខគេលើការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ បានឱ្យនិយមន័យប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងន័យទូលាយថាជា៖ ក្របខណ្ឌដើម្បីរៀបចំ ទំនាក់ទំនង និងយល់ដឹងពីវិទ្យាសាស្ត្រនៃផែនដីដែលយើងរស់នៅបច្ចុប្បន្ន។

Nicholas Chrisman [2] ដកស្រង់និយមន័យទូទៅមួយ ដែលត្រូវបានការទទួលស្គាល់ពីអ្នកជំនាញជាច្រើនថា ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System) គឺជាប្រព័ន្ធនៃហាដវែរ សុសវែរ ទិន្នន័យ មនុស្ស អង្គភាព និងរចនាសម្ព័ន្ធស្ថាប័ន ដើម្បីប្រមូល រក្សាទុក វិភាគ និងផ្សព្វផ្សាយព័ត៌មានអំពីតំបន់នានានៃផែនដី។

Michael N. Demers [3] យោងទៅដល់និយមន័យមួយដែលបានស្នើឡើងដោយ Marble និង Peuquet ដែលបញ្ជាក់ពីរបៀបដែលប្រព័ន្ធព័ត៌មានភូមិសាស្ត្រធ្វើការជាស៊េរីនៃអនុប្រព័ន្ធជាច្រើន ដែលធ្វើការនៅក្នុងប្រព័ន្ធធំមួយ។ និយមន័យនេះបញ្ជាក់ថាប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ធ្វើការជាមួយទិន្នន័យទីកន្លែង និងពេលវេលា (space-time data) ដែលភាគច្រើន ប៉ុន្តែមិនចាំបាច់ប្រើប្រាស់ហាដវែរ និងសុសវែរកុំព្យូទ័រ។ តាមនិយមន័យនេះ ប្រព័ន្ធព័ត៌មានភូមិសាស្ត្ររួមមានអនុប្រព័ន្ធដូចខាងក្រោម៖

១. អនុប្រព័ន្ធបញ្ចូលទិន្នន័យ (data input subsystem) ដែលប្រមូល (collect) ដំណើរការជាមុន (preprocess) នូវទិន្នន័យភូមិសាស្ត្រ (spatial data) ពីប្រភពផ្សេងៗគ្នា

២. អនុប្រព័ន្ធរក្សាទុក និងទាញយកទិន្នន័យ (data storage and retrieval subsystem) ដែលរៀបចំទិន្នន័យភូមិសាស្ត្រក្នុងរបៀបមួយដែលអនុញ្ញាតឱ្យធ្វើការទាញយក អាប់ដេត និងកែប្រែ

៣. អនុប្រព័ន្ធរៀបចំ និងវិភាគទិន្នន័យ (data manipulation and analysis subsystem) ដែលធ្វើការទាក់ទងនឹងទិន្នន័យដូចជា៖ បូកសរុប (aggregate) ផ្តាច់ចេញ (de-aggregate) ប៉ាន់ស្មានពីប៉ារ៉ាម៉ែត្រ និងដែនកំណត់ (constraints) និងអនុវត្តតួនាទីបង្កើតម៉ូដែល

៤. អនុប្រព័ន្ធធ្វើរបាយការណ៍ (reporting subsystem) ដែលធ្វើការបង្ហាញមូលទិន្នន័យទាំងមូល ឬដោយផ្នែកក្នុងទម្រង់ជា តារាង ក្រាហ្វិក ឬផែនទី។

យោងតាមនិយមន័យខាងលើនេះ Michael N. Demers បញ្ជាក់ថាក្នុងអនុប្រព័ន្ធទី ១ និងទី២ ដំណើរការបង្កើតផែនទី និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រប្រើប្រាស់វិធីសាស្ត្រប្រហាក់ប្រហែលគ្នា ទោះបីជាបច្ចេកវិទ្យាទំនើបជាងមុនក៏ដោយ។ ចំណុចស្នូលនៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រគឺ អនុប្រព័ន្ធវិភាគទិន្នន័យ ដែលក្នុងសម័យទំនើបគេប្រើប្រាស់អំណាចនៃកុំព្យូទ័រដើម្បីវាស់វែង ប្រៀបធៀប និងពិពណ៌នាទិន្នន័យនៅក្នុងមូលទិន្នន័យ។

## ២. ទិន្នន័យភូមិសាស្ត្រ (Spatial Data)

ទិន្នន័យនៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រតំណាងឱ្យវត្ថុពិត (physical entity) នៅលើផ្ទៃដី ដូចជា ផ្លូវ ភ្នំ ទីតាំង ឬលក្ខណៈនានាដែលយើងចង់កំណត់។ ទិន្នន័យរួមមានព័ត៌មានអំពីទីតាំង ភូមិសាស្ត្រ និងព័ត៌មានបន្ថែមផ្សេង

---

1 https://www.esri.com/en-us/what-is-gis/overview

2 Nicholas Chrisman, 1997, pp. 5

3 Michael N. Demers, 1997, pp. 9

ទៀត។ ជាធម្មតាទិន្នន័យភូមិសាស្ត្ររួមមានៈ កូអរដោណេ (coordinates) និងទិន្នន័យគុណលក្ខណៈ (attribute data)។ កូអរដោណេ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ពីទីតាំង និងទំហំនៃវត្ថុភូមិសាស្ត្រមួយ។ កូអរដោណេមួយផ្សំឡើងពីតួលេខ ពីរ ឬបី ដែលបញ្ជាក់ពីទីតាំងមួយធៀបទៅនឹងចំណុចគោលមួយ។ កូអរដោណេមួយក្រុម ឬច្រើនត្រូវបានគេប្រើប្រាស់ដើម្បីបង្ហាញពីរូបរាង និងព្រំដែននៃវត្ថុមួយ។ កូអរដោណេ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងម៉ូដែលទិន្នន័យភូមិសាស្ត្រ ហើយវាក៏អាចត្រូវបានបង្ហាញខុសៗគ្នាទៅតាមម៉ូដែលដែរ។ គេអាចប្រើប្រព័ន្ធកូអរដោណេស្តង់ដាខុសៗគ្នាដើម្បីបង្ហាញកូអរដោណេ។ ទិន្នន័យគុណលក្ខណៈ ត្រូវបានគេប្រើប្រាស់ដើម្បីកត់ត្រាលក្ខណៈមិនភូមិសាស្ត្រនៃវត្ថុមួយ។ វាគឺជាបញ្ជីនៃលក្ខណៈ មានតម្លៃ (values) ដែលពិពណ៌នាអំពីវត្ថុភូមិសាស្ត្រមួយ។ ឧទាហរណ៍ កូអរដោណេចំណុចមួយនៅលើផែនទី ជាទីក្រុងមួយដែលភ្ជាប់ជាមួយនឹងទិន្នន័យកូអរដោណេនោះរួមមាន ទិន្នន័យគុណលក្ខណៈដូចជា ចំនួនប្រជាជន និងទំហំផ្ទៃដីជាដើម។ ទិន្នន័យគុណលក្ខណៈច្រើនត្រូវបានរក្សាទុកនៅក្នុងតារាង ឬមូលទិន្នន័យដែលត្រូវបានរៀបចំជាជួរដេក និងជួរឈរ។ ជួរដេកនីមួយៗតំណាងឱ្យវត្ថុភូមិសាស្ត្រមួយ ហើយជួរឈរនីមួយៗតំណាងឱ្យគុណលក្ខណៈមួយ។

## ៣. ប្រព័ន្ធកូអរដោណេភូមិសាស្ត្រ (Geographic Coordinate Systems)

ដើម្បីបង្ហាញ និងវិភាគផែនទីនៅលើផ្ទាំងអេក្រង់កុំព្យូទ័រ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រប្រើប្រាស់កូអរដោណេ ដែលបញ្ជាក់ពីទីតាំង និងរូបរាងនៃវត្ថុឬលក្ខណៈនានា។ យោងតាម Maribeth Price [4], 2016 ប្រព័ន្ធកូអរដោណេទូទៅមួយឈរលើមូលដ្ឋាននៃការវាស់មុំចេញពីចំណុចកណ្តាលផែនដី និងមានខ្នាតជា ដឺក្រេ។ រយៈបណ្តោយ (longitude) វាស់មុំតាមជួរដេកទៅកើត ឬទៅទៅលិចនៃ ព្រីមមេរីឌាន (Prime Meridian) ដែលជាបន្ទាត់មួយដែលរយៈបណ្តោយស្មើសូន្យ ជាខ្សែ ដែលរត់កាត់ Greenwich ប្រទេសអង់គ្លេស។ រយៈបណ្តោយ មានចន្លោះពី -180 ទៅ +180។ រយៈទទឹង (latitude) វាស់មុំតាមជួរឈរទៅលើ ឬទៅក្រោម ខ្សែអេក្វាទ័រ ដែលមានចន្លោះពី 0 ទៅ -90 នៅប៉ូលខាងត្បូង និងពីពី 0 ទៅ +90 នៅប៉ូលខាងជើង។ ប្រព័ន្ធរង្វាស់នេះត្រូវបានគេហៅថា ប្រព័ន្ធកូអរដោណេភូមិសាស្ត្រ។




*រយៈបណ្តោយ (longitude) វាស់មុំពីកើតទៅលិចតាមបណ្តោយខ្សែអេក្វាទ័រ, រយៈទទឹង (latitude) វាស់មុំពីជើងទៅត្បូង ខាងលើ និងខាងក្រោមខ្សែអេក្វាទ័រ, ដកស្រង់ពី* Maribeth Price, 2016

ចំណុចទីតាំងកូអរដោណេភូមិសាស្ត្រមួយត្រូវបានកំណត់ដោយចំណុចប្រសព្វរវាងវ៉ិចទ័ររយៈបណ្តោយ និងរយៈទទឹង នៅលើផ្ទៃនៃផែនដី។ ដោយសារតែរាងនៃផែនដីមិនប្រាកដ ព្រោះសំប៉ែតត្រង់ប៉ូលទាំងពីរ ទើបផ្ទៃរបស់វាអាចកំណត់បានដោយការប៉ាន់ស្មាន (approximation) ប៉ុណ្ណោះ ដែលនេះហើយជាមូលហេតុនៃកំហុសក្នុងការកំណត់ទី

4 Maribeth Price, 2016 ទំព័រ 73

តាំង (positional errors)។ មូលហេតុនេះហើយទើបមានការប៉ាន់ស្មានខុសៗគ្នាត្រូវបានបង្កើតឡើង ដើម្បីបំពេញតម្រូវការជាក់ស្តែងក្នុងការធ្វើផែនទី ដែលការប៉ាន់ស្មាននីមួយៗបង្ហាញពីរូបរាងផែនដីខុសគ្នាបន្តិចបន្តួច។ ការប៉ាន់ស្មាននោះ ត្រូវបានគេហៅថា DATUM។ យោងតាម National Geodetic Survey geodetic datum [5] គឺជាប្រព័ន្ធកូអរដោណេអរូបីមួយដែលរួមមាន ផ្ទៃជាគោល (ដូចជាកម្រិតទឹកសមុទ្រ) ដែលមានតួនាទីផ្តល់នូវទីតាំងគោលសម្រាប់ការវាស់វែង និងបង្កើតផែនទី។

**ចំណោលផែនទី** (Map Projection)

ចំណោលគឺជាវិធីបង្ហាញប្រព័ន្ធកូអរដោណេនិងទិន្នន័យរបស់យើង នៅលើផ្ទៃរាបស្មើដូចជា ក្រដាស ឬអេក្រង់ឌីជីថល។ គេប្រើការគណនាគណិតវិទ្យាដើម្បីបំប្លែងប្រព័ន្ធកូអរដោណេដែលត្រូវបានប្រើនៅលើផ្ទៃកោងនៃផែនដីទៅចំណុចមួយនៃផ្ទៃរាបស្មើ។ ដោយសារមិនមានវិធីល្អឥតខ្ចោះក្នុងការផ្ទេរផ្ទៃកោងទៅផ្ទៃរាបស្មើដោយគ្មានការបង្ខូចខ្លះនោះ ការធ្វើចំណោលចេញជាផែនទីផ្សេងៗគ្នាជាច្រើនផ្តល់នូវលក្ខណៈផ្សេងៗគ្នា។ ខ្លះរក្សារាង រីឯខ្លះទៀតរក្សាចម្ងាយ ហើយវិធីខ្លះរក្សានូវតំបន់ ឬទិសដៅ។

បន្ទាប់ពីកំណត់ប្រព័ន្ធកូអរដោណេដែលត្រូវគ្នានឹងទិន្នន័យរបស់យើងហើយ ត្រូវគិតដល់ការធ្វើចំណោលដែលមានក្នុងប្រព័ន្ធផ្សេងៗទៀតដើម្បីអាចបំប្លែងទៅវិញទៅមកបាន។

## ៤. ប្រព័ន្ធកំណត់ទីតាំងសាកល [6] (Global Positioning System)

ប្រព័ន្ធកំណត់ទីតាំងសកល (ជីភីអេស) គឺជាប្រព័ន្ធរុករកមួយដែលប្រើផ្កាយរណប ជាអ្នកទទួល និងធ្វើសមកាលកម្ម ទីតាំង ទិន្នន័យ ល្បឿន និងពេលវេលា សម្រាប់ការធ្វើដំណើរតាមផ្លូវអាកាសសមុទ្រនិងផ្លូវគោក។ ប្រព័ន្ធផ្កាយរណបនេះមានក្រុមផ្កាយរណបចំនួន ២៤ ហោះនៅ ជុំវិញផែនដី ដែលរៀងរាល់សំណើពីឧបករណ៍ (គេហៅឧបករណ៍ទាំងនោះថា ជីភីអេសដែរ) ផ្តោតទៅលើផ្កាយរណប ៦ ដែលនៅជិតជាងគេ បន្ទាប់មកជ្រើសយកផ្កាយរណបចំនួន ៤ ដែលផ្តល់សញ្ញាត្រឡប់មកវិញ ពីទិសដៅនៅចម្ងាយ ១៣០០០ ម៉ាយល៍ (២០,០០០ គីឡូម៉ែត្រ) ពីលើផែនដីនិងធ្វើដំណើរក្នុងល្បឿន ៨.៧០០ ម៉ែល/ម៉ោង (១៤,០០០ គីឡូម៉ែត្រ/ម៉ោង)។

ដូចយើងធ្លាប់ដឹងស្រាប់ពីធរណីមាត្រប្លង់ ដើម្បីកំណត់ទីតាំងមួយ យើងត្រូវការតែចំណុច ៣ (ផ្កាយរណបចំនួន ៣) ប៉ុណ្ណោះ ដើម្បីបង្កើតទីតាំងនៅលើផ្ទៃផែនដី។ ចំណែកផ្កាយរណបទី ៤ ត្រូវបានគេប្រើដើម្បីផ្ទៀងផ្ទាត់បណ្តាល់ព័ត៌មានពីផ្កាយរណប ៣ ផ្សេងទៀត។ ផ្កាយរណបទីបួន ក៏មានតួនាទីកំណត់រយៈកម្ពស់នៃឧបករណ៍ដែលធ្វើសំណើទៅដែរ។

ជីភីអេសត្រូវបានបង្កើតឡើងដោយសមាសធាតុបីផ្សេងគ្នាដែលហៅថាផ្នែកដែលធ្វើការជាមួយគ្នា ដើម្បីផ្តល់ព័ត៌មានទីតាំង។ ជីភីអេសទាំង ៣ ផ្នែកនោះរួមមាន៖

- អវកាស (ផ្កាយរណប) - ផ្កាយរណបហោះព័ទ្ធជុំវិញផែនដី ហើយបញ្ជូនសញ្ញាទៅអ្នកប្រើប្រាស់នូវទីតាំងភូមិសាស្ត្រ និងកាលបរិច្ឆេទ ពេលវេលា ដែលធ្វើសំណើ។
- ទីតាំងលើដី នេះជាផ្នែកមួយនៃការត្រួតពិនិត្យ ដែលត្រូវបានបង្កើតឡើងដោយស្ថានីយ៍ មូលដ្ឋាននៅផែនដីចំណុចស្ថានីយត្រួតពិនិត្យផ្សេងៗ និងអង់តែនគោល។ គួរកត់សម្គាល់ថា សមាសធាតុនេះជួយផ្ទៀងផ្ទាត់បន្ថែមដោយប្រើកូអរដោណេនៃអង់តែនផ្សេងៗដែលផ្តល់សញ្ញាជាអចិន្ត្រៃយ៍ ដូចជាអង់តែនទូរសព្ទជាដើម ធៀបនឹងទិន្នន័យនៃផ្កាយរណប។
- ឧបករណ៍អ្នកធ្វើសំណើនិងទទួល ជាឧបករណ៍បញ្ជូនសំណើនិងរង់ចាំទទួល រួមមានធាតុដូចជា នាឡិកា

[5] -ដ- ទំព័រ 74

6 https://www.geotab.com/blog/what-is-gps/

ឆ្លាត ទូរសព្ទឆ្លាត ជីភីអេស ជាដើម។

គួរកត់សម្គាល់ថា តាមរយៈចំណុចដែលរៀបរាប់ខាងលើ យើងអាចសន្និដ្ឋានថា យើងនឹងទទួលទិន្នន័យល្បឿងខ្លាំង ប្រសិនបើយើងនៅទីតាំងដាច់ស្រយាល (មិនសូវមានអង់តែន) , នៅពេលដែលទូរសព្ទឆ្លាតមិនមានសេវាគ្រប់គ្រាន់ , នៅពេលអាកាសធាតុមិនល្អ (បាត់បង់សញ្ញាបញ្ជូន/ទទួល)

## ៥. កម្មវិធីផែនទីអនឡាញ អហ្វឡាញ និងហ្គូហ្គលម៉ែប

យោងតាម Stefan Steiniger and Robert Weibel [7] សុហ្វវែរដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើត គ្រប់គ្រង វិភាគ និងបង្ហាញឱ្យមើលឃើញ (visualize) នូវទិន្នន័យភូមិសាស្ត្រ ដែលជាទិន្នន័យដែលទាក់ទងនឹងទីកន្លែងនានានៅលើផែនដី ត្រូវបានគេហៅថា សុហ្វវែរប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS Software) ។ ដោយសារការការអនុវត្តជាច្រើននៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រ សុហ្វវែរទាំងនោះជំនួយដល់មុខងារខុសៗគ្នានៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងត្រូវបានបែងចែកជាប្រភេទខុសៗគ្នា ។

ជាធម្មតា មុននឹងគេធ្វើអាចវិភាគអំពីព័ត៌មានភូមិសាស្ត្របាន គេត្រូវប្រមូលទិន្នន័យពីៈ ទីតាំងជាក់ស្តែង ផែនទី ឬរូបភាពផ្កាយរណប ឬអ្នកផ្តល់ទិន្នន័យនានា ។ ដូចនេះជាបឋមគេត្រូវ ១) បង្កើត (create) ឬ ២) កែប្រែ (edit)ទៅតាមការជាក់ស្តែង និង ៣) រក្សាទុក (store) ទិន្នន័យ ។ ប្រសិនបើទិន្នន័យត្រូវបានទទួលមកពីប្រភពខុសៗគ្នា គេត្រូវការ ៤) មើល (view) និង ៥) ធ្វើសមាហរណកម្ម (integrate) វាទៅក្នុងទិន្នន័យដែលមានស្រាប់ ។ ដើម្បីឆ្លើយនឹងសំណួរនានា គេត្រូវ ៦)ស្វែងរក (query) និង ៧)វិភាគទិន្នន័យ ។ ពេលខ្លះការងារវិភាគមួយចំនួនទាមទារ ៨) ការបម្លែងទិន្នន័យ (transform and manipulation) ជាមុន ហើយជាចុងក្រោយលទ្ធផលនៃការវិភាគនានានឹងត្រូវ ៩) ធ្វើការបង្ហាញនៅលើផែនទី ។

**ហ្គូហ្គលម៉ែប** (Google Maps)

កម្មវិធីនេះបង្កើតឡើងដោយក្រុមហ៊ុន ហ្គូហ្គល នៅឆ្នាំ ២០០៥ ដែលមានទ្រង់ទ្រាយ ជាកម្មវិធីដែលដំណើរការក្នុងអ៊ីនធឺណែត។ វាជាកម្មវិធីមួយ ក្នុងចំណោមកម្មវិធីវេបរបស់ហ្គូហ្គល ដែលទទួលការពេញនិយមពីសំណាក់អ្នកប្រើប្រាស់នៃប្រភេទស្រដៀងគ្នានេះ រួមមាន ហ្គូហ្គលអ៊ីត (Google Earth) ហ្គូហ្គល ស្ទ្រីតវ្យូ (Google Street View)។

ហ្គូហ្គលម៉ែប [8] ជាកម្មវិធីដែលបម្រើអតិថិជនលើអ៊ីនធឺណែត ដោយផ្តល់នូវព័ត៌មានលម្អិត អំពីទីតាំងភូមិសាស្ត្រនីមួយៗ និងតំបន់រៀងអាយ នៅគ្រប់ទីតាំងទាំងអស់ក្នុងពិភពលោក។ លើសពីនេះ វាផ្តល់ព័ត៌មានពីផ្លូវគមនាគន៍ ដែលអ្នកប្រើប្រាស់អាចយកជាផែនទីផ្លូវបាន។ នៅតំបន់ទីប្រជុំជន កម្មវិធីនេះមានផ្តល់នូវព័ត៌មាន ដែលភ្ជាប់មកពីកម្មវិធីមួយទៀត គឺ ហ្គូហ្គល ស្ទ្រីតវ្យូ (Google Street View) ដែលអាចមើលឃើញនូវរូបថត ដែលផ្តិតយកទិដ្ឋភាពទីនោះថតពីយន្តហោះ។ សេវាឥតគិតថ្លៃនេះ តម្រូវឱ្យអតិថិជនមានតែគណនីជីមែល (Gmail) ដែលអាចបង្កើតដោយឥតគិតថ្លៃតែប៉ុណ្ណោះ។

ហ្គូហ្គលម៉ែប ផ្តល់នូវសេវាច្រើនយ៉ាងដូចតទៅៈ

- ផែនទីផ្លូវប្រកបដោយការបញ្ជាទិសដៅ (មានប្រាប់កន្លែងត្រូវបត់ ទិសធ្វើដំណើរ ទីតាំង បច្ចុប្បន្ន...) សម្រាប់អ្នកថ្មើរជើង អ្នកជិះកង់ និងយានយន្ត។ នៅទីប្រជុំជនធំៗដែលមាន រថយន្តក្រុង និងរថភ្លើងក៏មានបង្ហាញផងដែរ។
- កម្មវិធីហ្គូហ្គលម៉ែប ផ្តល់លទ្ធភាពដល់ស្ថាប័ននានា ដើម្បីបង្កើតផែនទីទីតាំងគោល និងសាខារបស់ខ្លួនសម្រាប់ប្រើប្រាស់ក្នុងក្រុមជាលក្ខណៈឯកជន ឬក៏បើកចំហជាសាធារណៈ។

---

7 Stefan Steiniger and Robert Weibel, 2009

8 https://whatis.techtarget.com/definition/Google-Maps

- កម្មវិធីហ្គូហ្គលម៉ែប ក្នុងទូរសព្ទស្មាត បង្ហាញទីតាំងបច្ចុប្បន្ន ដែលកំពុងស្ថិតនៅ គិតតាម ជីភីអេស (Global Positioning System (GPS)) ដែលភ្ជាប់ជាមួយទូរសព្ទស្មាតនោះ ដែលពិតណាស់ភាពប្រាកដប្រជា យោងទៅតាមសេវាទូរសព្ទ។
- ហ្គូហ្គល ស្ទ្រីតវ្យូ (Google Street View) ដែលភ្ជាប់ជាមួយ អាចឱ្យអ្នកប្រើប្រាស់មើលឃើញទាំងស្ថានភាពផ្លូវ និងទេសភាពជុំវិញ (តាមរូបថត៣៦០ ដែលបានថតដោយក្រុមការងារហ្គូហ្គលពីពេលមុន) ផងដែរ។ លើសពីនេះ បើសិនជាតំបន់ដែលត្រូវឆ្លងកាត់ មានសេវាទូរសព្ទខ្សោយ អ្នកប្រើប្រាស់អាចដោនឡូតទុកជាមុន ផែនទីតំបន់ដែលខ្លួនចង់ទៅ ទុកជាមុនបានដែរ។
- លើសពីនេះ ក៏មានផែនទីភពដទៃដែលមនុស្សលោកអាចបង្កើតបាន ដូចជាផែនទី ឋានព្រះ ចន្ទ ឋានព្រះអង្គារ ជាដើម។
- ហ្គូហ្គលម៉ែប បម្រើអតិថិជនលើអ៊ីនធឺណែត ដោយផ្តល់នូវព័ត៌មានលម្អិតអំពីទីតាំងភូមិសាស្ត្រ មើលឃើញជាពីរបែប គឺ វិមាត្រពីរ (បែបប្លង់) និង វិមាត្របី (បែបផែនទីរយៈកម្ពស់)។ ផែនទីរូបពីផ្កាយរណប បានមកពីការថត ដោយយន្តហោះពិសេស មានភាពច្បាស់ខ្សោយ ឬខ្លាំង អាស្រ័យលើទីតាំងនោះ។ ឧទាហរណ៍ នៅតំបន់ប្រជុំជនរូបអាចពង្រីកមើលបានច្បាស់ តែតំបន់ព្រៃភ្នំ ច្រើនតែព្រិល ដោយមូលហេតុមិនមានតម្រូវការចាំបាច់ជុំ ជុំនោះឯង។

## ៦. ការរៀបចំផែនទីអនឡាញសាលារៀនមធ្យមសិក្សា

ផែនទីទីតាំងសាលារៀន ត្រូវបានរៀបចំឡើងដើម្បីធ្វើការបង្ហាញទិន្នន័យសាលារៀនដែលយើងរកឃើញផង និងជាឧបករណ៍មួយដាច់ដោយឡែកសម្រាប់ស្វែងរកទីតាំងសាលារៀននៅលើ Google Maps ជាក់ស្តែងផង ។

ផែនទីត្រូវបានបង្កើតដោយការ នាំចូលទិន្នន័យអំពីសាលារៀន និងទីតាំងភូមិសាស្ត្រទៅក្នុង Google Mymaps ។ ខាងក្រោមនេះគឺជាបញ្ជីកូអរដោណេសាលារៀនដែលយើងកសាងរួច ។ ក្នុងនោះ សាលារៀនត្រូវបែងចែកជា បី ប្រភេទ៖ ១) វិទ្យាល័យ ២) វិទ្យាល័យទុតិយភូមិ (មានតែថ្នាក់ទី ១០ ដល់ទី ១២) និង ៣)អនុវិទ្យាល័យ។

| 1 | ល.រ | ខេត្ត | ស្រុក | ឃុំ | ទីតាំងសាលា | កូដសាលា | កូដភូមិសាស្ត្រ | ឈ្មោះ | ប្រ | ចំនួនសិ | ស្រី | GIS | 7a | 7g | 7c |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2 | 1 | កណ្ដាល | កណ្ដាលស្ទឹង | កណ្ដោក | គោករមៀត | 8010705710 | 80107 | អនុវិទ្យាល័យគោករមៀត | 3 | 144 | 79 | 11.401228,104.896 | 48 | 23 | |
| 3 | 2 | កណ្ដាល | កណ្ដាលស្ទឹង | គោកត្រប់ | ក្រាំងថ្លៃ | 8010902711 | 80109 | អនុវិទ្យាល័យគោកត្រប់ | 3 | 183 | 102 | 11.405281, 104.84 | 72 | 40 | |
| 4 | 3 | កណ្ដាល | កណ្ដាលស្ទឹង | ជើងកើប | ស្រុកជំ | 8010502708 | 80105 | អនុវិទ្យាល័យជើងកើប | 3 | 95 | 44 | 11.430713,104.879 | 37 | 13 | |
| 5 | 4 | កណ្ដាល | កណ្ដាលស្ទឹង | ដើមឫស | ដើមឫស | 8010603903 | 80106 | វិទ្យាល័យសម្ដេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុនរ៉ | 5 | 279 | 126 | 11.432966, 104.77 | 85 | 41 | |
| 6 | 5 | កណ្ដាល | កណ្ដាលស្ទឹង | ដើមឫស | ជាង | 8010612701 | 80106 | អនុវិទ្យាល័យហ៊ុនសែនដើមឫស | 3 | 217 | 108 | 11.441130, 104.74 | 74 | 36 | |
| 7 | 6 | កណ្ដាល | កណ្ដាលស្ទឹង | ក្បៀង | អង្គក្លើ | 8012501716 | 80125 | អនុវិទ្យាល័យហ៊ុនសែនក្បៀង | 3 | 192 | 95 | 11.355235,104.771 | 75 | 41 | |
| 8 | 7 | កណ្ដាល | កណ្ដាលស្ទឹង | ត្រពាំងវែង | ព្រៃទទឹង | 8012701706 | 80127 | អនុវិទ្យាល័យត្រពាំងវែង | 3 | 380 | 189 | 11.402199,104.784 | 168 | 88 | |
| 9 | 8 | កណ្ដាល | កណ្ដាលស្ទឹង | ថ្មី | ថ្មី | 8010801715 | 80108 | អនុវិទ្យាល័យថ្មី | 3 | 110 | 60 | 11.399487,104.812 | 54 | 23 | |
| 10 | 9 | កណ្ដាល | កណ្ដាលស្ទឹង | ទ្រា | ត្រស់ | 8012801709 | 80128 | អនុវិទ្យាល័យទ្រា | 3 | 203 | 114 | 11.376092,104.830 | 74 | 47 | |
| 11 | 10 | កណ្ដាល | កណ្ដាលស្ទឹង | បារគូ | ស្វាយមីង | 8010306901 | 80103 | វិទ្យាល័យហ៊ុនសែនកំពង់កន្ទួត | 5 | 1392 | 668 | 11.428403, 104.81 | 132 | 64 | |
| 12 | 11 | កណ្ដាល | កណ្ដាលស្ទឹង | បឹងខ្យាង | ប្រឡាយ | 8010405705 | 80104 | អនុវិទ្យាល័យបឹងខ្យាង | 3 | 338 | 178 | 11.367053, 104.87 | 136 | 75 | |
| 13 | 12 | កណ្ដាល | កណ្ដាលស្ទឹង | ព្រែករកា | កោះខ្នុរ | 8011503714 | 80115 | អនុវិទ្យាល័យព្រែករកា | 3 | 168 | 75 | 11.360326, 104.84 | 69 | 36 | |
| 14 | 13 | កណ្ដាល | កណ្ដាលស្ទឹង | ព្រែកស្លែង | ពន់ចាន | 8011602902 | 80116 | វិទ្យាល័យព្រែកស្លែង | 5 | 829 | 393 | 11.377256, 104.86 | 62 | 31 | |
| 15 | 14 | កណ្ដាល | កណ្ដាលស្ទឹង | ព្រះពុទ្ធ | ក្រាំងទ្រា | 8011301718 | 80113 | អនុវិទ្យាល័យព្រះពុទ្ធ | 3 | 42 | 20 | 11.423495,104.856 | 15 | 5 | |
| 16 | 15 | កណ្ដាល | កណ្ដាលស្ទឹង | រកា | គ្រួច | 8011706712 | 80117 | អនុវិទ្យាល័យរកា | 3 | 132 | 70 | 11.439468,104.718 | 44 | 31 | |
| 17 | 16 | កណ្ដាល | កណ្ដាលស្ទឹង | រលាំងកែន | ព្រៃកន្ទ្រា | 8011806704 | 80118 | អនុវិទ្យាល័យហ៊ុនសែនរលាំងកែន | 3 | 203 | 91 | 11.445981,104.667 | 88 | 38 | |
| 18 | 17 | កណ្ដាល | កណ្ដាលស្ទឹង | សៀមរាប | សៀមរាប | 8012201703 | 80122 | អនុវិទ្យាល័យសៀមរាប | 3 | 210 | 99 | 11.401765,104.860 | 93 | 35 | |
| 19 | 18 | កណ្ដាល | កណ្ដាលស្ទឹង | អន្លង់រមៀត | ដើមក្រាំង | 8010205717 | 80102 | អនុវិទ្យាល័យទួលសាលា | 3 | 182 | 87 | 11.419521, 104.79 | 45 | 22 | |
| 20 | 19 | កណ្ដាល | កណ្ដាលស្ទឹង | អំពៅព្រៃ | គាដោលទី២ | 8010104707 | 80101 | អនុវិទ្យាល័យគោកចេះ | 3 | 268 | 141 | 11.382318,104.897 | 117 | 58 | |

យើងអាចបោះពុម្ពផែនទីដែលយើងបង្កើតរួច ឬ Export ទៅជាហ្វាល .kml ឬ .kmz ដើម្បីយកទៅបើកក្នុងកម្មវិធី GIS នានា និង Embed ចូលក្នុងគេហទំព័រផ្ទាល់របស់យើង ។

ដើម្បីចូលទៅបើកមើលទិន្នន័យ Maps នោះ ៖

- គេត្រូវភ្ជាប់អ៊ីនធើណេត រួចចូលទៅកាន់ https://www.google.com/maps ដោយប្រើ account ផ្ទាល់ខ្លួន ( sonimithsun@gmail.com )

* ចុចលើ menu រួចចូលទៅ Your places រួចរើសយក Maps នឹងទទួលបានផែនទីដែលបានបង្កើតពីមុនមក ។




ក្រៅពីនេះ យើងក៏អាចចែករំលែកផែនទី ស្វែងរកឈ្មោះសាលារៀន បោះពុម្ពផែនទី និងរក្សាទុកហ្វាលជា .kml ឬ .kmz ដើម្បីបើកបង្ហាញនៅលើ GIS Software ផងដែរ ។ ឧទាហរណ៍៖ យើងអាចបើកមើលហ្វាល .kmz របស់យើងនៅលើ Google Earth Pro ផងដែរ ។

## គន្ថនិទ្ទេស

1. https://www.esri.com/en-us/what-is-gis/overview , 20/07/19
2. Nicholas Chrisman , Exploring Geographic Information Systems, First Edition, John Wiley & Sons, Inc., USA, 1997.
3. Michael N. Demers, Fundamentals of Geographic Information Systems, 7th Edition, John Wiley & Sons, Inc., USA, 1997.
4. Maribeth Price ,MASTERING ArcGIS, SEVENTH EDITION, © Copyright 2016 by McGraw-Hill Education.
5. https://www.geotab.com/blog/what-is-gps/ , 10-12-19
6. Stefan Steiniger and Robert Weibel, GIS Software - A description in 1000 words, University of Calgary (CA), University of Zurich (CH), 08.May.2009
7. https://whatis.techtarget.com/definition/Google-Maps , 10-12-19

# ទំនាក់ទំនងចិន-ជប៉ុន ស្ដីពីបញ្ហាសមុទ្រចិនខាងត្បូង និងតួនាទីរបស់កម្ពុជា

*បេក្ខជនបណ្ឌិត៖* ***ហេង សារិទ្ធ***
*គ្រូណែនាំ៖* ***បណ្ឌិត យង់ ពៅ***

សមុទ្រចិនខាងត្បូងគឺជាផ្នែកមួយនៃតំបន់ប៉ាស៊ីហ្វិក និងជាផ្លូវទឹកមួយសំខាន់តភ្ជាប់គ្នាពីមហាសមុទ្រឥណ្ឌា ចូលទៅមហាសមុទ្រប៉ាស៊ីហ្វិក ជាទីតាំងដ៏ល្អសម្រាប់ការធ្វើនាវាចរណ៍។ សមុទ្រនេះមានទីតាំងនៅខាងត្បូងប្រទេសចិន ខាងកើតប្រទេសវៀតណាម និងកម្ពុជា ភាគពាយ័ព្យប្រទេសហ្វីលីពីន និងខាងជើងប្រទេសឥណ្ឌូនេស៊ី។ ប្រទេសទាមទារអធិបតេយ្យភាពទាំងប្រាំមួយនៅសមុទ្រចិនខាងត្បូង រួមមានចិន ម៉ាឡេស៊ី វៀតណាម ប្រ៊ុយណេ ហ្វីលីពីន និងតៃវ៉ាន់។ ក្រោយពីបានចូលជាសមាជិកអាស៊ានក្នុងឆ្នាំ១៩៩៩ កម្ពុជាបានដើរតួនាទីយ៉ាងសកម្មក្នុងការចូលរួមចំណែកដោះស្រាយវិបត្តិសមុទ្រចិនខាងត្បូង ។ ក្នុងឆ្នាំ២០០២ ក្នុងពេលកម្ពុជាបានធ្វើជាប្រធានអាស៊ានជាលើកទី១ សេចក្ដីថ្លែងការណ៍ស្ដីពីការប្រតិបត្តិរបស់បណ្ដាភាគីនៅសមុទ្រចិនខាងត្បូង ត្រូវបានចុះចុះហត្ថលេខាដោយអាស៊ាន និងចិន នៅភ្នំពេញ។

ចំពោះចិន សមុទ្រចិនខាងត្បូងជាផ្លូវទឹកដ៏សំខាន់ ភ្ជាប់ពីមហាសមុទ្រឥណ្ឌាទៅសមុទ្រចិនខាងកើត ដែលចិនអាចទាញប្រយោជន៍យ៉ាងធំធេង ក្នុងវិស័យដឹកជញ្ជូន និងជាតំបន់យុទ្ធសាស្ត្ររបស់ចិន ក្នុងការទប់ទល់ការឈ្លានពានពីសំណាក់មហាអំណាចដទៃទៀត។ ចិនអាចកាន់កាប់ផ្លូវទឹក អាចហាមឃាត់កប៉ាល់ នាវាចម្បាំង មិនឱ្យធ្វើដំណើរ ក្រោមលេសគំរាមកំហែងដល់សន្តិសុខប្រទេសរបស់ខ្លួន ជាពិសេសគឺរាំងខ្ទប់ ការផ្គត់ផ្គង់លើមូលដ្ឋានយោធាសហរដ្ឋអាមេរិក នៅប្រទេសជប៉ុន ដែលជាប្រទេសជិតខាង។ ម្យ៉ាងវិញទៀត វាជាចំណុចសក្ដានុពលក្នុងការរក្សាតួនាទីនយោបាយចិន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយពង្រីកឥទ្ធិពល តាមរយៈសេដ្ឋកិច្ច និងកម្លាំងយោធា ដើម្បីកាត់បន្ថយការជ្រៀតចូលរបស់សហរដ្ឋអាមេរិកមកក្នុងតំបន់ ទប់ស្កាត់ការហ៊ុំព័ទ្ធប្រទេសចិន ក្រោមរូបភាពដាក់មូលដ្ឋានយោធាបរទេស នៅប្រទេសកូរ៉េចិន និងការចងសម្ព័ន្ធមិត្តជាដើម។ ចំណុចចម្បងមួយទៀត គឺជាតំបន់សំបូរភោគទ្រព្យ ដូចជារ៉ែ ប្រេងកាត និងឧស្ម័នធម្មជាតិ សម្រាប់ផ្គត់ផ្គង់ឧស្សាហកម្មចិន និងជាកន្លែងនេសាទត្រីសំខាន់ផងដែរ។

ជប៉ុនត្រូវការសមុទ្រចិនខាងត្បូង ដើម្បីទប់ស្កាត់ឥទ្ធិពលចិន មកលើសមុទ្រខាងកើត ពីព្រោះកំពុងតែមានភាពតានតឹង លើជម្លោះដែនកោះស៊ីកាគុ ដោយបារម្ភអំពីយុទ្ធសាស្ត្រចិន ក្នុងការដណ្ដើមយកកោះតៃវ៉ាន់ និងបន្តមានជម្លោះនៅប្រជុំកោះមួយចំនួនថែមទៀត។ ចំណុចសំខាន់មួយទៀត ជប៉ុនមិនអាចឱ្យចិនកាន់កាប់សមុទ្រចិនខាងត្បូងផ្ដាច់មុខបានទេ ដែលប៉ះ

ពាល់ដល់សកម្មភាពនេសាទ និងការធ្វើនាវាចរណ៍ដោយសេរី និងការបញ្ជ្រាបឥទ្ធិពលកាន់តែខ្លាំង ទៅលើប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីអាគ្នេយ៍ ជាពិសេសនៅកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

## ១. ប្រទេសចិននៅក្នុងជម្លោះសមុទ្រចិនខាងត្បូង

ចិនបានចាត់ទុកសមុទ្រចិនខាងត្បូងជាសមុទ្រដែនដី និងដែនទឹកប្រវត្តិសាស្ត្ររបស់ខ្លួន ដែលអាចមានសិទ្ធហាមឃាត់នាវាបរទេស មិនថាក្នុងគោលដៅពាណិជ្ជកម្ម ឬយោធា មិនឱ្យធ្វើសកម្មភាពឆ្លងកាត់ ដែលនេះជាការកាត់ផ្តាច់ផ្លូវនាវាចរណ៍ចូលទៅក្នុងសមុទ្រខាងកើត ហើយតែងតែត្រូវបានសហរដ្ឋអាមេរិក និងជប៉ុន ធ្វើការប្រឆាំង ដោយទាមទារឱ្យរក្សាបាននូវនាវាចរណ៍ និងការហោះហើរដោយសេរី។ ដើម្បីកាន់កាប់លើដែនទឹកដ៏ធំទូលាយនេះ ចិនបានដាក់ពង្រាយនាវាមុជទឹកជាច្រើនគ្រឿង ដែលមានមូលដ្ឋាននៅកោះហៃណាន សម្រាប់ធ្វើប្រតិបត្តិការទាន់ពេលវេលា ក្នុងករណីមានបញ្ហាណាមួយកើតឡើង។ នៅក្នុងបញ្ហានយោបាយ ចិនតែងព្យាយាមបញ្ចុះបញ្ចូលឱ្យប្រទេសមានជម្លោះ ដោះស្រាយតាមរយៈការចរចាទ្វេភាគី តាមគោលការណ៍មួយជាក់លាក់ ដែលរួមបញ្ចូលច្បាប់អន្តរជាតិ ហើយចិនក៏បានពង្រឹងវិស័យយោធានៅលើសមុទ្រផ្ទាល់ និងកាន់កាប់ប្រជុំកោះមួយចំនួននៅសមុទ្រចិនខាងត្បូងផងដែរ។

ចំណុចខ្វែងគ្នានៃនយោបាយជប៉ុន-ចិន ក្នុងអាស៊ាន គឺពាក់ព័ន្ធនឹងសន្តិសុខតំបន់ ដោយសារតែជម្លោះភូមិសាស្ត្រនយោបាយ។ ជារឿយៗ ចិនតែងតែចោទប្រកាន់អំពីចេតនាចង់ហ៊ុំព័ទ្ធប្រទេសចិន ពីសហរដ្ឋអាមេរិក ដែលមានជប៉ុន ជាសម្ព័ន្ធមិត្ត តាមរយៈការតាំងមូលដ្ឋានទ័ពនៅកោះអូគីណាវ៉ា។ ដូច្នេះចិនត្រូវការអាស៊ាន ដើម្បីទប់ស្កាត់ការជ្រៀតជ្រែកចូលតំបន់សមុទ្រចិនខាងត្បូង ពីព្រោះតែវាជាចំណុចយុទ្ធសាស្ត្រនយោបាយ ហើយជាតំបន់មានសក្តានុពលផ្នែកសេដ្ឋកិច្ច ដែលកំពុងមានជម្លោះ។ ដោយឡែកជប៉ុន ចង់ឱ្យអាស៊ាន ប្រឆាំងឥទ្ធិពលចិនលើតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ដែលអាចកាត់បន្ថយការគំរាមកំហែងដល់សន្តិសុខជប៉ុន និងតំបន់ ពីព្រោះភាពរីកចំរើននៃសេដ្ឋកិច្ច និងយោធាចិន គឺអាចគំរាមកំហែងដល់ជប៉ុនយ៉ាងខ្លាំង ដោយសារតែជប៉ុនកំពុងមានជម្លោះដែនសមុទ្រជាមួយចិន។

នៅក្នុងការរីកចម្រើនទៅមុខបន្តិចម្តងៗ ក្នុងការចរចាក្រមប្រតិបត្តិនៃសមុទ្រចិនខាងត្បូង (COC) ចាប់តាំងពីឆ្នាំ២០១៣ មក ជម្លោះរវាងចិន និងភាគីជម្លោះនៃសមាជិកអាស៊ានបានកើនឡើងបន្ទាប់ពីឆ្នាំ ២០១១។ នៅក្នុងឆមាសទីមួយនៃឆ្នាំ២០១៩ នាវាឃ្លាំមើលដែនសមុទ្រចិនបានរំខានដល់ការស្ទង់បាតសមុទ្រដែលត្រូវបានធ្វើឡើងដោយវៀតណាម និងហ្វីលីពីននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ពួកគេ(EEZs) ។ កាលពីចុងខែឧសភា ឆ្នាំ ២០១៤ នាវាស៊ើបការណ៍សមុទ្រចិនបានកាត់ផ្តាច់ខ្សែរុករក នៃនាវាស្ទង់ប្រេងវៀតណាមមួយដែលកំពុងស្វែងរកអណ្តូងប្រេងនិងឧស្ម័ននៅចម្ងាយ ១២០ម៉ាយពីឆ្នេរសមុទ្រវៀតណាមខាងត្បូង [1]។

[1] Zhao Hong, "THE SOUTH CHINA SEA DISPUTE AND CHINA-ASEAN RELATIONS," *Asian Affairs* 44, no. 1 (2013): xx, doi:10.1080/03068374.2012.760785.

នៅខែមេសាឆ្នាំ ២០១២ ការប៉ះទង្គិចថ្មីរវាងចិន និងហ្វីលីពីនបានកើតឡើងនៅក្នុងដែនទឹកជុំវិញកោះ Scarborough Shoal (កោះ Huangyan ជាភាសាចិន)។ ភាពតានតឹងរវាងទីក្រុងប៉េកាំង និងទីក្រុងម៉ានីលបានកើនឡើងបន្ទាប់ពីនោះមកហ្វីលីពីនចាំបាច់ស្វែងរកនីតិវិធីដោះស្រាយជម្លោះតាមច្បាប់អន្តរជាតិ។ នៅខែមករាឆ្នាំ ២០១៣ រដ្ឋាភិបាលហ្វីលីពីនបានយកជម្លោះសមុទ្រចិនខាងត្បូងទៅតុលាការមជ្ឈត្តិកម្មអន្តរជាតិ ក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) និងបានស្នើសុំឱ្យក្រុមប្រឹក្សានេះធ្វើការជំទាស់ទៅនឹងភាពស្របច្បាប់នៃអ្វីដែលហៅថា" ខ្សែត្រប្រាំបួនចំណុច" និងការទាមទារតាមរយៈសិទ្ធិប្រវត្តិសាស្ត្រលើសមុទ្រចិនខាងត្បូង។នៅខែកក្កដាឆ្នាំ២០១៦ តុលាការមជ្ឈត្តិកម្មអចិន្ត្រៃយ៍ (PCA) នៅទីក្រុងឡាអេបានចេញសេចក្តីសម្រេចរបស់ខ្លួនគាំទ្រការអះអាងរបស់ហ្វីលីពីន ដែលបានប្រានចោលការទាមទារភាគច្រើនរបស់ចិន។ អាមេរិក និងសម្ព័ន្ធមិត្តរួមទាំងជប៉ុនផងដែរ បានប្រកាសគាំទ្រសាលក្រមតុលាការមជ្ឈត្តិកម្មអចិន្ត្រៃយ៍នេះ ហើយបានអំពាវនាវឱ្យចិនគោរពតាម ដែលឱ្យចិនមានប្រតិកម្មតបត វិញយ៉ាងខ្លាំងក្លា។

## ២. ប្រទេសជប៉ុននៅក្នុងជម្លោះសមុទ្រចិនខាងត្បូង

ការព្រួយបារម្ភរបស់ជប៉ុនទៅលើសមុទ្រចិនខាងត្បូង បានចាប់ផ្តើមនៅទសវត្សឆ្នាំ ១៩៦០ ដែលភាគច្រើនគឺជាបញ្ហាសន្តិសុខនៅតាមបណ្តោយផ្លូវសមុទ្រ។ សមុទ្រចិនខាងត្បូងគឺជាតំបន់មានសារៈសំខាន់ ជាយុទ្ធសាស្ត្រនៅអាស៊ីអាគ្នេយ៍ដែលមានសារៈសំខាន់សម្រាប់ការផ្គត់ផ្គង់ពាណិជ្ជកម្មនិងថាមពលរបស់ជប៉ុន។ ប្រទេសជប៉ុនបានពឹងផ្អែកជាប្រចាំលើការនាំចូលធនធានថាមពលរបស់ខ្លួន(៩៦ភាគរយ ហើយមជ្ឈឹមបូព៌ាបានផ្គត់ផ្គង់តម្រូវការប្រេងភាគច្រើន របស់ជប៉ុន)។ ច្រកផ្លូវទឹកគមនាគមន៍សំខាន់បំផុតរបស់ជប៉ុន គឺឆ្លងកាត់សមុទ្រចិនខាងត្បូង និងច្រកម៉ាឡាកា។ យោងតាមការប៉ាន់ស្មានមួយ ក្នុងករណីមានភាពតានតឹងកម្រិតមធ្យមនៅសមុទ្រចិនខាងត្បូង ថ្លៃធានារ៉ាប់រងជាមធ្យមសម្រាប់កប៉ាល់ពាណិជ្ជកម្មនឹងកើនឡើងប្រមាណ ១០ លានយន់ក្នុងមួយថ្ងៃ នៅពេលធ្វើដំណើរឆ្លងកាត់តំបន់នោះ [2]។ បន្ទាប់ពីឆ្នាំ ២០១០ វត្តមានជប៉ុននៅសមុទ្រចិនខាងត្បូងបានកើនឡើង ដោយសារជម្លោះនៅលើសមុទ្រ មានទំនាក់ទំនងគ្នាមិនអាចវាស់វែងបានជាមួយនឹងជម្លោះដែនទឹករបស់ខ្លួន ជាមួយចិន។

ពាក់ព័ន្ធនឹងភាពវត្តមានយោធាចិន នៅក្នុងសមុទ្រចិនខាងត្បូង ជប៉ុនបានធ្វើការឆ្លើយតបទាំងផ្លូវការទូត និងយោធា ដោយបានស្តីបន្ទោសរដ្ឋាភិបាលក្រុងប៉េកាំង និងអំពាវនាវឱ្យមានដំណោះស្រាយចរចាគ្នា ហើយតែងតែសហការជាមួយសហរដ្ឋអាមេរិក និងប្រទេសសមាជិកអាស៊ានដទៃទៀត នៅក្នុងវេទិកាផ្សេងៗ ជាពិសេសនៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា

[2] Sueo Sudo, "Japan’s Mekong Policy and Myanmar: Complementing a Viable Strategic Partnership," ResearchGate, last modified February 2020, https://www.researchgate.net/publication/339532235_Japan%27s_Mekong_Policy_and_Myanmar_Complementing_a_Viable_S

ប្រចាំឆ្នាំ។ ចំពោះផ្នែកសន្តិសុខផ្លូវសមុទ្រវិញ ជប៉ុនបានចូលរួមចំណែកសំខាន់ នៅក្នុងសកម្មភាពប្រឆាំងឧក្រិដ្ឋកម្មចោរសមុទ្រ និងជួយដល់ការអភិវឌ្ឍបណ្ដាញផ្ទាំសមុទ្រ ដែលលាតសន្ធឹងពីតំបន់អាស៊ីអាគ្នេយ៍ ដល់មហាសមុទ្រឥណ្ឌា និងផ្ដល់កប៉ាល់ល្បាតដល់ប្រទេសវៀតណាម និងហ្វីលីពីន នៅឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០១៧ ជប៉ុនបានបញ្ជូននាវាទំនើបមួយឈ្មោះ IZUMO នៅក្នុងសមយុទ្ធយោធាមួយ ជាមួយសហរដ្ឋអាមេរិក និងឥណ្ឌា ដែលមានសមត្ថភាពប្រឆាំងនាវាមុជទឹក។ លើសពីនេះ ជប៉ុនបានដាក់ពង្រាយយន្តហោះចម្បាំងនៅតាមកោះក្បែរព្រំដែន ដើម្បីបង្ការទៅនឹងការប៉ះទង្គិចណាមួយ ជាមួយមូលដ្ឋានទ័ពចិនដែលកំពុងសាងសង់នៅក្នុងសមុទ្រចិនខាងត្បូង។

ប្រទេសជប៉ុនមានការប្ដេជ្ញាចិត្តជាយូរមកហើយចំពោះស្ថាប័នពហុភាគី ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចការដែនសមុទ្រនៅអាស៊ីបូព៌ា ដោយជប៉ុនសង្ឃឹមថានឹងពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការពហុភាគី ពីសុវត្ថិភាពដែនសមុទ្រ ដល់សន្តិសុខដែនសមុទ្រ ដោយបញ្ចូលជាតុល្យភាពស្ថាប័នប្រឆាំងនឹងចិន។ ជប៉ុនបានព្យាយាមពង្រឹងការសម្របសម្រួលជាមួយបណ្ដាប្រទេសជាដៃគូ ដែលមានអំណាចនយោបាយប្រហាក់ប្រហែលគ្នា ក្រោមគំនិតភូមិសាស្ត្រថ្មីនៃ 'ឥណ្ឌូ-ប៉ាស៊ីហ្វិក'។

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានផ្ដល់ឱ្យប្រទេសហ្វីលីពីននូវកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការអភិវឌ្ឍប្រព័ន្ធ ក្នុងការអប់រំសន្តិសុខដែនសមុទ្រ និងការគ្រប់គ្រងធនធានមនុស្សក៏ដូចជាផ្ដល់ជំនួយសម្រាប់ភាពខ្លាំងនៃប្រព័ន្ធទំនាក់ទំនងសម្រាប់សុវត្ថិភាពដែនសមុទ្រ។ JICA ក៏បានផ្ដល់កិច្ចសហប្រតិបត្តិការបច្ចេកទេសដល់ម៉ាឡេស៊ីសម្រាប់គម្រោងកែលម្អសមត្ថភាពសុវត្ថិភាពដែនសមុទ្រ និងជំនួយឥតសំណងក្នុងការរៀបចំឧបករណ៍សម្រាប់ពង្រឹងផ្ទាំសមុទ្រ។ ជំនួយទាំងនេះមានគោលបំណងជាចម្បងក្នុងការលើកកម្ពស់សមត្ថភាពរបស់បណ្ដាប្រទេសអ្នកទទួលនៅក្នុងសុវត្ថិភាពដែនសមុទ្រ។ នៅខែមិថុនា ឆ្នាំ ២០០៦ រដ្ឋាភិបាលជប៉ុនបានប្រកាសថាខ្លួននឹងបន្តផ្ដល់ជំនួយដល់ឥណ្ឌូណេស៊ីនូវទឹកប្រាក់ចំនួន ១,៩២ ពាន់លានយ៉េន សម្រាប់គម្រោងផលិតនាវាល្បាត(នាវាល្បាតដែលមានល្បឿនលឿន) សម្រាប់ការការពារចោរកម្មភេរវកម្មដែនសមុទ្រ និងការរីកសាយអាវុធ។ ប៉ុន្តែការផ្ដល់កប៉ាល់នេះត្រូវបានធ្វើឡើងជាការលើកលែងចំពោះគោលការណ៍បីស្ដីពីការនាំចេញអាវុធ ដែលហាមឃាត់ការនាំចេញអាវុធ និងបច្ចេកវិទ្យាដែលពាក់ព័ន្ធទាំងអស់[3]។

## ៣.សេចក្ដីសន្និដ្ឋាន

ចិនបានក្លាយជាដៃគូយុទ្ធសាស្ត្រដ៏ជិតស្និទ្ធជាមួយកម្ពុជា តាមរយៈកិច្ចសហប្រតិបត្តិការគ្រប់វិស័យ ។ បន្ថែមលើការគាំទ្រលើនយោបាយចិនតែមួយ ភាពជិតស្និទ្ធនេះបានធ្វើឱ្យកម្ពុ

[3] Ministry of Foreign Affairs of Japan, "Japan’s official development assistance white paper 2006," Ministry of Foreign Affairs of Japan, accessed April 6, 2020, https://www.mofa.go.jp/policy/oda/white/2006/ODA2006/html/honpen/index.htm.

ជាក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការគាំទ្រចិន ទល់នឹងភាគីមានជម្លោះសមុទ្រចិនខាងត្បូង ដែលអ្នកវិភាគមួយចំនួនបានលើកឡើងអំពីការធ្លាក់ចូលឥទ្ធិពលចិនតែម្ដង។ ជាក់ស្ដែង ការមិនអាចចេញសេចក្ដីថ្លែងការណ៍រួមរបស់អាស៊ានក្នុងឆ្នាំ២០១២ បាននាំឱ្យប្រទេសអាស៊ានមួយចំនួន ក៏ដូចជាក្នុងអ្នកវិភាគជាច្រើនបានចោទប្រកាន់កម្ពុជា ថាជារដ្ឋរណបចិន។ ចំពោះជប៉ុនវិញ ជប៉ុនបានព្យាយាមឱ្យកម្ពុជាអនុវត្តគោលការណ៍កុងសង់ស៊ុស ជាមួយសមាជិកអាស៊ានដទៃទៀត ស្ដីពីបញ្ហាសមុទ្រចិនខាងត្បូង តាមជំនួបជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលកម្ពុជា។ ជប៉ុនធ្លាប់បានបញ្ចុះបញ្ចូលកម្ពុជាឱ្យធ្វើការគាំទ្រលើសាលដីការបស់តុលាការមជ្ឈត្តកម្មអន្តរជាតិ ក្នុងឆ្នាំ២០១៦ ប៉ុន្តែកម្ពុជាបដិសេធ ដោយសារកម្ពុជាប្រកាន់ជំហរអព្យាក្រឹត្យ។

សមាសធាតុដ៏សំខាន់នៃយុទ្ធសាស្ត្រការពារហានិភ័យរបស់កម្ពុជា គឺការសម្របផ្នែកគោលនយោបាយការបរទេសប្រកបដោយភាពឆ្លាតវៃជាមួយចិន និងជប៉ុន។ យុទ្ធសាស្ត្រការពារហានិភ័យ និងរក្សាលំនឹងជាមួយចិន ត្រូវបានសង្កេតឃើញ ដូចខាងក្រោម៖

- ទីមួយ៖ កម្ពុជាមិនអនុញ្ញាតឱ្យទីតាំង ដូចជាកំពង់ផែ និងព្រលានយន្តហោះដែលសាងសង់ក្រោមជំនួយរបស់ចិន ត្រូវបានបង្វែរទៅជាការប្រើប្រាស់យោធា និងបដិសេធវត្តមានយោធាចិន ដោយផ្អែកលើរដ្ឋធម្មនុញ្ញកម្ពុជា។

- ទីពីរ៖ ដូចដែលត្រូវបានគេសង្កេតឃើញនៅក្នុងគម្រោងកំពង់ផែក្រុងព្រះសីហនុ កម្ពុជាបានប្រើយុទ្ធសាស្ត្រទាញជប៉ុន និងប្រទេសដទៃទៀត មកធ្វើជាលំនឹងសម្រាប់ឱ្យមានតុល្យភាពចំពោះជំនួយរបស់ចិន នោះគឺជប៉ុនត្រូវបានអនុញ្ញាតឱ្យអភិវឌ្ឍកំពង់ផែក្រុងព្រះសីហនុ ចំណែកចិនត្រូវបានអនុញ្ញាតឱ្យអភិវឌ្ឍទីតាំងតំបន់សេដ្ឋកិច្ចពិសេស ដែលនៅជុំវិញកំពង់ផែ។នេះបង្ហាញថា កម្ពុជាកំពុងស្វះស្វែងរកផលប្រយោជន៍ជាតិរបស់ខ្លួនឱ្យបានច្រើនជាអតិបរមា ស្របពេលជាមួយគ្នានេះដែរ កម្ពុជាកំពុងធ្វើឱ្យមានតុល្យភាពជាមួយចិន ដើម្បីកុំឱ្យគេមើលឃើញថា ស្ថិតនៅក្រោមឥទ្ធិពលរបស់ចិន តាមរយៈការគាំទ្រយុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិករបស់ជប៉ុន ដែលជាទូទៅត្រូវបានគេមើលឃើញថា ជាយុទ្ធសាស្ត្រហ៊ុមព័ទ្ធចិន ដែលមានអាមេរិកនៅពីក្រោយ។

ក្នុងនាមជាប្រទេសសមាជិកអាស៊ាន កម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មតាមរយៈក្របខ័ណ្ឌអាស៊ាន ក្នុងការដោះស្រាយវិបត្តិសមុទ្រចិនខាងត្បូង និងទប់ស្កាត់ការប្រឈមមុខគ្នាដោយផ្ទាល់រវាងភាគីជម្លោះដើម្បីរក្សានូវស្ថិរភាព និងសន្តិភាពក្នុងតំបន់ទាំងមូល តាមរយៈយុទ្ធសាស្ត្រនយោបាយឈ្នះ-ឈ្នះ ក្នុងឋានៈជារដ្ឋអធិបតេយ្យមួយ។

# គន្ថនិទ្ទេស


1. Agence France Presse, "Japan Vows to Help Philippines Amid China Sea Row," ABS-CBN News, last modified July 5, 2013, https://news.abs-cbn.com/focus/06/27/13/japan-vows-help-philippines-amid-china-sea-row
2. Evelyn Goh, "The Struggle for Order," 2013, xx, doi:10.1093/acprof:oso/9780199599363.001.0001.
3. Hidetaka YOSHIMATSU, "Economic Interdependence and Security Tension: China's Rare Earth Policy," *East Asian Policy* 04, no. 03 (2012): xx, doi:10.1142/s1793930512000268.
4. Min G. Koo, "Island Disputes and Maritime Regime Building in East Asia : Between a Rock and a Hard Place (Springer, 2010)," *Asia Review* 3, no. 1 (2013): xx, doi:10.24987/snuacar.2013.06.3.1.209.
5. Ministry of Foreign Affairs of Japan, "Japan's official development assistance white paper 2006," Ministry of Foreign Affairs of Japan, accessed April 6, 2020,
6. Sueo Sudo, "Japan's Mekong Policy and Myanmar: Complementing a Viable Strategic Partnership," ResearchGate, last modified February 2020,
7. Yoichi Kato, "China's Naval Expansion In the Western Pacific > Articles," Global Asia, last modified December 20, 2010, https://www.globalasia.org/v5no4/cover/chinas-naval-expansion-in-the-western-pacific_yoichi-kato
8. Zhao Hong, "THE SOUTH CHINA SEA DISPUTE AND CHINA-ASEAN RELATIONS," *Asian Affairs* 44, no. 1 (2013): xx, doi:10.1080/03068374.2012.760785.
9. https://www.mofa.go.jp/policy/oda/white/2006/ODA2006/html/honpen/index.htm.
10. https://www.nytimes.com/2018/09/18/world/asia/japan-submarine-south- china-sea.html
11. https://www.japantimes.co.jp/opinion/2017/08/29/commentary/japan-commentary/japans-maritime-diplomacy-mission-s-e-asia/#.Xq17wqgzZyy
12. https://www.researchgate.net/publication/339532235_Japan%27s_Mekong_Policy_and_Myanmar_Complementing_a_Viable_S

# ការគ្រប់គ្រងវិស័យសាសនានៅខេត្តកំពង់ចាម៖ ទស្សនៈនៃការគ្រប់គ្រងវិស័យសាសនានៅខេត្តកំពង់ចាម (២០១៤-២០២០)

*បេក្ខជនបណ្ឌិត៖* ***ស្រី សុភ័ក្ត្រ***
*ជំនាញ៖* ***រដ្ឋបាលសាធារណៈ***
*គ្រូណែនាំ៖* ***បណ្ឌិត សយ រាសី***

កំពង់ចាម ជាខេត្តមួយក្នុងចំណោមរាជធានី/ខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភាគខាងកើត មានចម្ងាយ១២៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានប្រជាជនរស់នៅ ១,១០៥,១៤៨នាក់[1] ជាមួយនឹងដង់ស៊ីតេប្រជាជន ២៤៣នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា។ ខេត្តនេះ មានសាសនាចំនួន៤ កំពុងធ្វើសកម្មភាពមាន ព្រះពុទ្ធសាសនា, ឥស្លាមសាសនា, គ្រិស្តសាសនា, និងពុទ្ធសាសនាមហាយាន[2]។ បើធៀបជាមួយនឹងចំនួនប្រជាជនទូទៅនៅក្នុងខេត្តឃើញថា អ្នកជឿលើព្រះពុទ្ធសាសនាមានរហូតដល់៩៧.៦%, ឥស្លាមសាសនា មាន ២.៣%, គ្រិស្តសាសនាមាន០,១%, និងសាសនាផ្សេងៗមានតិចតួចបំផុត[3]។ **ព្រះពុទ្ធសាសនា** មានពីរគណៈ គឺគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ។ វត្តអារាម មានចំនួន ៣៧៨ វត្ត (ធម្មយុត្តិ ១២វត្ត) និងមានព្រះសង្ឃសរុប ៥,៥០១អង្គ (ធម្មយុត្តិ ១៣៤អង្គ)។ មានសាលាពុទ្ធិកបឋមសិក្សា ២២កម្រងសាលា ពុទ្ធិកអនុវិទ្យាល័យ ៣សាលា ពុទ្ធិកវិទ្យាល័យ ១ សាលា និងពុទ្ធិកសាកលវិទ្យាល័យ ១សាលា។ **ឥស្លាមសាសនា** មានតែមួយនិកាយ គឺនិកាយស៊ុននីត មានវិហារ ៣២កន្លែង ស៊ូរ៉ាវ ៤៨កន្លែង និងមានសាសនិក ៣២,៥១៤នាក់។ **គ្រិស្តសាសនា** មានបីនិកាយ គឺនិកាយកាតូលិក និកាយប្រូតេស្តង់ និងនិកាយមរមន មានវិហារ និងស្នាក់ការថ្វាយបង្គំ ១១៧កន្លែង និងមានសាសនិក ៤,៦៣៦នាក់។ **ពុទ្ធសាសនាមហាយាន** មានវិហារ ៥កន្លែង មិននៅក្នុងក្រុមជាមួយគ្នាទេ និងមានសាសនិក ៥៩០នាក់[4]។

ជាការពិត ការគ្រប់គ្រប់គ្រងវិស័យសាសនា នៅខេត្តកំពង់ចាម គឺពិតជាមិនអាចផ្តាច់ចេញពីការគ្រប់គ្រងរបស់ជាតិទាំងមូលឡើយ ពោលគឺការគ្រប់គ្រងវិស័យសាសនា ត្រូវតែដើរឲ្យស្របទៅនឹងទស្សនៈច្បាប់ស្តីពីវិស័យសាសនា និងគោលនយោបាយសាសនាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។ ដូច្នេះ ដើម្បីយល់ពីទស្សនៈនៃការគ្រប់គ្រងវិស័យសាសនា នៅខេត្តកំពង់ចាម យើងនឹងធ្វើការសិក្សាពីទស្សនៈច្បាប់ និងគោលនយោបាយស្តីពីសាសនា។

---

1 រដ្ឋបាលខេត្តកំពង់ចាម, *ស្ថិតិប្រជាពលរដ្ឋប្រចាំឆ្នាំ២០២០*

2 *របាយការណ៍ឆ្នាំ២០២០ របស់មន្ទីរធម្មការ និងសាសនាខេត្តកំពង់ចាម*

3 ក្រសួងផែនការ, *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩*, ខែតុលា ឆ្នាំ២០២០, ទំព័រ៣១

4 *របាយការណ៍ឆ្នាំ២០២០ របស់មន្ទីរធម្មការ និងសាសនាខេត្តកំពង់ចាម*

## ១. ទស្សនៈច្បាប់ស្តីពីវិស័យសាសនា

ការគ្រប់គ្រងវិស័យសាសនានៅកម្ពុជា ត្រូវតែដើរឲ្យស្របជាដាច់ខាតទៅនឹងច្បាប់កំពូលរបស់ប្រទេស គឺរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញកម្ពុជា បានកំណត់បាវចនាជាតិ គឺ "**ជាតិ សាសនា ព្រះមហាក្សត្រ**"[5]។ បន្ថែមពីលើនេះ រដ្ឋធម្មនុញ្ញនេះ ក៏បានប្រកាសផងដែរថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ"[6]។

បាវចនាដែលត្រូវបានចែងថា "**ជាតិ សាសនា ព្រះមហាក្សត្រ**" គឺជារូបមន្តសរុបមួយតែប៉ុណ្ណោះ បញ្ជាក់អំពីទិសដៅកំណត់សកម្មភាពទាំងឡាយរបស់បុគ្គល រួមមានរូបវន្តបុគ្គល និងនីតិបុគ្គល ដែលរស់នៅ និងមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បុគ្គលទាំងនោះ ត្រូវយកចិត្តទុកដាក់ចំពោះ **ជាតិ សាសនា និងព្រះមហាក្សត្រ**។ ចំពោះការប្រតិបត្តិខាងផ្លូវសាសនា មានកំណត់ក្នុងបញ្ញត្តិនៃមាត្រាផ្សេងទៀតក្នុងរដ្ឋធម្មនុញ្ញ។

**ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ** មានន័យថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសេរីភាពបរិបូណ៌ក្នុងការជឿ ឬការប្រតិបត្តិជំនឿ និងសាសនាតាមសតិសម្បជញ្ញៈរបស់ខ្លួន គ្រប់ពេលវេលា និងគ្រប់កាលៈទេសៈ។

**សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃ ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ** មានន័យថា រដ្ឋត្រូវធានាឲ្យសេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាដំណើរការបានជាធម្មតា ប៉ុន្តែសេរីភាព និងការប្រព្រឹត្តនេះ ក៏មានព្រំដែនដែរ។ ការប្រើសេរីភាព និងការប្រតិបត្តិខាងផ្លូវជំនឿ និងសាសនា មិនត្រូវឲ្យប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃ ព្រមទាំងត្រូវគោរពសិទ្ធិសេរីភាព និងការប្រតិបត្តិខាងផ្លូវជំនឿ និងសាសនាអ្នកដទៃទៀតផង។ ម្យ៉ាងវិញទៀត ការប្រើសេរីភាព និងការប្រតិបត្តិខាងផ្លូវជំនឿ និងសាសនា មិនត្រូវឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈជាដាច់ខាត។

**ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ** ដែលដោយហេតុថារដ្ឋធម្មនុញ្ញបានចែងដូច្នេះហើយ ទើបបទប្បញ្ញត្តិនៃមាត្រាដទៃទៀតនៃរដ្ឋធម្មនុញ្ញ និងអត្ថបទច្បាប់ ព្រមទាំងអត្ថបទក្រោមច្បាប់ កំណត់ស្របតាមស្មារតីខាងលើនេះ មានជាអាទិ៍ ៖

- នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបានជួយឧបត្ថម្ភ គាំទ្រ និងលើកតម្កើងវិស័យព្រះពុទ្ធសាសនាឲ្យបានរីកចម្រើនថ្កុំថ្កើងរុងរឿង សក្តិសមជាសាសនារបស់រដ្ឋ។ ហេតុនេះ ទើបនៅក្នុងព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រកម្ពុជាគ្រងរាជសម្បត្តិ ក៏មានវត្តមានរបស់សម្តេច

[5] *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*, ១៩៩៣, ជំពូក១ មាត្រា៤

[6] -ដ- ជំពូក៣ មាត្រា៤៣

ព្រះសង្ឃរាជទាំងពីរគណៈ តាមព្រះរាជប្បវេណីដែរ។ មិនតែប៉ុណ្ណោះ ថ្ងៃបុណ្យធំៗក្នុងព្រះពុទ្ធសាសនា ជាអាទិ៍ ថ្ងៃបុណ្យមាឃបូជា វិសាខបូជា ត្រូវបានចាត់ទុកជាថ្ងៃបុណ្យរបស់ជាតិ។

- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ត្រូវបានឲ្យគង់ជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចមានចែងក្នុងមាត្រា១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ។ ម្យ៉ាងទៀត សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះអង្គត្រូវបានគង់ជាអធិបតីក្នុងពិធីធ្វើសច្ចាប្រណិធានធំៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទាំងឡាយនៃរដ្ឋធម្មនុញ្ញ ហើយក្នុងភ្លេងជាតិនគររាជទៀតសោត វគ្គទី៣ ចែងថា "គ្រប់វត្តអារាម ឮសូរតែស័ព្ទធម៌ សូត្រដោយអំណររំឭកគុណពុទ្ធសាសនា ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គង់ផ្គង់ ប្រយោជន៍ឲ្យ ដល់ប្រទេសខ្មែរ ជាមហានគរ។"

- វាក្យខ័ណ្ឌទី៣ មាត្រា៦៨ នៃរដ្ឋធម្មនុញ្ញបានចែងថា "រដ្ឋជួយផ្សព្វផ្សាយ និងលើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា"។

- ប្រជាពលរដ្ឋខ្មែរភាគច្រើនលើសលប់នៅព្រះរាជាណាចក្រកម្ពុជាបានលើកទង់ជាតិ ទង់ព្រះពុទ្ធសាសនា និងទង់ព្រះមហាក្សត្រ នៅទន្ទឹមគ្នា ព្រមទាំងមានសតិសម្បជញ្ញៈជឿជាក់ថា អាណាចក្រ និងពុទ្ធចក្រ ត្រូវដើរទន្ទឹមគ្នា ទើបជាតិបានថ្កុំថ្កើង រុងរឿង[7]។

សរុបមក ចំណុចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា គឺជាធាតុដ៏មានសារៈសំខាន់សម្រាប់រាជរដ្ឋាភិបាល ប្រើប្រាស់ជាមូលដ្ឋានក្នុងការកសាងច្បាប់ និងអត្ថបទក្រោមច្បាប់សំដៅធ្វើការគ្រប់គ្រងវិស័យសាសនានៅកម្ពុជា និងដាក់ចេញនូវគោលនយោបាយក្នុងវិស័យសាសនា។

## ២. គោលនយោបាយសាសនា

ការរៀបចំគោលនយោបាយសាសនា គឺត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញ និងគោលការណ៍ច្បាប់ដែលបានកំណត់រួចហើយ។ មិនតែប៉ុណ្ណោះ ការកសាងគោលនយោបាយសាសនា ក៏ត្រូវតែស្របទៅនឹងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញផងដែរ។ ចាប់តាំងពីឆ្នាំ២០០៤ មក រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំកម្មវិធីនយោបាយរបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រចតុកោណទៅតាមដំណាក់កាលនៃអាណត្តិរាជរដ្ឋាភិបាល ដែលមានរយៈពេល៥ឆ្នាំម្តង ដោយអនុវត្តបន្តគ្នានូវរបៀបវារៈគោលនយោបាយដែលបានកំណត់ក្នុងដំណាក់កាលនីមួយៗ។ ឆ្នាំ២០១៤ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ត្រូវបានដាក់ចេញសម្រាប់អនុវត្តឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨, និងឆ្នាំ២០១៩ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ត្រូវបានដាក់ចេញសម្រាប់អនុវត្តពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។

---

7 ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, *សេចក្តីសម្រេចលេខ ១០៧/០០៣/២០០៩ កបធ.ច ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩*

តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវគោលនយោបាយសាសនា គឺ **"លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា"** ស្របតាមកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាបានសមធម៌ និងប្រសិទ្ធភាព ឲ្យស្របតាមនិន្នាការរីកចម្រើនក្នុងតំបន់ និងពិភពលោក[8]។

ឆ្លើយតបនឹងគោលនយោបាយនេះ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ក្រសួងធម្មការ និងសាសនា នឹងត្រូវអនុវត្តសកម្មភាពស្នូលមួយចំនួន ដូចខាងក្រោម ៖

- បង្កើនការអប់រំ ពិសេសការអប់រំក្នុងស្រទាប់យុវជន និងកុមារ ឲ្យយល់ដឹងច្បាស់ពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ ហើយចូលរួមថែរក្សាលើកតម្កើង អភិវឌ្ឍវប្បធម៌ជាតិ និងកាត់បន្ថយឥទ្ធិពលវប្បធម៌អវិជ្ជមានពីបរទេស។
- បន្តគោរពសេរីភាពខាងជំនឿសាសនា លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ជាពិសេស ការបន្តពង្រឹង និងពង្រីកពុទ្ធិកសិក្សានៅគ្រប់កម្រិត ការបោះពុម្ពផ្សាយគម្ពីរដីកា ក្បួនច្បាប់នានា និងកិច្ចប្រតិបត្តិធម៌វិន័យ ទន្ទឹមនឹងនេះ គាំទ្រសកម្មភាពនៃសាសនាផ្សេងៗទៀតក្នុងសង្គម។
- ពង្រឹងសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនា ប្រឆាំងនឹងការរើសអើងបែងចែកក្នុងចំណោមប្រជាជន ដែលបណ្តាលមកពីភាពខុសគ្នាខាងសាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ ទៅជាកម្លាំងជំរុញអភិវឌ្ឍសង្គម សេដ្ឋកិច្ច សន្តិភាព សាមគ្គីភាព ថែរក្សាប្រពៃណីជាតិ និងលើកកម្ពស់តម្លៃសីលធម៌។ រាំងស្កាត់ការយកសាសនាទៅធ្វើអាជីវកម្ម និងបង្កជាវិបត្តិសាសនា។
- បង្កើតសាខាពុទ្ធិកសាកលវិទ្យាល័យតាមខេត្តនីមួយៗ ស្របតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង បន្តពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាតាំងពីកម្រិតធម្មវិន័យ បឋមសិក្សា រហូតដល់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា តាមរយៈការបណ្តុះបណ្តាលសមណសិស្ស-និស្សិតនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សានានា ដែលមាននៅក្នុងពេលបច្ចុប្បន្ន និងអនាគត។
- ពង្រឹង និងពង្រីកបណ្ណាល័យនៅតាមមន្ទីរ វត្តអារាម សាលាពុទ្ធិកសិក្សា ដោយបំពាក់សៀវភៅ គម្ពីរ ដីកា ក្បួនច្បាប់ និងឯកសារពាក់ព័ន្ធនានា ដើម្បីជំរុញការអាន ការសិក្សាស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់។
- បន្តរៀបចំវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងវិធីប្រតិបត្តិដូនជី និងបន្តថែរក្សាប្រពៃណី ទំនៀមទម្លាប់សាសនា និងពិធីបុណ្យគ្រប់សាសនានានា។

---

[8] រាជរដ្ឋាភិបាលកម្ពុជា, ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣***, ២០១៩, ទំព័រ២៨

- បន្តជំរុញការលើកកម្ពស់តួនាទីសាសនា ជាពិសេសព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ក្នុងការចូលរួមផ្តល់ការអប់រំផ្នែកគុណធម៌ សីលធម៌ និងចរិយាធម៌ ព្រមទាំងក្នុងការធានាសុខដុមរមនានៅក្នុងសង្គមកម្ពុជា តាមរយៈការផ្សព្វផ្សាយនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គមឲ្យបានទូលំទូលាយ និងជ្រួតជ្រាបគ្រប់ស្រទាប់មហាជន[៩]។

មកដល់ឆ្នាំ ២០១៩-២០២៣ ក្រសួងធម្មការ និងសាសនានឹងបន្តអនុវត្តសកម្មភាពស្នូលដូចខាងក្រោម ៖

❖ ការងារវិស័យពុទ្ធិកសិក្សា
  - បន្តសម្របសម្រួលការងារពុទ្ធិកសិក្សា សំដៅបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃ ពីកម្រិតធម្មវិន័យ រហូតដល់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា។
  - បន្តធ្វើសហប្រតិបត្តិការអន្តរជាតិវិស័យធម្មការ និងសាសនា។
  - បន្តពង្រឹងការបណ្តុះបណ្តាលធនធានមនុស្ស (ព្រះសង្ឃ) ពីកម្រិតបឋមរហូតដល់ឧត្តមសិក្សាឲ្យបានស្រមតាមស្តង់ដារអន្តរជាតិ។
  - បន្តពង្រីកសាលាពុទ្ធិកសិក្សានៅតាមមូលដ្ឋាន។

❖ ពង្រឹង និងពង្រីកការគ្រប់គ្រងផ្សព្វផ្សាយព្រះពុទ្ធសាសនា និងរក្សាសុខដុមនីយកម្មខាងជំនឿសាសនា
  - រៀបចំអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស និងផ្សព្វផ្សាយតាមរាជធានីខេត្ត។
  - បន្តយកចិត្តទុកដាក់សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រីកការផ្សព្វផ្សាយព្រះធម៌ តាមរយៈនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម។
  - បន្តផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនាអប់រំនៅតាមសាលារៀន តាមរយៈកម្មវិធី ទស្សនាទានព្រះពុទ្ធសាសនា ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។
  - យកចិត្តទុកដាក់សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើកកម្ពស់ដល់ការសិក្សាស្រាវជ្រាវ និងចងក្រងនូវរាល់គម្ពីរ ក្បួនតម្រា ពិធីបុណ្យផ្សេងៗ និងពិធីកិច្ចសាសនា។

---

[9] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨,* ២០១៤, ទំព័រ១៩៧-១៩៨

- បន្តទំនាក់ទំនងសហការជិតស្និទ្ធជាមួយមេដឹកនាំពាហិរសាសនា ក្នុងវិស័យកិច្ចការសាសនា។
- បន្តរៀបចំច្បាប់ និងគោលនយោបាយសម្រាប់ការគ្រប់គ្រង និងរៀបចំរចនាសម្ព័ន្ធសាសនាគ្រប់និកាយទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បន្តទំនាក់ទំនងជាមួយនឹងបណ្តាប្រទេស និងអង្គការ សមាគមចរិតសាសនា ដើម្បីឈ្វេងយល់ពីសាសនាផ្សេងៗលើសកលលោក។
- បន្តណែនាំ និងត្រួតពិនិត្យអង្គការសាសនាក្រោមឱវាទក្រសួង វត្តអារាម និកាយសាសនា មណ្ឌលសិក្សាស្រាវជ្រាវសាសនានានា និងរាល់អង្គការសមាគមដែលមានចរិតសាសនា ឲ្យប្រតិបត្តិ និងធ្វើសកម្មភាពសាសនាឲ្យស្របតាមច្បាប់របស់រដ្ឋ។
- បន្តធ្វើអធិការកិច្ចលើវិស័យសាសនា និងសម្របសម្រួលដោះស្រាយអធិករណ៍
- បន្តជំរុញការបង្កើតបណ្ណាល័យនៅតាមវត្តអារាម សម្រាប់ជាប្រយោជន៍ដល់សាធារណជន រួមទាំងបព្វជិត ទាំងគ្រហស្ថ ក្នុងព្រះរាជាណាចក្រកម្ពុជា។
- បន្តលើកទឹកចិត្តឲ្យគ្រប់សាសនាទាំងអស់ ចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ជំរុញវត្តអារាម និងវិហារសាសនានានា ឲ្យក្លាយជាមជ្ឈមណ្ឌលអប់រំខាងផ្នែកស្មារតី សីលធម៌ វប្បធម៌ និងសង្គមកិច្ច រក្សានូវសុខដុមនីយកម្ម និងសេរីភាពខាងជំនឿសាសនាទាំងអស់[10]។

សរុបសេចក្តីមក ទាំងទស្សនៈច្បាប់ស្តីពីសាសនា និងគោលនយោបាយសាសនា ដែលបានដាក់ចេញមកនេះ គឺជាមូលដ្ឋាននៃការគ្រប់គ្រងវិស័យសាសនាទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅខេត្តកំពង់ចាម ហើយគោលការណ៍នានាត្រូវបានដាក់ចេញជាបន្តបន្ទាប់សំដៅធ្វើការគ្រប់គ្រងវិស័យនេះ ព្រមទាំងផែនការសកម្មភាពនានា ក៏ត្រូវបានកសាងឡើងដោយអង្គភាពពាក់ព័ន្ធនៅខេត្តកំពង់ចាម ពិសេសមន្ទីរធម្មការ និងសាសនាខេត្តកំពង់ចាម គឺត្រូវតែស្របទៅនឹងទស្សនៈច្បាប់ស្តីពីសាសនា និងគោលនយោបាយខាងលើ ដើម្បីឆ្ពោះទៅថែរក្សាសណ្តាប់ធ្នាប់ក្នុងវិស័យសាសនា ចូលរួមលើកកម្ពស់គុណតម្លៃព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ រក្សាឲ្យបាននូវសុខដុមនីយកម្មសាសនានៅក្នុងសង្គម និងគ្រប់គ្រងអធិករណ៍សាសនាឲ្យបានល្អ ពិសេសទប់ស្កាត់ឲ្យបាននូវអធិករណ៍អន្តរសាសនា៕

[10] រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*, ២០១៩, ទំព័រ២១៧-២១៨

## «ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី»

*បេក្ខជនបណ្ឌិតៈ* ***ម៉ា សំអាល់***
*ជំនាញៈ* ***រដ្ឋបាលសាធារណៈ***
*គ្រូណែនាំៈ* ***បណ្ឌិត សឿន សោភ័ណ***

# សេចក្តីផ្តើម

ប្រព័ន្ធគ្រប់គ្រងថាមពល (PMS) ទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនី។ ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនីគឺមានភារកិច្ចដើម្បីធ្វើឱ្យប្រាកដថា ប្រព័ន្ធអគ្គិសនីមានសុវត្ថិភាព និង មានប្រសិទ្ធិភាព។ ប្រសិនបើការប្រើប្រាស់ថាមពលធំជាងសមត្ថភាពផលិតថាមពល ដើម្បីជៀសវាងការដាច់ភ្លើង ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនីគឺធ្វើការផ្តោះប្តូរបន្ទុកដោយស្វ័យប្រវត្តិ ឬក៏អាចមានលក្ខណៈពិសេសផ្សេងទៀត ដូចជាការចាប់ផ្តើម និង បញ្ឈប់ អ្នកប្រើប្រាស់មួយចំនួនដោយស្វ័យប្រវត្តិដោយសារបន្ទុកមានការប្រែប្រួល[១]។

ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) គឺពឹងផ្អែកទាំងស្រុងលើជាប្រព័ន្ធកុងតាក់ និង ប្រព័ន្ធគ្រប់គ្រងម៉ាស៊ីនភ្លើង ដើម្បីធ្វើសមកាលកម្មម៉ាស៊ីនជំនួយរបស់វា ដោយអនុវត្តការចែករំលែកបន្ទុកដោយស្វ័យប្រវត្តិ និង បង្កើនប្រសិទ្ធភាពនៃរោងចក្រថាមពល។ វាគ្រប់គ្រងការកំណត់ រចនាសម្ព័ន្ធផ្សេងៗនៃម៉ាស៊ីនភ្លើង ដែលជំរុញដោយម៉ាស៊ីនម៉ាស៊ូត, ទួរប៊ីនចំហាយទឹក (steam turbines) និង ម៉ាស៊ីនមេក្តី ក្នុងការរួមផ្សំជាមួយប្រព័ន្ធកុងតាក់របស់ខ្សែចង្វាក់ដ៏ទៃផ្សេងទៀត។

ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី ប្រតិបត្តិការនៅក្នុងការរួមបញ្ចូលគ្នានៃម៉ាស៊ីនភ្លើងណាមួយដែលត្រូវបានអនុវត្ត ដោយយោងទៅតាមការគណនាលើតារាងថាមពលអគ្គិសនីនីមួយៗ។ ប្រព័ន្ធគ្រប់គ្រងថាមពលគឺជាអ្នកសម្រេចថា តើការរួមផ្សំរបស់ម៉ាស៊ីនភ្លើងមួយណាដែលល្អបំផុត គឺយោងទៅតាមតម្រូវការនៃការប្រើប្រាស់។ សមត្ថភាពរបស់ម៉ាស៊ីនភ្លើង គឺតែងតែប្រតិបត្តិការបែបនេះនៅក្នុងព្រឹត្តិការណ៍នៃការបង្កើតណាមួយ និង ការបញ្ឈប់ នោះវានឹងនៅតែអាចផ្គត់ផ្គង់សេវាកម្មទាំងអស់ដែលចាំបាច់ ដើម្បីផ្តល់នូវលក្ខខណ្ឌប្រតិបត្តិការធម្មតានៃការជំរុញ និង សុវត្ថិភាព។ លើសពីនេះ វានឹងមានភាពគ្រប់គ្រាន់ដើម្បីចាប់ផ្តើមនូវម៉ាស៊ីដ៏ធំបំផុត ដោយមិនបណ្តាលឱ្យម៉ាស៊ីនផ្សេងទៀតឈប់ ឬមានផលប៉ះពាល់ដល់ឧបករណ៍ផ្សេងទៀតដែលកំពុងដំណើរការ។ ជាទូទៅ ប្រព័ន្ធគ្រប់គ្រងថាមពលអនុវត្តមុខងារខាងដូចខាងក្រោម[២]៖

-ធ្វើសមកាលកម្មដោយស្វ័យប្រវត្តិ
-ធ្វើការចែករំលែកបន្ទុកដោយស្វ័យប្រវត្តិ
-ម៉ាស៊ីនចាប់ផ្តើម / បញ្ឈប់ / ផ្អាកដំណើរការបណ្តោះអាសន្ន (Sandby) ដោយស្វ័យប្រវត្តិ យោងទៅតាមតម្រូវការបន្ទុក

[១] សូមមើល ៖ ប្រព័ន្ធគ្រប់គ្រងថាមពល (Power Management System), នៅក្នុងគេហទំព័រ https://en.wikipedia.org/wiki/Power_management_system
[២] -ដ-

-ម៉ាស៊ីនជំទប់ស្កាត់ដោយស្វ័យប្រវត្តិ
-ផ្ទុកការវិភាគ និង ការត្រួតពិនិត្យ
-ធ្វើការគ្រប់គ្រងដំណាក់កាលបី និង ការផ្គូផ្គងវ៉ុល
-ធ្វើការចែកចាយថាមពលដែលលែងត្រូវការតទៅទៀត
-ធ្វើការត្រួតពិនិត្យប្រេកង់
-ធ្វើការចាប់ផ្តើមដាច់ភ្លើង
-ធ្វើការជ្រើសរើសម៉ាស៊ីនភ្លើងជាអាទិភាព (ម៉ាស៊ីនភ្លើងនាំមុខទីមួយ, ទីពីរ និង ទីបី តាមលំដាប់លំដោយ)
-ធ្វើការបែងចែកបន្ទុកស្មើគ្នារវាងម៉ាស៊ីនភ្លើងនីមួយៗ
-ធ្វើការបិទក្រុមបន្ទុកមិនសំខាន់ (ការផ្ទុកបន្ទុកជាពីរជំហាន)
-ធ្វើការទប់ស្កាត់អ្នកប្រើប្រាស់ធ្ងន់
-ធ្វើប្រតិបត្តិការម៉ាស៊ីនភ្លើងទីពីរ ក្នុងករណីដែលម៉ាស៊ីនភ្លើងទីមួយនឹងត្រូវបានផ្ទុក ៨០% នៃសមត្ថភាពរបស់វា
-ធ្វើប្រតិបត្តិការម៉ាស៊ីនភ្លើងរង់ចាំ ក្នុងករណីមានដំណើរការខុសប្រក្រតី នៅក្នុងម៉ាស៊ីនភ្លើងមួយ ក្នុងចំណោមម៉ាស៊ីនភ្លើងទាំងពីរ
-ធ្វើការជ្រើសរើសម៉ាស៊ីនភ្លើងដោយដៃ, សុវត្ថិភាព, ពាក់កណ្តាលស្វ័យប្រវត្តិ និង ដោយស្វ័យប្រវត្តិ
-ធ្វើការត្រួតពិនិត្យការជ្រើសរើសម៉ាស៊ីនភ្លើងនៅក្នុងបន្ទប់គ្រប់គ្រងម៉ាស៊ីន[៣]។

## ១-ប្រព័ន្ធប្រតិបត្តិការ

ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) គឺជាប្រព័ន្ធនៃឧបករណ៍ជំនួយកុំព្យូទ័រ ដែលត្រូវបានប្រើដោយប្រតិបត្តិករបណ្តាញអគ្គិសនី សម្រាប់ត្រួតពិនិត្យ គ្រប់គ្រង និង បង្កើនប្រសិទ្ធភាពដំណើរការម៉ាស៊ីនភ្លើង ឬ ប្រព័ន្ធបញ្ជូនអគ្គិសនី។ ដូចគ្នានេះផងដែរ វាអាចត្រូវបានប្រើនៅក្នុងប្រព័ន្ធខ្នាតតូច ដូចជា មីក្រូក្រេឌីត។ បច្ចេកវិទ្យាកុំព្យូទ័រ ក៏ត្រូវបានគេហៅថា «ការគ្រប់គ្រង និង ទទួលទិន្នន័យសម្រាប់ប្រព័ន្ធគ្រប់គ្រងថាមពល SCADA/EMS ឬ EMS/SCADA (Supervisory Control and Data Acquisition for Energy Management System (SCADA/EMS) នៅក្នុងន័យទាំងនេះ ពាក្យអេឡិកត្រូនិកមិនរាប់បញ្ចូលនូវមុខងារត្រួតពិនិត្យ (Monitoring) និង ការគ្រប់គ្រង (Control) ទេ ប៉ុន្តែ អ្វីដែលកាន់តែពិសេស គឺសំដៅទៅលើបណ្តុំនៃបណ្តាញថាមពលអគ្គីសនី, កម្មវិធីគ្រប់គ្រងម៉ាស៊ីនភ្លើង, និង កម្មវិធីកំណត់ពេលវេលា។ ក្រុមហ៊ុនផលិត EMS ជាទូទៅផ្តត់ផ្គង់ឧបករណ៍ពិសោធន៍បញ្ជូនដែលត្រូវគ្នា (DTS)។ បច្ចេកវិទ្យាដែលទាក់ទងនេះ ធ្វើឱ្យការដោយប្រើប្រាស់សមាសធាតុនៃ SCADA ជាឧបករណ៍បណ្តុះបណ្តាលសម្រាប់ប្រតិបត្តិករនៃមជ្ឈមណ្ឌលបញ្ជា[៤]។

---

[៣] ប្រព័ន្ធគ្រប់គ្រងថាមពល (Power Management System), -ដ.ឯ.ម-
[៤] ដកស្រង់ចេញពីគេហទំព័រ https://en.m.wikipedia.org/wiki/Energy_management_system, ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៩

រហូតមកដល់ដើមឆ្នាំ ១៩៩០ គេក៏បានរកឃើញថាប្រព័ន្ធ EMS ត្រូវបានចែកចាយដោយផ្អែកលើផ្នែករឹង (Hardware) និង ប្រព័ន្ធប្រតិបត្តិការ (Operating Systems) ដែលមានកម្មសិទ្ធិ។ បន្ទាប់មក អ្នកផ្គត់ផ្គង់ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ដូចជា ក្រុមហ៊ុនត្រួតពិនិត្យហារីស (Harris Controls), ក្រុមហ៊ុនហ៊ីតាជី (Hitachi), ក្រុមហ៊ុនសេប៊ីក (Cebyc), ក្រុមហ៊ុនត្រួតពិនិត្យទិន្នន័យសាជីវកម្ម, ក្រុមហ៊ុនសៀមិន (Siemens), និង ក្រុមហ៊ុនតូហ្ស៊ីបា (Toshiba) ក៏បានផលិតផ្នែករឹង (Hardware) ផ្ទាល់ខ្លួនរបស់ពួកគេ។ អ្នកផ្គត់ផ្គង់ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ដែលមិនបានផលិតផ្នែករឹង (Hardware) ផ្ទាល់ខ្លួន ជារឿយៗ ពឹងផ្អែកលើផលិតផលដែលបង្កើតឡើងដោយឧបករណ៍ឌីជីថល (Digital Equipment), អេឡិកត្រូនិកហ្គូល (Gould Electronics), MODCOMP, និង VAX ១១/១៨០ ពីឧបករណ៍ឌីជីថល គឺជាជម្រើសដ៏ពេញនិយមក្នុងចំណោមអ្នកផ្គត់ផ្គង់ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) មួយចំនួន។ ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ឥឡូវនេះ ពឹងផ្អែកលើវិធីសាស្ត្រដែលផ្អែកលើគំរូ។ គំរូនៃការធ្វើផែនការតាមបែបប្រពៃណី និង គំរូប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) តែងតែត្រូវបានថែរក្សាដោយឯករាជ្យ និង កម្រធ្វើសមកាលកម្មជាមួយគ្នា។ ការប្រើប្រាស់ផ្នែកទន់ (Software) នៃប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) អនុញ្ញាតឱ្យអ្នករៀបចំផែនការ និង ប្រតិបត្តិករចែករម្លែកគំរូរួម កាត់បន្ថយភាពមិនស៊ីសង្វាក់គ្នារវាងផ្នែកទាំងពីរ និង ការថែរក្សាម៉ូដែលកាត់ពាក់កណ្តាល។ មានចំណុចប្រទាក់គ្នា គឺអ្នកប្រើទូទៅក៏អនុញ្ញាតឱ្យមានការផ្លាស់ប្តូរព័ត៌មានកាន់តែងាយស្រួល ពីការធ្វើផែនការទៅប្រតិបត្តិការដែរ។

នៅពេលដែលប្រព័ន្ធមានកម្មសិទ្ធិបានក្លាយជាសេដ្ឋកិច្ចពុំមានលក្ខណៈគ្រប់គ្រាន់នោះ អ្នកផ្គត់ផ្គង់ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) បានចាប់ផ្តើមផ្តល់ដំណោះស្រាយដោយផ្អែកលើវេទិកាផ្នែករឹង (Hardware) ស្តង់ដារឧស្សាហកម្ម ដូចជា ឧបករណ៍ទាំងនោះគឺបានមកពីឧបករណ៍ឌីជីថលរបស់ក្រុមហ៊ុនខំផាក (Compaq ក្រោយមកក្លាយជាក្រុមហ៊ុន HP), ក្រុមហ៊ុនអាយប៊ីអិម (IBM), និង ក្រុមហ៊ុនព្រះអាទិត្យ (Sun)។ ប្រព័ន្ធប្រតិបត្តិការទូទៅនៅពេលនោះគឺ DEC Open VMS ឬ Unix។ នៅឆ្នាំ២០០៤ អ្នកផ្គត់ផ្គង់ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ផ្សេងៗគ្នា រួមមាន អាល់ស្តូម (Alstom), អេប៊ីប៊ី (ABB) និង អូអេសអាយ (OSI) បានចាប់ផ្តើមផ្តល់ជូននូវដំណោះស្រាយដែលមានមូលដ្ឋានលើវីនដូ (Windows) ហើយនៅឆ្នាំ២០០៦ អតិថិជនមានជំរើសរវាងប្រព័ន្ធយូនីក លីនុច ឬ វីនដូ។ អ្នកផ្គត់ផ្គង់មួយចំនួន រួមមាន ETAP, NARI, PSI-CNI និង Siemens នៅតែបន្តផ្តល់ដំណោះស្រាយដែលមានមូលដ្ឋានលើយូនីក។ ឥឡូវនេះ វាជារឿងធម្មតាសម្រាប់អ្នកផ្គត់ផ្គង់ ដើម្បីរួមបញ្ចូលដំណោះស្រាយដែលមានមូលដ្ឋានលើយូនីក ទាំងលើ Sun Solaris ឬ IBM platform។ ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ថ្មី ដែលមានមូលដ្ឋានលើម៉ាស៊ីនបម្រើ blade កាន់កាប់ផ្នែកមួយនៃទំហំដែលបានទាមទារពីមុន។ ឧទាហរណ៍រ៉ាកែតនៃម៉ាស៊ីនបម្រើចំនួន២០ ដែលកាន់កាប់ចន្លោះប្រហាក់ប្រហែលនឹងកន្លែងដែលបានកាន់កាប់ពីមុនដោយម៉ាស៊ីនមេ MicroVAX តែមួយ[៥]។

---

[៥] ដកស្រង់ចេញពីគេហទំព័រ https://en.m.wikipedia.org/wiki/Energy_management_system, -ដ.ឯ.ម-

នៅក្នុងបរិបទខុសគ្នាបន្តិចបន្តួច ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ក៏អាចយោងទៅលើប្រព័ន្ធមួយ ដែលត្រូវបានរចនាឡើងដើម្បីសម្រេចបាននូវប្រសិទ្ធភាពថាមពល តាមរយៈការបង្កើនប្រសិទ្ធភាពដំណើរការ តាមរយៈការរាយការណ៍អំពីការប្រើប្រាស់ថាមពលតូចៗ ដោយបំណែកឧបករណ៍នីមួយៗ។ ប្រព័ន្ធគ្រប់គ្រងថាមពលថ្មី ផ្អែកលើ cloud បានផ្តល់នូវសមត្ថភាពក្នុងការគ្រប់គ្រងពីចម្ងាយ HVAC និង ឧបករណ៍ប្រើប្រាស់ថាមពលផ្សេងទៀត។ ប្រមូលព័ត៌មានលម្អិត និងពេលវេលាជាក់លាក់ សម្រាប់បំណែកនីមួយៗនៃឧបករណ៍ និង បង្កើតការណែនាំជាក់លាក់ពេលវេលាឆ្លាតវៃលើការស្វែងរក និង ចាប់យកឱកាសសន្សំគួរឱ្យទាក់ទាញអារម្មណ៍បំផុត[៦]។

ការគ្រប់គ្រងថាមពលតាមផ្ទះ (HEM) ជួយឱ្យអ្នកប្រើប្រាស់ក្នុងស្រុក អាចចូលរួមក្នុងសកម្មភាពដែលត្រូវការ ប៉ុន្តែ វាប្រឈមនឹងបញ្ហាមួយចំនួន ដែលបណ្តាលមកពីភាពមិនប្រាកដប្រជានៃធនធានថាមពលកកើតឡើងវិញ និង អាកប្បកិរិយារបស់អ្នកប្រើប្រាស់។ ខណៈពេលដែលអតិថិជនក្នុងស្រុក មានបំណងចង់បានផាសុកភាពឱ្យស្ថិតនៅកម្រិតខ្ពស់បំផុត ដែលគួរតែត្រូវបានពិចារណាដោយកាត់បន្ថយបាតុភូត «ផុនទ្រាន់នឹងឆ្លើយតប»[៧]។

ប្រព័ន្ធគ្រប់គ្រងថាមពល ក៏អាចសំដៅទៅលើប្រព័ន្ធកំព្យូទ័រមួយ ដែលត្រូវបានរចនាឡើងជាពិសេស សម្រាប់ការត្រួតពិនិត្យ និង ត្រួតពិនិត្យដោយស្វ័យប្រវត្តិនូវឧបករណ៍អេឡិចត្រូនិកទាំងនោះ នៅក្នុងអាគារដែលផ្តល់នូវការប្រើប្រាស់ថាមពលសំខាន់ៗ ដូចជា កំដៅខ្យល់ និង ការតម្លើងភ្លើងបំភ្លឺ។ វិសាលភាពអាចលាតសន្ធឹងចាប់ពីអគារមួយទៅអគារមួយក្រុម ដូចជា អគារសាកលវិទ្យាល័យ, អគារការិយាល័យ, បណ្តាញហាងលក់រាយ ឬ រោងចក្រ។ ភាគច្រើននៃប្រព័ន្ធគ្រប់គ្រងថាមពលទាំងនេះ ក៏ផ្តល់កន្លែងសម្រាប់ត្រួតពិនិត្យ និង វាស់វែងអគ្គិសនី ឧស្ម័ន និង ទឹកផងដែរ។ ទិន្នន័យដែលទទួលបានទាំងនេះ អាចត្រូវបានប្រើដើម្បីអនុវត្តការធ្វើវិនិច្ឆ័យដោយខ្លួនឯង ទម្លាប់បង្កើនប្រសិទ្ធភាពជាប្រចាំ និង ដើម្បីបង្កើតការវិភាគនិន្នាការ និង ការព្យាករណ៍អំពីការប្រើប្រាស់ប្រចាំឆ្នាំផងដែរ។

ប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី (EMS) ក៏ត្រូវបានប្រើជាញឹកញាប់ដោយអង្គភាពពាណិជ្ជកម្មនីមួយៗ ដើម្បីតាមដាន វាស់ និង គ្រប់គ្រងបន្ទុកអគារអគ្គិសនីរបស់ពួកគេ។ ប្រព័ន្ធគ្រប់គ្រងថាមពល អាចត្រូវបានប្រើដើម្បីបញ្ជាឧបករណ៍កណ្តាល ដូចជា HVAC និង ប្រព័ន្ធភ្លើងបំភ្លឺឆ្លងកាត់ទីតាំងជាច្រើន ដូចជា កន្លែងលក់រាយ គ្រឿងទេស និង ភោជនីយដ្ឋាន។ ប្រព័ន្ធគ្រប់គ្រងថាមពលក៏អាចផ្តល់នូវការវាស់ស្ទង់ការដាក់បញ្ចូលការវាស់វែង និង ការត្រួតពិនិត្យមុខងារដែលអនុញ្ញាតឱ្យអ្នកគ្រប់គ្រង និង អគារ ធ្វើការប្រមូលទិន្នន័យ និង ការយល់ដឹងដែលអនុញ្ញាតឱ្យពួកគេធ្វើការសម្រេចចិត្តកាន់តែច្បាស់ អំពីសកម្មភាពថាមពលនៅលើគេហទំព័ររបស់ពួកគេ[៨]។

## ២-ប្រព័ន្ធបញ្ជូន និង បណ្តាញបញ្ជូនអគ្គិសនី

ការផ្ទេរអគ្គិសនីជារូបភាពដុំក្នុងចម្ងាយវែង គឺត្រូវធ្វើឡើងតាមតង់ស្យុងខ្ពស់ ពីព្រោះ វាមានលក្ខណៈសេដ្ឋកិច្ចជាង និង មានប្រសិទ្ធភាពជាង។ ខ្សែបណ្តាញតង់ស្យុងខ្ពស់ដែលប្រើប្រាស់សម្រាប់

---

[៦] -ដដ-

[៧] -ដដ-

[៨] ដកស្រង់ចេញពីគេហទំព័រ https://en.m.wikipedia.org/wiki/Energy_management_system, -ដ.ឯ.ម-

ផ្ទេរអគ្គិសនីជារូបភាពធំនេះ ហៅថា «ខ្សែបណ្ដោញបញ្ជូន» ឬហៅថា «សៀគ្វីបញ្ជូន»។ ជាធម្មតា ខ្សែបណ្ដាញបញ្ជូនមួយ ភ្ជាប់ពីរោងចក្រអគ្គិសនី ឬ អនុស្ថានីយមួយ ទៅនឹងរោងចក្រអគ្គិសនី ឬ អនុស្ថានីយផ្សេងទៀត។ ត្រង់ស្វូម៉ាទ័រដែលគេប្រើនៅរោងចក្រអគ្គិសនី គឺសម្រាប់តម្លើងតង់ស្យុងនៃអគ្គិសនីដែលផលិតពីតង់ស្យុងផលិត ទៅជាតង់ស្យុងបញ្ជូន។ ត្រង់ស្វូម៉ាទ័រដែលគេប្រើនៅអនុស្ថានីយ គឺសម្រាប់តម្លើង ឬ បញ្ចុះតង់ស្យុង ដើម្បីធ្វើការភ្ជាប់ចូលគ្នានូវខ្សែបណ្ដាញបញ្ជូន ដែលមានតង់ស្យុងខុសគ្នាពីប្រព័ន្ធបញ្ជូនរង និង/ឬ ប្រព័ន្ធចែកចាយ។ នៅក្នុងប្រព័ន្ធបញ្ជូន គឺមានខ្សែបណ្ដាញបញ្ជូនច្រើនភ្ជាប់ចូលគ្នានឹងអនុស្ថានីយមួយចំនួន។ ភាគច្រើន ប្រព័ន្ធបញ្ជូនច្រើនតែប្រើខ្សែបណ្ដោញអាកាស និង ចរន្តឆ្លាស់ ប៉ុន្តែ ពេលខ្លះក៏មានប្រើចរន្តជាប់ ខ្សែកាបកប់ដី និង ខ្សែកាបក្នុងទឹកដែរ។ តង់ស្យុងនៃការបញ្ជូន ត្រូវបានជ្រើសរើសទៅតាមបរិមាណនៃអគ្គិសនី និង ចម្ងាយដែលត្រូវធ្វើការផ្ទេរ។ បរិមាណអគ្គិសនីកាន់តែច្រើន និង ចម្ងាយបញ្ជូនកាន់តែឆ្ងាយ គេត្រូវប្រើតង់ស្យុងកាន់តែខ្ពស់។ ជាធម្មតា ប្រព័ន្ធបញ្ជូនមួយប្រើបាស់តង់ស្យុងច្រើនលើសពីមួយ។ ប្រព័ន្ធបញ្ជូនភ្ជាប់រោងចក្រអគ្គិសនីទាំងអស់ជាមួយគ្នាទៅវិញទៅមក និង ដឹកជញ្ជូនថាមពលអគ្គិសនីពីរោងចក្រអគ្គិសនីទាំងនោះ ទៅឱ្យប្រព័ន្ធចែកចាយ។ ប្រព័ន្ធបញ្ជូនរង គឺជាផ្នែកមួយនៃប្រព័ន្ធបញ្ជូនដែលស្ថិតនៅចន្លោះនៃប្រព័ន្ធបញ្ជូន និង ប្រព័ន្ធចែកចាយ។ ប្រព័ន្ធចែកចាយដឹកជញ្ជូនថាមពលអគ្គិសនីទៅឱ្យអតិថិជនតាមលំនៅដ្ឋាន, អតិថិជនពាណិជ្ជកម្ម, និង អតិថិជនផ្សេងៗទៀត។ អតិថិជនដែលទិញអគ្គិសនីតាមតង់ស្យុងខ្ពស់ ត្រូវភ្ជាប់ជាមួយនូវប្រព័ន្ធបញ្ជូន។ ប្រព័ន្ធបញ្ជូន ឬ ហៅម្យ៉ាងទៀតថា ប្រព័ន្ធអគ្គិសនីធំ គឺជាបណ្ដាញនៃរោងចក្រអគ្គិសនីសៀគ្វីបញ្ជូន និង អនុស្ថានីយ[៩]។

## ៣-លំហូរនៃចរន្តអគ្គិសនីនៅក្នុងប្រព័ន្ធបញ្ជូន

លំហូរនៃចរន្តអគ្គិសនីពីរោងចក្រអគ្គិសនីមួយទៅអតិថិជនមួយ ធ្វើចលនាតាមរយៈខ្សែទាំងអស់ដែលភ្ជាប់រោងចក្រអគ្គិសនីនឹងអតិថិជននោះ មិនមែនធ្វើដំណើរតាមតែខ្សែណាដែលមានប្រវែងខ្លីជាងគេនោះទេ។ គេពិបាកនឹងធ្វើការកំណត់ថា តើអគ្គិសនីធ្វើចលនាតាមផ្លូវដោយឡែកណាមួយ និង ពិបាកនឹងត្រួតពិនិត្យលំហូររបស់វាឱ្យបានពិតប្រាកដណាស់។ ពុំមានវិស្វករបើកបិទណាមួយ អាចធ្វើការបើក ឬ បិទខ្សែដោយឡែកណាមួយ ដើម្បីបញ្ជាលំហូរអគ្គិសនី ឬ កាត់ផ្ដាច់លំហូរអគ្គិសនីទាំងស្រុងលើខ្សែ តាមរយៈការផ្ដាច់ប្រដាប់បើកបិទមួយបានឡើយ។ លំហូរអគ្គិសនីពុំទទួលស្គាល់ផ្លូវលំហូរតាមកិច្ចសន្យា ឬ ម្ចាស់កម្មសិទ្ធិហេដ្ឋារចនាសម្ព័ន្ធឡើយ។ លំហូរអគ្គិសនីនៅក្នុងប្រព័ន្ធបណ្ដាញមួយ គោរពទៅតាមតែច្បាប់រូបវិទ្យាប៉ុណ្ណោះ។

---

[៩] អាជ្ញាធរអគ្គិសនីកម្ពុជា, «*គោលការណ៍ និង លក្ខខណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៧ ទំព័រ៦

## រូបភាពទី១៖

លំហូរនៅក្នុង ប្រព័ន្ធអគ្គិសនី




*ប្រភព៖ ឯកសារ «**គោលការណ៍ និង លក្ខខណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា** », ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៧ ទំព័រ១០*

សៀគ្វីបញ្ជូនកំណត់មួយប៉ារ៉ាម៉ែត្រ គន្លឹះចំនួន៣ជាអ្នកកំណត់លំហូរអគ្គិសនី គឺ៖

-តង់ស្យុងនៃរបារខាងចុង

-អាំប៉េដង់ (រ៉េស៊ីស្តង់សរុប) របស់ខ្សែ និង

-មុំនៃហ្វាររវាងចុងដែលបញ្ជូន និង ចុងដែលទទួល។

អាំប៉េដង់នៃសៀគ្វីបញ្ជូនមួយ អាស្រ័យនឹងប្រវែងខ្សែ និង លក្ខណៈលំអិតរបស់ខ្សែ។ ផ្លូវដែលមានអាំប៉េដង់ទាប និង ទាក់ទាញឱ្យមានលំហូរច្រើនជាងផ្លូវដែលមានលំហូរខ្ពស់។ នៅក្នុងសៀគ្វីបញ្ជូននៃបណ្តាញមួយ អគ្គិសនីអាចធ្វើដំណើរតាមទិសដៅទាំងពីរ។

អគ្គិសនីដែលផ្តល់ពីរោងចក្រផលិតទៅឱ្យអតិថិជន អាចធ្វើដំណើរតាមខ្សែទាំងអស់ដែលភ្ជាប់គេទាំងពីរ។ នៅពេលដែលអគ្គិសនីធ្វើដំណើរតាមផ្លូវដោយឡែកពីផ្លូវដែលបានកំណត់ គេហៅថា «លំហូរស្របទិសដៅ»។ នៅពេលដែលការផ្ទេរអគ្គិសនីកើនឡើង លំហូរតាមផ្លូវជាមូលដ្ឋាន ក៏ដូចជាលំហូរតាមផ្លូវស្របទិសដៅកើនឡើងដូចគ្នា។ ការអោក់រអួលលើសៀគ្វីណាមួយ នឹងមានឥទ្ធិពលលើលំហូរនៃសៀគ្វីដ៏ទៃទៀតដែលនៅសល់។ ការប្រែប្រួលផលិតកម្ម ឬ ការប្រែប្រួលបន្ទុកនៅចំណុចណាមួយនៃប្រព័ន្ធបណ្តាញ នឹងធ្វើឱ្យមានការប្រែប្រួលនៃលំហូរអគ្គិសនីនៅក្នុងសៀគ្វីផ្សេងៗទៀត។ ស្ថានភាពនេះ អាចធ្វើឱ្យចរន្តអគ្គិសនីឡើងលើសកម្រិតដែលអនុញ្ញាតនៃសៀគ្វីណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃប្រព័ន្ធ។ ដូច្នេះ មុនពេលអនុញ្ញាតឱ្យបន្ថែមអានុភាពផលិតកម្មថ្មី ឬ បន្ទុកថ្មី ឬ សៀគ្វីបញ្ជូនថ្មីមួយ គឺទាមទារឱ្យមានការសិក្សាត្រឹមត្រូវពីប្រព័ន្ធទាំងមូល។ ការសិក្សានោះ ត្រូវតែធ្វើឱ្យ

ទាន់សម័យជានិច្ច ដើម្បីយល់ដឹងពីលទ្ធភាពនៃការលើសបន្ទុកតង់ស្យុងនៅតាមបណ្តាទីតាំងនានា និង ដំណើរការផ្សេងៗ។ ដូច្នេះ ការសិក្សា និង ការធ្វើផែនការ ទាមទារត្រូវធ្វើសម្រាប់ប្រព័ន្ធទាំងមូលដោយស្ថាប័នមួយ ទោះបីជាផ្នែកនីមួយៗនៃប្រព័ន្ធកាន់កាប់ដោយអ្នកធ្វើសេវាកម្មផ្សេងៗគ្នាក៏ដោយ។

អគ្គិសនីធ្វើចលនាពីរោងចក្រផលិតទៅកាន់អតិថិជនតាមប្រព័ន្ធបញ្ជូន និង ប្រព័ន្ធចែកចាយ នៅក្នុងល្បឿនមួយជិតស្មើនឹងល្បឿននៃពន្លឺ។ ដោយសារបច្ចុប្បន្ននេះពុំទាន់មានវិធីសាស្ត្រពិតប្រាកដណាមួយដើម្បីរក្សាទុកបរិមាណអគ្គិសនីក្នុងរូបភាពដុំ ចំនួនសរុបនៃអគ្គិសនីដែលបានផលិតជាបន្តបន្ទាប់ ត្រូវតែស្មើនឹងបរិមាណដែលប្រើប្រាស់ជាបន្តបន្ទាប់។ ជារួម បរិមាណផលិតនៃរោងចក្រផលិតទាំងអស់ ត្រូវតែស៊ីគ្នានឹងបរិមាណសរុបនៃបន្ទុកជាបន្តបន្ទាប់គ្នា និង ការបាត់បង់នៅក្នុងប្រព័ន្ធ។ ប្រព័ន្ធការពារ និង ការរិតចំណុចដំណើរការនៃប្រព័ន្ធនេះ សម្រាប់ផ្នែកផ្សេងៗនៃប្រព័ន្ធបណ្តាញ ត្រូវការសម្របសម្រួលគ្នាឱ្យបានត្រឹមត្រូវ ដើម្បីឱ្យក្នុងករណីមានកំហូចកើតឡើងនៅផ្នែកណាមួយ ប្រព័ន្ធការពារត្រូវតែអាចកាត់ផ្តាច់ផ្នែកដែលមានកំហូចនោះចេញពីបណ្តាញឱ្យបានឆាប់។ ជាទូទៅ គណៈកម្មការបច្ចេកទេសដែលមានសមាជិកមកពីអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗ ដែលជាអ្នកដំណើរការលើមធ្យោបាយផលិតកម្ម និង បញ្ជូននេះ ត្រូវទទួលបន្ទុកក្នុងការសម្រេចចិត្តទាក់ទងនឹងប្រព័ន្ធការពារ[១០]។

## ៤-មជ្ឈមណ្ឌលបញ្ជាអគ្គិសនី

ដើម្បីឱ្យប្រព័ន្ធបណ្តាញបន្តដំណើរការដោយប្រក្រតី គឺទាមទារការសម្របសម្រួលដោយផ្ទាល់ និង ការតាមដាន ត្រួតពិនិត្យមើលប្រព័ន្ធបណ្តាញ។ ការងារនេះ ត្រូវអនុវត្តដោយមជ្ឈមណ្ឌលបញ្ជា។ មជ្ឈមណ្ឌលបញ្ជាមួយ ធ្វើការចាត់ចែងសម្របសម្រួលដំណើរការនៃធាតុទាំងឡាយរបស់ប្រព័ន្ធ និង ទទួលខុសត្រូវដំណើរការប្រព័ន្ធអគ្គិសនី ដែលឋិតនៅក្នុងវង្វង់តំបន់ភូមិសាស្ត្រមួយ ហៅថាតំបន់បញ្ជា ដោយមិនគិតថា ហេដ្ឋារចនាសម្ព័ន្ធ ផលិតកម្ម និង/ឬ បណ្តាញបញ្ជូននៅក្នុងតំបន់នោះជារបស់អ្នកណាឡើយ។ ប្រព័ន្ធអគ្គិសនីដែលមានទំហំធំច្រើន មានមជ្ឈមណ្ឌលបញ្ជាច្រើនលើសពីមួយ។ ប្រព័ន្ធមួយដែលដំណើរការដោយមជ្ឈមណ្ឌលបញ្ជាមួយ ធ្វើការភ្ជាប់ជាមួយប្រព័ន្ធដទៃទៀត ដែលដំណើរការដោយមជ្ឈមណ្ឌលបញ្ជាផ្សេងទៀត ដោយខ្សែបណ្តេញបញ្ជូនតភ្ជាប់មួយចំនួន។

នៅប្រទេសថៃ EGAT មានមជ្ឈមណ្ឌលបញ្ជាចំនួនប្រាំមួយ។ មជ្ឈមណ្ឌលបញ្ជាដែលមានទីតាំងស្ថិតនៅទីស្នាក់ការកណ្តាលរបស់ EGAT នៅខេត្ត Nonthaburi ទទួលខុសត្រូវបញ្ជាទាំងប្រព័ន្ធបញ្ជូនដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល និង ខ្ពស់ជាង នៅទូទាំងប្រទេសថៃ ទាំងខ្សែបណ្តេញបញ្ជូនដែលតភ្ជាប់ប្រព័ន្ធ EGAT ជាមួយប្រព័ន្ធអគ្គិសនីឡាវ និង ប្រព័ន្ធអគ្គិសនីម៉ាឡេស៊ី និង ទាំងរោងចក្រអគ្គិសនីដែលមានអនុភាព ១០០ មេហ្គាវ៉ាត់ ឬ ខ្ពស់ជាង។ មជ្ឈមណ្ឌលបញ្ជាតាមតំបន់ចំនួន៥ទៀតដូចអធិប្បាយខាងក្រោម ទទួលខុសត្រូវបញ្ជាប្រព័ន្ធបញ្ជូនតង់ស្យុង ១១៥គីឡូវ៉ុល និង ទាបជាង និង បញ្ជារោងចក្រអគ្គិសនីដែលមានអនុភាពទាបជាង ១០០ មេហ្គាវ៉ាត់ ដែលឋិតនៅក្នុងតំបន់របស់ខ្លួន។

---

[១០] អាជ្ញាធរអគ្គិសនីកម្ពុជា, « *គោលការណ៍ និង លក្ខខ័ណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា* », -ដ.ឯ.ម- ទំព័រ១០

-មជ្ឈមណ្ឌលបញ្ជារាជធានី ដែលមានទីតាំងឋិតនៅក្នុងទីស្នាក់ការកណ្ដាល EGAT នៅខេត្ត Nonthaburi ទទួលខុសត្រូវលើតំបន់បាងកក និង ខេត្តដែលនៅជុំវិញ សរុបចំនួន ៤ខេត្ត។

-មជ្ឈមណ្ឌលបញ្ជាតំបន់វាលរាបកណ្ដាល ដែលមានទីតាំងឋិតនៅក្នុងទីស្នាក់ការកណ្ដាល EGAT នៅខេត្ត Nonthaburi ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន ២៣ ក្នុងតំបន់វាលរាប លើកលែងតែបាងកក និង ខេត្តជាប់ក្រុងបាងកក។

-មជ្ឈមណ្ឌលបញ្ជាសម្រាប់ភូមិភាគឥសាន្ត ដែលមានទីតាំងឋិតនៅក្នុងអនុស្ថានីយតង់ស្យុងខ្ពស់ Khon Kaen1 នៅស្រុក Mueang ខេត្ត Khon Kaen ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន១៩ ក្នុងតំបន់ភូមិភាគឦសាន។

-មជ្ឈមណ្ឌលបញ្ជាសម្រាប់ភូមិភាគខាងត្បូង ដែលមានទីតាំងឋិតនៅអនុស្ថានីយតង់ស្យុងខ្ពស់ Lamphura នៅស្រុក Huai Yot ខេត្ត Trang ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន១៦ ក្នុងតំបន់ភូមិភាគខាងត្បូង។

-មជ្ឈមណ្ឌលបញ្ជាសម្រាប់ភូមិភាគជើង ដែលមានទីតាំងឋិតនៅអនុស្ថានីយតង់ស្យុងខ្ពស់ Phitsanulok នៅស្រុក Mueang ខេត្ត Phitsanulok ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន១៤ ក្នុងតំបន់ភូមិភាគខាងជើង។

ប្រទេសវៀតណាមមានមជ្ឈមណ្ឌលបញ្ជាជាតិមួយ ដែលមានទីតាំងឋិតនៅក្នុងទីក្រុងហាណូយ ដែលបញ្ជាប្រព័ន្ធអគ្គិសនីរបស់វៀតណាមទាំងមូល ដោយបញ្ជាផ្ទាល់លើខ្សែបណ្ដាញបញ្ជូន ៥០០ គីឡូវ៉ុល និង រោងចក្រអគ្គិសនីធំៗ និង ដោយប្រយោល លើខ្សែបណ្ដាញបញ្ជូន ២២០ គីឡូវ៉ុល តាមរយៈមជ្ឈមណ្ឌលបញ្ជាតំបន់ (តំបន់ខាងជើង, តំបន់កណ្ដាល និង តំបន់ខាងត្បូង)។

នៅក្នុងសហគ្រាសដែលរួមបញ្ចូលសេវាកម្មទាំងអស់ មជ្ឈមណ្ឌលបញ្ជាគឺជារបស់សហគ្រាស។ ក្នុងប្រទេសជាច្រើន ដែលការងារបញ្ជូនអគ្គិសនីត្រូវបានបំបែកពីការងារដទៃទៀត ក្រុមហ៊ុនបញ្ជូនអគ្គិសនីដែលគ្រប់គ្រងដោយរដ្ឋគឺជាម្ចាស់ និង ជាអ្នកដំណើរការមជ្ឈមណ្ឌលបញ្ជា។ ឧទាហរណ៍ដូចជា ប្រទេសអង់គ្លេស និង ឥណ្ឌា។ នៅក្នុងប្រទេសទាំង២នេះ ក្រុមហ៊ុនបញ្ជូនអគ្គិសនីដែលដំណើរការមជ្ឈមណ្ឌលបញ្ជា មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាម្ចាស់កម្មសិទ្ធរោងចក្រអគ្គិសនី ឬ ធ្វើពាណិជ្ជកម្មអគ្គិសនីឡើយ។ ការធ្វើដូច្នេះ គឺដើម្បីចៀសវាងការប្រទាំងប្រទើសនឹងផលប្រយោជន៍ និង ដើម្បីបង្កើតនូវការធានាទុកចិត្តមួយ ក្នុងការដំណើរការមជ្ឈមណ្ឌលបញ្ជា។ នៅប្រទេសផ្សេងៗទៀត ដូចជា សហរដ្ឋអាមេរិក មជ្ឈមណ្ឌលបញ្ជាច្រើនដំណើរការដោយអ្នកដំណើរការឯករាជ្យ ដែលគេហៅថា Independent System Operators (ISO)។ ភារកិច្ចដែលមជ្ឈមណ្ឌលបញ្ជាត្រូវធ្វើជាទូទៅ មាន ៖

-ត្រួតពិនិត្យមើល និង បញ្ជាដំណើរការប្រព័ន្ធអគ្គិសនី ដើម្បីធានាឱ្យការផ្គត់ផ្គង់អគ្គិសនីមានស្ថិរភាព និង គ្រប់គ្រាន់ ប្រកបដោយកម្រិតគុណភាពមួយគ្រប់គ្រាន់ អាចទទួលយកបាន

-ធ្វើការដោះដូរថាមពលអគ្គិសនីជាមួយប្រព័ន្ធប្រទេសជិតខាង

-ដាក់កម្មវិធីឱ្យធ្វើការជួសជុល ថែទាំរោងចក្រអគ្គិសនី និង ខ្សែបណ្ដាញបញ្ជូនដែលមានតង់ស្យុងខ្ពស់

-រៀបចំកម្មវិធីដំណើរការប្រព័ន្ធអគ្គិសនីប្រចាំថ្ងៃ ប្រចាំអាទិត្យ ប្រចាំខែ

-កត់ត្រា និង ថែរក្សាទិន្នន័យ

ដើម្បីធ្វើការត្រួតពិនិត្យមើលប្រព័ន្ធអគ្គិសនីជាប់ជាប្រចាំ មជ្ឈមណ្ឌលបញ្ជាត្រូវទទួលប្រព័ន្ធទិន្នន័យពីរោងចក្រអគ្គិសនី និង ពីអនុស្ថានីយនានា។ តាមរយៈប្រព័ន្ធទំនាក់ទំនងដ៏ត្រឹមត្រូវ (ដែលមានប្រដាប់វាស់ស្ទង់ និង ប្រដាប់កត់ត្រា និង បញ្ជូនទិន្នន័យពីចម្ងាយ) មជ្ឈមណ្ឌលបញ្ជាអាចទទួលព័ត៌មានជាប្រចាំអំពីអនុភាពបណ្តាញពីរោងចក្រអគ្គិសនី លំហូរនៃចរន្តអគ្គិសនីនៅក្នុងខ្សែបណ្តាញបញ្ជូន ការតភ្ជាប់ជាមួយប្រព័ន្ធប្រទេសជិតខាង និង ល័ក្ខខ័ណ្ឌនៃប្រព័ន្ធ។ មជ្ឈមណ្ឌលបញ្ជាប្រើប្រាស់ព័ត៌មានទាំងនេះ សម្រាប់ធានាស្ថិរភាពរបស់ប្រព័ន្ធ ដោយតាមដានលក្ខណៈវិនិច្ឆ័យនៃស្ថិរភាព និង រក្សាតុល្យភាពនៃកម្មវិធីដោះដូរទៅវិញទៅមក ជាមួយមជ្ឈមណ្ឌលបញ្ជាដទៃទៀត។

ជាមួយនឹងបច្ចេកវិជ្ជាទំនើប មជ្ឈមណ្ឌលបញ្ជាបច្ចុប្បន្ននេះ អាចទទួលទិន្នន័យនៃប្រព័ន្ធអគ្គិសនីតាមរយៈគមនាគមន៍ ជាមួយឧបករណ៍ដែលមានខ្សែទំនាក់ទំនង ឬ អាចបញ្ចូលកម្មវិធីបញ្ជាបានតម្លើងនៅនឹងទីកន្លែងចង់ដឹងទិន្នន័យ។ ដើម្បីគោលបំណងនេះ គេប្រើឧបករណ៍បញ្ជូនទិន្នន័យពីចម្ងាយ ហៅថា Remote Terminal Units (RTUs) ឬ Intelligent Electronic Devices (IEDs) តម្លើងនៅនឹងទីកន្លែង។ ព័ត៌មាននេះ ត្រូវបានបញ្ជូនទៅឱ្យមជ្ឈមណ្ឌលបញ្ជាតាមរយៈប្រព័ន្ធ Supervisory Control and Data Acquisition (SCADA)។ គោលបំណងសំខាន់នៃការបញ្ជាប្រព័ន្ធអគ្គិសនីគឺ ៖

-ផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យមានចីរភាពដល់អ្នកប្រើប្រាស់

-រក្សាកម្រិតគុណភាពនៃការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់គ្រាន់ (គិតទាំងហ្វ្រេកង់ និង តង់ស្យុង)

-ធានាដំណើរការនៃប្រព័ន្ធអគ្គិសនី និង

-ដំណើរការប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនៃប្រព័ន្ធអគ្គិសនី។

ដើម្បីឱ្យប្រព័ន្ធអគ្គិសនីធំមួយអាចដំណើរការប្រកបដោយស្ថិរភាព ប្រព័ន្ធនេះត្រូវរៀបចំ និង ចាត់ចែងដំណើរការទៅតាមគោលការណ៍ដូចខាងក្រោម ៖

-បរិមាណផលិតសរុបនៅខណៈណាមួយ ត្រូវតែស្មើនឹងបរិមាណដែលប្រើប្រាស់សរុបបូក នឹងបរិមាណដែលបាត់បង់ គិតទាំងបរិមាណបាត់បង់លើប្រព័ន្ធបញ្ជូន និង ទាំងបរិមាណបាត់បង់លើប្រព័ន្ធចែកចាយនៅខណៈនោះ

-លំហូរនៃចរន្តអគ្គិសនីតាមប្រព័ន្ធបញ្ជូន ត្រូវតែអនុលោមទៅច្បាប់រូបវិទ្យា និង មិនអាចហូរតាមខ្សែពិសេសណាមួយឡើយ

-ប្រព័ន្ធនេះ ត្រូវតែរៀបចំយ៉ាងណាឱ្យមានអនុភាពបម្រុងសម្រាប់ផលិតកម្ម និង អនុភាពបម្រុងសម្រាប់ការបញ្ជូន ដើម្បីកុំឱ្យមានការផ្តាច់សេវា នៅពេលមានលំអៀងកើតឡើង[១១]។

---

[១១] អាជ្ញាធរអគ្គិសនីកម្ពុជា, «*គោលការណ៍ និង ល័ក្ខខ័ណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា*», -ដ.ឯ.ម- ទំព័រ១១

## ៥-ប្រព័ន្ធបញ្ជូនរង និង លំហូរនៃអគ្គិសនីនៅក្នុងប្រព័ន្ធបញ្ជូនរង

ប្រព័ន្ធបញ្ជូនរង គឺជាប្រព័ន្ធមួយដែលភ្ជាប់ប្រព័ន្ធបញ្ជូនជាមួយប្រព័ន្ធចែកចាយ ដើម្បីធ្វើការផ្គត់ផ្គង់អគ្គិសនីឱ្យទៅដល់អ្នកប្រើប្រាស់។ តង់ស្យុងនៃប្រព័ន្ធបញ្ជូនរង ជាធម្មតាទាបជាងតង់ស្យុងនៃប្រព័ន្ធបញ្ជូន។ តង់ស្យុងនៃប្រព័ន្ធបញ្ជូនរងដែលគេប្រើប្រាស់នៅក្នុងប្រទេសផ្សេងៗ មាន ៦៦kV, ៣៣kV, ២២kV, ១១LV។ល។ ជាទូទៅ ប្រព័ន្ធបញ្ជូនរងច្រើនតែមានផ្លូវលំហូរអគ្គិសនីតែមួយ ហើយពិតណាស់ដែលមានផ្លូវស្របទិសដៅ។ បរិមាណនៃលំហូរអគ្គិសនី និង ទំហំនៃតំបន់ដែលផ្គត់ផ្គង់ដោយប្រព័ន្ធបញ្ជូនរង តូចជាងធៀបទៅនឹងប្រព័ន្ធបញ្ជូន។ ដោយសារមូលហេតុនេះហើយ លំអៀងលើប្រព័ន្ធបញ្ជូនរង មិនសូវជាមានឥទ្ធិពលលើដំណើរការនៃផ្នែកផ្សេងៗទៀតរបស់ប្រព័ន្ធឡើយ។ នៅក្នុងប្រទេសភាគច្រើនប្រព័ន្ធបញ្ជូនរងមួយ ច្រើនផ្គត់ផ្គង់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយ។ ការធ្វើផែនការ និង ដំណើរការប្រព័ន្ធបញ្ជូនរង មិនទាមទារត្រូវធ្វើការសម្របសម្រួលធំដុំ ដូចជាក្នុងករណីខ្សែបណ្ដាញបញ្ជូនឡើយ[១២]។

## សេចក្តីសន្និដ្ឋាន

ជារួមប្រព័ន្ធគ្រប់គ្រងថាមពល គឺមានអត្ថប្រយោជន៍ណាស់ចំពោះការគ្រប់គ្រងថាមពលអគ្គិសនី ព្រោះប្រព័ន្ធគ្រប់គ្រងថាមពលអគ្គិសនី ជាអ្នកធ្វើការត្រួតពិនិត្យ និង គ្រប់គ្រងម៉ាស៊ីនភ្លើងដែលដើរដោយថាមពលប្រេងម៉ាស៊ូត, ធានាសុវត្ថិភាពម៉ាស៊ីនដែលដើរដោយថាមពលប្រេងម៉ាស៊ូត និង ការចាប់ផ្ដើម/បញ្ឈប់, បញ្ជាឧបករណ៍បំបែកសៀគ្វីឱ្យធ្វើសមកាលកម្ម និង ភ្ជាប់, ធ្វើការត្រួតពិនិត្យរ៉ុល និងហ្វ្រេកង់បន្ទាត់បន្ទុក, ធ្វើការត្រួតពិនិត្យរ៉ុល និង ហ្វ្រេកង់របស់ម៉ាស៊ីនភ្លើង, បន្ទុកម៉ាស៊ីនគិតជាគីឡូវ៉ាត់ (KW) និង ភាគរយ (%), ធ្វើការចែករំលែកបន្ទុកស៊ីមេទ្រី ឬ មិនស៊ីមេទ្រី, ធ្វើការគ្រប់គ្រងការផ្ទុកជាមួយនឹងការសម្រកបន្ទុក, ធ្វើការបែងចែកសំឡេងរោទិ៍ ការគ្រប់គ្រង និង សុវត្ថិ-ភាព, ធ្វើការគ្រប់គ្រងប្រព័ន្ធកុងតាក់តែមួយ ឬ ច្រើន, ផ្ញើតក្កវិជ្ជាអ្នកប្រើប្រាស់ធូន់, ចាប់ផ្ដើមដោយស្វ័យប្រវត្តិ និង ភ្ជាប់បន្ទាប់ពីដាច់ភ្លើង, ធ្វើការលៃតម្រូវហ្វ្រេកង់បន្ទាត់ដោយស្វ័យប្រវត្តិ, និង ធ្វើការគ្រប់គ្រងការជំរុញអគ្គិសនីពីម៉ាស៊ីដែលដើរដោយថាមពលប្រេងម៉ាស៊ូតជាដើម។ ប្រសិនបើគ្មានប្រព័ន្ធគ្រប់គ្រងថាមពលនេះទេ គេពិតជាមានពិបាកក្នុងការគ្រប់គ្រងប្រព័ន្ធអគ្គិសនីជាក់ជាមិនខាន។

[១២] អាជ្ញាធរអគ្គិសនីកម្ពុជា, «*គោលការណ៍ និង លក្ខខណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា*», -ដ.ឯ.ម-ទំព័រ១៤

# គន្ថនិទ្ទេស

**ឯកសារជាភាសាខ្មែរ៖**

១- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល, «*ល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដារបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល, ភ្នំពេញ, ឆ្នាំ២០០៤។

២- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល, «*ការអភិវឌ្ឍវិស័យថាមពលអគ្គិសនីនៅកម្ពុជា*», ការផ្សាយរបស់នាយកដ្ឋានវារីអគ្គិសនី អគ្គនាយកដ្ឋានថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល, ភ្នំពេញ, ឆ្នាំ២០១១។

៣- អាជ្ញាធរអគ្គិសនីកម្ពុជា, «*វឌ្ឍនភាពសំខាន់ៗរបស់វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជារហូតដល់ខែធ្នូ ឆ្នាំ២០១៧*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០១៧។

៤- អាជ្ញាធរអគ្គិសនីកម្ពុជា, «*បទប្បញ្ញត្តិស្តីពីល័ក្ខខ័ណ្ឌទូទៅនៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០១៦។

៥- អាជ្ញាធរអគ្គិសនីកម្ពុជា, «*ស្តង់ដារបច្ចេកទេសអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០១៥។

៦- អាជ្ញាធរអគ្គិសនីកម្ពុជា, «*គោលការណ៍ និង ល័ក្ខខ័ណ្ឌសម្រាប់ការចេញអាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៧។

៧- អាជ្ញាធរអគ្គិសនីកម្ពុជា, «*បទប្បញ្ញត្តិស្តីពីស្តង់ដារប្រតិបត្តិទូទៅ សម្រាប់អ្នកផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៤។

៨- អាជ្ញាធរអគ្គិសនីកម្ពុជា, «*បទប្បញ្ញត្តិលើការពង្រីកប្រព័ន្ធបញ្ជូន និង ប្រព័ន្ធចែកចាយអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៣។

៩- អាជ្ញាធរអគ្គិសនីកម្ពុជា, «*បទប្បញ្ញត្តិស្តីពីល័ក្ខខ័ណ្ឌទូទៅនៅក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា*», ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៣។

១០- ប្រកាសលេខ៧០១ ឧរថ អថ.ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពី «*ការបង្កើតល័ក្ខខ័ណ្ឌលម្អិតនៃស្តង់ដារបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា* », ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៧។

១១- ប្រកាសលេខ៧៩៦ ឧរថ អថ.ប្រក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៧ ស្តីពី «*ការធ្វើវិសោធនកម្មលើកទី១លើប្រកាសលេខ៤៧០ ឧរថ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីស្តង់ដារបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា* », ការផ្សាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា, ភ្នំពេញ, ឆ្នាំ២០០៧។

## ឯកសារជាភាសាបរទេស៖


១២- AGRAWAL K.C., "***Industrial Power Enineering and Applications Handbook***", Third Edition, Published by Matthew Deans Newnes, USA, 2000

១៣- EHSANI Mehrdad, GAO Yimin, and EMADI Ali, "***Modern Electric, Hybrid Electric, and Fuel Cell Vehicles***", Second Edition, Published by Taylor & Francis Group, USA, 2010

១៤- FARDO W. Stephen and PATRICK R. Dale, "***Electrical Power Systems Technology***", Third Edition, Published by Taylor & Francis Group, USA, 2009

១៥- GÖNEN Turan, "***Electric Power Distribution System Engineering***", Published by Scientific Publishing Services Pvt. Ltd, Chennai, India, 2011

១៦- GRIGSBY L. Leonard, "***Electric Power Generation, Transmission, and Distribution***", Published by Taylor & Francis Group, USA, 2008

១៧- GRIGSBY L. Leonard, "***Power Systems***", Third Edition, Published by Taylor & Francis Group, USA, 2008

១៨- LEE Jian, "***Advanced Electrical and Electronic Engineering***", Published by Scientific Publishing Services Pvt. Ltd, Chennai, India, 2011

១៩- MASOUM A.S. Mohammad and FUCHS F. Ewald, "***Power Quality in Power System and Electrical Machines***", Published by Academic Press, USA, 2015

២០- MURTY P.S.R., "***Power System Analysis***", Publication of BS, USA, 2007

២១- SEN P.C., "***Principles of Electric Machines and Power Electronics*** ", Third Edition, Published by John Wiley & Sons, Inc., USA, 2014

២២- THUMANN P.E., C.E.M. Albert and FRANZ P.E. Arry, "***Efficient Electrical Systems Design Handbook***", Published by Taylor & Francis Ltd., USA, 2009

២៣- TRZYNADLOWSKI M. Andrzej, "***CONTROL OF INDUCTION MOTORS***", Published by Academic Press, USA, 2001

២៤- WALTERS R.B., "***Hydraulic and Electric-Hydraulic Control Systems***", Second Edition, Published by Taylor & Francis Group, USA, 2009

២៥- WANG Xi-Fan, SONG Yonghua, and IRVING Malcolm, "***Modern Power System Analysis***", Published by Springer Science+Business Media, LLC., USA, 2008

២៦- WHITAKER C. Jerry, "***Electronics Handbook*** ", Second Edition, Published by Taylor & Francis Group, USA, 2005


## ឯកសារដកស្រង់ពីគេហទំព័រ៖


២៧- https://www.eac.gov.kh/

២៨- https://www.edc.com.kh/aboutus.php

២៩- https://en.wikipedia.org/wiki/AC_power

៣០- https://en.m.wikipedia.org/wiki/Voltage

៣១- https://en.wikipedia.org/wiki/Power_management_system

# ទិដ្ឋភាពទូទៅនៃទំនាក់ទំនងការទូតកម្ពុជា-ជប៉ុនឆ្នាំ២០០៨-២០១៨

*និស្សិតៈ* ***ហុង សុវណ្ណសុនិតា***
*គ្រូណែនាំៈ* ***បណ្ឌិត គិន ភា***

## I. សេចក្តីផ្តើម

ប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយប្រទេសជប៉ុនតាំងពីយូរលង់ណាស់មកហើយ។ តឹងតាងប្រវត្តិសាស្ត្របានបញ្ជាក់ថា ការដោះដូរទំនិញរវាងប្រទេសទាំងពីរបានចាប់ផ្តើមនៅឆ្នាំ១៥៦៩ នៅពេលដែលនាវាដឹកទំនិញពីប្រទេសកម្ពុជាបានទៅដល់ច្រាំងគ្យូស៊ូនៃប្រទេសជប៉ុន ហើយស្វែងរកការបង្កើតទំនាក់ទំនងជាមួយជប៉ុន។ ដូចគ្នានេះដែរ នាវាដឹកទំនិញជប៉ុនចំនួន៨៤ គ្រឿងបានធ្វើដំណើរមកកម្ពុជាដោយមានលិខិតបញ្ជាក់ការធ្វើដំណើរដែលចេញដោយរដ្ឋាភិបាលជប៉ុនចន្លោះឆ្នាំ១៦០៤ និងឆ្នាំ១៦៣៥ ដើម្បីស្វែងរកឱកាសថ្មីៗនៅកម្ពុជា។ លើសពីនេះ សិលាចារឹកចំនួន១៤ ផ្ទាំងរបស់អ្នកគោរពបូជាខាងសាសនាជនជាតិជប៉ុនដែលបានរកឃើញនៅលើជញ្ជាំងនិងសសរនៃប្រាសាទអង្គរវត្ត បង្ហាញពីស្នាមជានប្រវត្តិសាស្ត្រនៃការចូលរួមរបស់ជប៉ុនជាមួយកម្ពុជានៅដើមឆ្នាំ១៦១២[១]។

គួរបញ្ជាក់ផងដែរថា នៅសម័យបុរាណ ជនជាតិជប៉ុនមួយចំនួនដែលបានមកធ្វើពាណិជ្ជកម្មជាមួយកម្ពុជា ក៏បាននាំមាសពីកម្ពុជាត្រឡប់ទៅសាងសង់ប្រាសាទនៅប្រទេសជប៉ុនវិញផងដែរ។ ចំណែកនៅសម័យបច្ចុប្បន្នវិញ ប្រទេសកម្ពុជានិងប្រទេសជប៉ុនបានបង្កើតទំនាក់ទំនងការទូតជាលើកដំបូងនៅឆ្នាំ១៩៥៣ ហើយកម្ពុជាបានប្រកាសនៅឆ្នាំ១៩៥៤ ថាខ្លួនបានលះបង់សិទ្ធិរបស់រដ្ឋដើម្បីស្នើសុំការទូទាត់សំណងចំពោះការខូចខាតដែលបង្កឡើងដោយការលុកលុយរបស់កងទ័ពជប៉ុននៅកម្ពុជាក្នុងអំឡុងសង្គ្រាមលោកលើកទី២។ នៅពេលដែលប្រទេសជប៉ុនបានបញ្ជូនកងរក្សាសន្តិភាពមកកម្ពុជាក្នុងទសវត្សទី៩០ វាគឺជាលើកទីមួយហើយដែលប្រទេសជប៉ុនបានបញ្ជូនកងទ័ពដើម្បីរក្សាសន្តិភាពទៅបរទេសបន្ទាប់ពីសង្គ្រាមលោកលើកទី២ បានបញ្ចប់ ហើយសម្តេច

[១] Pnhom Penh Post, "*Japan and Cambodia: A Long and Prosperous Strategic Partnership*", February 19, 2018, https://phnompenhpost.com/supplements-special-reports/japan-and-cambodia-long-and-prosperous-strategic-partnership ( re-accessed 17 October 2020, at 9:01am )

សីហនុក៏ជាស្តេចអាស៊ីទី១ ដែលបានធ្វើទៅទស្សនកិច្ចនៅជប៉ុន បន្ទាប់ពីសង្គ្រាមលោកលើកទី២ បានបញ្ចប់ដូចគ្នា[២]។

ប្រទេសជប៉ុនគឺជាម្ចាស់ជំនួយដ៏ធំមួយនៅក្នុងប្រទេសកម្ពុជាហើយក៏បានផ្តល់ប្រាក់រាប់លានដុល្លារដល់សាលាក្តីខ្មែរក្រហម ហើយនេះក៏ជួយបង្កើនឥទ្ធិពលជប៉ុននៅអាស៊ីអាគ្នេយ៍។ ចំណែកកម្ពុជាវិញ បានធ្វើការគាំទ្រលើគោលនយោបាយជប៉ុននៅលើឆាកអន្តរជាតិជាច្រើន ហើយប្រទេសកម្ពុជាក៏ស្ថិតនៅតំបន់យុទ្ធសាស្រ្តតំបន់ទន្លេមេគង្គផងដែរ។ នៅឆ្នាំ២០១៣ ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជានិងប្រទេសជប៉ុនត្រូវបានបង្កើនទៅជាទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្រ្ត។ ក្នុងនាមជាប្រជាជាតិក្រីក្រតូចមួយ ប្រទេសកម្ពុជាត្រូវតែផ្សារភ្ជាប់ជាមួយប្រទេសដទៃទៀតហើយមិនអាចផ្តាច់ខ្លួនចេញពីអំណាចសេដ្ឋកិច្ចធំៗ នោះទេ។ រូបភាពនៃប្រទេសជប៉ុនចំពោះប្រជាជនកម្ពុជាហាក់បីដូចជាមានលក្ខណៈវិជ្ជមាននៅទូទាំងប្រទេសតាំងពីទីក្រុង រហូតដល់ជនបទ។

ទោះបីយ៉ាងណាក៏ដោយ សារជាតុពិតនៅក្នុងទំនាក់ទំនងអន្តរជាតិគឺមានតែផលប្រយោជន៍តែប៉ុណ្ណោះ។ ហេតុនេះហើយ អត្ថបទនេះមានគោលបំណងធ្វើការសិក្សាស្រាវជ្រាវស្តីពីទិដ្ឋភាពទូទៅនៃនយោបាយការបរទេសកម្ពុជានិងជប៉ុនក្នុងកំឡុងឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ហើយនឹងធ្វើការឆ្លុះបញ្ចាំងនិងវិភាគពីកត្តាដែលនាំឱ្យប្រទេសទាំងពីរដំឡើងទំនាក់ទំនងទ្វេភាគីទៅជាភាពជាដៃគូយុទ្ធសាស្រ្តនៅឆ្នាំ២០១៣។

## II. គោលនយោបាយការបរទេសកម្ពុជានិងជប៉ុនពីឆ្នាំ២០០៨-២០១៨

ប្រទេសកម្ពុជាប្រកាន់ភ្ជាប់នូវគោលការណ៍ប្រាំមួយចំណុចនៃការអនុវត្តគោលនយោបាយការបរទេសរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៥៣ នៃរដ្ឋធម្មនុញ្ញ[៣]របស់ខ្លួនដូចជា៖ (១) កម្ពុជាត្រូវប្រកាន់ភ្ជាប់ជានិច្ចនូវគោលនយោបាយអព្យាក្រឹត អចិន្រ្តៃយ៍និងមិនចូលបក្សសម្ព័ន្ធ (២) កម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងជាមួយបណ្តាប្រទេសដទៃទៀតទាំងអស់លើសកលលោក (៣) កម្ពុជាមិនឈ្លានពានប្រទេសណាជាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ឬដោយប្រយោល ទោះបីក្នុងរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក (៤) កម្ពុជាមិនចងសម្ព័ន្ធភាពយោធាឬនៅក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របទៅនឹងអព្យាក្រឹតភាពរបស់

---

[២] KHMER TIMES, "*Cambodia and Japan Relations after 65 years*", February 2, 2018, https://www.khmertimeskh.com/106104/cambodia-japan-relations-65-years/ (re-accessed 17 October 2020, at 9:15am)

[៣] រដ្ឋសភា៖ ***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ព្រះបរមរាជវាំង ១៩៩៣ ទំព័រទី២៥-២៦ https://pressocm.gov.kh/wp-content/uploads/2017/07/CONSTITUTION-OF-THE-KINGDOM-OF-CAMBODIA_KH.pdf (accessed 17 October 2020, 11:10am)

ខ្លួនឡើយ (៥) កម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសលើទឹកដីខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌសំណូមពររបស់អង្គការសហប្រជាជាតិ (៦) កម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀតដើម្បីការពារខ្លួន ជានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ហើយគោលបំណងសំខាន់នៃគោលនយោបាយកម្ពុជាគឺអភិវឌ្ឍសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ក៏ដូចជាដើរតួនាទីរួមចំណែកកសាងសន្តិភាព សន្តិសុខក្នុងសហគមន៍អន្តរជាតិ។

ដោយឡែក បើយើងក្រឡេកមើលពីគោលនយោបាយការបរទេសរបស់ជប៉ុនក្នុងវិស័យការទូតសំខាន់ៗ ដែលចែងក្នុង Diplomatic Bluebook របស់ខ្លួនពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ គឺ ផ្តែកលើកិច្ចខិតខំជាច្រើនដូចជា៖ (១) កិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានសន្តិភាពនិងស្ថិរភាពនៅក្នុងសហគមន៍អន្តរជាតិ (២) កិច្ចខិតខំប្រឹងប្រែងរបស់ជប៉ុនក្នុងការដោះស្រាយបញ្ហាពិភពលោកនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ (៣) កិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់វិបុលភាពនៅប្រទេសជប៉ុននិងសហគមន៍អន្តរជាតិ (៤) កិច្ចខិតខំប្រឹងប្រែងផ្តល់ព័ត៌មានដល់ប្រទេសដទៃទៀតនិងការទូតវប្បធម៌ (៥) កិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ការយល់ដឹងនិងការជឿទុកចិត្តចំពោះប្រទេសជប៉ុន និងកិច្ចខិតខំចុងក្រោយ គឺការទូតសេដ្ឋកិច្ច[៤]។

ហើយវិស័យអាទិភាពទាំង៩នៃគោលនយោបាយការបរទេសរបស់ជប៉ុន មានដូចជា (១) ពង្រឹងសម្ព័ន្ធភាពជប៉ុន-អាមេរិកនិងមិត្តភាពជាមួយសម្ព័ន្ធមិត្ត (២) បង្កើនទំនាក់ទំនងជាមួយប្រទេសជិតខាង (៣) ជំរុញការទូតសេដ្ឋកិច្ច (៤) ការធ្វើច្បាប់ដើម្បីជំរុញប្រព័ន្ធសេដ្ឋកិច្ចសកលដោយសេរីនិងបើកចំហ (៥) គាំទ្រដល់ការពង្រីកអាជីវកម្មនៅក្រៅប្រទេសរបស់ក្រុមហ៊ុនជប៉ុនតាមរយៈការលើកកម្ពស់ភាពជាដៃគូសាធារណៈឯកជន (៦) ជំរុញការទូតធនធាននិងការវិនិយោគចូលប្រទេសជប៉ុន (៧) ចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាសកល (៨) រួមចំណែកដល់សន្តិភាពនិងស្ថិរភាពនៅមជ្ឈឹមបូព៌ា និង (៩) យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិកសេរីនិងបើកចំហ[៥]។

ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) គឺជាឧបករណ៍គោលនយោបាយដ៏សំខាន់សម្រាប់ប្រទេសជប៉ុនក្នុងការបំពេញនូវការទទួលខុសត្រូវនិងតួនាទីជាអន្តរជាតិរបស់ខ្លួន។ អាទិភាពគោលនយោបាយរបស់រដ្ឋាភិបាលជប៉ុនឆ្ពោះទៅរកការអភិវឌ្ឍប្រទេសកម្ពុជាគឺដើម្បីជួយដល់ប្រទេសកម្ពុជាសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន

[៤] Ministry of Foreign Affairs, "*Foreign Policy: Diplomatic Bluebook*", https://www.mofa.go.jp/policy/other/bluebook/index.html ( re-accessed on 17 October 2020, at 3:01 pm )

[៥] Diplomatic Bluebook 2018, "Chapter 1 International Situation and Japan's Diplomacy in 2017", n.d., https://www.mofa.go.jp/files/000401241.pdf ( re-accessed on 17 October 2020, at 4:25 pm )

ដែលបានពិពណ៌នានៅក្នុង «យុទ្ធសាស្ត្រចតុកោណ» ហើយដែលគោលបំណងរបស់កម្ពុជាគឺស្របតាមគោលដៅអាទិភាពនៃគោលនយោបាយការបរទេសជប៉ុន។ ផ្អែកលើគោលការណ៍ទាំងនេះ ប្រទេសជប៉ុនប្រើប្រាស់ ODA ដើម្បីសម្រេចគោលបំណងនយោបាយការបរទេសរបស់ខ្លួននៅកម្ពុជា [៦]។

ប្រទេសជប៉ុនបានបន្តពង្រឹងក្របខ័ណ្ឌរបស់ខ្លួនសម្រាប់ការសន្ទនានិងកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ីអាគ្នេយ៍ រួមមាន៖ ប្រទេសកម្ពុជាក្នុងវិស័យនយោបាយនិងសន្តិសុខ និងជំរុញ «ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព» ដោយសហការជាមួយស្ថាប័នអន្តរជាតិក្នុងគោលបំណងធ្វើឱ្យសម្រេចបាននូវ «កំណើនប្រកបដោយគុណភាព» ប្រកបដោយនិរន្តរភាពហើយនឹង ពន្លឿនការផ្តួចផ្តើមគំនិតដើម្បីកែលំអការតភ្ជាប់តំបន់អាស៊ីអាគ្នេយ៍ [៧]។

ជប៉ុនក៏បានជួយផ្តល់មូលនិធិសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដែលនេះជាផ្នែកមួយរបស់គោលនយោបាយការបរទេសជប៉ុនក្នុងការជំរុញ «ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព» ដូចយើងឃើញជាក់ស្តែងរួមមាន៖ ការសាងសង់ស្ពានស្ទឹងបាសា ការជួសជុលផ្លូវជាតិលេខ៥ ដែលមានប្រវែងសរុប ៣៦៨,៧ គីឡូម៉ែត្រ ចាប់ពីក្រុងប៉ោយប៉ែត មកដល់ព្រែកក្តាមដើម្បីត្រៀមរៀបចំផ្លូវល្បឿនលឿនអាស៊ាន។ ការពង្រីកស្ថាបនាផ្លូវជាតិ៥នេះ ស្ថិតក្នុងគម្រោងកែលំអផ្លូវជាតិលេខ៥ ដែលរដ្ឋាភិបាលជប៉ុនបានផ្តល់ជាកម្ចីមករដ្ឋាភិបាលកម្ពុជាសម្រាប់ជួសជុលកំណាត់ផ្លូវជាតិលេខ៥ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដែលហៅកាត់ថាJICA។ ការស្ថាបនាផ្លូវនេះនឹងបញ្ចប់នៅឆ្នាំ២០២២ [៨]។

ក្នុងផ្នែកកិច្ចការផ្នែកការទូតវប្បធម៌ បុរាណវិទូជនជាតិជប៉ុនក៏បានជួយស្តារនិងជួសជុលប្រាសាទនៅក្នុងតំបន់អង្គរ ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការយូណេស្កូ និងអង្គការអន្តរជាតិផ្សេងទៀត ដើម្បីចូលរួមចំណែកអន្តរជាតិនៅក្នុងវិស័យវប្បធម៌ដូចជា៖ ការអភិរក្សបេតិកភណ្ឌវប្បធម៌ជាដើម។ ក្រសួងការបរទេសជប៉ុនក៏ធ្វើឱ្យស៊ីជម្រៅនូវការផ្លាស់ប្តូរជាមួយកម្ពុជាដោយការអញ្ជើញ និងការផ្លាស់ប្តូររាប់តាំងពីមន្ត្រីរដ្ឋាភិបាល

---

[៦] Country Assistance Policy for Cambodia, April, 2012, https://www.kh.emb-japan.go.jp/economic/cooperation/Assistance%20Policy.pdf ( re-accessed on 18 October 2020, at 8:33 am )

[៧] Diplomatic Bluebook 2017, "Chapter 2 Japan's Foreign Policy that Takes a Panoramic Perspective of the World Map", n.d., https://www.mofa.go.jp/files/000287677.pdf ( re-accessed 18 October 2020, at 8:40 am )

[៨] Property Area, «ដីនៅតាមបណ្តោយផ្លូវជាតិលេខ៥ ចាប់ផ្តើមឡើងថ្លៃបន្ទាប់ពីការពង្រីកផ្លូវបានចាប់ផ្តើម», 2018, https://www.cambodiaproperty.news/km/អចលនទ្រព្យ/ដីនៅតាមបណ្តោយផ្លូវជាតិ/ ( re-accessed on 18 October 2020, at 8:50 am )

ដល់យុវជននិងសិស្សវិទ្យាល័យដូចជា៖ តាមរយៈកម្មវិធី JENESYS (បណ្តាញផ្លាស់ប្តូរសម្រាប់និស្សិតនិងយុវជនអាស៊ីបូព៌ា) កម្មវិធី SSEAYP (កម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍និងជប៉ុន) ក៏ដូចជា ការអញ្ជើញថ្នាក់ដឹកនាំទៅធ្វើទស្សនកិច្ចនៅជប៉ុនលក្ខណៈទ្វេភាគី ជាដើម។

ជប៉ុនក៏ទាក់ទាញភ្ញៀវទេសចរមកជប៉ុនតាមរយៈការបញ្ចប់កិច្ចព្រមព្រៀងសេវាកម្មអាកាសចរណ៍ជាមួយប្រទេសកម្ពុជា ក៏ដូចជា ផ្សព្វផ្សាយព័ត៌មានអំពីប្រធានបទផ្សេងៗដូចជាគោលនយោបាយរបស់ប្រទេសជប៉ុន សង្គម និងវប្បធម៌ទៅកាន់កម្ពុជា។ កិច្ចការទាំងនេះជាកិច្ចការអាទិភាពក្នុងសៀវភៅការទូតរបស់ជប៉ុន។

គួរបញ្ជាក់ផងដែរថា ប្រទេសកម្ពុជានិងជប៉ុនបានបង្កើនទំនាក់ទំនងទ្វេភាគីរបស់ពួកគេទៅជា «ភាពជាដៃគូយុទ្ធសាស្ត្រ» នៅក្នុងខែធ្នូ ឆ្នាំ២០១៣[៩]។ ភាពជាដៃគូយុទ្ធសាស្ត្រគឺជាផ្នែកមួយនៃគោលនយោបាយការបរទេសរបស់ជប៉ុន ហើយគ្របដណ្តប់លើផ្នែកជាច្រើន រួមទាំងការផ្តោតលើកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខនិងការពារ ដែលរួមបញ្ចូលទាំងកិច្ចសហប្រតិបត្តិការយោធាដែលមិនធ្លាប់មានពីមុនមក និងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមនគរបាលនៃប្រទេសទាំងពីរ។

សម្រាប់ប្រទេសជប៉ុន ទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយប្រទេសកម្ពុជាគឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ជប៉ុនដើម្បីបញ្ឈប់ការបន្តធ្លាក់ចុះនៃឥទ្ធិពលភូមិសាស្ត្រនយោបាយរបស់ជប៉ុន។ ជាមួយនឹងប្រទេសចិនដែលបានក្លាយជាប្រទេសលេចធ្លោនៅក្នុងតំបន់នោះ ប្រទេសជប៉ុនបានមើលឃើញនូវការធ្លាក់ចុះនៃឥទ្ធិពលរបស់ខ្លួននៅទូទាំងអាស៊ីអាគ្នេយ៍។ ដើម្បីទប់ស្កាត់នូវសំណឹកបន្តទៀត ជប៉ុនបានចុះហត្ថលេខាលើភាពជាដៃគូយុទ្ធសាស្ត្រជាច្រើន រួមមានភាពជាដៃគូជាមួយសហភាពអឺរ៉ុបនិងអាស៊ាន។ ទំនាក់ទំនងការពារជាតិកាន់តែរឹងមាំរវាងកម្ពុជានិងជប៉ុនក៏បង្ហាញពីចំណាប់អារម្មណ៍របស់ជប៉ុនក្នុងការដើរតួនាទីកាន់តែលេចធ្លោក្នុងវិស័យសន្តិសុខនៅអាស៊ាន។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ប្រទេសជប៉ុនក៏បានបង្កើតគំនិតផ្តួចផ្តើមការពារអាស៊ាន ដែលបានគូសបញ្ជាក់ពីផែនការរបស់ជប៉ុនក្នុងការពង្រឹងសន្តិសុខដែនសមុទ្រនៅក្នុងតំបន់អាស៊ានតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការនិងការគាំទ្រដល់រដ្ឋនីមួយៗ[១០]។

---

[៩] Ministry of Foreign Affairs of Japan, "*Asia: Visit to the Kingdom of Cambodia by Minister for Foreign Affairs Fumio Kishida*", July 11, 2014, https://www.mofa.go.jp/s_sa/sea1/kh/page3e_000193.html ( re-accessed 18 October 2020, at 8:45 am )

[១០] Oliver Ward, "*Cambodian-Japanese Ties: Preserving Cambodia's Foreign Policy Autonomy*", August 25, 2017 https://www.aseantoday.com/2017/08/cambodian-japanese-ties-preserving-cambodias-foreign-policy-autonomy/, ( re-accessed on 19 October 2020, at 9:10 am )

## III. ការដំឡើងកម្រិតទំនាក់ទំនងអន្តររដ្ឋដល់កម្រិតយុទ្ធសាស្ត្រ

កម្ពុជាជាប្រទេសយុទ្ធសាស្ត្រមួយនៅតំបន់អាស៊ីអាគ្នេយ៍និងតំបន់មេគង្គ ហើយប្រទេសអាស៊ីអាគ្នេយ៍កំពុងបង្កើនសារៈសំខាន់និងវត្តមានរបស់ពួកគេនៅក្នុងសហគមន៍អន្តរជាតិ។ នៅខែធ្នូ ឆ្នាំ២០១៣ នាយករដ្ឋមន្ត្រីកម្ពុជា និង នាយករដ្ឋមន្ត្រីជប៉ុនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយក្នុងអំឡុងកិច្ចប្រជុំមួយនៅទីក្រុងតូក្យូដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងប្រទេសទាំងពីរដល់កម្រិត «យុទ្ធសាស្ត្រ»។ ប្រទេសទាំងពីរក៏បានចុះហត្ថលេខាលើអនុស្សារណៈដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការការពារជាតិរបស់ខ្លួនផងដែរ។ កិច្ចព្រមព្រៀងទាំងនេះបញ្ជាក់ពីវិសាលភាពដែលប្រទេសទាំងពីរពឹងផ្អែកលើគ្នាទៅវិញទៅមកដើម្បីជំរុញផលប្រយោជន៍ទៅវិញសងខាង[៩៩]។ ជាការពិតណាស់ សារជាតុពិតនៅក្នុងទំនាក់ទំនងអន្តរជាតិគឺមិនអាចនិយាយពីគុណធម៌ឬទឹកចិត្ត ហើយក៏គ្មានមិត្តឬសត្រូវអមតៈឡើយ គឺមានតែផលប្រយោជន៍តែប៉ុណ្ណោះ។

## IV. សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ កម្ពុជានិងជប៉ុនបានភ្ជាប់ទំនាក់ទំនងជាមួយគ្នាតាំងពីសម័យអង្គរមកម្ល៉េះ ហើយទំនាក់ទំនងនេះបានបន្តមកដល់សម័យបច្ចុប្បន្ន។ កម្ពុជាបានប្រកាន់ភ្ជាប់គោលការណ៍ប្រាំមួយចំណុចនៃការអនុវត្តនយោបាយការបរទេសរបស់ខ្លួន ហើយកម្ពុជាបានសម្រេចសេចក្តីប្រាថ្នាជាតិរួចហើយ ទាក់ទងទៅនឹងការទទួលបានឯករាជ្យភាពពេញលេញ ការទទួលបានសមាជិកនៅអង្គការសហប្រជាជាតិនិងនៅអាស៊ាន និងការទទួលស្គាល់ពីបណ្តាមហាអំណាចធំៗ គ្រប់ទំនោរទាំងអស់។ គោលនយោបាយការបរទេសកម្ពុជា អាចសម្របខ្លួនទៅនឹងកាលៈទេសៈនិងព្រឹត្តិការណ៍នានាក្នុងពិភពលោក ដោយមិនធ្វើឱ្យអាក់អន់ស្រពន់ចិត្តនូវប្រទេសមហាអំណាចណាមួយឡើយ។ ចំណែកឯ អាទិភាពគោលនយោបាយរបស់រដ្ឋាភិបាលជប៉ុនឆ្ពោះទៅរកការអភិវឌ្ឍប្រទេសកម្ពុជាក៏ដើម្បីជួយដល់ប្រទេសកម្ពុជាសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួនដែលបានពិពណ៌នានៅក្នុង «យុទ្ធសាស្ត្រចតុកោណ» ហើយដែលគោលបំណងរបស់កម្ពុជាគឺស្របតាមគោលដៅអាទិភាពគោលនយោបាយការបរទេសជប៉ុនដែលបានចែងទុកក្នុងសៀវភៅការទូតរបស់ខ្លួន។

«ភាពជាដៃគូយុទ្ធសាស្ត្រ» ជាមួយកម្ពុជាគឺជាផ្នែកមួយនៃគោលនយោបាយការបរទេសរបស់ជប៉ុន។ លើសពីនេះទៅទៀត ជប៉ុនចាត់ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិជាសសរគ្រឹះសំខាន់នៃគោលនយោបាយការបរទេស ហើយក៏ចាត់ទុកការកសាងសន្តិភាពស្ថិតក្នុងចំណោមអាទិភាពការទូត។ សម្រាប់ប្រទេសជប៉ុន

---

[៩៩] Phoak Kung, "*Cambodia-Japan Relations: Beyond the East China Sea*" *The Diplomat*, February 24, 2015, https://thediplomat.com/2015/02/cambodia-japan-relations-beyond-the-east-china-sea/ ( re-accessed 17 October 2020, at 9:24am )

ទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយប្រទេសកម្ពុជាគឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ជប៉ុន ដើម្បីបញ្ឈប់ការបន្តធ្លាក់ចុះនៃឥទ្ធិពលភូមិសាស្ត្រនយោបាយរបស់ជប៉ុន។ ទំនាក់ទំនងការពារជាតិកាន់តែរឹងមាំរវាងកម្ពុជានិងជប៉ុនក៏បង្ហាញពីចំណាប់អារម្មណ៍របស់ជប៉ុនក្នុងការដើរតួនាទីកាន់តែលេចធ្លោក្នុងវិស័យសន្តិសុខនៅអាស៊ានផងដែរ។

# បញ្ជីឯកសារយោង

## ក. ឯកសារផ្លូវការ


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។


## ខ. ឯកសារស្រាវជ្រាវជាភាសាបរទេស


- Country Assistance Policy for Cambodia, April, 2012, https://www.kh.emb-japan.go.jp/economic/cooperation/Assistance%20Policy.pdf

- Diplomatic Bluebook 2017, "Chapter 2 Japan's Foreign Policy that Takes a Panoramic Perspective of the World Map", n.d., https://www.mofa.go.jp/files/000287677.pdf

- Diplomatic Bluebook 2018, "Chapter 1 International Situation and Japan's Diplomacy in 2017", n.d., https://www.mofa.go.jp/files/000401241.pdf

- KHMER TIMES, "*Cambodia and Japan Relations after 65 years*", February 2, 2018, https://www.khmertimeskh.com/106104/cambodia-japan-relations-65-years/

- Ministry of Foreign Affairs of Japan, "*Asia: Visit to the Kingdom of Cambodia by Minister for Foreign Affairs Fumio Kishida*", July 11, 2014, https://www.mofa.go.jp/s_sa/sea1/kh/page3e_000193.html

- Ministry of Foreign Affairs, "*Foreign Policy: Diplomatic Bluebook*", https://www.mofa.go.jp/policy/other/bluebook/index.html

- Phoak Kung, "*Cambodia-Japan Relations: Beyond the East China Sea*" *The Diplomat*, February 24, 2015, https://thediplomat.com/2015/02/cambodia-japan-relations-beyond-the-east-china-sea/

- Pnhom Penh Post, "*Japan and Cambodia: A Long and Prosperous Strategic Partnership*", February 19, 2018, https://phnompenhpost.com/supplements-special-reports/japan-and-cambodia-long-and-prosperous-strategic-partnership

- Oliver Ward, "*Cambodian-Japanese Ties: Preserving Cambodia's Foreign Policy Autonomy*", August 25, 2017 https://www.aseantoday.com/2017/08/cambodian-japanese-ties-preserving-cambodias-foreign-policy-autonomy/

- Property Area, «ដីនៅតាមបណ្តោយផ្លូវជាតិលេខ៥ ចាប់ផ្តើមឡើងថ្លៃបន្ទាប់ពីការពង្រីកផ្លូវបានចាប់ផ្តើម», 2018, https://www.cambodiaproperty.news/km/អចលនទ្រព្យ/ដីនៅតាមបណ្តោយផ្លូវជាតិ/

# ការអនុវត្តការលក់ទិញអចលនវត្ថុនៅខណ្ឌសែនសុខ

*និស្សិត៖* ***យ៉ុន មករា***

*គ្រូណែនាំ៖* ***បណ្ឌិត វ៉ាន់ ច័ន្ទតារា***

## ១. អំពីភូមិសាស្ត្រ

ខណ្ឌសែនសុខ គឺជាខណ្ឌមួយ ក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់៖

- ខាងជើងទល់នឹង ខណ្ឌព្រែកព្នៅ និងខណ្ឌឬស្សីកែវ
- ខាងត្បូងទល់នឹង ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌមានជ័យ
- ខាងកើតទល់នឹង ខណ្ឌទួលគោក និងខណ្ឌមានជ័យ
- ខាងលិចទល់នឹង ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌព្រែកព្នៅ

មានទីតាំង ស្ថិតនៅជិតឡូតិ៍បណ្ដោយ ផ្លូវហាន់ណូយ ជាប់របងសាលាសង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញនឹងមាន ផ្ទៃដីសរុប ចំនួន ៥០,៣៨គីឡូម៉ែត្រការ៉េ មានសង្កាត់ ចំនួន ៦គឺ៖ សង្កាត់ភ្នំពេញថ្មី សង្កាត់ទឹកថ្លា សង្កាត់ឃ្មួញ សង្កាត់ក្រាំងធ្នង់ សង្កាត់គោកឃ្លាង និងសង្កាត់អូរបែកក្អម។ មានភូមិសរុប ចំនួន ៤៧ភូមិ, គ្រួសារសរុប ចំនួន ៣៦,៨១០ គ្រួសារ និងមានប្រជាពលរដ្ឋសរុប ចំនួន ១៧៨,៧៣៦ នាក់ ក្នុងនោះស្ត្រីសរុប ចំនួន ៩៧,០៩៨ នាក់។

➢ **សង្កាត់ភ្នំពេញថ្មី** ជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង៦ របស់ខណ្ឌសែនសុខ ដែលមានភូមិចំនួន ៦ គឺ ភូមិពោងពាយ ភូមិបាយ៉ាប ភូមិភ្នំពេញថ្មី ភូមិទំនប់ ភូមិទំនប់១ និងភូមិឧកញ៉ាវាំង។ មានព្រំប្រទល់៖

- ខាងជើងទល់នឹង សង្កាត់ឃ្មួញ
- ខាងត្បូងទល់នឹង សង្កាត់ទឹកថ្លា
- ខាងកើតទល់នឹង សង្កាត់បឹងកក់ទី១ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក
- សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ, ខាងលិចទល់នឹង សង្កាត់គោកឃ្លាង

នឹងមាន៖

- ផ្ទៃដីសរុប ចំនួន ៦.៥១គីឡូម៉ែត្រការេ
- មានភូមិចំនួន ៦
- គ្រួសារសរុប ចំនួន ៤,៣៤៥ គ្រួសារ
- មានប្រជាពលរដ្ឋសរុប ចំនួន ២០,០៩៣នាក់ ក្នុងនោះស្រីសរុប ចំនួន ១០,២០១នាក់

- **សង្កាត់ទឹកថ្លា** ជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង៦ របស់ខណ្ឌសែនសុខ ដែលមានភូមិចំនួន ៧ គឺៈ ភូមិផ្សារទឹកថ្លា ភូមិបុរី ១០០ខ្នង ភូមិសេប៉េសេ ភូមិចុងថ្នល់ខាងកើត ភូមិចុងថ្នល់ខាងលិច ភូមិទឹកថ្លា និងភូមិបុរីកម្មករ។

  មានព្រំប្រទល់ៈ

  - ខាងជើងទល់នឹង សង្កាត់ភ្នំពេញថ្មី និងសង្កាត់គោកឃ្លាង
  - ខាងត្បូងទល់នឹង សង្កាត់អូរបែកក្អម
  - ខាងកើតទល់នឹង សង្កាត់ទឹកល្អក់ទី១ សង្កាត់ទឹកល្អក់ទី២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក
  - ខាងលិចទល់នឹង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ

  នឹងមានៈ

  - ផ្ទៃដីសរុប ចំនួន ៣,០១២គីឡូម៉ែត្រការេ
  - ភូមិចំនួន ៧
  - គ្រួសារសរុប ចំនួន ៦,០២៧ គ្រួសារ
  - មានប្រជាពលរដ្ឋសរុប ចំនួន ៣៣,៨៥៧នាក់ ក្នុងនោះស្រីសរុប ចំនួន ១៩,២៩៣នាក់

- **សង្កាត់ឃ្មួញ** គឺជាសង្កាត់មួយនៅក្នុងចំណោមសង្កាត់ទាំង៦ របស់ខណ្ឌសែនសុខដែលមានភូមិចំនួន១៣ គឺៈ ភូមិឃ្មួញ ភូមិបន្លាស្អិត ភូមិសំរោង ភូមិអន្លង់ក្ងាន ភូមិត្រពាំងរាំង ភូមិត្រពាំងរាំងថ្មី ភូមិសែនសុខទី១ ភូមិសែនសុខទី២ ភូមិសែនសុខទី៣ ភូមិសែនសុខទី៤ ភូមិ សែនសុខទី៥ ភូមិសែនសុខទី៦ និងភូមិសែនសុខទី៧។

  មានព្រំប្រទល់ៈ

  - ខាងជើងទល់នឹង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ
  - ខាងត្បូងទល់នឹង សង្កាត់ភ្នំពេញថ្មី និងសង្កាត់គោកឃ្លាង
  - ខាងកើតទល់នឹង សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ
  - ខាងលិចទល់នឹង សង្កាត់ក្រាំងធ្នង់ និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ

  នឹងមានៈ

  - ផ្ទៃដីសរុប ចំនួន ១,៨៩៦គីឡូម៉ែត្រការេ
  - ភូមិចំនួន ១៣
  - គ្រួសារសរុប ចំនួន ៥,៧៤៥គ្រួសារ
  - មានប្រជាពលរដ្ឋសរុប ចំនួន ១៨,៨៥៧នាក់ ក្នុងនោះស្រីសរុប ចំនួន ៩,៧១៧នាក់

- **សង្កាត់ក្រាំងធ្នង់** ជាសង្កាត់មួយនៅក្នុងចំណោមសង្កាត់ទាំង៦ របស់ខណ្ឌសែនសុខ ដែលមានភូមិចំនួន ៨ គឺ៖ ភូមិក្រាំងអង្រ្គង ភូមិត្រពាំងមាន ភូមិជាងទង ភូមិត្រពាំងជើងស្រុក ភូមិព្រៃខ្លា ភូមិសំរោងទាវ ភូមិព្រៃស្ពួល និងភូមិវិមានទ្រង់។

  មានព្រំប្រទល់៖
  - ខាងជើងទល់នឹង សង្កាត់ឃ្មួញ
  - ខាងត្បូងទល់នឹង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ
  - ខាងកើតទល់នឹង សង្កាត់គោកឃ្លាង
  - ខាងលិចទល់នឹង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ

  នឹងមាន៖
  - ផ្ទៃដីសរុប ចំនួន ១១.៥៤គីឡូម៉ែត្រការេ
  - ភូមិចំនួន ៨
  - គ្រួសារសរុប ចំនួន ៣,១០១គ្រួសារ
  - មានប្រជាពលរដ្ឋសរុប ចំនួន ១៣,៤១៥នាក់ ក្នុងនោះស្រីសរុប ចំនួន ៦,៩១១នាក់
- **សង្កាត់គោកឃ្លាង** ជាសង្កាត់មួយនៅក្នុងចំណោមសង្កាត់ទាំង ៦ របស់ខណ្ឌសែនសុខ មានភូមិចំនួន ៨ គឺ៖ ភូមិរោងចក្រ ភូមិរោងចក្រទី១ ភូមិក្រុងថ្មី ភូមិត្រពាំងស្វាយ ភូមិដីថ្មី ភូមិដំណាក់ ភូមិគោកឃ្លាង និងភូមិប្រេស។

  មានព្រំប្រទល់៖
  - ខាងជើងទល់នឹង សង្កាត់ឃ្មួញ
  - ខាងត្បូងទល់នឹង សង្កាត់ទឹកថ្លា និងសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ
  - ខាងកើតទល់នឹង សង្កាត់ភ្នំពេញថ្មី
  - ខាងលិចទល់នឹង សង្កាត់ក្រាំងធ្នង់ និងសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ

  នឹងមាន៖
  - ផ្ទៃដីសរុប ចំនួន ៥.៥៨គីឡូម៉ែត្រការេ
  - ភូមិចំនួន ៦
  - គ្រួសារសរុប ចំនួន ៥,៧៤៥គ្រួសារ
  - មានប្រជាពលរដ្ឋសរុប ចំនួន ២៧,១៣២នាក់ ក្នុងនោះស្រីសរុប ចំនួន ១៣,៧៧៧នាក់
- **សង្កាត់អូរបែកក្អម** ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ដោយកាត់យកភូមិចំនួន ៥ ពីសង្កាត់ទឹកថ្លា នៃខណ្ឌសែនសុខ រាជធានីភ្នំពេញ គឺ៖ ភូមិអូរបែកក្អម ភូមិត្រពាំងឈូក ភូមិអ័រគីដេ ភូមិស្លែងរលើង និងភូមិទ្រុងមាន់។ មានទីតាំងបណ្ដោះអាសន្ន ស្ថិតនៅផ្ទះល្វែង

(ជួល) ក្រុមទី២ ផ្លូវកា៤អា ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ តាមបណ្តោយផ្លូវណេតប្រ៊ីត ចូលតាមផ្លូវផ្សារដើមឬស្សី ប្រមាណ២០០ម៉ែត្រ ពីផ្លូវណេតប្រ៊ីត។
មានព្រំប្រទល់៖

- ខាងជើងទល់និង សង្កាត់ទឹកថ្លា
- ខាងត្បូងទល់និង សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ
- ខាងលិចទល់និង សង្កាត់កាកាប សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ
- ខាងកើតទល់និង សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក។

នឹងមាន៖

- ផ្ទៃដីសរុប ចំនួន ៤.៤៥១ហិកតា
- ភូមិចំនួន ៥ និងក្រុម ចំនួន ២៣ក្រុម
- គ្រួសារសរុប ចំនួន ៥,៨១០គ្រួសារ
- មានប្រជាពលរដ្ឋសរុប ចំនួន ៣១,២៩៨នាក់ ក្នុងនោះស្រីសរុប ចំនួន ១៧,០៣៥នាក់

## ២. អំពីតម្លៃអចលនវត្ថុ

### ក. សង្កាត់ភ្នំពេញថ្មី

សង្កាត់ភ្នំពេញថ្មី មាន០៦ ភូមិ គឺ៖ ភូមិពោងពាយ ភូមិទំនប់ ភូមិទំនប់០១ ភូមិបាយ៉ាប ភូមិឧញ៉ាវាំង និងភូមិភ្នំពេញថ្មី។

- តម្លៃ ២០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ១៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ភូមិ
- តម្លៃ ១០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

### ខ. សង្កាត់ទឹកថ្លា

សង្កាត់ទឹកថ្លាមាន ០៦ភូមិ គឺ៖ ភូមិផ្សារទឹកថ្លា ភូមិសេប៉េសេ ភូមិបុរី ១០០ខ្នង ភូមិចុងថ្នល់ខាងកើត ភូមិចុងថ្នល់ខាងលិច និងភូមិទឹកថ្លា។

- តម្លៃ ២៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ២០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ១៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

### គ. សង្កាត់ឃ្មួញ

សង្កាត់ឃ្មួញ មាន១៣ភូមិ គឺ៖ ភូមិឃ្មួញ ភូមិបន្លាស្អិត ភូមិអន្លង់ក្ងាន ភូមិសែនសុខ០១ ភូមិសែនសុខ០២ ភូមិសែនសុខ០៣ ភូមិសែនសុខ០៤ ភូមិសែនសុខ០៥ ភូមិសែនសុខ០៦ ភូមិសែនសុខ០៧ ភូមិត្រពាំងវាំង ភូមិត្រពាំងវាំងថ្មី និងភូមិសំរោង។

ក) ភូមិឃ្នួញ ភូមិបន្ទាស្និត និងភូមិអន្លង់ក្លាន

- តម្លៃ ១២០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់

- តម្លៃ ១០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ

- តម្លៃ ៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ) ភូមិសែនសុខ០១ ភូមិសែនសុខ០២ ភូមិសែនសុខ០៣ ភូមិសែនសុខ០៤ ភូមិសែនសុខ០៥ ភូមិសែនសុខ០៦ ភូមិសែនសុខ០៧ ភូមិត្រពាំងរាំង ភូមិត្រពាំងរាំងថ្មី និងភូមិសំរោង

- តម្លៃ ៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់

- តម្លៃ ៣៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ

- តម្លៃ ២៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

### ឃ. សង្កាត់ក្រាំងធ្នង់

សង្កាត់ក្រាំងធ្នង់ មាន ០៨ភូមិ គឺ៖ ភូមិក្រាំងអង្រ្កង ភូមិជាងទង ភូមិវិមានទ្រង់ ភូមិសំរោងទាវ ភូមិព្រៃមូល ភូមិត្រពាំងជើងស្រុក ភូមិត្រពាំងមាន និងភូមិព្រៃខ្លា។

ក)ភូមិក្រាំងអង្រ្កង ភូមិជាងទង ភូមិវិមានទ្រង់ និងភូមិសំរោងទាវ

- តម្លៃ ៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់

- តម្លៃ ៣៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ

- តម្លៃ ២៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ) ភូមិព្រៃមូល ភូមិត្រពាំងជើងស្រុក ភូមិត្រពាំងមាន និងភូមិព្រៃខ្លា

- តម្លៃ ៣៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់

- តម្លៃ ២៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ

- តម្លៃ ១៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

### ង. សង្កាត់គោកឃ្លាង

សង្កាត់គោកឃ្លាង មាន ០៨ភូមិ គឺ៖ ភូមិរោងចក្រ ភូមិរោងចក្រ០១ ភូមិក្រុងថ្មី ភូមិដីថ្មី ភូមិត្រពាំងស្វាយ ភូមិប្រេស ភូមិគោកឃ្លាង និងភូមិដំណាក់។

ក) ភូមិរោងចក្រ ភូមិរោងចក្រ០១ ភូមិក្រុងថ្មី និងភូមិដីថ្មី

- តម្លៃ ២០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់

- តម្លៃ ១៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ

- តម្លៃ ១០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

ខ) ភូមិត្រពាំងស្វាយ ភូមិប្រេស ភូមិគោកឃ្លាង និងភូមិដំណាក់

- តម្លៃ ១៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់

- តម្លៃ ១០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ

- តម្លៃ ៧៥ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

### ច. សង្កាត់អូរបែកក្អម

សង្កាត់អូរបែកក្អម មាន ០៦ភូមិ គឺៈ ភូមិអូរបែកក្អម ភូមិត្រពាំងឈូក ភូមិអ័រគីដេ ភូមិបុរីកម្មករ ភូមិស្លែងរលើង និងភូមិទ្រុងមាន់។

- តម្លៃ ២៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ២០០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីជាប់ភូមិ
- តម្លៃ ១៥០ ដុល្លា ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

## ៣-សំណង់

| ប្រភេទសំណង់ | ដល់ ១០ឆ្នាំ (តម្លៃ/១ម$^2$) | | | លើសដល់ ១០ឆ្នាំ (តម្លៃ/១ម$^2$) | | |
|---|---|---|---|---|---|---|
| | សំណង់ឥដ្ឋបេតុង | សំណង់មិនមែនឥដ្ឋបេតុង | ខុនដូ | សំណង់ឥដ្ឋបេតុង | សំណង់មិនមែនឥដ្ឋបេតុង | ខុនដូ |
| ជាន់ក្រោមដី | ១៨០ | ១៨០ | ១៨០ | ១៥០ | ១៥០ | ១៥០ |
| ជាន់ផ្ទាល់ដី | ២០០ | ១០០ | ៥៩០ | ១៨០ | ៨០ | ៥៥០ |
| ជាន់ទី០១ | ១៨០ | ៨០ | ៥៥០ | ១៣០ | ៧០ | ៤៥០ |
| ជាន់ទី០២ ដល់ទី ០៥ | ១៣០ | ៧០ | ៦០០ | ៨០ | ៥០ | ៥០០ |
| ជាន់ទី០៦ ដល់ទី ១០ | ៥៥០ | ៤៥០ | ៧០០ | ៤៥០ | ៣៥០ | ៥៥០ |
| ចាប់ពីជាន់ទី១១ ឡើងទៅ | ៦៥០ | ៥៥០ | ៨០០ | ៥៥០ | ៤៥០ | ៦៥០ |

© ២០២២ រាជបណ្ឌិត្យសភាកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង
គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

©2022 Royal Academy of Cambodia

All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.



**Royal Academy of Cambodia**
Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**
**មហាវិថីសហព័ន្ធរុស្ស៊ី**
**ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ**
**ព្រះរាជាណាចក្រកម្ពុជា**
**ទូរសព្ទលេខ**: (៨៥៥)២៣ ៨៩០១៨០
**ទូរសារលេខ**: (៨៥៥)២៣ ៨៩០១៨០
**អ៊ីម៉ែល**: info@rac.gov.kh
**វេបសាយ**: www.rac.gov.kh